ឆ្ពោះទៅអនាគត

CIMB BANK

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី
របាយការណ៍ប្រចាំឆ្នាំ ២០២០

១០ ឆ្នាំ
ជូន១០ឆ្នាំ នៃប្រតិបត្តិការ
នៅប្រទេសកម្ពុជា

ការបង្កើត ផលប្រយោជន៍ហិរញ្ញវត្ថុ ប្រកបដោយនិរន្តរភាព	ការអនុវត្តផែនការ ប្រកបដោយវិន័យ	ការផ្តោតលើការយកចិត្ត ទុកដាក់ លើអតិថិជន	ការអភិវឌ្ឍ មូលដ្ឋានគ្រឹះ	ស្ថាប័នដែលឆ្ពោះទៅមុខ តាមចក្ខុវិស័យ

FORWARD 23+ ក្លាយជាធនាគារឈានមុខគេ ដែលផ្តោតលើតំបន់អាស៊ាន

ដំណើរការក្នុង **១០ប្រទេស**
នៅទូទាំងតំបន់ **អាស៊ាន**
និងប្រទេសដទៃទៀត

មានបុគ្គលិកបម្រើការ
ប្រមាណ**៣៤.០០០នាក់**

មានបណ្តាញសាខាជាង
៧០០កន្លែង

ឆ្នាំ

ខួប១០ឆ្នាំ នៃប្រតិបត្តិការ
នៅប្រទេសកម្ពុជា

បម្រើអតិថិជនជាង
១៦លាននាក់

ផ្នែកខាងក្នុង

01

ទិដ្ឋភាពទូទៅ

- ៨ សារតារធនាគារ
- ៩ ការប្តេជ្ញាលើគុណភាពសេវាកម្ম និងឧត្តមភាព
- ៩ តម្លៃស្នូលរបស់ស្ថាប័ន
- ១០ សារពីប្រធានក្រុមប្រឹក្សាភិបាល
- ១២ សារពីប្រធាននាយកប្រតិបត្តិក្រុមហ៊ុនមេ
- ១៤ ការពិនិត្យមើលលទ្ធផលប្រតិបត្តិការរបស់ប្រធាននាយកប្រតិបត្តិ

02

ការពិនិត្យមើលធុរកិច្ច

- ២០ សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
- ២១ សេវាកម្មហិរញ្ញវត្ថុបុគ្គល
- ២២ សេវាកម្មហិរញ្ញវត្ថុសាជីវកម្មសេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ
- ២៣ ធនធានសាជីវកម្ម
- ២៤ ហិរញ្ញវត្ថុ
- ២៥ ប្រតិបត្តិតាម
- ២៦ គ្រប់គ្រងហានិភ័យ
- ២៨ បច្ចេកវិទ្យា និងប្រតិបត្តិការ
- ៣០ រតនាភិបាល និងទីផ្សារ
- ៣១ ទីផ្សារ និងទំនាក់ទំនង
- ៣២ សវនកម្មផ្ទៃក្នុង
- ៣២ នីតិកម្ម និងលេខាធិការក្រុមហ៊ុន
- ៣៣ បទពិសោធន៍សេវាកម្មអតិថិជន
- ៣៣ គ្រប់គ្រងផលិតផល

03

អភិបាលកិច្ចធនាគារ

- ៣៦ សេចក្តីថ្លែងការណ៍ស្តីពីអភិបាលកិច្ចធនាគារ
- ៤៦ របាយការណ៍គណៈកម្មាធិការសវនកម្ម
- ៤៩ សេចក្តីថ្លែងការណ៍ស្តីអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
- ៥២ រចនាសម្ព័ន្ធគ្រប់គ្រងក្រុមហ៊ុនមេ
- ៥៣ រចនាសម្ព័ន្ធក្រុមហ៊ុន
- ៥៤ របាយការណ៍ព័ត៌មានរបស់ធនាគារ

04

ព្រឹត្តិការណ៍សំខាន់ៗ និងការចុះផ្សាយក្នុងសារព័ត៌មាននៅឆ្នាំ២០២០

- ៥៨ ព្រឹត្តិការណ៍សំខាន់ៗ
- ៦៤ ការចុះផ្សាយក្នុងសារព័ត៌មាន

នៃរបាយការណ៍

ឆ្នាំ
ខួប១០ឆ្នាំ នៃប្រតិបត្តិការ
នៅប្រទេសកម្ពុជា

០៥ ប្រវត្តិសង្ខេបរបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការគ្រប់គ្រង

៦៨ ក្រុមប្រឹក្សាភិបាល
៧៤ លេខាធិការក្រុមហ៊ុនរួម
៧៨ គណៈកម្មាធិការគ្រប់គ្រង

០៦ របាយការណ៍ហិរញ្ញវត្ថុ

៨៦ របាយការណ៍ក្រុមប្រឹក្សាភិបាល
៨៨ របាយការណ៍សវនករឯករាជ្យ
៩០ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
៩១ របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ
៩២ របាយការណ៍បម្រែបម្រួលមូលធន
៩៣ របាយការណ៍លំហូរសាច់ប្រាក់
៩៤ កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
១៤០ ព័ត៌មានហិរញ្ញវត្ថុបន្ថែម ទៅតាមតម្រូវការរបស់ធនាគារជាតិ នៃកម្ពុជា

០៧ បណ្តាញរបស់ធនាគារ

១៥៦ បណ្តាញធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី
១៥៨ បណ្តាញសាខារបស់ក្រុមហ៊ុនមេ

ទិដ្ឋភាពទូទៅ

៨ សារតារធនាគារ
៩ ការប្តេជ្ញាលើគុណភាពសេវាកម្ម និងឧត្តមភាព
៩ តម្លៃស្នូលរបស់ស្ថាប័ន
១០ សារពីប្រធានក្រុមប្រឹក្សាភិបាល
១២ សារពីប្រធាននាយកប្រតិបត្តិក្រុមហ៊ុនមេ
១៤ ការពិនិត្យមើលលទ្ធផលប្រតិបត្តិការរបស់ប្រធាននាយកប្រតិបត្តិ

ខួប១០ឆ្នាំ នៃប្រតិបត្តិការ
នៅប្រទេសកម្ពុជា

សាវតារធនាគារ

អំពីធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចាប់ផ្តើមប្រតិបត្តិការ នៅក្នុងទីផ្សារប្រទេសកម្ពុជា នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ ដោយបានបើកដំណើរការសាខាធនាគារពាណិជ្ជទី១ នៅចំកណ្ដាលរាជធានីភ្នំពេញ។ រហូតមកដល់បច្ចុប្បន្ននេះ ធនាគារមានសាខាចំនួន ១៤កន្លែង ជាមួយនឹងម៉ាស៊ីនដាក់ប្រាក់ ១១កន្លែង ម៉ាស៊ីនដាក់មូលប្បទានបត្រ ១០កន្លែង និងម៉ាស៊ីនអេធីអិម ៣៩កន្លែង នៅក្នុងខេត្ត និងរាជធានីសំខាន់ៗចំនួនប្រាំ នៃព្រះរាជាណាចក្រកម្ពុជា រួមមានរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តបាត់ដំបង និងខេត្តកំពង់ចាម។

បច្ចុប្បន្ននេះ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី កំពុងបម្រើសេវាកម្ម និងផ្ដល់ផលិតផលធនាគារជូនដល់អតិថិជន ប្រមាណ ៣៥.០០០ នាក់ ដែលរួមមានទាំងអតិថិជនជាបុគ្គល និងក្រុមហ៊ុន។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការកើនឡើងរបស់ចំនួនអតិថិជន នៅក្នុងប្រទេសកម្ពុជា ធនាគារមានផ្ដល់ជូនសេវាកម្ម និងផលិតផលធនាគារដ៏ទូលំទូលាយ រួមមានសេវាកម្មហិរញ្ញវត្ថុបុគ្គល សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម ព្រមទាំងសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុផងដែរ។

គិតត្រឹមខែធ្នូ ឆ្នាំ២០២០ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី មាននិយោជិតជាង ៤០០នាក់ ដែលមានបទពិសោធន៍ និងជំនាញផ្សេងៗគ្នា ទាំងក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ក៏ដូចជាវិស័យផ្សេងៗទៀតផងដែរ។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី នៅក្នុងប្រទេសកម្ពុជា បានប្តេជ្ញាចិត្ត ក្នុងការកសាងវិស័យហិរញ្ញវត្ថុឲ្យរឹងមាំ និងយូរអង្វែងមួយ សម្រាប់អតិថិជនរបស់ខ្លួន ហើយនឹងបន្តព្យាយាមបង្កើតឱកាស និងគុណតម្លៃ តាមរយៈផលិតផល និងសេវាកម្មថ្មីៗ ដែលមានអត្ថប្រយោជន៍ខ្ពស់។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី មានមោទនភាពក្រៃលែង ដោយសារតែយើងមិនត្រឹមតែជាអ្នកបម្រើសេវាកម្មហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាដៃគូអាជីវកម្មដ៏ល្អមួយរបស់អតិថិជនផងដែរ ក្នុងការគាំទ្ររួកគេឲ្យធ្វើការសម្រេចចិត្តត្រឹមត្រូវ លើផ្នែកហិរញ្ញវត្ថុ និងការវិនិយោគ។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺជាសាខារបស់ស៊ីអាយអិមប៊ី គ្រុប។

អំពី ស៊ីអាយអិមប៊ី គ្រុប

ស៊ីអាយអិមប៊ី គ្រុប គឺជាធនាគារសាកលឈានមុខគេមួយ ក្នុងតំបន់អាស៊ាន និងជាដៃគូប្រឹក្សាសាជីវកម្មធំបំផុតមួយ ក្នុងតំបន់។ ស៊ីអាយអិមប៊ី គ្រុប ក៏នាំមុខគេ ក្នុងពិភពលោក លើផ្នែកហិរញ្ញវត្ថុឥស្លាមផងដែរ។

ស៊ីអាយអិមប៊ី គ្រុប មានទីស្នាក់ការកណ្ដាល នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ហើយមានផ្ដល់សេវាកម្មធនាគារពាណិជ្ជ ធនាគារវិនិយោគ ធនាគារឥស្លាម និងសេវាកម្មគ្រប់គ្រងទ្រព្យធន។ ស៊ីអាយអិមប៊ី គ្រុប គឺស្ថិតក្នុងលំដាប់លេខ ៥ នៅអាស៊ីអាគ្នេយ៍ បើគិតលើទ្រព្យសកម្ម នៅចុងឆ្នាំ ២០២០ ដែលមានបុគ្គលិកជាង ៣៤.០០០នាក់ និងអតិថិជនប្រហែល ១៦លាននាក់។

ស៊ីអាយអិមប៊ី គ្រុប ហូលឌីង ប៊ើហាដ ត្រូវបានចុះបញ្ជី នៅលើទីផ្សារភាគហ៊ុន ប៊ូរសា ម៉ាឡេស៊ី (Bursa Malaysia) តាំងពីឆ្នាំ ១៩៨៧ ជាមួយតម្លៃលើទីផ្សារភាគហ៊ុន ៤៣,៥ពាន់លានរីងហ្គីត ម៉ាឡេស៊ី បើគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។ ទ្រព្យសរុប គិតត្រឹមចុងឆ្នាំ២០២០ មានចំនួន ៦០២,៤ពាន់លានរីងហ្គីតម៉ាឡេស៊ី ជាមួយប្រាក់បម្រុងរបស់ភាគហ៊ុនិកសរុបចំនួន ៥៥,៩ពាន់លានរីងហ្គីតម៉ាឡេស៊ី ហើយទ្រព្យសរុបរបស់ធនាគារឥស្លាមមានចំនួន ១៤៣ពាន់លានរីងហ្គីតម៉ាឡេស៊ី។ គិតត្រឹមចុងឆ្នាំ២០២០ ភាគហ៊ុនិកដែលមានភាគហ៊ុនច្រើនបំផុត គឺ Khazanah Nasional ដែលមាន ២៧,២% នៃភាគហ៊ុនសរុប។ ប្រាក់បម្រុងសម្រាប់បុគ្គលិក (EPF) មានចំនួន ១៦% Permodalan Nasional Berhad មានចំនួន ១២,២០% និង Kumpulan Wang Persaraan (Diperbadankan) មានចំនួន ៦,៦%។

ការប្តេជ្ញាលើគុណភាពសេវាកម្ម និងឧត្តមភាព

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺជាក្រុមហ៊ុន ដែលផ្តោតលើការដឹកនាំរបស់មនុស្ស។ នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី អ្វីដែលយើងផ្តោតជាសំខាន់នោះ គឺការផ្តល់សេវាដល់អតិថិជន ឬក៏គាំទ្រដល់អ្នកដែលផ្តល់សេវាកម្មដល់អតិថិជន។

តាំងពីដើមរៀងមក អតិថិជន គឺជាចំណុចស្នូលនៃគ្រប់ការងារទាំងអស់ ដែលយើងបានធ្វើ។

គុណតម្លៃស្នូលទី១ របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺយើងផ្តោតការយកចិត្តទុកដាក់ លើអតិថិជន។ វត្តមានរបស់ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺដើម្បីអតិថិជន ហើយយើងផ្តល់ផលិតផល និងសេវាកម្ម ដែលអតិថិជនយល់ និងផ្តល់តម្លៃឲ្យ។

យើងក៏ផ្តោតសំខាន់ដូចគ្នាផងដែរ ទៅលើគុណតម្លៃស្នូលចំនួនបួនផ្សេងទៀត រួមមានសមិទ្ធផលខ្ពស់ ការផ្តល់លទ្ធភាពដល់បុគ្គលិក កម្លាំងចម្រុះ និងសុចរិតភាព។ យើងជឿជាក់ថា ការរួមបញ្ចូលគ្នានៃគុណតម្លៃស្នូលទាំងអស់នេះ ទៅលើអ្វីគ្រប់យ៉ាង ដែលយើងធ្វើ នឹងបង្កើតនូវគុណតម្លៃយូរអង្វែង មិនត្រឹមតែសម្រាប់អតិថិជនប៉ុណ្ណោះទេ តែថែមទាំងសម្រាប់បុគ្គលិក និងភាគីពាក់ព័ន្ធរបស់យើងផងដែរ។

ដើម្បីសម្រេចបានគោលដៅសេវាកម្មអតិថិជនដ៏ល្អឥតខ្ចោះ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានកំណត់គោលការណ៍ នៃសេវាកម្មអតិថិជនរបស់ខ្លួន ដើម្បីផ្តល់សេវាកម្មល្អប្រសើរ ជូនដល់អតិថិជន។ គ្រប់ពេលវេលាទាំងអស់ យើងនឹង៖

- ធ្វើការងារកិច្ចអតិថិជនដោយការសំពះ
- ផ្តល់សេវាកម្ម ភ្ជាប់ជាមួយនឹងស្នាមញញឹ
- 00:5 បម្រើសេវាកម្មអតិថិជនដោយកាត់បន្ថយ រយៈពេលរង់ចាំ មិនលើសពី ៥ នាទី
- ផ្តោតទៅលើ ដំណោះស្រាយ សម្រាប់អតិថិជន

នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី អតិថិជន គឺជាអ្វីដែលយើងផ្តោតការយកចិត្ត ទុកដាក់ខ្លាំងបំផុត

តម្លៃស្នូលរបស់ស្ថាប័ន

ការយកចិត្តទុកដាក់លើអតិថិជន
យើងខ្ញុំតែងតែនៅជាមួយ អតិថិជន ដើម្បីធានាថា ពួកគេទទួលបានភាពរីករាយ និងការពេញចិត្ត។

សមិទ្ធផលខ្ពស់
យើងខ្ញុំតែងតែខិតខំ បំពេញការងារ អស់ពីសមត្ថភាព និងលើសពីការរំពឹងទុក។

សុចរិតភាព
យើងខ្ញុំតែងតែរក្សានូវសុចរិតភាព ទំនួលខុសត្រូវ និងគណនេយ្យភាព ក្នុងការបំពេញការងារ។ មានភាពប្រុងប្រយ័ត្ន មានការត្រៀមខ្លួនជានិច្ច មានភាពហ្មត់ចត់។

ភាពចម្រុះគ្នា និងភាពរួមគ្នា
យើងខ្ញុំជឿជាក់ថា អ្នកគ្រប់គ្នាសុទ្ធតែបានចូលរួមចំណែក ដោយមិនប្រកាន់ជាតិសាសន៍ ភេទ ឬគំនិតផ្សេងគ្នា។

ភាពរហ័សរហួន
យើងខ្ញុំបត់បែនយ៉ាងឆាប់រហ័ស ក្នុងការផ្លាស់ប្តូរ ហើយធ្វើជាអ្នកដោះស្រាយ បញ្ហាឲ្យបានល្អ។

សារពីប្រធានក្រុមប្រឹក្សាភិបាល

ក្នុងឆ្នាំ២០២០ ពិភពលោកទាំងមូលបានឆ្លងកាត់ការផ្លាស់ប្តូរ ដែលមិនធ្លាប់មាន និងបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារជំងឺរាតត្បាត ដែលបានផ្លាស់ប្តូរជីវិតរស់នៅយ៉ាងច្រើន ដូចដែលយើងទាំងអស់គ្នាបានដឹងស្រាប់ហើយ។ ខណៈដែលជំងឺកូវីដ-១៩ បានធ្វើឲ្យប៉ះពាល់ដល់ពិភពលោកយ៉ាងខ្លាំងក្លា ប្រទេសកម្ពុជាបានគ្រប់គ្រងយ៉ាងល្អប្រសើរ ទោះបីប្រព័ន្ធសុខាភិបាលមិនមានថវិកាច្រើនក្តី ដោយមានការឆ្លងត្រឹមតែ ៣៦៣ករណីប៉ុណ្ណោះ បើយោងតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោក (WHO) ដែលបានចេញផ្សាយកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០។ ទោះបីសេដ្ឋកិច្ចកម្ពុជាធ្លាក់ចុះក្នុងអត្រា -១,៩% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ដែលត្រូវបានបញ្ជាក់នៅក្នុងកិច្ចប្រជុំចុងឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏ដោយ សេដ្ឋកិច្ចកម្ពុជានឹងងើបឡើងវិញ ជាមួយនឹងកំណើន ៤% ក្នុងឆ្នាំ២០២១ បើផ្អែកតាមការព្យាករណ៍របស់ធនាគារជាតិ នៃកម្ពុជា (NBC)។

វិធានការយ៉ាងសកម្មរបស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយផលប៉ះពាល់ ដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ-១៩ បានកសាងទំនុកចិត្ត ក្នុងចំណោមវិនិយោគិន ដែលឆ្លុះបញ្ចាំងតាមរយៈបរិយាកាសវិនិយោគ និងធុរកិច្ចដ៏ល្អប្រសើរ ក្នុងប្រទេស។ តាមរយៈការចុះហត្ថលេខា លើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន (FTA) កាលពីខែតុលា ក៏ដូចជាកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) កាលពីខែវិច្ឆិកាឆ្នាំមុន វាគឺជាឧទាហរណ៍ដ៏សំខាន់មួយនៃភាពរឹងមាំរបស់រាជរដ្ឋាភិបាល និងជាការឆ្លើយតប ចំពោះបញ្ហាប្រឈមនៃវិបត្តិសេដ្ឋកិច្ច ចាប់តាំងពី «វិបត្តិហិរញ្ញវត្ថុសាកល» ក្នុងឆ្នាំ២០០៧។ ជាក់ស្តែង កិច្ចព្រមព្រៀង RCEP នឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើន ដល់ប្រទេសកម្ពុជា ជាមួយនឹងការកាត់បន្ថយពន្ធ ដ៏ដូចជាការសម្រួលដល់ការធ្វើពាណិជ្ជកម្ម ចំពោះប្រទេសជាសមាជិកទាំង១៥នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលគ្របដណ្តប់ប្រមាណ ៣០% នៃផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក និងមានប្រជាជនប្រមាណ ៣០% នៃចំនួនប្រជាជនពិភពលោក។ ឱកាសធ្វើពាណិជ្ជកម្ម និងការរីកចម្រើនលូតលាស់រយៈពេលវែងរបស់ RCEP នឹងជួយឲ្យប្រទេសកម្ពុជាធ្វើទំនើបកម្ម និងពិពិធកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនបានយ៉ាងរលូន។

ចាប់តាំងពីឆ្នាំ២០១៩មក យើងបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ រយៈពេលមធ្យម «Forward23» របស់យើង ដែលឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តរបស់ស៊ីអាយអិមប៊ី គ្រុប និងធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា ចំពោះការបង្កើតនូវគុណតម្លៃ ប្រកបដោយនិរន្តរភាព ដើម្បីជួយលើកកម្ពស់អតិថិជន និងសង្គមជាតិរបស់យើងឲ្យកាន់តែរីកចម្រើន។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានកែសម្រួលឡើងវិញ ក្នុងឆ្នាំ២០២០ និងបានប្តូរឈ្មោះទៅជា Forward23+ ដែលគ្របដណ្តប់លើគោលដៅយុទ្ធសាស្ត្រស្នូលចំនួន៥ រួមមាន -ការបង្កើតផលប្រយោជន៍ហិរញ្ញវត្ថុ ប្រកបដោយនិរន្តរភាព -ការអនុវត្តផែនការ ប្រកបដោយវិន័យ -ការផ្តោតលើការយកចិត្តទុកដាក់ លើអតិថិជន -ការអភិវឌ្ឍមូលដ្ឋានគ្រឹះ និង -ស្ថាប័នដែលឆ្លើយតបទៅមុខ តាមចក្ខុវិស័យ ដើម្បីធ្វើឲ្យធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា អនុវត្តគោលគំនិតផ្តួចផ្តើមច្បាស់លាស់ទាំងនេះ ក្នុងការរក្សាសន្ទុះលូតលាស់ និងចាប់យកឱកាសរីកចម្រើន ទាំងនៅទីផ្សារក្នុងស្រុក និងអន្តរជាតិ ដែលកំពុងមានកំណើនឆាប់រហ័ស ក្នុងពេលបច្ចុប្បន្ន រហូតដល់ឆ្នាំ២០២៤។ ដើម្បីគាំទ្រយុទ្ធសាស្ត្រ Forward23+ យើងបានផ្តោតអាទិភាពដល់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការវិនិយោគលើប្រព័ន្ធឌីជីថល ដើម្បីសម្រេចបាននូវគោលដៅ ដែលបានគ្រោងទុក ក្នុងចំណោមគោលដៅយុទ្ធសាស្ត្រទាំងអស់។

ទោះបីជាការរីករាលដាលនៃជំងឺកូវីដ-១៩ បានបង្ករការំខានយ៉ាងខ្លាំង ដល់វិស័យធនាគារ និងហិរញ្ញវត្ថុ ដែលបានធ្វើឲ្យឆ្នាំ២០២០ ក្លាយជាឆ្នាំដ៏លំបាកបំផុតមួយ ក្នុងការទទួលបានភាពរីកចម្រើនយ៉ាងណាក្តី យើងនៅតែអាចសម្រេចបានសមិទ្ធផលហិរញ្ញវត្ថុដ៏រឹងមាំមួយ នៅគ្រប់ផ្នែកប្រតិបត្តិការ និងអាជីវកម្មសំខាន់ៗរបស់យើង ដែលជម្នះនឹងស្ថានភាពមិនច្បាស់លាស់នេះ។ យើងរក្សាបានភាពរីកចម្រើនល្អប្រសើរ កាលពីឆ្នាំមុន ដែលនាំឲ្យធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា កត់ត្រាប្រាក់ចំណេញមុនបង់ពន្ធ ចំនួន ២៦.៨ លានដុល្លារអាមេរិក ដែលមានកំណើនប្រចាំឆ្នាំ ១៧% ធៀបនឹងឆ្នាំ២០១៩។ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលគ្រប់ផ្នែកសេវាកម្មធនាគារ និងហិរញ្ញវត្ថុសំខាន់ៗ នៃធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា បានសហការគ្នា ក្នុងសម្រេចបាននូវសមិទ្ធិផលដ៏អស្ចារ្យនេះ ដែលយើងទាំងអស់គ្នាពិតជាមានមោទនភាព ក្នុងការប្រកាស និងចូលរួមអបអរសាទរខួប១០ឆ្នាំ នៃប្រតិបត្តិការរបស់ធនាគារ ក្នុងប្រទេសកម្ពុជា។

កម្មវិធីទំនួលខុសត្រូវសង្គម | អប់រំ | សុខភាព | បរិស្ថាន | ការអភិវឌ្ឍសង្គម

កម្មវិធីបរិច្ចាគឈាម នៅការិយាល័យធនាគារ ស៊ីអាយអិមប៊ី រាជធានីភ្នំពេញ

ពិធីប្រគល់អាហារូបករណ៍ នៅការិយាល័យកណ្តាលធនាគារ ស៊ីអាយអិមប៊ី រាជធានីភ្នំពេញ

កម្មវិធីដាំកូនឈើ និងពិធីអបអរខួបគម្រប់១០ឆ្នាំ របស់ធនាគារ ស៊ីអាយអិមប៊ី នៅប្រាសាទបន្ទាយក្តី ខេត្តសៀមរាប

ក្នុងការរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីសម្រាលបន្ទុករបស់អតិថិជនក្នុងអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុនេះ កាលពីខែមីនា ឆ្នាំ២០២០ ធនាគារជាតិ នៃកម្ពុជា បានសម្រេចកាត់បន្ថយអត្រាការប្រាក់បម្រុងកាតព្វកិច្ច មកនៅត្រឹម ៧% និងពន្យាពេលឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុរក្សាកម្រិតទ្រនាប់ដើមទុន ត្រឹម៥០% តាមរយៈប្រកាសថ្មី។ ជាមួយនឹងសេចក្ដីណែនាំនេះ វិស័យធនាគារអាចចាក់បញ្ចូលសាច់ប្រាក់សុទ្ធប្រមាណ ១,៨ ពាន់លានដុល្លារអាមេរិក ទៅក្នុងសកម្មភាពសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ជាលទ្ធផលវាបានជួយឲ្យធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា ពង្រីកទំហំឥណទាន ឬផ្ដល់ឥណទាន ដល់អតិថិជនថ្មីៗ ដើម្បីជួយឲ្យពួកគេអាចទ្រទ្រង់ដំណើរការអាជីវកម្ម និងគាំទ្រដល់សេដ្ឋកិច្ចរបស់ពួកគេទាំងក្នុងនិងក្រៅប្រទេស អំឡុងពេលមានវិបត្តិជំងឺរាតត្បាតនេះ។

ជាផ្នែកមួយ នៃការគាំទ្ររបស់ធនាគារ ដល់ប្រព័ន្ធហិរញ្ញវត្ថុសាកល ក្នុងការប្រយុទ្ធប្រឆាំងនឹងការលាងលុយកខ្វក់ និងហិរញ្ញប្បទានភេរវកម្ម ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា បានត្រួតពិនិត្យឡើងវិញ ដល់ទីកន្លែង ចំពោះការអនុវត្តបទប្បញ្ញត្តិ ស្ដីពីការប្រឆាំងការសម្អាតប្រាក់ (AML) និងហិរញ្ញប្បទានភេរវកម្ម (CFT) ទៅលើអង្គភាពអាជីវកម្ម ចំនួន១១ និងសាខាធនាគារ ចំនួន១០ នៅទូទាំងប្រទេស។ ជាចំណុចផ្តោតសំខាន់មួយ សម្រាប់នាយកដ្ឋានប្រតិបត្តិតាម និយោជិត ដែលទើបចូលបម្រើការងារថ្មីទាំងអស់ ត្រូវបានតម្រូវឲ្យចូលរួមវគ្គបណ្តុះបណ្តាល ក្នុងអំឡុងពេលបីខែ គិតចាប់ពីថ្ងៃចូលបម្រើការងារ ក្នុងធនាគារ ហើយនិយោជិត ដែលបានបម្រើការងារស្រាប់ តម្រូវឲ្យចូលរៀនវគ្គសិក្សា តាមប្រព័ន្ធអេឡិកត្រូនិក អំពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មផងដែរ។ កាលពីឆ្នាំមុន នាយកដ្ឋានប្រតិបត្តិតាម បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ១៦លើក ដែលមានការចូលរួមពីនិយោជិតចំនួន ២៩០នាក់ ដែលជាផ្នែកមួយ នៃកិច្ចខិតខំប្រឹងប្រែងរបស់យើង ក្នុងការប្រយុទ្ធប្រឆាំងនឹងការលាងលុយកខ្វក់ និងហិរញ្ញប្បទានភេរវកម្ម។

ស្របពេលដែលចំនួននិយោជិតភាគច្រើន ត្រូវបានណែនាំឲ្យកាត់បន្ថយម៉ោងបំពេញការងារនៅក្នុងធនាគារ ដើម្បីអនុវត្តវិធានការការក្សាគម្លាត និងការបិទខ្ទប់ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា បានសម្រេចបង្កើនឱកាសនានា ក្នុងពេលដែលមានការរំខាន ដល់ប្រតិបត្តិការរបស់ធនាគារនេះ។ ជាមួយនឹងការគាំទ្រយ៉ាងពេញទំហឹង ពីក្រុមការងារផ្នែកអភិវឌ្ឍន៍បុគ្គលិក ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលតាមបណ្តាញអនឡាញ និងក្នុងថ្នាក់រៀន ប្រមាណ ៧.៥០០ម៉ោង ក្នុងឆ្នាំ២០២០ សម្រាប់បុគ្គលិកក្នុងមុខជំនាញដ៏សម្បូរបែប ដូចជាការវាយតម្លៃឥណទាន ការគ្រប់គ្រងហានិភ័យ ការយល់ដឹងពីប្រព័ន្ធនីងដំណើរការធនាគារ ក៏ដូចជាផ្នែកលក់ និងការបម្រើសេវាកម្មអតិថិជនជាដើម។ ការប្តេជ្ញាចិត្តរបស់យើង ចំពោះការបន្តអភិវឌ្ឍជំនាញវិជ្ជាជីវៈ សម្រាប់និយោជិតរបស់យើង ឲ្យស្ថិតក្នុងកម្រិតខ្ពស់បំផុត បានរួមចំណែកធ្វើឲ្យធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា ឈ្នះពានរង្វាន់ «ទីកន្លែងការងារល្អបំផុត នៅកម្ពុជា» ក្នុងឆ្នាំ២០២០ ផ្ដល់ដោយទស្សនាវដ្ដី HR Asia ដែលជាទស្សនាវដ្ដី ស្ដីពីធនធានមនុស្សឈានមុខគេ ក្នុងតំបន់។

ការសម្រេចបានសមិទ្ធិផល និងការផ្ដល់ត្រឡប់ ដល់សហគមន៍ ដែលជាទីកន្លែងដែលយើងប្រកបអាជីវកម្ម គឺជាផ្នែកមួយនៃគុណតម្លៃស្នូលរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី។ ក្នុងនាមជាក្រុមហ៊ុនដ៏ល្អប្រពៃមួយ ធនាគារ ស៊ីអាយអ៊ីមប៊ី បានរួមចំណែក ក្នុងគម្រោងទំនួលខុសត្រូវសង្គមជាច្រើន រួមមានវិស័យអប់រំ សុខាភិបាល បរិស្ថាន សង្គមកិច្ច និងគម្រោងជាច្រើនទៀតផងដែរ។ ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា បានផ្ដល់អាហារូបករណ៍ ១០០% ដល់និស្សិតក្រីក្រចំនួនបីនាក់ មកពីអង្គការមូលនិធិកុមារកម្ពុជា សម្រាប់សិក្សាថ្នាក់បរិញ្ញាបត្រ និងបានផ្ដល់អាហារូបករណ៍តំបន់អាស៊ាន ដល់និស្សិតឆ្នើមម្នាក់ទៀតផងដែរ។ សម្រាប់វិស័យសុខាភិបាល និងសង្គមកិច្ច យើងបានរៀបចំកម្មវិធីបរិច្ចាគឈាម ដោយមានការចូលរួមស្ម័គ្រចិត្ត ពីគណៈគ្រប់គ្រង និងបុគ្គលិករបស់ធនាគារ ព្រមទាំងបានបរិច្ចាគថវិកាចំនួន ៤០លានរៀល និងសម្ភារៈប្រើប្រាស់ចាំបាច់មួយចំនួនទៀត ដល់ជនរងគ្រោះដោយទឹកជំនន់ នៅតាមខេត្តមួយចំនួន ដែលរងគ្រោះដោយគ្រោះមហន្តរាយទឹកជំនន់ទូទាំងប្រទេសផងដែរ។

ក្នុងនាមជាក្រុមហ៊ុនមួយ ដែលយកចិត្តទុកដាក់លើវិស័យអប់រំ បរិស្ថាន និងនិរន្តរភាព ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា បានរៀបចំកម្មវិធីសប្បុរសធម៌មួយ ដោយបានបរិច្ចាគសម្ភារៈសិក្សានិងដាំកូនឈើ នៅវិទ្យាល័យ ព្រៃកដំបូក ខេត្តកំពង់ចាម។ ដោយមានកិច្ចសហការ ជាមួយនឹងធនាគារជាតិ នៃកម្ពុជា ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា ក៏បានរៀបចំព្រឹត្តិការណ៍ស្រដៀងគ្នានេះផងដែរ នៅវិទ្យាល័យកំពង់ថ្ម ខេត្តកំពង់ធំ។ មិនតែប៉ុណ្ណោះ ជាមួយនឹងរដ្ឋបាលខេត្តសៀមរាប និងអាជ្ញាធរជាតិអប្សរា យើងបានសហការរៀបចំ និងឧបត្ថម្ភពិធីដាំកូនឈើ ប្រមាណ ១.៥០០ដើម នៅទីធ្លាប្រាសាទបន្ទាយក្ដី ដែលមានភ្ញៀវចូលរួមជាង ៥០០នាក់ រួមមានបុគ្គលិកធនាគារ ភ្ញៀវកិត្តិយស និងសាធារណៈជនទៀតផង។ ឯកឧត្តមអភិបាលរងខេត្តសៀមរាប អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា និងប្រធាននាយកប្រតិបត្តិរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី បានប្រារព្ធពិធីអបអរសាទរខួប១០ឆ្នាំ របស់ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា នៅក្នុងព្រឹត្តិការណ៍ដ៏គួរឲ្យចងចាំនោះផងដែរ។

ខណៈការផ្ទុះផ្ទង់វ៉ាក់សាំងកូវីដ-១៩ កាន់តែមានភាពទូលំទូលាយ ក្នុងឆ្នាំ២០២១នេះ ហើយរាជរដ្ឋាភិបាលបានចាប់ផ្ដើមកម្មវិធីចាក់វ៉ាក់សាំង ដល់ប្រជាពលរដ្ឋរបស់ខ្លួនដែរនោះ ក្ដីសង្ឃឹមនៃការស្តារឡើងវិញ នៃសេដ្ឋកិច្ចសង្គមសំខាន់ៗ កំពុងប្រព្រឹត្តទៅយ៉ាងរលូនផងដែរ។ ជាមួយនឹងការរំពឹងទុកនៃការវិវឌ្ឍថ្មីៗ និងដំណឹងគួរឲ្យរីករាយរបស់ប្រទេសជាតិ នៅពេលខាងមុខ យើងនឹងបន្ត នាំយកភាពងាយស្រួលកាន់តែល្អប្រសើរ បណ្ដាញតភ្ជាប់ទំនាក់ទំនងកាន់តែទូលំទូលាយ និងឱកាសកាន់តែច្រើនទៀត ដល់អតិថិជនរបស់យើង ខណៈដែលបុគ្គលិករបស់យើងបានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយក្រុមការងារថ្នាក់តំបន់ ដោយទាញយកគុណសម្បត្តិ ពីវត្តមានទីតាំងដ៏ច្រើនរបស់ ធនាគារ ស៊ីអាយអ៊ីមប៊ី នៅទូទាំងតំបន់អាស៊ាន និងតំបន់អាស៊ីប៉ាស៊ីហ្វិក។

ជាចុងក្រោយ តាងនាមឲ្យក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់របស់ធនាគារ ស៊ីអាយអ៊ីមប៊ី ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់រាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិ នៃកម្ពុជា និងអតិថិជនទាំងអស់ ដែលតែងតែគាំទ្រ ជឿជាក់ និងរីកចម្រើន ជាមួយយើង ពេញមួយឆ្នាំ២០២០។ យើងសង្ឃឹមយ៉ាងមុតមាំថា ឆ្នាំ២០២១ ដែលពោរពេញដោយការប្រកួតប្រជែង និងឱកាស អាចផ្ដល់នូវភាពរីកចម្រើនម្តងទៀត សម្រាប់វិស័យធនាគារ និងហិរញ្ញវត្ថុ នៅកម្ពុជា ដោយផ្ដល់នូវការលូតលាស់ និងវិបុលភាព សម្រាប់យើងទាំងអស់គ្នា៖

Datuk Mohd Nasir Ahmad
ប្រធានក្រុមប្រឹក្សាភិបាល

សារពីប្រធាននាយកប្រតិបត្តិក្រុមហ៊ុនមេ

ជូនចំពោះ ភាគទុនិកទាំងអស់

ឆ្នាំ២០២០ គឺជាពេលវេលាមួយ ដែលពិភពលោកត្រូវដោះស្រាយ ជាមួយនឹងជំងឺរាតត្បាតសាកល ដោយបានធ្វើឲ្យធ្លាក់ចូលយ៉ាងឆាប់រហ័ស ក្នុងវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរបំផុត គិតចាប់តាំងពីវិបត្តិសេដ្ឋកិច្ច កាលពីទស្សវត្សរ៍ឆ្នាំ១៩៣០មក។ បម្រាមគោចរ ត្រូវបានដាក់ឲ្យអនុវត្ត ពីសំណាក់រដ្ឋាភិបាល ក្នុងប្រទេសភាគច្រើន ដែលបានបណ្តាលឲ្យផ្នែកសេដ្ឋកិច្ចទទួលរងគ្រោះ។ សេដ្ឋកិច្ចតំបន់អាស៊ានមានភាពវឹកវរ ហើយស្ថានភាពមិនប្រាកដប្រជាបែបនេះ បាននាំឲ្យមានការធ្លាក់ចុះ នៃទំនុកចិត្ត និងការចាយវាយ របស់ប្រជាពលរដ្ឋ។ ទោះបីជាប្រទេសមួយចំនួន សម្រេចបានជោគជ័យ ក្នុងការទប់ស្កាត់ការរាតត្បាតជំងឺនេះក៏ដោយ ការកើតឡើងនៃរលកឆ្លងជាថ្មី និងការបម្លែងខ្លួនរបស់មេរោគ បានបន្តបង្កជាហានិភ័យធ្ងន់ធ្ងរ ដែលបង្កើតនូវផលវិនាស ទៅលើវិស័យសំខាន់ៗ ដូចជាវិស័យទេសចរណ៍ ពាណិជ្ជកម្ម និងផលិតភាពជាដើម។ ប្រទេសមួយចំនួន ក្នុងតំបន់អាស៊ាន ធ្លាប់មានបទពិសោធន៍ នៃការធ្លាក់ចុះលំហូរហិរញ្ញវត្ថុ និងតម្លៃរូបិយប័ណ្ណ ដែលប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្ម និងការវិនិយោគផងដែរ។

សេដ្ឋកិច្ចកម្ពុជា បានធ្លាក់ចុះដល់ -១,៩% នៃទំហំផលិតផលក្នុងស្រុកសរុប ដែលជាលើកដំបូងបំផុត ក្នុងរយៈពេលជាង ២ទសវត្សរ៍ចុងក្រោយមកនេះ ចាប់តាំងពីវិបត្តិហិរញ្ញវត្ថុអាស៊ី ក្នុងឆ្នាំ១៩៩៨។ វិស័យទេសចរណ៍ និងឧស្សាហកម្មកាត់ដេរ ដែលជាចលករសំខាន់ ក្នុងការរួមចំណែកដល់សេដ្ឋកិច្ចប្រទេស បានទទួលរងផលប៉ះពាល់ គួរឲ្យកត់សម្គាល់។ ចំនួនភ្ញៀវទេសចរបរទេស បានថយចុះរហូតដល់ -៧៩% ខណៈដែលការនាំចេញផលិតផលឧស្សាហកម្ម បានធ្លាក់ចុះ -៨,១% បើធៀបនឹងឆ្នាំមុន។ ទោះជាយ៉ាងណាក៏ដោយ សញ្ញានៃការងើបឡើងវិញ អាចនឹងកើតមាន តាមរយៈការបន្ធូរបន្ថយ លើបម្រាមគោចរ ដែលជំណើរការសេដ្ឋកិច្ចក្នុងស្រុក នឹងមានភាពល្អប្រសើរបន្តិចម្តងៗ ស្របពេលដែលលំហូរទុនវិនិយោគដោយផ្ទាល់ពីបរទេស លើវិស័យមួយចំនួន មានការងើបឡើងវិញផងដែរ។

ក្នុងឆ្នាំ២០២០ ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា សម្រេចបានសមិទ្ធផលហិរញ្ញវត្ថុល្អប្រសើរ លើគ្រប់ផ្នែកទាំងអស់ និងបានក្លាយជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលមានភាពរីកចម្រើនខ្ពស់បំផុតមួយ របស់ស៊ីអាយអិមប៊ី គ្រុប។ ឆ្លើយតបនឹងកត្តាប្រយោម នៃការរាតត្បាតជំងឺសាកលនេះ ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា បានបន្តរក្សាកំណើនពីរខ្ទង់ ជាមួយនឹងប្រាក់ចំណេញមុនបង់ពន្ធចំនួន ២៦,៨លានដុល្លារអាមេរិក ដែលមានកំណើនប្រចាំឆ្នាំ ១៧% ធៀបនឹងឆ្នាំមុន។ ផ្នែកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម រួមចំណែកដល់ ៥៧% នៃទំហំឥណទានសរុបរបស់ធនាគារ ខណៈដែលផ្នែកសេវាកម្មហិរញ្ញវត្ថុបុគ្គល មានចំនួន ៥២% នៃទំហំប្រាក់បញ្ញើសរុបរបស់ធនាគារ។ មិនតែប៉ុណ្ណោះ ផ្នែកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម អាចរក្សាបាននូវសន្ទុះរីកចម្រើនរបស់ខ្លួន ជាមួយនឹងកំណើនឥណទានប្រចាំឆ្នាំ ក្នុងកម្រិត ៩៤%។ ផ្នែកសេវាកម្មគ្រឹះស្ថានហិរញ្ញវត្ថុ សម្រេចបានកំណើនប្រាក់បញ្ញើ លើសផែនការ ក្នុងកម្រិត ២២៩% ធៀបនឹងឆ្នាំមុន។ ស្របនឹងភាពរីកចម្រើនខាងលើនេះ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានឈ្នះពានរង្វាន់ «ទីកន្លែងការងារល្អបំផុត នៅកម្ពុជា» ដែលផ្តល់ដោយទស្សនាវដ្ដី HR Asia។

ស្ថិតក្នុងបរិបទរបស់ក្រុមហ៊ុនមេ ឆ្នាំ២០២០ គឺជាពេលវេលា ដែលមានការកែលម្អ និងដាក់ឲ្យអនុវត្ត នូវផែនការយុទ្ធសាស្ត្ររយៈពេលមធ្យមឡើងវិញ គឺ «Forward23+»។ ផែនការនេះមានគោលដៅប្រែក្លាយធនាគារ ស៊ីអាយអិមប៊ី ទៅជាធនាគារឈានមុខគេមួយ ដែលផ្តោតលើតំបន់អាស៊ាន តាមរយៈការបន្តបេសកកម្ម ក្នុងការកសាងស្ថាប័នមួយ ដែលសម្រេចបានសមិទ្ធផលខ្ពស់ ប្រកបដោយនិរន្តរភាព ដើម្បីជួយលើកកម្ពស់ភាពរីកចម្រើនរបស់អតិថិជន និងសង្គមជាតិទាំងមូល។ Forward23+ គ្របដណ្ដប់លើគោលដៅយុទ្ធសាស្ត្រគន្លឹះចំនួនប្រាំ រួមមាន ១-ការបង្កើតផលប្រយោជន៍ហិរញ្ញវត្ថុ ប្រកបដោយនិរន្តរភាព។២-ការអនុវត្តផែនការប្រកបដោយវិន័យ។៣-ការផ្តោតលើការយកចិត្តទុកដាក់លើអតិថិជន។ ៤-ការអភិវឌ្ឍមូលដ្ឋានគ្រឹះ និង ៥-ស្ថាប័នដែលឆ្ពោះទៅមុខ តាមចក្ខុវិស័យ។ គោលដៅទាំងអស់នេះបង្ហាញពីគោលបំណងច្បាស់លាស់ ដែលនឹងត្រូវសម្រេចឲ្យបាន មុនឆ្នាំ២០២៤។ យើងមានផែនការសម្រេចឲ្យបាននូវផលលើមូលធន (ROE) ឈានមុខគេលើទីផ្សារ អនុបាតចំណាយធៀបនឹងចំណូល (CIR) ក្នុងកម្រិត ៤៥% និងមូលធនទូទៅ ថ្នាក់ទី១ (CET1) ក្នុងកម្រិត ១៣%។ ហើយសម្រាប់គោលដៅមិនពាក់ព័ន្ធនឹងផ្នែកហិរញ្ញវត្ថុ យើងខិតខំប្រឹងប្រែង ដើម្បីក្លាយជាក្រុមហ៊ុនកំពូលមួយ និងស្ថិតក្នុងចំណាត់ថ្នាក់ គិតជាភាគរយ ទាំង៧៥ នៃពិន្ទុវាយតម្លៃសរុប (NPS) ព្រមទាំងស្ថិតក្នុងតារាងចំណាត់ថ្នាក់ Dow Jones Sustainability Index (DJSI)។

ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់យើង ក្នុងប្រទេសកម្ពុជា បានរក្សាភាពរីកចម្រើនល្អបំផុតមួយ ក្នុងចំណោមក្រុមហ៊ុនដទៃទៀត របស់ស៊ីអាយអិមប៊ី គ្រុប

ជាមួយនឹងកំណើនជារួម លើប្រាក់ចំណេញមុនបង់ពន្ធ ក្នុងកម្រិត

៤៥%

ផែនការយុទ្ធសាស្ត្រ Forward23+ បញ្ជាក់ពីការប្តេជ្ញាចិត្ត របស់ស៊ីអាយអិមបុី គ្រុប ចំពោះធនាគារ ស៊ីអាយអិមបុី ភីអិលស៊ី។ ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់យើង ក្នុងប្រទេសកម្ពុជា បានរក្សាភាពរីកចម្រើនល្អបំផុតមួយ ក្នុងចំណោមក្រុមហ៊ុនដទៃទៀត របស់ស៊ីអាយអិមបុី គ្រុប ជាមួយនឹងកំណើនជារួម លើប្រាក់ចំណេញមុនបង់ពន្ធ ក្នុងកម្រិត ៤៥% សម្រាប់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ហើយបានបង្ហាញនូវសក្តានុពលរីកចម្រើនដ៏អស្ចារ្យមួយ។ យើងមានទំនុកចិត្តថា នាឆ្នាំខាងមុខ ធនាគារ ស៊ីអាយអិមបុី ក្នុងប្រទេសកម្ពុជា នឹងសម្រេចបានចក្ខុវិស័យក្នុងការក្លាយជា ធនាគារសាកលលយានមុខគេមួយ ដែលផ្តោតលើសហគមន៍ ក្នុងប្រទេសកំពុងអភិវឌ្ឍឆាប់រហ័សមួយនេះ។

ក្នុងឆ្នាំ២០២១ ស្របពេលដែលវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ត្រូវបានចាក់លើមនុស្សកាន់តែច្រើនឡើង នៅលើសាកលលោក ក្តីសង្ឃឹមនៃការត្រឡប់មកភាពប្រក្រតីវិញ នឹងគ្របដណ្តប់លើប្រទេសកាន់តែច្រើនឡើងផងដែរ។ ធនាគារជាតិ នៃកម្ពុជា បានព្យាករកំណើនសេដ្ឋកិច្ច ក្នុងកម្រិត ៤% សម្រាប់ឆ្នាំ២០២១ តាមរយៈការងើបឡើងវិញនៃវិស័យសំណង់ និងអចលនទ្រព្យ។ លំហូរទុនវិនិយោគដោយផ្ទាល់ ពីបរទេស ក្នុងឧស្សាហកម្មមិនមែនកាត់ដេរ និងវិស័យកសិកម្ម នឹងមានកំណើនល្អប្រសើរ តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងថ្នាក់តំបន់ រួមមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ជាដើម។ កសិកម្ម គឺនៅតែជាវិស័យដ៏សំខាន់ ប្រកបដោយសក្តានុពលខ្ពស់ ស្របពេលដែលផលិតកម្មប្រេង នឹងផ្តល់ឲ្យប្រទេសកម្ពុជា នូវប្រភពចំណូលមួយផ្នែកទៀត ដល់ថវិកាជាតិ សម្រាប់ការអភិវឌ្ឍ នាពេលអនាគត លើវិស័យអាទិភាព។ ជាមួយគ្នានេះ យើងរំពឹងទទួលបានកំណើនវិជ្ជមាន សម្រាប់ធនាគារ ស៊ីអាយអិមបុី ក្នុងប្រទេសកម្ពុជា ស្របនឹងការងើបឡើងវិញ នៃសេដ្ឋកិច្ចជាតិនេះ។

តាងនាមឲ្យស៊ីអាយអិមបុី គ្រុប ខ្ញុំសូមសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅ ដល់រាជរដ្ឋាភិបាលកម្ពុជា និងធនាគារជាតិ នៃកម្ពុជា សម្រាប់ការបន្តជួយជ្រោមជ្រែងរៀងរហូតមក។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណ ដល់ប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាលធនាគារ អតិថិជនភាគទុនិក និងភាគីពាក់ព័ន្ធទាំងអស់ សម្រាប់ការបន្តជឿទុកចិត្ត និងគាំទ្រ ដល់ធនាគារ ស៊ីអាយអិមបុី ក្នុងប្រទេសកម្ពុជា។ ជាចុងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណ ដល់សហសេវិកទាំងអស់ក្នុងក្រុមការងារ #TeamCIMB ក្រោមការដឹកនាំយ៉ាងរឹងមាំ របស់លោក ប៊ិន យីន ក្នុងការបន្តការប្តេជ្ញាចិត្ត និងគាំទ្ររួមចំណែក ប្រកបដោយគុណតម្លៃ ចំពោះភាពជោគជ័យ ដែលសម្រេចបាន ក្នុងឆ្នាំ២០២០។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំមានទំនុកចិត្តថា ធនាគារ ស៊ីអាយអិមបុី ក្នុងប្រទេសកម្ពុជា នឹងបន្តចាប់យកឱកាសរីកចម្រើន ក្នុងពេលនៃការងើបឡើងវិញ នៃកំណើនសេដ្ឋកិច្ចជាតិ។

ធនាគារ ស៊ីអាយអិមបុី ក្នុងប្រទេសកម្ពុជា បន្តដើរតួនាទីយ៉ាងសំខាន់ នៅក្នុងយុទ្ធសាស្ត្រមេរបស់ Forward23+ ដែលជាការកែលម្អឡើងវិញ លើផែនការដែលមានស្រាប់ សម្រាប់ការកំណត់គោលដៅយុទ្ធសាស្ត្រ។ ក្នុងន័យនេះ ធនាគារ ស៊ីអាយអិមបុី ក្នុងប្រទេសកម្ពុជា មានគោលដៅក្លាយជា ធនាគារសាកលលយានមុខគេ ដែលផ្តោតលើសហគមន៍ នៅកម្ពុជា មុនឆ្នាំ២០២៤។ គំនិតផ្តួចផ្តើមជាក់លាក់នេះ ត្រូវបានរៀបចំឡើង នៅគ្រប់ស្ថាប័នក្រោមចំណុះ ដើម្បីដឹកនាំយុទ្ធសាស្ត្រ ដែលបានកំណត់។ យុទ្ធសាស្ត្រ ដែលបានកែលម្អឡើងវិញនេះ នឹងពង្រឹងមូលដ្ឋានគ្រឹះដ៏រឹងមាំរបស់ធនាគារ ស៊ីអាយអិមបុី ក្នុងប្រទេសកម្ពុជា ដើម្បីរក្សាសន្ទុះកំណើន ក្នុងទីផ្សារ ដែលកំពុងមានកំណើនខ្ពស់។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធឌីជីថល នឹងក្លាយជាចំណុចអាទិភាពចម្បងបំផុតមួយ ដែលវានឹងជួយឲ្យយើងជម្នះបញ្ហាប្រឈម នៃការរាតត្បាតជំងឺកូវីដ-១៩ ហើយបង្កើតនូវបទពិសោធន៍សេវាកម្មកាន់តែល្អប្រសើរ ដល់អតិថិជនរបស់ធនាគារ ស៊ីអាយអិមបុី ក្នុងប្រទេសកម្ពុជា។

Tengku Zafrul Tengku Abdul Aziz
ប្រធាននាយកប្រតិបត្តិក្រុមហ៊ុនមេ
ស៊ីអាយអិមបុី គ្រុប ហូលឌីង ប៊ើហាដ

ការពិនិត្យមើលលទ្ធផលប្រតិបត្តិការរបស់ប្រធាននាយកប្រតិបត្តិ

បរិយាកាសប្រតិបត្តិការ ឆ្នាំ២០២០

ទិដ្ឋភាពសេដ្ឋកិច្ច នៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០២០ ត្រូវបានរងផលប៉ះពាល់យ៉ាងខ្លាំង ពីការរាតត្បាតជាសាកលនៃជំងឺកូវីដ-១៩។ វិស័យឧស្សាហកម្មទាំងអស់បានផ្លាស់ប្តូរប្រតិបត្តិការរបស់ខ្លួន ហើយអ្នកគ្រប់គ្នាបានផ្លាស់ប្តូរមធ្យោបាយ ដែលពួកគេបំពេញការងារ និងរស់នៅ ក្នុងការសម្របខ្លួនទៅនឹង «បរិបទថ្មី» នៃការធ្លាក់ចុះសកម្មភាពសេដ្ឋកិច្ច ប្រាក់ចំណូលក្នុងគ្រួសារ និងការរក្សាគម្លាតផ្ទាល់ខ្លួន និងសង្គម។

ដូចការរំពឹងទុក វិស័យឧស្សាហកម្មជាក់លាក់មួយចំនួនបានរងផលប៉ះពាល់ខ្លាំងជាងគេ។ ជាក់ស្តែង វិស័យទេសចរណ៍ បានធ្លាក់ចុះរហូតដល់ -៧៩% នៃចំនួនភ្ញៀវទេសចរអន្តរជាតិ បើធៀបនឹងឆ្នាំមុន ខណៈដែលវិស័យផលិតកម្មបានធ្លាក់ចុះ -៨,១% នៃការនាំចេញទំនិញសំខាន់ៗ ដូចជាសម្លៀកបំពាក់ និងស្បែកជើងជាដើម។ ធនាគារជាតិ នៃកម្ពុជា (NBC) បានរាយការណ៍ថា ផលិតផលក្នុងស្រុកសរុប (GDP) ក្នុងឆ្នាំ២០២០ បានធ្លាក់ចុះ -១,៩% ធៀបនឹងឆ្នាំមុន។ ហើយទោះបីជានេះ បានបង្ហាញពីការប្រែប្រួលគួរឲ្យកត់សម្គាល់ ធៀបនឹងស្ថិរភាពកំណើន GDP ប្រចាំឆ្នាំជាមធ្យម ប្រមាណ ៦-៧% ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះក្តី ក៏សេដ្ឋកិច្ចកម្ពុជារក្សាមានភាពអំណោយផលល្អប្រសើរជាងប្រទេសជាច្រើនទៀត សូម្បីប្រៀបធៀបនឹងប្រទេស ដែលមានសេដ្ឋកិច្ចរីកចម្រើនខ្លាំងក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

យើងទទួលបានការជួយជ្រោមជ្រែងយ៉ាងកក់ក្តៅ ពីរាជរដ្ឋាភិបាល និងនិយ័តករទាំងអស់ ដែលបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការកាត់បន្ថយផលប៉ះពាល់គួរឲ្យកត់សម្គាល់ ចំពោះសេដ្ឋកិច្ចកម្ពុជាជារួម។ វិធានការចាំបាច់ ដែលបានដាក់ចេញកន្លងមកនេះ មានដូចជាការបន្ធូរបន្ថយពន្ធ ដល់អាជីវកម្ម នៅក្នុងវិស័យទេសចរណ៍ ការឧបត្ថម្ភថវិកា និងគ្រឿងឧបភោគបរិភោគ សម្រាប់គ្រួសារដែលមានប្រាក់ចំណូលទាប ការចំណាយទាក់ទងនឹងវិស័យសុខាភិបាល និងគម្រោងផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល ដូចជាកម្មវិធីសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យមជាដើម។ គំនិតផ្តួចផ្តើមទាំងអស់នេះបានរួមចំណែក ក្នុងការការពារប្រទេសកម្ពុជា និងប្រជាជនរបស់ខ្លួន ពីផលប៉ះពាល់នានា នៃការធ្លាក់ចុះសេដ្ឋកិច្ចសាកល។

តាមរយៈវិធានការណ៍ដ៏ឈ្លាសវៃរបស់ធនាគារជាតិ នៃកម្ពុជា ទោះបីជាមានការសម្រួលដល់អនុបាតមួយចំនួន ដូចជាទ្រនាប់ដើមទុន តម្រូវការដើមទុនបម្រុង និងការផ្អាកបង់សងឥណទានប្រព័ន្ធធនាគារក្សាបានភាពរឹងមាំរបស់ខ្លួន និងបន្ថែមចំណែក ដល់សេដ្ឋកិច្ចប្រទេស។ ជាមួយនឹងចំនួនគណនីបញ្ញើ ជាង ៨,៩លានគណនី និងចំនួនឥណទានជាង ៣,២លានគណនី ទ្រព្យសកម្មសរុបរបស់ប្រព័ន្ធធនាគារ បានកើនឡើងដល់ប្រមាណ ៣៧,៣៣ន់លានដុល្លារអាមេរិក ជាមួយនឹងកំណើនប្រចាំឆ្នាំ ១៥,៧%។ ធនាគារជាតិ នៃកម្ពុជា បានរាយការណ៍ថា ក្នុងឆ្នាំ២០២០ មានធនាគារពាណិជ្ជចំនួន៥២ ធនាគារឯកទេសចំនួន១៤ ស្ថាប័នទទួលប្រាក់បញ្ញើចំនួន១៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៧៥ ប្រតិបត្តិករឥណទានជនបទចំនួន២៤៦ ក្រុមហ៊ុនភតិសន្យាចំនួន១៥ និងក្រុមហ៊ុនផ្តល់សេវាទូទាត់ប្រាក់ចំនួន២៤។

១៧% **២៦,៨**លានដុល្លារអាមេរិក
ប្រាក់ចំណេញមុនកាត់ពន្ធ

១,៣ពាន់លានដុល្លារអាមេរិក
ទ្រព្យសកម្ម

២១% ឥណទានរបស់អតិថិជន

១៦% ប្រាក់បញ្ញើរបស់អតិថិជន

១១% ឥណទានជាប្រាក់រៀល

0.15% ឥណទានមិនដំណើរការ

15% ទំហំដំណើរការនៃប្រតិបត្តិការ

12% ចំនួនអតិថិជន

38% អនុបាតចំណាយធៀបនឹងចំណូល

17% ផលលើមូលធន (ROE)

លទ្ធផលប្រតិបត្តិការ ឆ្នាំ២០២០

ទោះបីជាឆ្នាំ២០២០ គឺជាឆ្នាំដ៏លំបាកបំផុតមួយ ដែលធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា បានជួបប្រទះ ខណៈដែលដំណើរការប្រតិបត្តិការមានការប្រឈមខ្លះក្តី យើងពិតជាមានមោទនភាពចំពោះសមិទ្ធផលហិរញ្ញវត្ថុរបស់យើង។ ឆ្លើយតបនឹងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ច ធនាគារបានកត់ត្រានូវប្រាក់ចំណេញមុនបង់ពន្ធគួរឲ្យកត់សម្គាល់ ស្របតាមគោលដៅរបស់ខ្លួន ក្នុងអត្រា ១៧% បើធៀបនឹងឆ្នាំមុន។ យើងខ្ញុំមានក្តីសោមនស្សរីករាយ ដែលសម្រេចបានប្រាក់ចំណេញមុនបង់ពន្ធចំនួន ២៦,៨លានដុល្លារអាមេរិក ដែលនាំឲ្យទ្រព្យសកម្មរបស់យើង កើនឡើងដល់ ១,៣៣ន់លានដុល្លារអាមេរិក។

ទំហំឥណទានសរុប បានកើនឡើង ៨៥១លានដុល្លារអាមេរិក ហើយប្រាក់បញ្ញើសរុប (រាប់បញ្ចូលទាំងប្រាក់បញ្ញើ ពីគ្រឹះស្ថានហិរញ្ញវត្ថុ) បានកើនឡើង ១,០៣៣ន់លានដុល្លារអាមេរិក ទោះបីជាបរិយាកាសសេដ្ឋកិច្ចមានបញ្ហាប្រឈមក៏ដោយ។ តារាងតុល្យការរបស់ធនាគារមានកំណើនល្អប្រសើរ ដោយទំហំឥណទានរបស់អតិថិជនបានកើនឡើង ២១% និងប្រាក់បញ្ញើរបស់អតិថិជន បានកើនឡើង ១៦% បើធៀបនឹងឆ្នាំមុន។ ទំហំឥណទានជាប្រាក់រៀលនៅរក្សាបានល្អ ក្នុងកម្រិត ១១% នៃទំហំឥណទានសរុបរបស់យើង ដែលអនុលោមតាមបទប្បញ្ញត្តិឥណទានជាប្រាក់រៀល។ ទំហំដំណើរការនៃប្រតិបត្តិការ បានកើនឡើង ១៥% បើធៀបនឹងឆ្នាំមុន ហើយចំនួនអតិថិជនរបស់យើងបានកើនឡើងប្រមាណ ១២% ផងដែរ។ ការចំណាយប្រតិបត្តិការ ត្រូវបានរក្សាក្នុងកម្រិតល្អប្រសើរ ជាមួយនឹងអនុបាតចំណាយធៀបនឹងចំណូល ក្នុងកម្រិត ៣៨%។

ស្របតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា បានពន្យារពេលជូនអតិថិជន ចំពោះការផ្អាកបង់សងឥណទាន ដើម្បីជួយសម្រាលបន្ទុកហិរញ្ញវត្ថុរបស់ពួកគេ ក្នុងគ្រាដ៏លំបាកនេះ។ គួរឲ្យកត់សម្គាល់ដែរនោះ ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា អាចរក្សាបានកំណត់ត្រា នៃឥណទានមិនដំណើរការស្ទើរស្មើសូន្យ ក្នុងកម្រិត ០,១៥% ទាបជាងអត្រាជាមធ្យម ក្នុងវិស័យធនាគារទាំងមូល ដែលមានកម្រិត ២,៥០%។

សរុបមក សមិទ្ធផលប្រតិបត្តិការរបស់ធនាគារ ក្នុងឆ្នាំ២០២០ មានភាពល្អប្រសើរ ជាមួយនឹងផលលើមូលធន (ROE) ក្នុងអត្រា ១៧%។ កម្រិតនៃផលលើមូលធននេះរក្សាបាននូវតំណែងរបស់យើង ក្នុងចំណោមធនាគារពាណិជ្ជកំពូល នៅប្រទេសកម្ពុជា បើគិតលើប្រាក់ចំណេញ ហើយនឹងស្ថិតក្នុងចំណោមក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលមានភាពរីកចម្រើនខ្ពស់បំផុតមួយ របស់ស៊ីអាយអ៊ីមប៊ី គ្រុប នៅក្នុងតំបន់។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអតិថិជនរបស់យើង សម្រាប់ការបន្តគាំទ្ររហូតមក និងក្រុមការងារទាំងអស់របស់ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា សម្រាប់ការលះបង់ដ៏សំខាន់ ក្នុងការបន្តបម្រើអតិថិជនរបស់យើងឲ្យបានល្អប្រសើរ។ យើងខ្ញុំមានកិត្តិយសយ៉ាងធំធេង ដែលធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា បានឈ្នះពានរង្វាន់ «ទីកន្លែងការងារល្អបំផុតនៅកម្ពុជា» ក្នុងឆ្នាំ២០២០។

ចក្ខុវិស័យ សម្រាប់ឆ្នាំ ២០២១

ធនាគារជាតិ នៃកម្ពុជា បានព្យាករថា ទំហំផលិតផលសរុបរបស់ប្រទេសកម្ពុជានឹងងើបឡើងវិញ ក្នុងអត្រា ៤% ក្នុងឆ្នាំ២០២១ ស្របពេលដែលវ៉ាក់សាំងកូវីដ-១៩ នឹងអាចទប់ស្កាត់ការរីករាលដាលនៃការឆ្លងជំងឺ ដោយជោគជ័យ ក្នុងឆមាសទីមួយនៃឆ្នាំ២០២១។ ការព្យាកររបស់ធនាគារជាតិ នៃកម្ពុជា ដែលបានចេញផ្សាយ នៅក្នុងរបាយការណ៍វឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ច និងវិស័យធនាគារឆ្នាំ២០២០ ក្នុងខែធ្នូ ឆ្នាំ២០២០ គឺស្របទៅនឹងការព្យាកររបស់ធនាគារពិភពលោក ក្នុងខែដដែលនោះដែរ។ បើតាមរបាយការណ៍នេះ បានឲ្យដឹងថា អតិផរណានឹងស្ថិតក្នុងអត្រាក្រោម ៣% ដែលធនាគារជាតិ នៃកម្ពុជា ជឿជាក់ថា មកពីកត្តាស្ថិរភាពនៃអត្រាប្តូរប្រាក់ និងការគ្រប់គ្រងរឹងមាំ នៃទុនបម្រុងរូបិយប័ណ្ណអន្តរជាតិ។

យើងមានសុទិដ្ឋិនិយមថា ឆ្នាំ២០២១ នឹងក្លាយជាឆ្នាំវិជ្ជមានមួយទៀត សម្រាប់ប្រតិបត្តិការរបស់ធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ស្របតាមផែនការរយៈពេលមធ្យមរបស់ស៊ីអាយអ៊ីមប៊ី គ្រុប ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា បានផ្តួចផ្តើមយុទ្ធសាស្ត្រ Forward23 + របស់ខ្លួន ដែលជួយដល់ការសម្រេចចិត្ត ផ្នែកអាជីវកម្ម ដើម្បីសម្រេចគោលដៅហិរញ្ញវត្ថុរបស់ធនាគារ ស្របពេលដែលផ្តល់គុណតម្លៃ ដល់អតិថិជនរបស់ខ្លួន។

FORWARD 23+

ចក្ខុវិស័យនៃយុទ្ធសាស្ត្រ

ចក្ខុវិស័យនៃយុទ្ធសាស្ត្រ Forward23+ របស់យើង គឺដើម្បីក្លាយជា ធនាគារសាកលឈានមុខគេ ដែលផ្តោតលើសហគមន៍ នៅកម្ពុជា មុនឆ្នាំ២០២៤ ដោយផ្តោតលើការរកប្រាក់ចំណេញរយៈពេលវែង។ ចលករនៃភាពរីកចម្រើនរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា ត្រូវបានរួមចំណែកយ៉ាងសំខាន់ ដោយសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម សេវាកម្មហិរញ្ញវត្ថុបុគ្គល និងគាំទ្រដោយសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងប្រតិបត្តិការ។ ចក្ខុវិស័យយុទ្ធសាស្ត្ររបស់យើង គឺសំដៅដល់យុទ្ធសាស្ត្រប្រតិបត្តិការ ដែលត្រូវអនុវត្តដោយអង្គភាពអាជីវកម្ម និងអ្នកគាំទ្រអាជីវកម្មរបស់យើង។ ចំណុចផ្តោតសំខាន់រយៈពេលមធ្យមរបស់យើង គឺរួមមានប្រាក់ចំណេញ ប្រសិទ្ធភាពនៃការចំណាយ ការយកចិត្តទុកដាក់លើអតិថិជន និងការវិនិយោគលើធនធានមនុស្ស និងបច្ចេកវិទ្យា។

ប្រាក់ចំណេញ

ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា មានបំណងទាញយកផលចំណេញ ពីមូលដ្ឋានគ្រឹះអាជីវកម្មរបស់ខ្លួន ដើម្បីរក្សាកំណត់ត្រាប្រាក់ចំណេញរបស់ខ្លួន នៅក្នុងបរិយាកាសនៃភាពរីកចម្រើនចម្រុះបែប។ សម្រាប់ឆ្នាំខាងមុខ យើងបានកំណត់គោលដៅហិរញ្ញវត្ថុ ដែលរួមមានកំណើនប្រចាំឆ្នាំ ១០% សម្រាប់ប្រាក់ចំណេញមុនបង់ពន្ធ កំណើនឥណទាន ១៥% និងកំណើនប្រាក់បញ្ញើ ១២%។ ហើយធនាគារបានប្តេជ្ញាចិត្ត ក្នុងការរក្សាកម្រិតអនុបាតឥណទានមិនដំណើរការ ក្នុងអត្រាអតិបរិមា ០.៥%។ កំណើនឥណទានជួយជំរុញ ពីសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម ខណៈដែលកំណើនប្រាក់បញ្ញើនឹងបំពេញដោយសេវាកម្មហិរញ្ញវត្ថុបុគ្គល ជាពិសេសផ្នែកសេវាកម្មធនាគារជាន់ខ្ពស់ Preferred។ យើងនឹងផ្តោតលើប្រាក់ចំណូល លើកម្រៃសេវាកម្មពីសេវាកម្មប្រតិបត្តិការ និងសេវាកម្មដែលទាក់ទងនឹងអត្រាប្តូរប្រាក់បរទេស។ យើងរំពឹងសម្រេចបានផលលើមូលធន ក្នុងអត្រាប្រមាណ ១៥% ក្នុងឆ្នាំ២០២១ ដែលអាចរក្សាតំណែងរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា ក្នុងចំណោមក្រុមហ៊ុន ដែលសម្រេចបានអត្រាផលលើមូលធនខ្ពស់បំផុតរបស់ស៊ីអាយអ៊ីមប៊ី គ្រុប។

ប្រសិទ្ធភាពនៃការចំណាយ

ដើម្បីសម្រេចបានប្រសិទ្ធភាពនៃការចំណាយ យើងនឹងចាប់ផ្តើមអនុវត្តគំនិតផ្តួចផ្តើមផ្សេងគ្នា ដែលរួមបញ្ចូលកិច្ចខិតខំប្រឹងប្រែងរួម ពីគ្រប់អង្គភាពអាជីវកម្ម និងអង្គភាពគាំទ្រអាជីវកម្ម។ ដើម្បីរក្សាការចំណាយឥណទាន ទៅជាចំណូល យើងមានគោលបំណងរក្សាអនុបាតគណនីចរន្ត និងគណនីសន្សំ ក្នុងអត្រាប្រមាណ ៥៧% ដោយលើកទឹកចិត្ត ដល់អតិថិជនពាណិជ្ជកម្ម និងសាជីវកម្ម បន្តប្រតិបត្តិការគណនីរបស់ពួកគេ ជាមួយធនាគារ ស៊ីអាយអ៊ីមប៊ី។ យើងសង្ឃឹមជឿជាក់ ក្នុងការរក្សាអនុបាតចំណូលធៀបនឹងចំណាយ ទាបជាង ៤០% ដែលជាអត្រាទាបបំផុត ក្នុងចំណោមក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ស៊ីអាយអ៊ីមប៊ី គ្រុប។ យើងក៏នឹងបន្តអនុវត្តគំរូជាក់ស្តែង នៃគោលការណ៍គ្រប់គ្រងឥណទានរឹងមាំ ការចំណាយប្រុងប្រយ័ត្ន និងការវិនិយោគ ទៅលើការបណ្តុះបណ្តាលសមត្ថភាពបុគ្គលិក ជាមួយនឹងគោលបំណងចម្បង នៃបង្កើនផលិតភាពការងារ។

ការអភិវឌ្ឍធនធានមនុស្ស

ធនធានមនុស្ស រួមចំណែកធ្វើឲ្យធនាគារ រហូតមានថ្ងៃនេះ ដែលបានក្លាយជាធនាគារឈានមុខគេមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយថ្មីៗនេះបានឈ្នះពានរង្វាន់ «ទីកន្លែងការងារល្អបំផុត នៅកម្ពុជា» ក្នុងឆ្នាំ២០២០ ផ្តល់ដោយទស្សនាវដ្តី HR Asia។ ទាំងអស់នេះកើតឡើង ដោយសារជំនឿចិត្តរបស់យើង ក្នុងការជំរុញគំនិតផ្តួចផ្តើមផ្សេងៗ ដើម្បីបន្តអភិវឌ្ឍបុគ្គលិករបស់យើង។ ឆ្នាំ២០២១ នឹងគ្មានការប្រែប្រួលឡើយ ខណៈដែលយើងផ្តោតលើការអនុវត្តយុទ្ធសាស្ត្រ Forward23+ ដើម្បីពង្រឹងជំនាញ និងសមត្ថភាពរបស់បុគ្គលិក ជាពិសេសលើផ្នែកធនាគារឌីជីថល ស្របតាមការវិវឌ្ឍនៃឧស្សាហកម្មធនាគារ។

ការយកចិត្តទុកដាក់លើអតិថិជន

ចាប់តាំងពីដាក់ឲ្យអនុវត្ត ក្នុងឆ្នាំ២០១៩ ក្របខណ្ឌបទពិសោធន៍សេវាកម្មអតិថិជនរបស់យើង បានជួយផ្លាស់ប្តូរឲ្យធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា ក្លាយជាស្ថាប័នដែលយកចិត្តទុកដាក់ខ្ពស់ លើអតិថិជន។ ស្របពេលដែលបទពិសោធន៍សេវាកម្មអតិថិជន គឺជាផ្នែកមួយដ៏សំខាន់ នៃវប្បធម៌ស្ថាប័នរបស់យើង ធនាគារបានកំណត់គោលដៅ ក្នុងឆ្នាំ២០២១ ដើម្បីក្លាយជាក្រុមហ៊ុនកំពូលមួយ នៃពិន្ទុវាយតម្លៃសរុប (NPS) ព្រមទាំងស្ថិតក្នុងតារាងចំណាត់ថ្នាក់ Dow Jones Sustainability Index (DJSI) ដែលជាផ្នែកមួយ នៃការប្តេជ្ញាចិត្តរបស់យើង ក្នុងការលើកកម្ពស់បទពិសោធន៍សេវាកម្មអតិថិជន ជាមួយធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា។

បច្ចេកវិទ្យា និងទិន្នន័យ

យើងនឹងវិនិយោគឲ្យបានសមស្រប ដើម្បីបន្តគាំទ្រដល់ប្រតិបត្តិការធនាគារឌីជីថលរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា ព្រោះយើងយល់ច្បាស់ថាតរិយាបថរបស់អតិថិជន និងការធ្វើប្រតិបត្តិការធនាគារ ត្រូវបានផ្លាស់ប្តូរ ដោយសារការរាតត្បាតជំងឺ។ អាទិភាពរបស់យើង ក្នុងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន (IT) និងកម្មវិធីឌីជីថល នឹងជួយយើងឲ្យសម្របខ្លួន ទៅនឹងបរិបទថ្មី នៃសម័យកាលជំងឺកូវីដ-១៩ និងផ្តល់បទពិសោធន៍សេវាកម្មកាន់តែល្អប្រសើរ ចំពោះសេវាកម្មហិរញ្ញវត្ថុ និងធនាគារ ដល់អតិថិជនដ៏មានតម្លៃរបស់យើង។

ផែនការយុទ្ធសាស្ត្រ «Forward23» បានបញ្ជាក់ពីការរួមចំណែករបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា ចំពោះចក្ខុវិស័យរបស់ស៊ីអាយអ៊ីមប៊ី គ្រុប ដើម្បីក្លាយជាធនាគារឈានមុខគេមួយ ដែលផ្តោតលើតំបន់អាស៊ាន។ គោលបំណងរួមរបស់យើង មានភាពច្បាស់លាស់ ក្នុងការកសាងស្ថាប័នមួយ ប្រកបដោយនិរន្តរភាព និងសមិទ្ធផលខ្ពស់ ដើម្បីជួយលើកកម្ពស់ភាពចម្រើនរបស់អតិថិជន និងសង្គមជាតិទាំងមូល។ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងមកនេះ ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា បានក្លាយជាក្រុមហ៊ុនរីកចម្រើនលឿនបំផុតមួយ របស់ស៊ីអាយអ៊ីមប៊ី គ្រុប ជាមួយនឹងអត្រាកំណើនរួមប្រចាំឆ្នាំ (CAGR) នៅក្នុងប្រាក់ចំណេញមុនបង់ពន្ធរបស់ខ្លួន ក្នុងកម្រិត ៤៥% ហើយយើងមានទំនុកចិត្តខ្ពស់ថា ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា នឹងបន្តកំណត់ត្រាគួរឲ្យកត់សម្គាល់ នៃកំណើនដ៏រឹងមាំ ប្រកបដោយនិរន្តរភាព។

ជាចុងក្រោយ ខ្ញុំសូមសម្តែងការដឹងគុណដ៏ជ្រាលជ្រៅ ចំពោះអតិថិជនដ៏ស្មោះស្ម័គ្ររបស់យើង ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងសហការីទាំងអស់ ចំពោះការបន្តគាំទ្រ និងការប្តេជ្ញាចិត្តរហូតមក។ តាងនាមឲ្យធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី ខ្ញុំសូមសម្តែងការគោរព និងកោតសរសើរដ៏ខ្ពង់ខ្ពស់ ចំពោះរាជរដ្ឋាភិបាលកម្ពុជា និងធនាគារជាតិ នៃកម្ពុជា ចំពោះការគាំទ្រណែនាំយ៉ាងពេញទំហឹង ចាប់តាំងពីការបើកដំណើរការរបស់ធនាគារមក។ ជាមួយនឹងទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌបទប្បញ្ញត្តិដ៏រឹងមាំ យើងមានសុទិដ្ឋិនិយមយ៉ាងមុតមាំថា យើងនឹងឈានឆ្ពោះទៅមុខ ក្នុងឆ្នាំ២០២១ និងបន្តភាពជោគជ័យរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា។

លោក ប៊ុន យ៉ីន
ប្រធាននាយកប្រតិបត្តិ

ការពិនិត្យ
មើលធុរកិច្ច

២០ សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
២១ សេវាកម្មហិរញ្ញវត្ថុបុគ្គល
២២ សេវាកម្មហិរញ្ញវត្ថុសាធារណៈ
សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ
២៣ ធនធានសាធារណៈ
២៤ ហិរញ្ញវត្ថុ
២៥ ប្រតិបត្តិតាម
២៦ គ្រប់គ្រងហានិភ័យ
២៨ បច្ចេកវិទ្យា និងប្រតិបត្តិការ
៣០ រតនាភិបាល និងទីផ្សារ
៣១ ទីផ្សារ និងទំនាក់ទំនង
៣២ សវនកម្មផ្ទៃក្នុង
៣២ នីតិកម្ម និងលេខាធិការក្រុមហ៊ុន
៣៣ បទពិសោធន៍សេវាកម្មអតិថិជន
៣៣ គ្រប់គ្រងផលិតផល

ឆ្នាំ

ខួប១០ឆ្នាំ នៃប្រតិបត្តិការ

នៅប្រទេសកម្ពុជា

សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម

សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បំពេញតម្រូវការដល់ពាណិជ្ជករបស់ធនាគារ ដោយផ្តល់ជូននូវផលិតផលឥណទាន និងប្រាក់បញ្ញើ ព្រមទាំងសេវាកម្មប្រតិបត្តិការ ទៅដល់សហគ្រាសធុនតូច និងមធ្យម ក៏ដូចជាសហគ្រាសធំៗផងដែរ។

លទ្ធផលហិរញ្ញវត្ថុ និងសមិទ្ធផលសំខាន់ៗ ក្នុងឆ្នាំ ២០២០

នៅក្នុងឆ្នាំ២០២០ ឥណទានសរុបរបស់សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម រក្សាបានកំណើនរឹងមាំ ក្នុងកម្រិត ២០% ហើយប្រាក់បញ្ញើបានកើនឡើង ២១% បើធៀបនឹងឆ្នាំចាស់។ ជាមួយនឹងកំណើនឥណទានរឹងមាំ និងការរួមចំណែកយ៉ាងល្អប្រសើរ ពីប្រាក់ចំណូលមិនមែនការប្រាក់ សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មទទួលបានកំណើន នៃប្រាក់ចំណូលប្រតិបត្តិការសរុប រហូតដល់ ១៣%។ អនុបាតគណនីចរន្ត/គណនីសន្សំ ក្នុងកម្រិត ៧៣% គឺជាសញ្ញាបញ្ជាក់ពីការគ្រប់គ្រងតារាងតុល្យការដ៏មានប្រសិទ្ធភាព ដែលនាំឲ្យមានការចំណាយថវិកាជារួម ក្នុងកម្រិតទាប។ គុណភាពទ្រព្យសកម្ម របស់សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម នៅតែមានភាពរឹងមាំ ក្នុងឆ្នាំ២០២០ ដោយរក្សាបានកម្រិតឥណទានមិនដំណើរការ ត្រឹមតែ ០,០៨% ប៉ុណ្ណោះ ដែលជាទិន្នន័យល្អបំផុតមួយ ក្នុងវិស័យធនាគារ។

ក្នុងឆ្នាំ២០២០ សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម មានបុគ្គលិកប្រកបដោយសក្តានុពលសរុប ចំនួន ៤៦នាក់ រួមមានផ្នែកទំនាក់ទំនងអតិថិជន និងត្រួតពិនិត្យឥណទាន។ ជាមួយនឹងការផ្តោតសំខាន់ លើការលើកកម្ពស់ការផ្ទេរចំណេះដឹង និងបទពិសោធន៍ ព្រមទាំងដំណើរអភិវឌ្ឍន៍អាជីពយ៉ាងច្បាស់លាស់ យើងបានផ្តល់ជូនកម្មវិធីបណ្តុះបណ្តាលផ្សេងៗគ្នា ដើម្បីអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិក នៅគ្រប់កម្រិត។ ជាលទ្ធផលសមត្ថភាពរបស់បុគ្គលិកមានការរីកចម្រើន គួរឲ្យកត់សម្គាល់ ទៅលើប្រសិទ្ធភាព និងផលិតភាពការងារ ហើយបុគ្គលិកដែលមានស្នាដៃឆ្នើម ត្រូវបានដំឡើងតំណែង នៅក្នុងចំណោមក្រុមការងារផងដែរ។

យើងបាននាំយកបណ្តាញទំនាក់ទំនងថ្នាក់តំបន់ របស់ស៊ីអាយអិមប៊ី គ្រុប សម្រាប់ផលប្រយោជន៍ទៅវិញទៅមក រវាងធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា និងទីផ្សារសំខាន់ៗផ្សេងទៀត របស់ស៊ីអាយអិមប៊ី គ្រុប នៅក្នុងប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី សិង្ហបុរី វៀតណាម និងថៃ។ ជាមួយនឹងក្របខណ្ឌទំនាក់ទំនងថ្នាក់តំបន់នេះ យើងបានបង្កើតនូវគុណតម្លៃល្អប្រសើរបន្ថែមទៀត សម្រាប់អតិថិជនរបស់យើង ដោយសម្រួល ដល់ការស្វែងរកធនធាន និងការពង្រីកអាជីវកម្មឆ្លងប្រទេស សម្រាប់ពួកគេ។

ផែនការ សម្រាប់ឆ្នាំ ២០២១

ជាមួយនឹងមូលដ្ឋានគ្រឹះដ៏រឹងមាំ និងសមត្ថភាពបុគ្គលិកដ៏ខ្លាំងក្លា យើងជឿជាក់យ៉ាងមុតមាំថា យើងនឹងទទួលបានលទ្ធផលល្អប្រសើរ ក្នុងការរក្សាបានគុណភាពទ្រព្យសកម្ម ក្នុងឆ្នាំ២០២១។ ទោះបីជាមានកត្តាប្រឈមនានា នៅក្នុងស្រុក និងជាសាកលក៏ដោយ យើងរំពឹងថា ប្រទេសកម្ពុជានៅតែរក្សាបានកំណើនសេដ្ឋកិច្ចល្អប្រសើរ ក្នុងឆ្នាំ២០២១ ដោយផ្តល់នូវឱកាសអាជីវកម្មកាន់តែច្រើន សម្រាប់សហគ្រាសធុនតូច និងមធ្យម ព្រមទាំងសហគ្រាសធំៗ នៅក្នុងប្រទេស។

ក្នុងឆ្នាំ២០២១ យើងនឹងបន្តលើកកម្ពស់សមត្ថភាពក្រុមការងាររបស់យើង ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើង នូវសេវាកម្មបម្រើអតិថិជន ដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស ក៏ដូចជាការអភិវឌ្ឍផលិតភាពជារួម។ យើងនឹងបន្តវិនិយោគ លើការអភិវឌ្ឍសមត្ថភាពនិយោជិត តាមរយៈកម្មវិធីបណ្តុះបណ្តាល និងទិសដៅលើកកម្ពស់ជំនាញបន្ថែមទៀត។

ផលិតផលសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មទាំងអស់ រួមមាន៖

- ឥណទានមានកាលកំណត់
- ឥណទានវិចារូបន៍
- ឥណទាន សម្រាប់ទុនបង្វិល
- លិខិតធានា ពីធនាគារ
- លិខិតឥណទាន
- ផលិតផល និងសេវាកម្មហិរញ្ញប្បទាន ពាណិជ្ជកម្មផ្សេងៗ
- គណនីចរន្ត
- គណនីបញ្ញើ មានកាលកំណត់
- គណនី រូបិយប័ណ្ណបរទេស
- គណនីបញ្ញើទុក ក្នុងដៃតតិយជន
- សេវាកម្មប្តូរប្រាក់
- សេវាកម្មប្រតិបត្តិការ

សេវាកម្មហិរញ្ញវត្ថុបុគ្គល

នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុបុគ្គល គឺជាគ្រឹះយ៉ាងសំខាន់ សម្រាប់ដំណើរការអាជីវកម្ម របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងប្រទេសកម្ពុជា ដែលមានបុគ្គលិកប្រមាណ៥០% នៃចំនួនបុគ្គលិកសរុបរបស់ធនាគារ។ នាយកដ្ឋាននេះផ្តល់ជូននូវផលិតផល និងសេវាកម្មធនាគារដ៏សម្បូរបែបដល់អតិថិជន។ នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុបុគ្គល មានអង្គភាពក្រោមចំណុះចំនួន៤ រួមមាននាយកដ្ឋានគ្រប់គ្រងសាខា និងការលក់ នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុអតិថិជនអាទិភាព (Preferred Banking) នាយកដ្ឋានឥណទានបុគ្គល និងនាយកដ្ឋានប័ណ្ណឥណទាន (Credit Card)។

សមិទ្ធផលសំខាន់ៗ ក្នុងឆ្នាំ ២០២០

ការរាតត្បាត នៃជំងឺកូវីដ-១៩ បានបង្ក នូវឧបសគ្គប្រឈម ដល់វិស័យធនាគារ ដែលធ្វើឲ្យឆ្នាំ២០២០ ក្លាយជាឆ្នាំដ៏តានតឹងមួយ សម្រាប់ភាពរីកចម្រើន។ តែទោះជាយ៉ាងណាក៏ដោយ នាយកដ្ឋានហិរញ្ញវត្ថុបុគ្គល សម្រេចបាននូវលទ្ធផលដ៏គាប់ប្រសើរជាច្រើនផ្នែក រួមមានការរក្សាបានអត្រាកំណើនឥណទានជាវិជ្ជមាន និងអាចគ្រប់គ្រងបាននូវឥណទានមិនដំណើរការ ឲ្យស្ថិតនៅក្នុងកម្រិតមួយដ៏ទាបបំផុតផងដែរ។

សមិទ្ធផលសំខាន់ៗ រួមមាន៖

- ឥណទាន កើនឡើង ៦,២% ធៀបនឹងឆ្នាំ២០១៩
- ដាក់ឲ្យដំណើរការសេវាកម្ម Cambodia Shared Switch (CSS) ជាមួយនឹងអត្ថប្រយោជន៍ល្អៗ ដល់អតិថិជន
- សម្រួលដល់អតិថិជន អំឡុងពេលដ៏លំបាកនេះ ដោយផ្តល់ជូន និងពង្រីក ពេលវេលាបង់សងឥណទាន
- NPL រក្សាគុណភាពទ្រព្យសកម្ម ជាមួយនឹងអត្រាឥណទានមិនដំណើរការ ក្នុងកម្រិតទាប
- កែលម្អប្រព័ន្ធ និងដំណើរការ ដើម្បីធ្វើឲ្យប្រសើរឡើង នូវបទពិសោធន៍សេវាកម្មអតិថិជន
- កែលម្អ និងធ្វើទំនើបកម្ម សាខាចំនួន ៤ទីតាំង នៅក្នុងរាជធានីភ្នំពេញ

កម្មវិធីអភិវឌ្ឍសមត្ថភាពនិយោជិត គឺជាអាទិភាពចម្បងមួយ ក្នុងចំណោមអាទិភាពផ្សេងៗរបស់យើង។ តាមរយៈការគាំទ្រ ពីក្រុមការងារអភិវឌ្ឍធនធានមនុស្ស យើងបានរៀបចំវគ្គសិក្សា និងបណ្តុះបណ្តាលសរុបចំនួន ៧.៥០០ម៉ោង ដោយជោគជ័យ លើការពង្រឹងជំនាញ និងសមត្ថភាពផ្នែកលក់ សេវាកម្មអតិថិជន ការវិភាគឥណទាន ការគ្រប់គ្រងហានិភ័យ វិធាននិងការអនុវត្តច្បាប់ពាក់ព័ន្ធ ព្រមទាំងការយល់ដឹងពីប្រព័ន្ធ និងប្រតិបត្តិការធនាគារជាដើម។

ផែនការ សម្រាប់ឆ្នាំ ២០២១

វិធាន និងយុទ្ធសាស្ត្រសំខាន់ៗជាច្រើន នឹងត្រូវបានដាក់ឲ្យអនុវត្ត ដើម្បីលើកកម្ពស់សេវាកម្មអតិថិជន និងបង្កើនសមិទ្ធផលអាជីវកម្ម។

សម្រាប់ឆ្នាំ២០២១ យើងនឹងផ្តោតលើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- ដាក់ដំណើរការសេវាកម្មធនាគារចល័ត លើទូរសព្ទដៃ ដើម្បីទាក់ទាញអតិថិជនកាន់តែច្រើន និងធ្វើឲ្យប្រសើរឡើងនូវសេវាកម្មបម្រើអតិថិជន
- ផ្តោតលើការកែលម្អសេវាកម្មបម្រើអតិថិជន ជាមួយនឹងកម្មវិធីគាំទ្រមួយចំនួន ដើម្បីឲ្យអតិថិជនពេញចិត្ត និងសរសើរណែនាំ ពីសេវាកម្ម របស់ធនាគារ
- បន្តជំរុញឥណទានអតិថិជន និងប័ណ្ណឥណទាន
- បន្តកែលម្អ និងអភិវឌ្ឍជំនាញ បំពេញការងាររបស់បុគ្គលិក
- បន្តកែលម្អ និងធ្វើទំនើបកម្មសាខា ដើម្បីធ្វើឲ្យប្រសើរឡើងនូវការ រក្សាកេរ្តិ៍ឈ្មោះ និងកិត្តិនាមរបស់ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។

សេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ

សេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ ទទួលបន្ទុកលើការទំនាក់ទំនងរបស់ធនាគារ ជាមួយនឹងអតិថិជន ជាប្រភេទក្រុមហ៊ុន ដែលរួមមានក្រុមហ៊ុនក្នុងស្រុក និងក្រុមហ៊ុនថ្នាក់តំបន់គ្រឹះស្ថានហិរញ្ញវត្ថុ ព្រមទាំងក្រុមហ៊ុនសាកលរបស់ស៊ីអាយអិមប៊ី គ្រុប ដែលកំពុងដំណើរការអាជីវកម្ម ក្នុងប្រទេសកម្ពុជា។ វិសាលភាពនៃនាយកដ្ឋាននេះ គឺរួមមានការស្វែងរកចំណូល ហិរញ្ញវត្ថុពាណិជ្ជកម្ម ការគ្រប់គ្រងសាច់ប្រាក់ សេវាកម្មប្រតិបត្តិការ និងភាពច្នៃប្រឌិតផលិតផលជាដើម។

សេចក្ដីសង្ខេប ក្នុងឆ្នាំ ២០២០

នៅធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម និងសេវាប្រតិបត្តិការ បានបន្តសម្រេចជោគជ័យ សម្រាប់ឆ្នាំ២០២០។ ប្រាក់ចំណូល ពីការប្រាក់ បានកើនឡើង ៦% និងកម្រៃជើងសា បានកើនឡើង ១៥% បើធៀបនឹងឆ្នាំចាស់ ជាមួយនឹងឥណទានមិនដំណើរការ ក្នុងកម្រិតសូន្យ ហើយអនុបាតគណនីសន្សំ និងគណនីចរន្ត មានចំនួន ៧២%។ សមិទ្ធផលនេះបានកើតឡើង តាមរយៈការរួមបញ្ចូលគ្នា និងការបង្កើនភាពច្នៃប្រឌិត លើគុណភាព និងប្រភេទផលិតផល ព្រមទាំងការចាប់យកនូវក្រុមអតិថិជន ក្នុងវិស័យថ្មីៗ។

ក្រុមការងាររបស់យើងបានប្រឹងប្រែងបំពេញការងារ ឲ្យអស់លទ្ធភាព ដើម្បីស្វែងយល់ពីការវិវឌ្ឍអាជីវកម្ម និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់អតិថិជន ឲ្យកាន់តែស៊ីជម្រៅ លើសពីការបម្រើជូនសេវាកម្ម និងផលិតផល តាមទម្លាប់ចាស់។ ក្រុមការងាររបស់យើង បានខិតខំទាញប្រយោជន៍ ពីបណ្តាញថ្នាក់តំបន់ដ៏រឹងមាំ របស់ស៊ីអាយអិមប៊ី គ្រុប ដែលអតិថិជនរបស់យើងអាចទទួលបានផលិតផល និងសេវាកម្មដ៏ល្អប្រសើរបំផុត នៅគ្រប់ទីកន្លែង ដែលពួកគេប្រកបអាជីវកម្ម ក្នុងតំបន់អាស៊ាន។

ផ្នែកគ្រឹះស្ថានហិរញ្ញវត្ថុ គឺជាអង្គភាពអាជីវកម្មថ្មីមួយ របស់ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា ស្របទៅនឹងភាពចាំបាច់ និងកំណើន នៃគ្រឹះស្ថានហិរញ្ញវត្ថុ នៅប្រទេសកម្ពុជា រួមទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផងដែរ។ វិសាលភាព នៃការងារចម្បងរបស់អង្គភាពនេះ គឺផ្តល់ជូននូវសាច់ប្រាក់ និងមូលនិធិ ទៅដល់គ្រឹះស្ថានហិរញ្ញវត្ថុនានា នៅក្នុងប្រទេស។

ប្រាក់ចំណូល
ពីការប្រាក់

កម្រៃជើងសា

ឥណទាន
មិនដំណើរការ

អនុបាតគណនីសន្សំ
និងគណនីចរន្ត

ទស្សនវិស័យ ក្នុងឆ្នាំ ២០២១

រាជរដ្ឋាភិបាល បានដាក់ចេញវិធានការចាំបាច់ ដើម្បីទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននានា បណ្តាលមកពីការប្រកួតប្រជែងខ្ពស់ នៅក្នុងតំបន់ ការបាត់បង់ដោយផ្នែក របស់ប្រព័ន្ធអនុគ្រោះពន្ធ EBA ក៏ដូចជាការថយចុះ នៃវិស័យទេសចរណ៍ និងការរាតត្បាត នៃជំងឺកូវីដ-១៩។ វិធានការទាំងអស់នោះ គឺរួមមានការពង្រឹងផលិតភាព ការបន្ធូរបន្ថយពន្ធ និងការវិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា នឹងបន្តតួនាទីរបស់ខ្លួន ក្នុងការបំពេញតម្រូវការអតិថិជន ដែលបន្តភាពរីកចម្រើនរបស់ពួកគេ។ យើងនឹងបង្កើនភាពច្នៃប្រឌិត ដើម្បីស្របតាមតម្រូវការ ក្នុងវិស័យធនាគារសម័យទំនើប ការគ្រប់គ្រងហានិភ័យ និងសន្តិសុខបច្ចេកវិទ្យា។ ជាមួយគ្នានេះ ការប្តេជ្ញាចិត្តចម្បងរបស់យើង គឺបន្តប្រកាន់ខ្ជាប់នូវការផ្តល់សេវាកម្មធនាគារ ដោយប្រុងប្រយ័ត្ន ដែលអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ របស់ធនាគារជាតិ នៃកម្ពុជា និងស្តង់ដារអន្តរជាតិ។

ធនធានសាជីវកម្ម

នាយកដ្ឋានធនធានសាជីវកម្ម ទទួលបន្ទុកផ្នែកធនធានមនុស្ស រដ្ឋបាល និងការគ្រប់គ្រងទ្រព្យសម្បត្តិ ព្រមទាំងដំណើរការយុទ្ធសាស្ត្រលទ្ធកម្ម។ តួនាទីសំខាន់របស់ផ្នែកធនធានមនុស្ស គឺរួមមានការជ្រើសរើសបុគ្គលិកសក្តានុពល / ការអភិវឌ្ឍស្ថាប័ន និងការធ្វើផែនការបុគ្គលិករបស់អង្គភាព / ការគិតគូរពីប្រាក់រង្វាន់ និងការគ្រប់គ្រងការអនុវត្តការងារ / ការសិក្សា និងការអភិវឌ្ឍទេពកោសល្ស / ការកសាងកិត្តិនាមស្ថាប័ន និងការចូលរួមរបស់បុគ្គលិកក្នុងស្ថាប័ន។ ផ្នែករដ្ឋបាល និងគ្រប់គ្រងទ្រព្យសម្បត្តិ ព្រមទាំងដំណើរការលទ្ធកម្មយុទ្ធសាស្ត្រ ចាត់ចែងការងាររដ្ឋបាលទូទៅ ការរៀបចំគម្រោង និងការថែរក្សាទ្រព្យសម្បត្តិក្រុមហ៊ុន រួមទាំងដំណើរការលទ្ធកម្ម / ដេញថ្លៃ និងសន្តិសុខ។

ការអភិវឌ្ឍធនធានមនុស្ស និងទេពកោសល្ស

“ យើងពេញចិត្តជាមួយការអភិវឌ្ឍទេពកោសល្ស យើងផ្តល់តម្លៃដល់បុគ្គលិកគ្រប់រូប ដែលរួមចំណែកជួយគាំទ្រធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី រហូតដល់មានថ្ងៃនេះ ”

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺជាទីកន្លែង

បណ្តុះទេពកោសល្ស

យើងតែងតែខិតខំទាក់ទាញ រក្សា និងបណ្តុះសមត្ថភាពបុគ្គលិករបស់យើង ដើម្បីឲ្យពួកគាត់បានត្រៀមខ្លួនរួចជាស្រេច សម្រាប់អនាគតរបស់ពួកគាត់។ ជាការពិតណាស់ យើងក៏ផ្តល់ឲ្យពួកគាត់ នូវឱកាសនៅខាងក្នុង ឬឆ្លងនាយកដ្ឋាន ទាំងនៅក្នុងស្រុក និងថ្នាក់តំបន់ផងដែរ។ យើងផ្តល់ឱកាសដល់និយោជិត ក្នុងការបង្ហាញសមត្ថភាព ទៅតាមក្របខណ្ឌ និងយន្តការ ដែលមានប្រសិទ្ធភាពផ្សេងៗ ដើម្បីធានាដល់ការបង្កើនចំណេះដឹង ការបន្ថែមគុណតម្លៃ ភាពច្នៃប្រឌិត និងការចែករំលែក នៃការអនុវត្តការងារល្អៗរបស់ពួកគេ។ ដូច្នេះ និយោជិតរបស់យើង អាចកសាងចំណុចខ្លាំងរបស់ពួកគេ ដើម្បីនាំយកគុណប្រយោជន៍ល្អបំផុត ក្នុងការរក្សាភាពរឹងមាំរបស់ធនាគារ សម្រាប់ការប្រកួតប្រជែងដ៏យូរអង្វែង នៅក្នុងទីផ្សារប្រទេសកម្ពុជា។

ភ្ជាប់ទំនាក់ទំនងនិយោជិត

យើងខិតខំបំពេញការងារ ដើម្បីធានាថា ការភ្ជាប់ទំនាក់ទំនងនិយោជិត និងការបំពេញការងារជាក្រុម គឺស្ថិតក្នុងកម្រិតខ្ពស់បំផុតមួយ។ យើងបានរៀបចំកិច្ចប្រជុំបង្ហាញលទ្ធផលការងារប្រចាំឆ្នាំ (Town Hall) និងប្រារព្ធធ្វើកម្មវិធីមួយចំនួន រួមមានវគ្គបណ្តុះបណ្តាលចែករំលែកយុទ្ធសាស្ត្រភាពជាអ្នកដឹកនាំ កម្មវិធីជួបជុំជាមួយបុគ្គលិកថ្ងៃអង្គារ កម្មវិធីកសាងភាពជាក្រុមការងារ និងកម្មវិធីជួបជុំបុគ្គលិកទូទាំងធនាគារជាដើម។ ជារៀងរាល់ឆ្នាំ យើងក៏បានរៀបចំកម្មវិធីស្វង់មតិការបំពេញការងារផ្ទៃក្នុង ដើម្បីអនុញ្ញាតឲ្យបុគ្គលិករបស់យើង ចែករំលែកសំឡេងរបស់ពួកគេ ដោយជំរុញឲ្យស្ថាប័នទាំងមូល កាន់តែប្រសើរមួយកម្រិតទៀត។ យើងបណ្តុះផ្នត់គំនិត នៃវប្បធម៌បើកចំហរ ដើម្បីនាំយកភាពរីកចម្រើន និងភាពប្រសើរឡើង ក្នុងស្ថាប័នការងារ។ យើងជឿជាក់ថា និយោជិត ដែលមានការភ្ជាប់ទំនាក់ទំនងល្អ គឺជាបុគ្គលិកដែលប្រកបដោយផលិតភាពឆ្នើមផងដែរ។

មានសមាមាត្រគ្នា រវាងលទ្ធផលការងារ និងប្រាក់រង្វាន់

យើងមានប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារដ៏រឹងមាំ ដែលកំណត់ដោយសូចនាករអនុវត្តន៍ការងារ (KPI)។ យើងធានាថា សូចនាករអនុវត្តន៍ការងារ គឺស្របទៅតាមគោលដៅអាជីវកម្ម និងទិសដៅរបស់ ស៊ីអាយអិមប៊ី គ្រុប។ សូចនាករអនុវត្តន៍ការងារ តម្រូវឲ្យមានសមាសធាតុប្រតិបត្តិតាម (Compliance) និងអភិបាលកិច្ច (Governance) ដែលផ្សារភ្ជាប់ភាពសមាមាត្រគ្នា រវាងលទ្ធផលការងារ និងប្រាក់រង្វាន់។ ក្រៅពីសូចនាករអនុវត្តន៍ការងារ យើងលើកកម្ពស់វប្បធម៌ នៃការបន្តសម្រេចសមិទ្ធផល នៅក្នុងស្ថាប័ន ដើម្បីធានាថា និយោជិតរបស់យើង គឺស្ថិតក្នុងលក្ខខណ្ឌល្អប្រសើរ និងអាចទទួលបានការលើកទឹកចិត្ត ទៀងទាត់ ដែលជួយឲ្យពួកគេអាចសម្រេចបានលទ្ធផលការងារកាន់តែល្អប្រសើរ។

លើកកម្ពស់វប្បធម៌ របស់ធនាគារ ស៊ីអាយអិមប៊ី

គុណតម្លៃ និងវប្បធម៌ស្នូលរបស់យើង ត្រូវបានចូលរួមអនុវត្តទាំងអស់គ្នា ដើម្បីលើកតម្កើងតម្លៃទាំង៣ «បំពេញភារកិច្ចលើសពីការរំពឹងទុក ដើម្បីបំពេញចិត្តអតិថិជន / ភ្ជាប់ទំនាក់ទំនងដោយបើកចំហរ និងធ្វើការរួមគ្នា / គោរព និងតែងតែជួយគាំទ្រគ្នាទៅវិញទៅមក»។ គោលការណ៍ណែនាំនេះ អាចជួយឲ្យបុគ្គលិកយើង ប្រកបការងារកាន់តែមានប្រសិទ្ធភាព ទាំងជាមួយក្រុមការងារ ក្នុងស្រុក និងថ្នាក់តំបន់។ ដើម្បីជំរុញ នូវការប្រកាន់ខ្ជាប់វប្បធម៌របស់ក្រុមហ៊ុន យើងបានតែងតាំង អ្នកគាំទ្រអាជីវកម្ម និងអ្នកដឹកនាំក្រៅផ្លូវការ នៅតាមអង្គភាពជីវកម្មផ្សេងៗគ្នា ដើម្បីលើកទឹកចិត្ត ដល់បុគ្គលិក ក្នុងការអនុវត្តតម្លៃទាំង ៣ ហើយសាយភាយវប្បធម៌ល្អប្រពៃនេះ ក្នុងនាមជាអ្នកគំរូល្អទៅដល់បុគ្គលិកដទៃទៀត។

ហិរញ្ញវត្ថុ

នាយកដ្ឋានហិរញ្ញវត្ថុ មានតួនាទីរៀបចំ និងអនុវត្តគោលការណ៍ និងនីតិវិធីគណនេយ្យ ដើម្បីឲ្យស្របតាមគំរូស្តង់ដារគណនេយ្យកម្ពុជា និងបទប្បញ្ញត្តិ ដែលបានរៀបចំ ដោយធនាគារជាតិ នៃកម្ពុជា។ នាយកដ្ឋាននេះ ក៏ដើរតួនាទីគ្រប់គ្រងរបាយការណ៍ និងការវិភាគលទ្ធផលហិរញ្ញវត្ថុ ជូនគ្រប់អង្គភាពអាជីវកម្មផងដែរ។

ក្នុងការរៀបចំគណនេយ្យហិរញ្ញវត្ថុ យើងធានាថា រាល់ដំណើរការគណនេយ្យ មានភាពច្បាស់លាស់ តម្លាភាព និងមានការរក្សាទុកយ៉ាងត្រឹមត្រូវ។ យើងក៏ធានាការប្រតិបត្តិតាមបទប្បញ្ញត្តិគ្រប់ពេលផងដែរ នូវរាល់របាយការណ៍ ដែលតម្រូវដោយបទប្បញ្ញត្តិ របស់ធនាគារជាតិ នៃកម្ពុជា ក៏ដូចជាការប្រកាសពន្ធ ជូននាយកដ្ឋានពន្ធដារ និងរៀបចំរបាយការណ៍យ៉ាងត្រឹមត្រូវ និងទាន់ពេលវេលា សម្រាប់ក្រុមហ៊ុនមេ និងគណៈគ្រប់គ្រងផងដែរ។

សមិទ្ធផលសំខាន់ៗ សម្រាប់ឆ្នាំ ២០២០

ការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (Cambodia International Financial Reporting Standard) គឺជាបញ្ហាប្រឈមមួយ ក្នុងការបិទបញ្ជីគណនីសវនកម្ម សម្រាប់ឆ្នាំហិរញ្ញវត្ថុ២០១៩។ ផ្អែកលើការគាំទ្រ និងក្រុមជំនាញបច្ចេកទេស របស់ស៊ីអាយអិមប៊ី គ្រុប យើងបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការបំពេញការងារជាមួយនឹងសវនករខាងក្រៅ ដើម្បីសម្រេចបានគណនីសវនកម្ម ដើម្បីដាក់ជូនធនាគារជាតិ នៃកម្ពុជា ទាន់ពេលវេលា។

ក្នុងដើមឆ្នាំ២០២០ ជាផ្នែកមួយនៃវិធានការបន្ធូរបន្ថយ លើបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល ធនាគារជាតិ នៃកម្ពុជា បានដាក់ឲ្យអនុវត្តវិធានការ ដើម្បីលើកស្ទួយវិស័យហិរញ្ញវត្ថុ ដោយបង្កើតនូវប្រកាសថ្មីមួយ លើការកាត់បន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ច នៃប្រាក់បញ្ញើ មកត្រឹម ៧ភាគរយ ព្រមទាំងពន្យារពេលការតម្រូវទ្រនាប់ដើមទុនខនស៊ើវេសិន (Conservation Capital Buffer) ដែលបានបន្ទាបអនុបាតសងធនភាព។ យើងបានអនុវត្តតាមការផ្លាស់ប្តូរទាំងនេះ ដើម្បីសម្រួលដល់កំណើនអាជីវកម្ម ស្នូលផងដែរ។

ប្រកាសថ្មី សម្រាប់ពន្ធលើប្រាក់ចំណេញរបស់ក្រុមហ៊ុន ត្រូវបានដាក់ឲ្យអនុវត្ត ដែលជាកត្តាប្រឈមមួយ សម្រាប់ឆ្នាំ២០២០ ក្នុងការអនុវត្តសេចក្តីណែនាំថ្មីនេះ។ យើងបានធ្វើការជាមួយនឹងក្រុមអ្នកជំនាញផ្នែកពន្ធ របស់សមាគមធនាគារ ក្នុងប្រទេសកម្ពុជា (Association of Banks in Cambodia) ដើម្បីទំនាក់ទំនងជាមួយនឹងអគ្គនាយកដ្ឋានពន្ធដារ លើសេចក្តីណែនាំអំពីការបង់ពន្ធ សម្រាប់ការប្រកាសពន្ធ ស្របតាមការអនុវត្ត CIFRS ។

យើងបានដាក់ឲ្យអនុវត្តនូវ CIMB Group Reporting Framework ដើម្បីធានានូវប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងត្រឹមត្រូវគ្រប់គ្រាន់ សម្រាប់ការអនុវត្ត ដើម្បីបង្ការ និងកាត់បន្ថយហានិភ័យរបាយការណ៍។

ទោះបីជាមានការរាតត្បាត នៃជំងឺកូវីដ-១៩ យើងបានបោះផ្សាយនូវបំណុលបន្ទាប់បន្សំបន្ថែមចំនួន ១៥លានដុល្លារអាមេរិក ជាដើមទុនថ្នាក់ទី២ ដើម្បីបំពេញតម្រូវការបទប្បញ្ញត្តិដើមទុនអប្បបរមា និងបទប្បញ្ញត្តិទ្រនាប់ដើមទុនខនស៊ើវេសិន ក៏ដូចជាដើម្បីគាំទ្រកំណើនអាជីវកម្មស្នូលរបស់ធនាគារ ក្នុងឆ្នាំ២០២០។

ស្របតាមផែនការអាជីវកម្មរយៈពេល ៤ឆ្នាំរបស់ក្រុមហ៊ុនមេ គឺ Forward23+ យើងបានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយនឹងអ្នកជំនាញរបស់ស៊ីអាយអិមប៊ី គ្រុប សម្រាប់គម្រោងផ្ទួចផ្តើមមួយចំនួនរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី និងការព្យាករហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០២១-២០២៤។ ផែនការទាំងនេះត្រូវបានអនុវត្ត នៅទូទាំងអង្គភាពអាជីវកម្ម ក៏ដូចជាអង្គភាពគាំទ្រអាជីវកម្ម ក្នុងរយៈពេល ៤ឆ្នាំ (២០២១-២០២៤) ក្នុងគោលបំណងក្លាយជាធនាគារសហគមន៍សាកលឈានមុខគេមួយ ក្នុងប្រទេសកម្ពុជា បើគិតលើទំហំប្រាក់ចំណេញ។

យើងបានបោះផ្សាយនូវ
បំណុលបន្ទាប់បន្សំបន្ថែមចំនួន

១៥លាន
ដុល្លារអាមេរិក

FORWARD 23+

រយៈពេល ៤ឆ្នាំ (២០២១-២០២៤) ក្នុងគោលបំណងក្លាយជាធនាគារសហគមន៍សាកលឈានមុខគេមួយ ក្នុងប្រទេសកម្ពុជា បើគិតលើទំ**ហំប្រាក់ចំណេញ**

ផែនការ សម្រាប់ឆ្នាំ ២០២១

ការកែសម្រួល នូវការអនុវត្ត CIFRS ទាំងផ្នែកក្របខណ្ឌ (Framework) និងគំរូហិរញ្ញវត្ថុ (Financial Modeling) រហូតដល់ការត្រួតពិនិត្យឡើងវិញ នូវគោលការណ៍ និងនីតិវិធីរបស់ធនាគារ នឹងនៅតែជាចំណុចផ្តោតចម្បងសំខាន់ សម្រាប់ក្រុមការងារហិរញ្ញវត្ថុ ក្នុងឆ្នាំ២០២១ ដើម្បីធានានូវការប្រតិបត្តិតាមបទប្បញ្ញត្តិ និងស្របតាមការអនុវត្តរបាយការណ៍របស់ស៊ីអាយអិមប៊ី គ្រុប។ ក្រុមការងារហិរញ្ញវត្ថុ នឹងបន្តធ្វើការ ជាមួយនឹងក្រុមការងារបច្ចេកទេសព័ត៌មាន និងក្រុមការងារហិរញ្ញវត្ថុ របស់ស៊ីអាយអិមប៊ី គ្រុប ដើម្បីអនុវត្តការផ្លាស់ប្តូរនៃតារាងគណនី នៅក្នុងប្រព័ន្ធគណនី និងកែលម្អប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ធនាគារ (management information system) ដើម្បីគាំទ្ររបាយការណ៍បទប្បញ្ញត្តិបន្ថែមថ្មីៗ បន្ទាប់ពីការអនុវត្ត CIFRS។

ការប្រកាសពន្ធតាមប្រព័ន្ធអេឡិកត្រូនិក (E-Filling) នឹងបន្តជាឧបសគ្គប្រឈមមួយទៀត សម្រាប់ឆ្នាំ២០២១ ក្នុងការអនុវត្តសេចក្តីណែនាំថ្មី ជាមួយនឹងភាគីដៃគូរបស់ធនាគារ ដំណើរការផ្ទៃក្នុង នៅគ្រប់នាយកដ្ឋាន/អង្គភាព ការប្រកាសពន្ធ។លម។ យើងនឹងបន្តធ្វើការជាមួយនឹងក្រុមអ្នកជំនាញផ្នែកពន្ធរបស់សមាគមធនាគារ ក្នុងប្រទេសកម្ពុជា ដើម្បីទំនាក់ទំនងជាមួយនឹងអគ្គនាយកដ្ឋានពន្ធដារ ដើម្បីធានាថា ធនាគារបានអនុលោមតាមការតម្រូវផ្ទៃកឯកសារពន្ធ តាមប្រព័ន្ធអេឡិកត្រូនិក។

ការគ្រប់គ្រងដើមទុននឹងនៅតែជាចំណុចផ្តោតសំខាន់របស់យើង ក្នុងឆ្នាំ២០២១ ជាមួយនឹងការអនុវត្តទ្រនាប់ដើមទុនខនស៊ើវេសិន (Regulatory Conservation Capital Buffer) និងទ្រនាប់ដើមទុនខោនធើស៊ីយ្លីខល (Countercyclical Capital Buffer)។ យើងនឹងរៀបចំផែនការ ក្នុងការពិនិត្យដើមទុនបន្ថែម ទាំងថ្នាក់ទី១ និងទី២ ដើម្បីបំពេញតម្រូវការបទប្បញ្ញត្តិដើមទុនអប្បបរមា ក៏ដូចជាដើម្បីគាំទ្រកំណើនអាជីវកម្មស្នូលរបស់ធនាគារ ក្នុងឆ្នាំ២០២១ និងឆ្នាំបន្តបន្ទាប់។

យុទ្ធសាស្ត្រ Forward23+ ដែលបានបង្កើតឡើង នឹងត្រូវបន្តតាមដាន ត្រួតពិនិត្យ និងរាយការណ៍ នៅក្នុង Cambodia Business Review Committee សម្រាប់គ្រប់គម្រោងនីមួយៗ ហើយគោលដៅហិរញ្ញវត្ថុគន្លឹះនឹងផ្តោតសំខាន់ សម្រាប់ឆ្នាំ២០២១ ដល់ឆ្នាំ២០២៣។ យើងនឹងបន្តធ្វើការយ៉ាងជិតស្និទ្ធ ជាមួយស៊ីអាយអិមប៊ី គ្រុប សម្រាប់ការណែនាំ ការគាំទ្រ ក៏ដូចជាធានានូវការសម្រេចបាននូវគម្រោងនានា។

ប្រតិបត្តិតាម

នាយកដ្ឋានប្រតិបត្តិតាម ទទួលបន្ទុក ក្នុងការធានាថា គ្រប់នាយកដ្ឋាន ក៏ដូចជាបុគ្គលិកទាំងអស់នៅក្នុងធនាគារ ដឹងអំពីកាតព្វកិច្ច និងផលប៉ះពាល់នានា នៃបទប្បញ្ញត្តិពាក់ព័ន្ធ។ តួនាទីចម្បងរបស់នាយកដ្ឋាននេះ គឺរួមមានការត្រួតពិនិត្យ និងផ្តល់យោបល់ ដល់ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ដើម្បីធានាការអនុវត្តអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិ និងសេចក្តីណែនាំផ្សេងៗ របស់ធនាគារ។

សម្រាប់ត្រួតពិនិត្យលើការប្រតិបត្តិតាម នាយកដ្ឋាននេះបានធ្វើការត្រួតពិនិត្យ ដល់ទីកន្លែង និងវាយតម្លៃ អំពីប្រសិទ្ធភាពនៃការធ្វើតេស្តខ្លួនឯង លើបទប្បញ្ញត្តិនានា ដើម្បីធានាថា រាល់ដំណើរការ និងនីតិវិធីពាក់ព័ន្ធទាំងឡាយ ត្រូវបានអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងសេចក្តីណែនាំផ្សេងៗ ដែលពាក់ព័ន្ធ។ មិនតែប៉ុណ្ណោះ នាយកដ្ឋាននេះចូលរួមយ៉ាងសកម្ម ជាមួយនឹងភាគីពាក់ព័ន្ធផ្សេងៗ ដើម្បីធានាថាធនាគារបានអនុវត្តគ្រប់គ្រាន់ នូវកាតព្វកិច្ចរបស់ធនាគារ ចំពោះបទប្បញ្ញត្តិផ្សេងៗ ដូចជាច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT) ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានការជួញដូរអាវុធ (AFP) ច្បាប់ស្តីពីគ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារ បទប្បញ្ញត្តិស្តីពីការប្រតិបត្តិតាមពន្ធគណនីបរទេសរបស់សហរដ្ឋអាមេរិក (FATCA) និងបទប្បញ្ញត្តិដទៃទៀត។

នាយកដ្ឋានប្រតិបត្តិតាម បានបំពេញការងារដោយឯករាជ្យ និងរាយការណ៍ដោយផ្ទាល់ ទៅកាន់ក្រុមប្រឹក្សាភិបាល ដែលជាអ្នកពិនិត្យមើល និងអនុម័តផែនការការងារប្រតិបត្តិតាមប្រចាំឆ្នាំ ដែលស្នើសុំដោយនាយកដ្ឋានប្រតិបត្តិតាម។ ផ្អែកលើគោលនយោបាយ នៃការអនុវត្តការប្រតិបត្តិតាម នាយកដ្ឋាននេះត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធី សម្រាប់ការប្រតិបត្តិតាម និងគោលការណ៍ និងនីតិវិធី ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ ជាមួយគ្នានេះ នាយកដ្ឋាននេះក៏បានសហការជាមួយនឹងនាយកដ្ឋានដទៃទៀត ដើម្បីបង្កើតគោលការណ៍ណែនាំ និងក្រមសីលធម៌វិជ្ជាជីវៈផ្សេងៗ រួមមានគោលការណ៍ណែនាំ អំពីការបើកគណនីធនាគារ គោលការណ៍ណែនាំ អំពីការត្រួតពិនិត្យប្រតិបត្តិការដែលមានសញ្ញាប្រុងប្រយ័ត្ន ក្រមសីលធម៌នៃការលក់ផលិតផល និងសេវាកម្ម ។ល។

សមិទ្ធផល ក្នុងឆ្នាំ ២០២០

ក្នុងឆ្នាំ២០២០ នាយកដ្ឋានប្រតិបត្តិតាម សម្រេចបានការត្រួតពិនិត្យដល់ទីកន្លែង ចំនួន ១១ការិយាល័យ និងការត្រួតពិនិត្យឡើងវិញ ចំពោះបទប្បញ្ញត្តិ ដែលកំពុងអនុវត្តនានា ចំនួន ១០ការិយាល័យ។ នាយកដ្ឋាននេះក៏បានរៀបចំកម្មវិធីពិនិត្យមើលប្រតិបត្តិការ និងតាមដានដំណើរការអតិថិជនផងដែរ។

កម្មវិធីបណ្តុះបណ្តាលចំណេះដឹង និងជំនាញ គឺជាផ្នែកផ្តោតសំខាន់គន្លឹះមួយ សម្រាប់នាយកដ្ឋានប្រតិបត្តិតាម។ គ្រប់និយោជិត ដែលទើបចូលបម្រើការងារថ្មីទាំងអស់ តម្រូវឲ្យចូលរួមវគ្គបណ្តុះបណ្តាលក្នុងអំឡុងពេលបីខែ គិតចាប់ពីថ្ងៃចូលបម្រើការងារ នៅធនាគារ ហើយនិយោជិត ដែលបានបម្រើការងារស្រាប់ តម្រូវឲ្យចូលរៀនវគ្គសិក្សា តាមប្រព័ន្ធអេឡិកត្រូនិក អំពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មផងដែរ។ ក្នុងឆ្នាំ២០២០ នាយកដ្ឋានប្រតិបត្តិតាម បានរៀបចំវគ្គបណ្តុះបណ្តាលសរុប ចំនួន១៦លើក ដែលមានការចូលរួម ពីនិយោជិត ចំនួន ២៩០នាក់។

១១ការិយាល័យ
ត្រួតពិនិត្យដល់
ទីកន្លែង

១០ការិយាល័យ
ត្រួតពិនិត្យឡើងវិញ
ចំពោះ**បទប្បញ្ញត្តិ**

នាយកដ្ឋានប្រតិបត្តិតាមបានរៀបចំ
វគ្គបណ្តុះបណ្តាលសរុបចំនួន
១៦លើក ដែលមានការចូលរួម
ពីនិយោជិតចំនួន **២៩០នាក់**

ផែនការ សម្រាប់ឆ្នាំ ២០២១

នាយកដ្ឋានប្រតិបត្តិតាម នឹងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិ និងនីតិវិធី លើការត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ស្របតាមច្បាប់ថ្មីស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានការជួញដូរអាវុធ (AFP)។ ទន្ទឹមនឹងនេះ នាយកដ្ឋានប្រតិបត្តិតាម នឹងបង្កើតជាបទប្បញ្ញត្តិ និងនីតិវិធីនៃការអនុវត្ត ចំពោះបញ្ជីឈ្មោះ ដែលត្រូវបានដាក់ទណ្ឌកម្ម និងបទប្បញ្ញត្តិ និងនីតិវិធី នៃការគ្រប់គ្រងបញ្ជីវាយនាមឈ្មោះបុគ្គល និងអង្គភាពហាមឃាត់។ ប្រព័ន្ធស្វ័យប្រវត្តិ លើការត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការកែសម្រួល លើក្របខណ្ឌវាយតម្លៃហានិភ័យរបស់អតិថិជន នឹងបន្តកែលម្អឲ្យកាន់តែប្រសើរ ក្នុងឆ្នាំ២០២១។ នាយកដ្ឋាននេះនឹងចុះត្រួតពិនិត្យ ដល់ទីកន្លែង លើការអនុវត្តការអនុលោមតាមច្បាប់ និងការត្រួតពិនិត្យ តាមជាក់ស្តែង។ នាយកដ្ឋាននេះនឹងបន្តធ្វើឲ្យប្រសើរឡើង នូវវគ្គបណ្តុះបណ្តាល លើការត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងបទប្បញ្ញត្តិ នៃការអនុវត្តតាម និងបទប្បញ្ញត្តិផ្សេងៗទៀត។

គ្រប់គ្រងហានិភ័យ

ភាពរីកចម្រើនយ៉ាងឆាប់រហ័ស នៃវិស័យធនាគារ ក្នុងប្រទេសកម្ពុជា ការផ្លាស់ប្តូរ លើតម្រូវការបទប្បញ្ញត្តិ នៅកម្រិតសាកល និងហានិភ័យថ្មីៗ បានកើតចេញពីទស្សនវិស័យ នៃការអនុលោមតាមច្បាប់ និងផ្នែកបច្ចេកវិទ្យា។ ដូច្នេះហើយធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានបង្កើតនូវក្របខណ្ឌគ្រប់គ្រងហានិភ័យដ៏រឹងមាំ ដើម្បីគ្រប់គ្រងហានិភ័យ ដែលពាក់ព័ន្ធ ឲ្យបានល្អប្រសើរ។ ធនាគារបានចាត់ទុកថា ការគ្រប់គ្រងហានិភ័យ គឺជាផ្នែកមួយយ៉ាងសំខាន់ សម្រាប់អាជីវកម្ម ហើយធនាគារក៏បានបញ្ចូលវប្បធម៌ហានិភ័យដ៏រឹងមាំ ទៅក្នុងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ និងដំណើរការសម្រេចចិត្តរបស់ធនាគារ។ នាយកដ្ឋានគ្រប់គ្រងហានិភ័យ បានចូលរួមតាំងពីដំណាក់កាលដំបូង នៃដំណើរការទទួលយកហានិភ័យ ដើម្បីផ្តល់នូវទស្សនៈឯករាជ្យ សម្រាប់ការវាយតម្លៃផលិតផលថ្មី ការកំណត់យុទ្ធសាស្ត្រការវាយតម្លៃឥណទាន និងផ្នែកដទៃទៀត។

ហានិភ័យឥណទាន

ហានិភ័យឥណទាន និងសមភាគី សំដៅដល់លទ្ធភាពនៃការខាតបង់ ដោយសារអតិថិជន ដែលមានបំណុល ជាមួយធនាគារ ឬដៃគូទីផ្សារ ឬអ្នកចេញមូលបត្រ បរាជ័យក្នុងការបំពេញកាតព្វកិច្ច សម្រាប់ការទូទាត់សងមកធនាគារវិញ តាមការសន្យា។ ហានិភ័យឥណទាន ដែលបានផ្តល់ដោយធនាគារ ត្រូវបានគ្រប់គ្រងដោយគោលនយោបាយ ហានិភ័យឥណទាន គោលការណ៍គោលនយោបាយឥណទាន (CPG) / នីតិវិធីឥណទាន (CPM) និងច្បាប់ជំនួញឥណទាននីមួយៗ។

ធនាគារបានប្រើប្រាស់សូចនាករផ្តល់សញ្ញាជាមុន (Early Warning Indicator) និងក្របខណ្ឌបញ្ជីតាមដាន (Watchlist frameworks) ជាវិធានការត្រៀមទុកជាមុន សម្រាប់គ្រប់គ្រងហានិភ័យឥណទាន ដែលអាចចង្អុលបង្ហាញ នូវភាពចុះខ្សោយនៃឥណទាន ពីដំណាក់កាលដំបូង ដើម្បីកាត់បន្ថយការខាតបង់ឥណទាន ដែលអាចកើតមានឡើង។

ដើម្បីធានាថា សំណើសុំឥណទានទាំងអស់ ពិតជាទទួលបានការវាយតម្លៃឯករាជ្យ ការអនុម័តឥណទានទាំងអស់ ទាមទារការបោះឆ្នោតសម្រេចចិត្ត ពីបុគ្គលវាយតម្លៃ ហានិភ័យ។ ធនាគារក៏បានអនុវត្តក្របខណ្ឌអ្នកជំនាញវាយតម្លៃរួមគ្នា ដោយផ្តល់សិទ្ធិ អំណាច ដល់គណៈគ្រប់គ្រងបុគ្គល ក្នុងការអនុម័តពាក្យស្នើសុំឥណទាន ដែលស្ថិតក្រោមសិទ្ធិអំណាចរបស់ពួកគេ។ ផ្នែកគ្រប់គ្រងឥណទាន ត្រូវបានបង្កើតឡើងក្រោម នាយកដ្ឋានគ្រប់គ្រងហានិភ័យ ដើម្បីបំពេញតួនាទីឯករាជ្យ ក្នុងការវាយតម្លៃសំណើ សុំឥណទាន។

ទំហំឥណទាន ត្រូវបានតាមដានយ៉ាងសកម្ម ត្រួតពិនិត្យឡើងវិញយ៉ាងទៀងទាត់ និងរាយការណ៍ ជូនគណៈកម្មាធិការហានិភ័យ ជារៀងរាល់ខែ។ ភាពអន់ថយនៃ ឥណទាន ត្រូវបានកំណត់សម្គាល់ វិភាគ និងពិភាក្សា ជាមួយនឹងអង្គភាពអាជីវកម្ម ដែលពាក់ព័ន្ធ ដើម្បីចាត់វិធានការកែលម្អឲ្យបានសមស្រប។

ហានិភ័យសន្ទនីយភាព

ហានិភ័យសន្ទនីយភាព កើតឡើង នៅពេលដែលធនាគារ ពុំមានលទ្ធភាព ក្នុងការបំពេញតម្រូវការថវិកា នាពេលបច្ចុប្បន្ន និងពេលអនាគត ឬមិនអាចបំពេញកាតព្វកិច្ចនិយ័តកម្ម នៅពេលដល់កាលកំណត់។ វាអាចធ្វើឲ្យប៉ះពាល់ ដល់ប្រតិបត្តិការអាជីវកម្ម ប្រចាំថ្ងៃ យ៉ាងធ្ងន់ធ្ងរ និងអាចបង្កឲ្យមានការខាតបង់។ តួនាទីចម្បងរបស់ធនាគារ គឺការប្រើប្រាស់ប្រាក់បញ្ញើរយៈពេលខ្លី ដើម្បីផ្តល់ជាឥណទានរយៈពេលវែង ដូច្នេះធ្វើឲ្យ ធនាគារងាយនឹងរងគ្រោះ ដោយសារហានិភ័យសន្ទនីយភាព។ ជាងនេះទៅទៀត ធនាគារ ត្រូវតែប្រតិបត្តិអាជីវកម្មរបស់ខ្លួន ស្របទៅតាមតម្រូវការបទប្បញ្ញត្តិ គ្រប់ពេលវេលា។

ហានិភ័យសន្ទនីយភាព ជាបឋមត្រូវបានធ្វើការតាមដាន និងគ្រប់គ្រង ដោយផ្អែក លើមូលដ្ឋាន នៃការព្យាករលំហូរសាច់ប្រាក់របស់ធនាគារ តាមរយៈការព្យាករឲ្យបាន ទៀងទាត់ ទៅលើលំហូរសាច់ប្រាក់របស់ធនាគារ ដែលកើតឡើងពីទម្រង់កាលកំណត់ នៃទ្រព្យសកម្ម បំណុល កាតព្វកិច្ចក្រៅតារាងតុល្យការ និងនិស្សន្ទវត្ថុ ទៅតាមរយៈពេលផ្សេងៗគ្នា ស្ថិតក្រោមស្ថានភាពអាជីវកម្មធម្មតា និងស្ថានភាពមានវិបត្តិ។

ធនាគារក៏បានធ្វើស្ត្រេសតេស្ត (Stress Test) ជារៀងរាល់ឆមាស រួមមានស្ត្រេសតេស្ត ទៅលើសន្ទនីយភាព ដើម្បីកំណត់ផ្នែក ដែលងាយរងគ្រោះ ទៅលើទំហំសន្ទនីយភាព និងដើម្បីប៉ាន់ស្មានផលប៉ះពាល់ ផ្នែកហិរញ្ញវត្ថុ និងបង្កភាពងាយស្រួល ដល់គណៈគ្រប់គ្រងរបស់ធនាគារ ចាត់វិធានការទុកជាមុន។

នាយកដ្ឋានគ្រប់គ្រងហានិភ័យ ទទួលខុសត្រូវ ចំពោះការត្រួតពិនិត្យតាមដាន ដោយ ឯករាជ្យ លើទម្រង់ហានិភ័យសន្ទនីយភាពរបស់ធនាគារ និងរៀបចំរបាយការណ៍ប្រចាំ ខែ ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលទ្រព្យសកម្ម និងគណៈកម្មាធិការគ្រប់គ្រង ហានិភ័យ។ វាមានសារៈសំខាន់ សម្រាប់ធនាគារ ក្នុងការគ្រប់គ្រងស្ថានភាពសន្ទនីយភាព របស់ខ្លួន ដើម្បីអាចបំពេញតម្រូវការប្រតិបត្តិការប្រចាំថ្ងៃ និងតម្រូវការ ផ្នែកច្បាប់ដែល មាន ចំពោះហានិភ័យឥណទាន ដែលបានកំណត់ផងដែរ។

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលជាផ្នែកមួយ នៃស៊ីអាយអិមប៊ី គ្រុប បានប្រើប្រាស់ក្របខណ្ឌគ្រប់គ្រងហានិភ័យទូទៅមួយ សម្រាប់សហគ្រាសទាំងមូល (EWRM) ដើម្បីគ្រប់គ្រងហានិភ័យ និងឱកាសរបស់ខ្លួន។ ក្របខណ្ឌគ្រប់គ្រងហានិភ័យទូទៅ សម្រាប់សហគ្រាសទាំងមូល ផ្តល់ជូនក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង នូវឧបករណ៍មួយ ដើម្បីធ្វើការប្រមើលមើលទុកជាមុន និងគ្រប់គ្រងហានិភ័យដែលមានស្រាប់ និងហានិភ័យ ដែលអាចនឹងកើតមាន ដោយធ្វើការពិចារណា ទៅលើការកែប្រែទម្រង់ហានិភ័យ ស្របតាមការផ្លាស់ប្តូរយុទ្ធសាស្ត្រអាជីវកម្ម បទប្បញ្ញត្តិច្បាប់ និងសកម្មភាពបំពេញមុខងារ។

គណៈកម្មាធិការហានិភ័យ គឺជាគណៈកម្មាធិការមួយ ដែលទទួលសិទ្ធិអំណាច ពីក្រុមប្រឹក្សាភិបាល និងរាយការណ៍ ទៅក្រុមប្រឹក្សាភិបាល នូវរាល់បញ្ហា ពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យ។ កិច្ចប្រជុំរបស់គណៈកម្មាធិការហានិភ័យ បានធ្វើឡើងជារៀងរាល់ខែ ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យការអនុវត្ត លើរាល់សកម្មភាព ក្នុងការគ្រប់គ្រងហានិភ័យរបស់ធនាគារ។

គណៈកម្មាធិការឥណទានកម្ពុជា ធ្វើរបាយការណ៍ ជូនគណៈកម្មាធិការហានិភ័យ នូវរាល់បញ្ហាទាក់ទងនឹងឥណទានរបស់ធនាគារ។ គណៈកម្មាធិការឥណទានកម្ពុជា រៀបចំកិច្ចប្រជុំពិភាក្សា ជារៀងរាល់សប្តាហ៍ ដោយទទួលបានសិទ្ធិអំណាច ពីក្រុមប្រឹក្សាភិបាល ក្នុងការពិចារណា និងការសម្រេច លើសំណើឥណទាន។

ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ គឺរួមមានហានិភ័យ លើការខាតបង់ដោយផ្ទាល់ ឬដោយប្រយោល ដែលបណ្តាលមកពីកង្វះខាត ឬភាពបរាជ័យ នៃដំណើរការផ្ទៃក្នុង បុគ្គលិក ប្រព័ន្ធកុំព្យូទ័រ ឬកត្តាពីខាងក្រៅ។

ហានិភ័យប្រតិបត្តិការ ត្រូវបានបញ្ចូលជាផ្នែកមួយដ៏សំខាន់ ដល់ការវាយតម្លៃហានិភ័យ ទាក់ទងនឹងផលិតផល សេវាកម្ម ដំណើរការផ្ទៃក្នុង និងប្រព័ន្ធ នៅក្នុងធនាគារ។

គំនិតផ្តួចផ្តើមជាច្រើន ត្រូវបានធ្វើឡើង ដើម្បីពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ដែលមានស្រាប់ លើសមត្ថភាពនៃប្រព័ន្ធ ការគ្រប់គ្រងទិន្នន័យ និងការគ្រប់គ្រងផ្ទៃក្នុង។

យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យប្រតិបត្តិការ របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី គឺផ្តោតលើក្របខណ្ឌគ្រង់គ្រងហានិភ័យដ៏រឹងមាំ ដែលផ្តល់នូវគោលការណ៍ណែនាំរួមជាមួយនឹងរចនាសម្ព័ន្ធអភិបាលកិច្ចដ៏ល្អប្រសើរមួយ ដើម្បីបណ្តុះនូវវប្បធម៌គ្រប់គ្រងហានិភ័យមួយ តាមបែបបុរេសកម្ម គ្រប់ពេលជានិច្ច។

ផ្នែកគ្រប់គ្រងហានិភ័យប្រតិបត្តិការ តែងធ្វើការណែនាំ ផ្តល់យោបល់ និងតាមដាន លើគ្រប់នាយកដ្ឋានទាំងអស់ ដើម្បីធានាឲ្យបានថា គោលការណ៍ និងនីតិវិធីដែលបានកំណត់ ត្រូវបានអង្កេត លើគ្រប់គម្រោងទាំងអស់ និងស្ថិតនៅក្នុងដំណើរកិច្ចប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារ។ ផ្នែកគ្រប់គ្រងហានិភ័យប្រតិបត្តិការ ក៏ធានាឲ្យបាននូវការអនុលោមតាមច្បាប់បទប្បញ្ញត្តិ ដែលមានស្រាប់ ដោយការអង្កេតយ៉ាងតឹងរ៉ឹង។

ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ សំដៅទៅលើហានិភ័យ ដែលធ្វើឲ្យខាតបង់ ដោយសារការប្រែប្រួល លើតម្លៃមូលធន អត្រាការប្រាក់ លើទីផ្សារ ភាគរយនៃប្រាក់ចំណេញឥណទាន អត្រាប្តូរប្រាក់បរទេស តម្លៃទំនិញ ព្រមទាំងសូចនាករផ្សេងៗ ដែលតម្លៃត្រូវបានកំណត់នៅក្នុងទីផ្សារសាធារណៈ។

សកម្មភាពទូទៅរបស់ធនាគារ ដែលរួមមានការផ្តល់ឥណទាន និងទទួលប្រាក់បញ្ញើ ជាមួយនឹងកាលបរិច្ឆេទកំណត់ និងអត្រាការប្រាក់ខុសៗគ្នា បានបណ្តាលឲ្យធនាគារ ពុំអាចចៀសផុត ពីហានិភ័យអត្រាការប្រាក់បានឡើយ។

ហានិភ័យអត្រាការប្រាក់ ជាចម្បងបណ្តាលមកពីកាលបរិច្ឆេទ និងការកំណត់តម្លៃខុសៗគ្នា នៃលំហូរសាច់ប្រាក់។ ហានិភ័យអត្រាការប្រាក់ នាពេលបច្ចុប្បន្ន ត្រូវបានវាស់វែង ដោយរបាយការណ៍គម្លាតវេទយិតភាព នៃអត្រាការប្រាក់។ នាយកដ្ឋានគ្រប់គ្រងហានិភ័យ ទទួលខុសត្រូវ លើការត្រួតពិនិត្យឡើងវិញ ដោយឯករាជ្យ និងតាមដានទម្រង់ហានិភ័យអត្រាការប្រាក់របស់ធនាគារ ដោយផ្អែកលើរបាយការណ៍គម្លាតវេទយិតភាព នៃអត្រាការប្រាក់។

បច្ចេកវិទ្យា និងប្រតិបត្តិការ

នាយកដ្ឋានបច្ចេកវិទ្យា និងប្រតិបត្តិការ មានតួនាទីផ្តល់ប្រតិបត្តិការ និងគាំទ្រសេវាកម្មបច្ចេកវិទ្យាព័ត៌មានរបស់ធនាគារទាំងមូល។ នាយកដ្ឋាននេះមានរចនាសម្ព័ន្ធប្រតិបត្តិការ ស្របតាមនាយកដ្ឋានបច្ចេកវិទ្យា និងប្រតិបត្តិការរបស់ស៊ីអាយអិមប៊ី គ្រុប។ នាយកដ្ឋានបច្ចេកវិទ្យា និងប្រតិបត្តិការ រាយការណ៍ដោយផ្ទាល់ ទៅកាន់ប្រធាននាយកប្រតិបត្តិរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី និងរាយការណ៍បន្តទៅនាយកដ្ឋានបច្ចេកវិទ្យា និងប្រតិបត្តិការ របស់ស៊ីអាយអិមប៊ី គ្រុបផងដែរ។

ផ្នែកបច្ចេកវិទ្យា

ផ្នែកបច្ចេកវិទ្យា ផ្តល់រាល់សេវាកម្មព័ត៌មានវិទ្យា ជូនគ្រប់អង្គភាពអាជីវកម្ម គ្រប់គ្រងរាល់គម្រោងបច្ចេកវិទ្យាព័ត៌មាន ថែទាំហេដ្ឋារចនាសម្ព័ន្ធ និងកម្មវិធីបច្ចេកវិទ្យាព័ត៌មាន ដែលមានស្រាប់ បង្កើតកម្មវិធីប្រព័ន្ធ បច្ចេកវិទ្យាព័ត៌មានថ្មីៗ នៅក្នុងក្រុមហ៊ុន ដើម្បីគាំទ្រអាជីវកម្ម និងគ្រប់គ្រងផ្ទៃក្នុង ព្រមទាំងពិនិត្យតាមដានប្រព័ន្ធសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានជាប្រចាំ។

ក្នុងឆ្នាំ២០២០ ផ្នែកបច្ចេកវិទ្យា សម្រេចបានគម្រោងយុទ្ធសាស្ត្រមួយចំនួន រួមមាន គម្រោងទី១៖ ការធ្វើបច្ចុប្បន្នភាព នៃហេដ្ឋារចនាសម្ព័ន្ធរបស់ប្រព័ន្ធធនាគារស្នូល ទី២៖ ការធ្វើបច្ចុប្បន្នភាព នៃប្រព័ន្ធការពារសុវត្ថិភាពផ្ទៃក្នុង ទី៣៖ កែលម្អ និងបន្ថែមមុខងារថ្មីៗ នៃប្រព័ន្ធដែលមានស្រាប់ ដើម្បីកាត់បន្ថយការងារប្រតិបត្តិការ ដែលធ្វើដោយដៃ គាំទ្រកំណើនអាជីវកម្ម និងអនុលោមតាមនិយ័តករ និងច្បាប់។ មិនតែប៉ុណ្ណោះ មានគម្រោងចំនួន២ កំពុងស្ថិតក្នុងការអភិវឌ្ឍ និងជិតរួចរាល់ទាំងស្រុង រួមមាន ក៖ ប្រព័ន្ធប្រឆាំងការសម្អាតប្រាក់ (AML) ខ៖ ការធ្វើបច្ចុប្បន្នភាព លើគោលនយោបាយបច្ចេកវិទ្យាព័ត៌មានទាំងមូល ដើម្បីអនុលោមតាមសេចក្តីណែនាំរបស់និយ័តករ និងស្តង់ដាររបស់ស៊ីអាយអិមប៊ី គ្រុប។

ក្នុងឆ្នាំ២០២១នេះ ផ្នែកបច្ចេកវិទ្យា នឹងផ្តោតលើគម្រោង ដែលជាតម្រូវការរបស់និយ័តករ ការធ្វើបច្ចុប្បន្នភាព លើផ្នែកបច្ចេកវិទ្យាបន្ថែមទៀត ការធ្វើទំនើបកម្មនៃមជ្ឈមណ្ឌលទិន្នន័យ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដើម្បីប្រើប្រាស់សេវា Cloud Computing សម្រាប់ប្រព័ន្ធមិនសូវសំខាន់ ការពង្រឹងប្រព័ន្ធសុវត្ថិភាព (Cyber Resiliency) ការកែលម្អអភិបាលកិច្ចបច្ចេកវិទ្យាព័ត៌មាន និងគាំទ្រអង្គភាពអាជីវកម្ម ដោយធ្វើឲ្យប្រសើរឡើង នូវប្រព័ន្ធដែលប្រើប្រាស់ដោយអតិថិជន។

២០២០

ផ្នែកបច្ចេកវិទ្យា សម្រេចបាន
គម្រោងយុទ្ធសាស្ត្រមួយចំនួន រួមមាន៖

i. ការធ្វើបច្ចុប្បន្នភាព នៃហេដ្ឋារចនាសម្ព័ន្ធរបស់ប្រព័ន្ធធនាគារស្នូល

ii. ការធ្វើបច្ចុប្បន្នភាព នៃប្រព័ន្ធការពារសុវត្ថិភាពផ្ទៃក្នុង

iii. កែលម្អ និងបន្ថែមមុខងារថ្មីៗ នៃប្រព័ន្ធដែលមានស្រាប់

២០២១

ផ្នែកបច្ចេកវិទ្យា នឹងផ្តោតលើ៖

- គម្រោង ដែលជាតម្រូវការរបស់និយ័តករ
- ការធ្វើទំនើបកម្មនៃមជ្ឈមណ្ឌលទិន្នន័យ
- ការធ្វើបច្ចុប្បន្នភាពលើផ្នែកបច្ចេកវិទ្យាបន្ថែមទៀត
- ការពង្រឹងប្រព័ន្ធសុវត្ថិភាព
- ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដើម្បីប្រើប្រាស់សេវា Cloud Computing សម្រាប់ប្រព័ន្ធមិនសូវសំខាន់
- ការកែលម្អអភិបាលកិច្ចបច្ចេកវិទ្យាព័ត៌មាន
- និងគាំទ្រអង្គភាពអាជីវកម្ម ដោយធ្វើឲ្យប្រសើរឡើង នូវប្រព័ន្ធដែលប្រើប្រាស់ដោយអតិថិជន

ផ្នែកប្រតិបត្តិការ

ផ្នែកប្រតិបត្តិការ ទទួលបន្ទុក លើការធានាថា រាល់ប្រតិបត្តិការប្រចាំថ្ងៃ ដែលបានប្រព្រឹត្តទៅ នៅផ្នែកខាងមុខ ដែលមានទំនាក់ទំនងជាមួយអតិថិជន ត្រូវបានបំពេញបន្តតាមលក្ខខណ្ឌត្រឹមត្រូវ និងទាន់ពេលវេលា។ តួនាទីចម្បងរបស់ផ្នែកប្រតិបត្តិការ គឺរួមមានសេវាកម្មផ្ទេរប្រាក់ ក្នុងប្រទេស និងក្រៅប្រទេស ហិរញ្ញប្បទានពាណិជ្ជកម្ម ការទូទាត់មូលប្បទានបត្រ ការគ្រប់គ្រងម៉ាស៊ីនប្រតិបត្តិការស្វ័យប្រវត្តិ (ម៉ាស៊ីនដកប្រាក់ ដាក់ប្រាក់ និងដាក់មូលប្បទានបត្រ) ការគ្រប់គ្រងសាច់ប្រាក់របស់ធនាគារទាំងមូល ការផ្តល់សេវាកម្មធនាគារតាមប្រព័ន្ធអ៊ីនធើណេត និងសេវាកម្មបើកប្រាក់បៀវត្ស ប្រតិបត្តិការរតនាគារ សេវាកម្មគ្រប់គ្រងឥណទានទាំងមូល ព្រមទាំងសេវាកម្មទូទាត់ប្រាក់ដទៃទៀត។

ក្នុងឆ្នាំ២០២០ ផ្នែកប្រតិបត្តិការ សម្រេចបានការងារសំខាន់ៗមួយចំនួន រួមមាន ទី១៖ បញ្ចប់គម្រោងថ្មីៗចំនួន៤ ដើម្បីកែលម្អដំណើរការផ្ទៃក្នុង និងបង្កើនផលិតភាពការងាររបស់បុគ្គលិក ទី២៖ គម្រោងកែលម្អ ទៅលើប្រព័ន្ធ និងដំណើរការប្រតិបត្តិចំនួន១០ និងគម្រោងដែលមិនបានព្រៀងទុកចំនួន១១ ដើម្បីសម្រួលដល់ការងារប្រចាំថ្ងៃឲ្យបានរហ័ស និងគាំទ្រអង្គភាពអាជីវកម្ម អំឡុងពេលរាតត្បាត នៃជំងឺកូវីដ-១៩។ មិនតែប៉ុណ្ណោះ ផ្នែកប្រតិបត្តិការ សម្រេចបានផែនការសន្សំ លើការចំណាយ ក្នុងកម្រិត ២៦% ធៀបនឹងកញ្ចប់ថវិកា ជាងនេះទៅទៀតការគាំទ្រ ក្នុងការបញ្ចេញឥណទាន ជូនដល់អតិថិជន បានអនុវត្ត តាមការកំណត់ពេលវេលា (SLA) រហូតដល់ ១០០% ហើយផលិតភាពការងាររបស់បុគ្គលិកបានកើនឡើង ២% បើធៀបទៅនឹងឆ្នាំ២០១៩។

៤ គម្រោងថ្មីៗ
ដើម្បីកែលម្អដំណើរការផ្ទៃក្នុង និងបង្កើនផលិតភាពការងាររបស់បុគ្គលិក

១០ គម្រោងកែលម្អ ទៅលើ ប្រព័ន្ធ និងដំណើរការប្រតិបត្តិ
ដើម្បីសម្រួលដល់ការងារប្រចាំថ្ងៃឲ្យបានរហ័ស និងគាំទ្រអង្គភាពអាជីវកម្ម អំឡុងពេលរាតត្បាត នៃជំងឺកូវីដ-១៩

១១ គម្រោងដែលមិនបានព្រៀងទុក

២៦% ផែនការសន្សំ លើការចំណាយ

១០០% ការបញ្ចេញឥណទាន តាមការកំណត់ ពេលវេលា (SLA)

២% ផលិតភាពការងារ របស់បុគ្គលិក

ដោយឡែកក្នុងឆ្នាំ២០២១នេះ ផ្នែកប្រតិបត្តិការ នឹងបន្តផែនការយុទ្ធសាស្ត្រ កាលពីឆ្នាំ២០២០បន្ថែមទៀត ដោយផ្តោតសំខាន់ទៅលើ ៣ចំណុចធំៗ រួមមាន ទី១៖ បន្តកែសម្រួលប្រព័ន្ធ និងប្រតិបត្តិការ ទី២៖ ពង្រឹងហានិភ័យ នៃប្រតិបត្តិការ និងទី៣៖ អភិវឌ្ឍធនធានមនុស្សឲ្យស្របទៅតាមសម័យកាល នៃបច្ចេកវិទ្យា4.0។

រតនាភិបាល និងទីផ្សារ

នាយកដ្ឋានរតនាភិបាល និងទីផ្សារ នៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងកិច្ចសហការ ជាមួយនឹងអង្គភាពអាជីវកម្មផ្សេងទៀត តែងតែផ្តល់នូវដំណោះស្រាយឆ្លងតំបន់ ដល់អតិថិជន ទាំងក្នុង និងក្រៅប្រទេស សម្រាប់តម្រូវការពាណិជ្ជកម្ម ការវិនិយោគ និងហិរញ្ញវត្ថុ ដែលរួមមានប្រតិបត្តិការទិញលក់រូបិយវត្ថុ-រូបិយប័ណ្ណ សម្រាប់ការទូទាត់ភ្លាមៗ និងការព្រមព្រៀងទុកជាមុន ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស និងសេវាផ្ទេរប្រាក់ក្រៅប្រទេសជាដើម។ នាយកដ្ឋានរតនាភិបាល និងទីផ្សារ ទទួលបន្ទុក លើការចាត់ចែងគ្រប់គ្រងមូលនិធិ សម្រាប់ប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ដោយធានានូវកម្រិតសន្ទនីយភាពបានគ្រប់គ្រាន់ ជាមួយនឹងលំហូរសាច់ប្រាក់ដ៏មានប្រសិទ្ធភាពខ្ពស់ ដល់ធនាគារ ព្រមទាំងរក្សាឲ្យបាននូវប្រភពមូលនិធិផ្សេងៗគ្នា តាមរយៈការធ្វើទំនាក់ទំនង ជាមួយធនាគារដៃគូដទៃទៀត នៅលើទីផ្សារ។

ការពិនិត្យមើលសមិទ្ធផល ក្នុងឆ្នាំ ២០២០

ឆ្នាំ២០២០ ជាពេលវេលាមួយ ដែលយើងបានឆ្លងកាត់ នូវការផ្លាស់ប្តូរបរិយាកាសរបស់ពិភពលោកទាំងមូល។ មិនខុសពីប្រទេសដទៃ ធនាគារជាតិ នៃកម្ពុជា បានបំពេញកាតព្វកិច្ចយ៉ាងល្អប្រសើរ និងឆ្លើយតបបានទាន់ពេលវេលា ទៅលើស្ថានការទីផ្សារ តាមរយៈការបង្កើនកម្រិតសន្ទនីយភាព ចូលក្នុងទីផ្សារហិរញ្ញវត្ថុ និងការបន្ធូរនូវគោលនយោបាយរូបិយវត្ថុ ដូចជាការសម្រួល ដល់ការតម្កល់ដើមទុនរបស់ធនាគារពាណិជ្ជ ការរៀបចំតណទានឡើងវិញ សម្រាប់អតិថិជន ឬវិស័យ ដែលរងផលប៉ះពាល់ ការរក្សាតុល្យភាពរូបិយប័ណ្ណក្នុងស្រុក និងការគាំទ្រផ្នែកហិរញ្ញវត្ថុ ដល់សហគ្រាសធុនតូច និងមធ្យមក្នុងស្រុកជាដើម ដើម្បីរក្សាស្ថេរភាពផ្នែកហិរញ្ញវត្ថុ និងគាំទ្រផ្នែកសេដ្ឋកិច្ចទាំងមូល។

ជាមួយគ្នានេះ នាយកដ្ឋានរតនាភិបាល និងទីផ្សារ ក៏សម្រេចបាននូវសមិទ្ធផលហិរញ្ញវត្ថុប្រចាំឆ្នាំល្អប្រសើរ ស្របគ្នានឹងអង្គភាពអាជីវកម្មដទៃទៀតរបស់ធនាគារ។ បើធៀបនឹងឆ្នាំ២០១៩ ប្រាក់ចំណូលបានកើនឡើង ក្នុងកម្រិត ១៥% ដែល ២៣២% ក្នុងចំណោមនោះ ទទួលបានពីផ្នែកអាជីវកម្មប្តូររូបិយប័ណ្ណបរទេស។ កំណើនគួរឲ្យកត់សម្គាល់ ក្នុងអាជីវកម្មប្តូររូបិយប័ណ្ណបរទេសនេះ គឺដោយសារមានការចូលរួមយ៉ាងមុតមាំ ពីអាជីវកម្មផ្នែកអតិថិជនបុគ្គល និងផ្នែកក្រុមហ៊ុន ដែលបានផ្តល់នូវសេវាកម្មក្រោមលក្ខខណ្ឌប្រកួតប្រជែងខ្ពស់ និងសប្បុរបែប និងក្រោមអានុភាពនៃបណ្តាញអាជីវកម្ម និងកេរ្តិ៍ឈ្មោះថ្នាក់តំបន់ របស់ស៊ីអាយអិមប៊ី គ្រុប។

មិនត្រឹមតែប៉ុណ្ណោះ ក្នុងតួនាទីជាសមាជិកមួយ របស់គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម ផ្នែកគ្រប់គ្រងមូលនិធិ នៃនាយកដ្ឋានរតនាភិបាល និងទីផ្សារ បានភ្ជាប់ទំនាក់ទំនងយ៉ាងសកម្ម ជាមួយដៃគូ ទាំងក្នុង និងក្រៅប្រទេស ដើម្បីរក្សាបណ្តាញទំនាក់ទំនង ឲ្យកាន់តែរឹងមាំ និងដើម្បីពង្រីកកម្រិតទំហំពាណិជ្ជកម្មជាមួយគ្នា។ ទាំងអស់នេះបានផ្តល់ឲ្យធនាគារ នូវភាពបត់បែនអាជីវកម្មមួយ ដែលល្អប្រសើរជាងមុន ដើម្បីអាចស្វែងរកប្រាក់ចំណូលបន្ថែម ឲ្យបានកាន់តែច្រើនពីមូលនិធិដែលលើស ហើយស្របពេលជាមួយគ្នានោះ យើងក៏នៅតែបន្តស្វែងរកឱកាសបង្កើនមូលនិធិបន្ថែមទៀតផងដែរ។ ជាលទ្ធផល ថ្លៃដើមមូលនិធិរបស់ធនាគារបាន និងកំពុងបន្តទាបជាងមុន ដែលជំរុញឲ្យគម្លាតអត្រាការប្រាក់ចំណញបានខ្ពស់ជាងមុនទៀតផង។ ក្រៅពីនោះ នាយកដ្ឋានបានត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាព លើផែនការមូលនីធិបម្រុងទុក (CFP) ជាមួយនឹងនាយកដ្ឋានគ្រប់គ្រងហានិភ័យ ដើម្បីធ្វើការព្យាករ និងកំណត់នូវហានិភ័យផ្សេងៗ អំពីមូលនិធិ ដែលអាចកើតមាន។

ទស្សនវិស័យ និងយុទ្ធសាស្ត្រ ក្នុងឆ្នាំ ២០២១

ស្របតាមការព្យាករ បែបសុទិដ្ឋិនិយម នៃកំណើនសេដ្ឋកិច្ចប្រទេសកម្ពុជា ក្នុងឆ្នាំ២០២១ ដោយធនាគារជាតិ នៃកម្ពុជា និងធនាគារពិភពលោក យើងជឿជាក់យ៉ាងមុតមាំថា ឱកាសអាជីវកម្មទាក់ទងនឹងកិច្ចការតនាភិបាល និងទីផ្សារ នឹងបន្តកើតមានឡើង តាមរយៈលំហូរទុននៃការវិនិយោគបរទេស តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងថ្នាក់តំបន់ ព្រមទាំងតម្រូវការកាន់តែច្រើន ទៅលើរូបិយប័ណ្ណក្នុងស្រុក ជាមួយនឹងកំណើនរំពឹងទុក ទៅលើអាជីវកម្ម និងសហគ្រាសធុនតូច និងមធ្យមក្នុងស្រុកថ្មីៗ ដែលមានការយកចិត្តទុកដាក់ខ្ពស់ ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងមូលដ្ឋានសេដ្ឋកិច្ចក្នុងស្រុក។

នាយកដ្ឋានរតនាភិបាល និងទីផ្សារ នឹងពង្រឹងយុទ្ធសាស្ត្រយូរអង្វែង ដោយការចាប់ដៃគូសហការជាមួយនឹងអង្គភាពអាជីវកម្មដទៃទៀត ក្នុងការផ្តល់ផលិតផល និងសេវាកម្មដ៏ប្រកួតប្រជែង ទៅដល់អតិថិជនថ្មី និងមានស្រាប់ ព្រមទាំងពង្រីកបណ្តាញឲ្យកាន់តែទូលំទូលាយ ជាមួយនឹងភាគីដៃគូធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត។ យើងក៏នឹងបន្តពិនិត្យ និងធ្វើបច្ចុប្បន្នភាពផែនការមូលនិធិបម្រុងទុកផងដែរ ដើម្បីឆ្លើយតបនឹងហេតុការណ៍បន្ទាន់ចាំបាច់ណាមួយ ក៏ដូចជារក្សាភាពខ្លាំងនៃកម្រិតសន្ទនីយភាពដើម្បីបំពេញតម្រូវការរបស់អតិថិជនបានពេញលេញ។ កាន់តែសំខាន់ជាងនេះទៀត យើងនឹងធ្វើការបន្តពង្រឹងប្រភពប្រាក់រៀលរបស់ធនាគារ តាមរយៈភាគីពាក់ព័ន្ធ និងប្រភពនានា ដើម្បីត្រៀមបម្រុងឲ្យបានគ្រប់គ្រាន់ សម្រាប់ការកើនឡើង លើតារាងតុល្យការ និងសេវាកម្មទូទាត់ជាប្រាក់រៀលនៅក្នុងធនាគារ។

ទីផ្សារ និងទំនាក់ទំនង

នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង ដើរតួនាទីយ៉ាងសំខាន់ ក្នុងការគាំទ្រកម្មវិធីទំនាក់ទំនងរបស់ធនាគារ ដើម្បីលើកកម្ពស់សាវតារ និងស្លាកសញ្ញា របស់ធនាគារ ស៊ីអាយអិមប៊ី នៅក្នុងប្រទេសកម្ពុជា។ នាយកដ្ឋាននេះត្រួតពិនិត្យ លើការទំនាក់ទំនងផ្ទៃក្នុង រវាងនាយកដ្ឋានផ្សេងៗ និងសកម្មភាពទំនាក់ទំនងខាងក្រៅ ដើម្បីជំរុញការលក់ផលិតផល និងសេវាកម្មរបស់ធនាគារ។ នាយកដ្ឋាននេះអភិវឌ្ឍ និងលើកកម្ពស់ការកំណត់ទិសដៅស្លាកសញ្ញាធនាគារ និងរបៀបវារៈទំនាក់ទំនង តាមរយៈក្របខណ្ឌចម្រុះមួយដែលមានមុខងារផ្សេងៗគ្នា ដូចជាការផ្សព្វផ្សាយពាណិជ្ជកម្ម និងទីផ្សារ / ទំនាក់ទំនងសាធារណៈ និងសារព័ត៌មាន / គ្រប់គ្រងការឧបត្ថម្ភ និងការរៀបចំកម្មវិធីទីផ្សារ ព្រមទាំងការគ្រប់គ្រងទំនាក់ទំនងផ្ទៃក្នុង។

សមិទ្ធផលសំខាន់ៗ ក្នុងឆ្នាំ ២០២០

យើងបានកំណត់ទិសដៅយ៉ាងជាក់លាក់ របស់ធនាគារ ស៊ីអាយអិមប៊ី នៅប្រទេសកម្ពុជា ក្នុងនាមជាអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុ និងជាដៃគូពាណិជ្ជកម្ម ដែលមានមូលដ្ឋានគ្រឹះយ៉ាងរឹងមាំ នៅក្នុងស្រុក និងមានបណ្តាញដ៏ទូលំទូលាយ នៅទូទាំងតំបន់អាស៊ាន។ ក្រៅពីបង្កើតយុទ្ធសាស្ត្រ ក្នុងការចាក់គ្រឹះអត្តសញ្ញាណ នៅក្នុងស្រុករបស់ធនាគារ ស៊ីអាយអិមប៊ី យើងបានពឹងផ្អែកលើធនធាន ក្នុងតំបន់របស់ស៊ីអាយអិមប៊ី គ្រុប និងភ្ជាប់សេវាកម្មថ្នាក់តំបន់ ដែលសមស្របបំផុត សម្រាប់អតិថិជន ក្នុងប្រទេសកម្ពុជា ដែលរួមមានសេវាកម្មបណ្តាញអេធីអិម ក្នុងតំបន់អាស៊ាន សេវាផ្ទេរប្រាក់តេលេក្រាម ក្នុងថ្ងៃតែមួយ សម្រាប់៥ប្រទេស ក្នុងតំបន់អាស៊ាន ព្រមទាំងកម្មវិធី និងបុព្វសិទ្ធិពិសេសថ្នាក់តំបន់ សម្រាប់ការទិញទំនិញក្នុងហាង ការទទួលទានអាហារ និងដំណើរកម្សាន្តជាដើម។ មិនតែប៉ុណ្ណោះ យើងបានផ្សព្វផ្សាយលក្ខណៈស្លាកសញ្ញាថ្មីរបស់ ស៊ីអាយអិមប៊ី គ្រុប គឺ «Forward» ដែលត្រូវបានប្រើប្រាស់រួមគ្នា នៅគ្រប់ទីផ្សារ របស់ស៊ីអាយអិមប៊ី គ្រុប ដើម្បីបង្ហាញការប្តេជ្ញាចិត្ត របស់ធនាគារ ស៊ីអាយអិមប៊ី ក្នុងការជំរុញ ដល់ការសម្រេចបានគោលដៅ និងបំណងប្រាថ្នារបស់អតិថិជន។

ក្នុងឆ្នាំ ២០២០ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានឈានចូលឆ្នាំទី១០ ដែលជាយៈពេលគួរឲ្យកត់សម្គាល់មួយ នៃប្រតិបត្តិការរបស់ធនាគារ ក្នុងប្រទេសកម្ពុជា ទៅលើដំណើរអាជីវកម្ម ការកសាងធនធានមនុស្ស និងស្លាកសញ្ញារបស់ខ្លួន។ ទោះបីជាស្ថិតក្នុងបរិបទប្រឈម នៃការរាតត្បាតជំងឺកូវីដ-១៩ ជាសាកលក៏ដោយ យើងនៅតែអាចសម្រេចបានសមិទ្ធផលប្រចាំឆ្នាំ ដែលជាការអបអរខួបគម្រប់១០ឆ្នាំរបស់ធនាគារ ដោយបានកត់ត្រាប្រាក់ចំណេញមុនបង់ពន្ធចំនួន ២៦,៨លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២០ ដែលមានកំណើនប្រចាំឆ្នាំ ១៧% បើធៀបនឹងឆ្នាំ២០១៩។

ពានរង្វាន់
«ទីកន្លែងការងារល្អបំផុត»

ផ្តល់ដោយទស្សនាវដ្តី HR Asia

នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង បានដឹកនាំរៀបចំសកម្មភាព និងព្រឹត្តិការណ៍របស់ធនាគារនានា ដូចជាទិវានារីអន្តរជាតិរបស់ធនាគារ ស៊ីអាយអិមប៊ី ពិធីគម្រប់ខួប១០ឆ្នាំ និងកិច្ចប្រជុំបុគ្គលិកប្រចាំឆ្នាំជាដើម។ ម្យ៉ាងវិញទៀត យើងបានគាំទ្រ ដល់គម្រោងទំនួលខុសត្រូវសង្គមរបស់ធនាគារ ទៅលើវិស័យផ្សេងៗគ្នា ដូចជាវិស័យអប់រំ សុខាភិបាល សង្គម និងបរិស្ថានជាដើម ដែលរួមមានកម្មវិធីដាំកូនឈើ នៅប្រាសាទបន្ទាយក្តី កម្មវិធីបរិច្ចាគឈាម និងកម្មវិធីបរិច្ចាគជួយជនរងគ្រោះនានាជាច្រើនទៀតផងដែរ។

លើសពីសកម្មភាពការងារ លើគម្រោងក្នុងស្រុក នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង បានគាំទ្រជារៀងរាល់ឆ្នាំ ដល់ការរៀបចំព្រឹត្តិការណ៍ផ្សព្វផ្សាយ និងការចុះផ្សាយព័ត៌មាន អំពីកម្មវិធីអាហារូបករណ៍តំបន់អាស៊ាន របស់ធនាគារ ស៊ីអាយអិមប៊ី ដោយប្រកាសយ៉ាងទូលំទូលាយ និងលើកទឹកចិត្ត ដល់សិស្សនិស្សិតខ្មែរ ក្នុងការដាក់ពាក្យស្នើសុំអាហារូបករណ៍១០០%នេះ នៅគ្រប់សាកលវិទ្យាល័យល្បីឈ្មោះ ជុំវិញពិភពលោក។ ជាលទ្ធផល មាននិស្សិតខ្មែរមួយរូបទៀត ដែលបានប្រកួតប្រជែងជាមួយសិស្សនិស្សិតដទៃទៀត ក្នុងតំបន់អាស៊ាន ទទួលបានអាហារូបករណ៍នេះ។

នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង បានខិតខំបង្កើនការផ្សព្វផ្សាយព័ត៌មានរបស់ធនាគារ ជាមួយនឹងស្ថាប័នសារព័ត៌មាននានា ចាប់ពីសារព័ត៌មានប្រពៃណី រហូតដល់សារព័ត៌មានឌីជីថល ដូចជាកាសែត ទស្សនាវដ្តី វិទ្យុ និងទូរទស្សន៍ ព្រមទាំងគេហទំព័រជាដើម។ យើងបានបង្កើនវត្តមានរបស់ធនាគារ នៅលើបណ្តាញទំនាក់ទំនងសង្គម LinkedIn ដែលជាផ្នែកមួយ នៃកម្មវិធីភ្ជាប់ទំនាក់ទំនង ក្នុងបណ្តាញសង្គម ដែលជួយដល់ធនាគារ ក្នុងការខិតកាន់តែជិត ជាមួយនឹងអតិថិជនថ្មីៗ ដែលជួយពង្រីកដល់ទិសដៅអាជីវកម្មរបស់យើង។ មិនតែប៉ុណ្ណោះ យើងសម្រេចបានជោគជ័យ លើគម្រោងកែលម្អគេហទំព័រ ទៅលើរចនាបទ និងមុខងារ ដើម្បីធ្វើឲ្យសេវាកម្មបម្រើអតិថិជនកាន់តែល្អប្រសើរ។

ផែនការអាទិភាព សម្រាប់ឆ្នាំ ២០២១

ឆ្នាំ២០២១ នឹងក្លាយជាឆ្នាំដ៏រំភើបរីករាយមួយទៀត សម្រាប់នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី នឹងឈានចូលទសវត្សរ៍ថ្មីមួយទៀត នៃប្រតិបត្តិការ និងការចាក់គ្រឹះអាជីវកម្ម របស់ធនាគារ ក្នុងប្រទេសកម្ពុជា។ ជាមួយនឹងកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សដ៏រឹងមាំ និងការគិតគូរ លើសុខមាលភាព និងអត្ថប្រយោជន៍បុគ្គលិកដ៏ល្អប្រសើរ ធនាគារបានឈ្នះពានរង្វាន់ «ទីកន្លែងការងារល្អបំផុត» ផ្តល់ដោយទស្សនាវដ្តី HR Asia។ តួនាទីស្នូលរបស់យើង គឺណែនាំឡើងវិញ នូវស្លាកសញ្ញា របស់ធនាគារ ស៊ីអាយអិមប៊ី ទៅកាន់ទីផ្សារ ក្នុងនាមជាធនាគារអន្តរជាតិឈានមុខគេមួយ ដែលជួយជំរុញឲ្យបំណងប្រាថ្នា និងគោលដៅ ទាំងផ្ទាល់ខ្លួន និងអាជីវកម្មរបស់អតិថិជន ឈានទៅរកភាពជោគជ័យ។ ស្របតាមយុទ្ធសាស្ត្រមេ របស់ស៊ីអាយអិមប៊ី គ្រុប យើងនឹងបន្តពង្រឹង និងពង្រីកអត្តសញ្ញាណស្លាកសញ្ញា និងកេរ្តិ៍ឈ្មោះរបស់ធនាគារ ក្នុងនាមជា «ធនាគារ ដែលផ្តោតលើអាស៊ាន»។ ជាងនេះទៅទៀត យើងនឹងបន្តពង្រីកកម្មវិធីទំនាក់ទំនងសាធារណៈរបស់ធនាគារ ដោយភ្ជាប់ទំនាក់ទំនងកាន់តែទូលំទូលាយ ជាមួយនឹងស្ថាប័នសារព័ត៌មាននានា។

សវនកម្មផ្ទៃក្នុង

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់នូវការវាយតម្លៃឯករាជ្យ ទៅលើភាពគ្រប់គ្រាន់ ប្រសិទ្ធភាព និងប្រសិទ្ធផល នៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដែលអនុវត្តដោយគណៈគ្រប់គ្រងរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី។ ការវាយតម្លៃរបស់នាយកដ្ឋាននេះ គឺធ្វើទៅលើស្ថានភាព នៃការត្រួតពិនិត្យរបស់ធនាគារ ការវាយតម្លៃហានិភ័យ សកម្មភាពត្រួតពិនិត្យ ប្រភពព័ត៌មាន ប្រសិទ្ធភាពនៃការទំនាក់ទំនង និងសកម្មភាពគ្រប់គ្រងតាមដាន។ សវនកម្មផ្ទៃក្នុង មានភារកិច្ចរាយការណ៍ដោយផ្ទាល់ ជូនគណៈកម្មាធិការសវនកម្ម និងមានឯករាជ្យភាព ពីផ្នែកប្រតិបត្តិការអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មផ្សេងៗ។

នៅក្នុងឆ្នាំ២០២០ ដោយមានការគាំទ្រ ពីសវនកម្មផ្ទៃក្នុង នៃស៊ីអាយអ៊ីមប៊ី គ្រុប នាយកដ្ឋានសវនកម្មផ្ទៃក្នុង សម្រេចបានការងារចំនួន ១៧គម្រោង ដែលបានគ្របដណ្តប់ផ្នែកសំខាន់ៗ រួមមានសវនកម្មសាខា សវនកម្មនាយកដ្ឋាន និងសវនកម្មតាមផ្នែក (រួមមានការពិនិត្យមើលតាមជាក់ស្តែងចំនួន ២ដងផងដែរ)។

ផែនការរបស់យើង ក្នុងឆ្នាំ២០២១ គឺបន្តការងារសវនកម្ម តាមរយៈការវាយតម្លៃហានិភ័យរបស់សវនកម្មផ្ទៃក្នុង ព្រមទាំងការស៊ើបអង្កេតចាំបាច់ផ្សេងៗទៀត។

សម្រេចបានការងារចំនួន **១៧** គម្រោង

នីតិកម្ម និងលេខាធិការក្រុមហ៊ុន

នាយកដ្ឋាននីតិកម្ម និងលេខាធិការក្រុមហ៊ុន រួមមានផ្នែកនីតិកម្ម និងលេខាធិការក្រុមហ៊ុន។

នាយកដ្ឋាននីតិកម្ម ដើរតួនាទីចម្បង ក្នុងការផ្តល់ដំបូន្មានផ្នែកច្បាប់ ទៅបុគ្គលិកទាំងអស់ នៅក្នុងធនាគារ ក្នុងការអនុវត្តការងាររបស់ពួកគេ ដើម្បីធានាបានថា អត្ថប្រយោជន៍របស់ធនាគារត្រូវបានការពារ ក្នុងការធ្វើអាជីវកម្ម លើគ្រប់វិស័យ។ ក្នុងនោះផងដែរ នាយកដ្ឋាននីតិកម្ម បានចាត់ចែងរឿងក្តីតុលាការ ដែលទទួលបាន ពីនាយកដ្ឋានផ្សេងៗរបស់ធនាគារ រួចហើយសហការជាមួយក្រុមមេធាវីខាងក្រៅ ដើម្បីគ្រប់គ្រងរឿងក្តីឡើងតុលាការ។

នាយកដ្ឋាននីតិកម្ម ត្រួតពិនិត្យលើទិដ្ឋភាព ផ្នែកច្បាប់នៃ សកម្មភាព ដែលអនុវត្តដោយធនាគារ និងទទួលខុសត្រូវ លើការសម្របសម្រួល ផ្តល់ដំបូន្មាន និងពិនិត្យមើល លើផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ដើម្បីធានាការអនុវត្តអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិ និងសេចក្តីណែនាំផ្សេងៗ។

ដើម្បីឲ្យស្របជាមួយនឹងអភិបាលកិច្ចល្អ លេខាធិការក្រុមហ៊ុនរបស់យើងផ្តល់ការគាំទ្រ ទៅដល់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង សម្រាប់ការអនុវត្តកាតព្វកិច្ច និងទំនួលខុសត្រូវរបស់ពួកគាត់។ បន្ថែមពីនេះ លេខាធិការក្រុមហ៊ុនមានតួនាទីផ្តល់ដំបូន្មាន លើការងារអភិបាលកិច្ច រួមមានតម្រូវការផ្នែកច្បាប់ និងបទប្បញ្ញត្តិ ទៅគ្រប់ផ្នែក ក្នុងធនាគារ។ លេខាធិការក្រុមហ៊ុន ក៏ចាត់ចែងការងារ និងមុខងារប្រចាំថ្ងៃ ទាក់ទងនឹងលេខាធិការក្រុមហ៊ុន របស់ធនាគារ រួមទាំងនីតិវិធីដែលពាក់ព័ន្ធ ជាមួយការអនុម័តរបស់អាជ្ញាធរ និងបញ្ញត្តិករ។

នាយកដ្ឋានក៏ចូលរួមធ្វើការងារ ជាមួយក្រុមការងារគម្រោងផ្សេងៗរបស់ធនាគារ ដើម្បីធានាដល់ទំនួលខុសត្រូវរបស់ធនាគារ ចំពោះបទប្បញ្ញត្តិនានា។

បទពិសោធន៍សេវាកម្មអតិថិជន

នាយកដ្ឋានបទពិសោធន៍សេវាកម្មអតិថិជន ត្រូវបានបង្កើតឡើង ដើម្បីជួយសម្រួលដល់កិច្ចខិតខំប្រឹងប្រែងរួមរបស់ធនាគារ តាមរយៈការផ្តល់ជូននូវសេវាកម្មល្អបំផុត ក្នុងការបំពេញចិត្តអតិថិជន។ នាយកដ្ឋាននេះ អនុវត្តវិធីសាស្ត្រផ្តោតការយកចិត្តទុកដាក់ ទៅលើអតិថិជន ដើម្បីបំពេញសេចក្តីត្រូវការរបស់ពួកគេ នៅគ្រប់កម្រិតតាមរយៈភាគីពាក់ព័ន្ធ រួមមានសាខាធនាគារ ការិយាល័យបម្រើសេវាកម្មអតិថិជន ព្រមទាំងអង្គភាពទំនាក់ទំនងអតិថិជននានា រួមជាមួយនឹងប្រព័ន្ធឌីជីថល ដូចជាសេវាកម្មធនាគារតាមប្រព័ន្ធអ៊ីនធើណេត និងគេហទំព័ររបស់ធនាគារ ក៏ដូចជាដំណើរការក្រុមការងារគាំទ្រផ្សេងៗផងដែរ។

ក្រៅពីនេះ នាយកដ្ឋានបទពិសោធន៍សេវាកម្មអតិថិជន ធានាថា ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ពង្រឹងការប្តេជ្ញាចិត្តទាំងបីរបស់ខ្លួន ទៅកាន់អតិថិជន រួមមានប្រសិទ្ធភាព និងភាពងាយស្រួល ក្នុងការសហការជាមួយធនាគារ ស៊ីអាយអិមប៊ី ហើយយើងនឹងតែងតែជំរុញការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីបំពេញតម្រូវការអតិថិជន។

នាយកដ្ឋានបទពិសោធន៍សេវាកម្មអតិថិជន ក៏ទទួលបន្ទុកផ្នែកគ្រប់គ្រងការគាំទ្រអាជីវកម្មផងដែរ ដោយពិនិត្យមើលភាពស្របគ្នា និងការអភិវឌ្ឍនៃប្រព័ន្ធ ព្រមទាំងដំណើរការបំពេញមុខងារ។ នាយកដ្ឋាននេះជួយគាំទ្រការគ្រប់គ្រងគម្រោង ដល់អង្គភាពអាជីវកម្មទាំងអស់ នៅក្នុងធនាគារ ដោយធានានូវការអនុវត្តគម្រោង តាមកាលកំណត់។

ក្នុងឆ្នាំ២០២០ នាយកដ្ឋានបទពិសោធន៍សេវាកម្មអតិថិជន បានកែលម្អដំណើរការ និងប្រព័ន្ធប្រតិបត្តិការធនាគារ ឲ្យកាន់តែល្អប្រសើរ ដើម្បីលើកកម្ពស់បទពិសោធន៍សេវាកម្មអតិថិជន និងវប្បធម៌នៃការយកចិត្តទុកដាក់ ដែលក្នុងនោះយើងមានកម្មវិធីជាច្រើន ដើម្បីការពារអតិថិជនរបស់យើង ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ ដែលយកអតិថិជនជាធំ។

ក្នុងឆ្នាំ២០២០ ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា នឹងបន្តលើកកម្ពស់បទពិសោធន៍សេវាកម្មអតិថិជន តាមរយៈកម្មវិធីល្អៗមួយចំនួន នៅទូទាំងធនាគារ ដើម្បីបង្កើនពិន្ទុបុគ្គលិកបម្រើសេវាកម្មអតិថិជន។

គ្រប់គ្រងផលិតផល

នាយកដ្ឋានគ្រប់គ្រងផលិតផល គឺជាផ្នែកដ៏សំខាន់មួយ នៃសកម្មភាពអាជីវកម្មរបស់ធនាគារ។ មុខងាររបស់នាយកដ្ឋាននេះ គឺជួយជំរុញធនាគារឲ្យរក្សាបាននូវភាពប្រកួតប្រជែង និងបន្តបង្កើនចំណែកទីផ្សារ ដោយធ្វើការណែនាំផលិតផល និងសេវាកម្មថ្មីៗបន្ថែមទៀត ដើម្បីបំពេញតម្រូវការអតិថិជន។

នាយកដ្ឋានគ្រប់គ្រងផលិតផល ក៏ទទួលបន្ទុកលើផ្នែកសេវាកម្មធនាគារឌីជីថលផងដែរ ដែលរួមចំណែករក្សានូវភាពប្រកួតប្រជែង នៅក្នុងទីផ្សាររបស់ធនាគារ តាមរយៈការណែនាំ និងលើកកម្ពស់ផលិតផល និងសេវាកម្មថ្មីៗបន្ថែមទៀត។ ទាំងអស់នេះជួយជំរុញធនាគារ ក្នុងការបំពេញតម្រូវការអតិថិជន ស្របតាមការវិវឌ្ឍផ្នែកបច្ចេកវិទ្យាទំនើប។ សេវាកម្មធនាគារឌីជីថល គឺរួមមានម៉ាស៊ីនប្រតិបត្តិការ ដោយខ្លួនឯង និងសេវាកម្មបណ្តាញអេធីអិម ថ្នាក់តំបន់ ដែលអនុញ្ញាតឲ្យអតិថិជនរបស់ធនាគារ ស៊ីអាយអិមប៊ី អាចដកប្រាក់ជារូបិយប័ណ្ណក្នុងស្រុក តាមប្រទេស ក្នុងតំបន់អាស៊ាន រួមមានប្រទេសម៉ាឡេស៊ី សិង្ហបុរី និងឥណ្ឌូនេស៊ី។

អតិថិជន អាចដកប្រាក់ជា **រូបិយប័ណ្ណក្នុងស្រុក** តាមប្រទេس ក្នុងតំបន់អាស៊ាន រួមមានប្រទេس ម៉ាឡេស៊ី សិង្ហបុរី និងឥណ្ឌូនេស៊ី

សម្រាប់ឆ្នាំ២០២១ យើងមានបំណងអភិវឌ្ឍផលិតផល ឲ្យកាន់តែប្រកួតប្រជែង និងផ្ទៃប្រឌិតខ្ពស់ ទាំងលើឥណទាន និងប្រាក់បញ្ញើ ស្របតាមបទពិសោធន៍ល្អបំផុត នៅក្នុងស៊ីអាយអិមប៊ី គ្រុប។ យើងមានផែនការនាំយកសេវាកម្ម និងផលិតផលបន្ថែមទៀត ដើម្បីផ្តល់ជាប្រយោជន៍ ដល់សង្គម និងសហគមន៍ ស្របតាមគោលការណ៍អភិវឌ្ឍន៍ ប្រកបដោយនិរន្តរភាព។ មិនតែប៉ុណ្ណោះ យើងមានគម្រោងពង្រឹងការអភិវឌ្ឍ នៃសេវាកម្មធនាគារចល័ត តាមទូរសព្ទដៃ ហើយអាចឲ្យអតិថិជនគ្រប់រូបអាចប្រើប្រាស់បានទូលំទូលាយ។ ការជំរុញឲ្យសេវាកម្មធនាគារ អាចប្រើប្រាស់បាន នៅតាមបណ្តាញផ្សេងៗគ្នា គឺទិសដៅស្នូល នៃយុទ្ធសាស្ត្ររបស់យើង ស្របតាមទស្សនវិស័យរបស់យើង ក្នុងការជំរុញកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីបំពេញចិត្ត និងតម្រូវការរបស់អតិថិជន។

អភិបាលកិច្ច ធនាគារ

៣៦ សេចក្តីថ្លែងការណ៍ ស្តីពីអភិបាលកិច្ចធនាគារ
៤៦ របាយការណ៍គណៈកម្មាធិការសវនកម្ម
៤៩ សេចក្តីថ្លែងការណ៍ ស្តីអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
៥២ រចនាសម្ព័ន្ធគ្រប់គ្រងក្រុមហ៊ុនមេ
៥៣ រចនាសម្ព័ន្ធក្រុមហ៊ុន
៥៤ របាយការណ៍ព័ត៌មានរបស់ធនាគារ

10 ឆ្នាំ

ខួប១០ឆ្នាំ នៃប្រតិបត្តិការ

នៅប្រទេសកម្ពុជា

សេចក្តីថ្លែងការណ៍ ស្តីពីអភិបាលកិច្ចធនាគារ

ក្រុមប្រឹក្សាភិបាលមានជំនឿថា អភិបាលកិច្ចធនាគារដ៏រឹងមាំមួយមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការផ្តល់នូវតម្លៃជានិរន្តរ ការលើកកម្ពស់សុចរិតភាព ក្នុងការធ្វើធុរកិច្ច និងការរក្សានូវទំនុកចិត្តរបស់វិនិយោគិន ចំពោះធនាគារឆ្ពោះទៅរកការសម្រេចបាននូវគោលដៅ និងទស្សនវិស័យរបស់ធនាគារ។

វប្បធម៌ និងរចនាសម្ព័ន្ធអភិបាលកិច្ច ប្រកបដោយប្រសិទ្ធភាព គឺជាធាតុសំខាន់បំផុតក្នុងការកំណត់អំពីរបៀបរបបដែលធនាគារដំណើរការ ហើយថ្នាក់ដឹកនាំធនាគារតែងតែសង្កត់ធ្ងន់លើចំណុចនេះ ក្នុងការណែនាំដល់គ្រប់បុគ្គលិករបស់ខ្លួនទាំងអស់ ជាបន្តបន្ទាប់។ ក្របខណ្ឌអភិបាលកិច្ចដែលធនាគារសម្រេចយកត្រូវបានរៀបចំឡើង ដោយផ្អែកលើគោលការណ៍នានា និងការអនុវត្តល្អបំផុត ដូចមានចែងក្នុងប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា ស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងប្រកាសស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របសម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ និងការអនុវត្តល្អបំផុតជាលក្ខណៈអន្តរជាតិ ក្នុងអភិបាលកិច្ចធនាគារដែលពាក់ព័ន្ធ។

ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល និងតុល្យភាពនៃក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ននេះ ក្រុមប្រឹក្សាភិបាលមានសមាជិកចំនួន ០៦ រូប ដែលរួមមានអភិបាលប្រតិបត្តិចំនួន ០១ រូប និងអភិបាលមិនប្រតិបត្តិចំនួន ០៥ រូប ហើយក្នុងចំណោមអភិបាលទាំងអស់ មានអភិបាលចំនួន ០៣ រូប ជាអភិបាលឯករាជ្យ។ ក្រុមប្រឹក្សាភិបាលបានបញ្ជាក់ថា សមាសភាពក្រុមប្រឹក្សាភិបាលមានចំនួនអភិបាលឯករាជ្យគ្រប់គ្រាន់ ដែលអាចធ្វើការវិនិច្ឆ័យដោយឯករាជ្យបំផុត នៅក្នុងកិច្ចពិភាក្សានានារបស់ក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលក៏គោរពដំណើរការ នៃការធ្វើសេចក្តីសម្រេចរួមផងដែរ។

ក្រុមប្រឹក្សាភិបាលទទួលបានអត្ថប្រយោជន៍ ពីការចូលរួមចំណែកនានារបស់អភិបាលមិនប្រតិបត្តិម្នាក់ៗ នៅក្នុងគ្រប់វិស័យទាំងអស់នៃអាជីវកម្មរបស់ធនាគារ។ បន្ថែមពីលើជំនាញ និងបទពិសោធន៍ផ្នែកអាជីវកម្មជាច្រើនឆ្នាំរបស់អភិបាលម្នាក់ៗ អភិបាលមិនប្រតិបត្តិក៏ធ្វើការវិនិច្ឆ័យ ដោយឯករាជ្យក្នុងកិច្ចពិភាក្សាស្តីពីបញ្ហាយុទ្ធសាស្ត្រ សវនកម្ម ប្រតិបត្តិការ និងហានិភ័យផងដែរ។

រចនាសម្ព័ន្ធ និងសមាភាពរបស់ក្រុមប្រឹក្សាភិបាលត្រូវគោរពទៅតាមលក្ខខណ្ឌតម្រូវ ដែលមានចែងក្នុងប្រកាសរបស់ ធនាគារជាតិនៃកម្ពុជា។

សមាសភាពក្រុមប្រឹក្សាភិបាល

ដើម្បីធានាឲ្យបាននូវតុល្យភាពនៃអំណាច ការបង្កើននូវគណនេយ្យភាព និងសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចប្រកបដោយឯករាជ្យភាព នោះតួនាទីរបស់ប្រធានក្រុមប្រឹក្សាភិបាល និងតួនាទីរបស់អភិបាលប្រតិបត្តិ (Executive Director) ត្រូវបានបែងចែក និងដាក់ឲ្យនៅដាច់ពីគ្នា ដោយមានការបែងចែកយ៉ាងច្បាស់លាស់ អំពីការទទួលខុសត្រូវ រវាងប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលប្រតិបត្តិ ដើម្បីចៀសវាងកុំឲ្យបុគ្គលណាម្នាក់ ឬក្រុមណាមួយអាចត្រួតត្រាលើដំណើរការនៃការធ្វើសេចក្តីសម្រេចបាន។

ប្រធានក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រូវបានដឹកនាំ ដោយប្រធានក្រុមប្រឹក្សាភិបាល គឺ Datuk Mohd Nasir Bin Ahmad ដែលបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាល នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩។ Datuk Mohd Nasir Bin Ahmad ទទួលខុសត្រូវលើការដឹកនាំ និងការគ្រប់គ្រងក្រុមប្រឹក្សាភិបាល និងធានាប្រសិទ្ធភាពនៃការបំពេញមុខងាររបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។ ប្រធានក្រុមប្រឹក្សាភិបាលបំពេញតួនាទីផ្ទូវការជាថ្នាក់ដឹកនាំ និងធ្វើជាអធិបតី ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលទាំងអស់ ដឹកនាំការពិភាក្សារវាងអភិបាល ព្រមទាំងតម្រង់ទិសក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យលើការគ្រប់គ្រងធនាគារផងដែរ។ ប្រធានក្រុមប្រឹក្សាភិបាលធ្វើការសម្របសម្រួលលំហូរព័ត៌មាន រវាងគណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល ព្រមទាំងប្រឹក្សាយោបល់ជាមួយគណៈគ្រប់គ្រង ដើម្បីដាក់ចេញនូវរបៀបវារៈសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សានីមួយៗ។

អភិបាលប្រតិបត្តិ

លោក ប៊ុន យីន ដែលមានសញ្ជាតិខ្មែរ គឺជាប្រធាននាយកប្រតិបត្តិរបស់ធនាគារ ហើយក៏ជាអភិបាលប្រតិបត្តិផងដែរ។ លោកត្រូវបានតែងតាំងជាប្រធាននាយកប្រតិបត្តិ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ និងតែងតាំងជាអភិបាលប្រតិបត្តិ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥។ លោក ប៊ុន យីន ក៏ជាបុគ្គលដំបូង ដែលដឹកនាំធនាគារបរទេសលំដាប់អន្តរជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

ក្នុងនាមជាអភិបាលប្រតិបត្តិ/ប្រធាននាយកប្រតិបត្តិ លោក ប៊ុន យីន ទទួលខុសត្រូវរួមលើការអនុវត្តយុទ្ធសាស្ត្ររបស់ធនាគារ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល រៀបចំអាជីវកម្មរបស់ធនាគារ និងដឹកនាំប្រតិបត្តិការ ស្របតាមគោលដៅយុទ្ធសាស្ត្រ និងទិសដៅអាជីវកម្ម។ លោកធ្វើការដឹកនាំគណៈគ្រប់គ្រងក្នុងការអនុវត្តយុទ្ធសាស្ត្រ និងទស្សនវិស័យរបស់ធនាគារ។ ក្នុងឋានៈជាអភិបាលប្រតិបត្តិ/ប្រធាននាយកប្រតិបត្តិ លោកទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាភិបាល លើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ។

ទំហំ និងសមាសភាពរបស់ក្រុមប្រឹក្សាភិបាល

ទំហំ និងសមាសភាពរបស់ក្រុមប្រឹក្សាភិបាលត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ដោយពិនិត្យមើលទៅលើវិសាលភាព លក្ខណៈ ភាពខុសប្លែកគ្នា និងការពង្រីកអាជីវកម្មធនាគារ។

ក្រុមប្រឹក្សាភិបាលយល់ឃើញ និងអះអាងថា សមាសភាពក្រុមប្រឹក្សាភិបាល នាពេលបច្ចុប្បន្នមានលក្ខណៈគ្រប់គ្រាន់ សម្រាប់ការគ្រប់គ្រងអាជីវកម្មទាំងមូលរបស់ធនាគារ។ សមាជិកក្រុមប្រឹក្សាភិបាលបច្ចុប្បន្ន បាននាំយកនូវចំណេះដឹង បទពិសោធន៍ និងជំនាញដ៏មានតម្លៃមកកាន់ក្រុមប្រឹក្សាភិបាល ដើម្បីដឹកនាំធនាគារ ឆ្ពោះទៅសម្រេចទស្សនវិស័យរបស់ក្រុមហ៊ុនមេ ស៊ីអាយអិមប៊ី គ្រុប (CIMB Group)។

អភិបាលទាំងអស់របស់ធនាគារ សុទ្ធតែបានបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យគ្រប់គ្រាន់ដើម្បីទទួលបានមុខតំណែងជាអភិបាល ដូចមានចែងក្នុងប្រកាសរបស់ធនាគារជាតិនៃកម្ពុជា។ គ្រប់អភិបាលឯករាជ្យទាំងអស់របស់ធនាគារបង្ហាញពីការវិនិច្ឆ័យដោយឯករាជ្យ និងអាចទទួលយកបាន និងមិនចូលរួមក្នុងប្រតិបត្តិការអាជីវកម្មណា ដែលអាចមានផលប៉ះពាល់ដល់ការវិនិច្ឆ័យ និងការធ្វើសេចក្តីសម្រេចដោយឯករាជ្យរបស់ខ្លួន។

ប្រវត្តិសង្ខេបរបស់អភិបាលម្នាក់ៗ មានបង្ហាញនៅលើទំព័រ ៦៨ ដល់ ៧៣ នៃរបាយការណ៍ប្រចាំឆ្នាំនេះ។

ក្រមសីលធម៌របស់អភិបាល

ក្រុមប្រឹក្សាភិបាលគោរពតាមវិធាននៃក្រមសីលធម៌ ដែលមានចែងក្នុងប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា។

អភិបាលធនាគារប្រកាន់ខ្ជាប់នូវក្រមសីលធម៌ ដែលជាគោលការណ៍ណែនាំ សម្រាប់ការអនុវត្តនូវបទដ្ឋានក្រមសីលធម៌មួយដ៏ត្រឹមត្រូវ និងការអនុវត្តអាជីកម្មប្រកបដោយភាពប្រុងប្រយ័ត្ន ក៏ដូចជាបទដ្ឋានអាកប្បកិរិយាប្រកបដោយក្រមសីលធម៌ សម្រាប់អភិបាលម្នាក់ៗ ដោយផ្អែកទៅលើគោលការណ៍សុចរិតភាព ការទទួលខុសត្រូវ ភាពស្មោះត្រង់ និងការទទួលខុសត្រូវចំពោះសង្គម។

កាតព្វកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល គឺជាអង្គភាពមួយរបស់ធនាគារដែលធ្វើសេចក្តីសម្រេចចុងក្រោយបង្អស់ លើកលែងតែបញ្ហាណា ដែលទាមទារឲ្យមានការអនុម័តយល់ព្រមពីភាគទុនិក។ ក្រុមប្រឹក្សាភិបាលដាក់ចេញនូវទិសដៅយុទ្ធសាស្ត្រ និងទស្សនវិស័យរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវទាំងស្រុងលើការដឹកនាំ គ្រប់គ្រង ណែនាំ និងត្រួតពិនិត្យលើគ្រប់ប្រតិបត្តិការទាំងមូលរបស់ធនាគារ និងពង្រឹងបទដ្ឋាននៃគណនេយ្យភាព ក្នុងគោលគំនិតជួយដល់គណៈគ្រប់គ្រង ដើម្បីអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវរួមលើការបង្កើតក្របខណ្ឌការងារនៃអភិបាលកិច្ចល្អ នៅក្នុងធនាគារ រាប់បញ្ចូលទាំងដំណើរការនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាមច្បាប់។ សមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូបនាំយកនូវការវិនិច្ឆ័យឯករាជ្យ ចំណេះដឹងផ្សេងៗគ្នា និងបទពិសោធន៍នានា ដើម្បីធ្វើការពិភាក្សាអំពីបញ្ហានានាទាក់ទងនឹងយុទ្ធសាស្ត្រ ប្រតិបត្តិការ ធនធាន និងការធ្វើអាជីវកម្ម។

ក្រុមប្រឹក្សាភិបាលបានអនុម័តលើរបៀបវារៈនៃបញ្ហាមួយចំនួន ដែលត្រូវបានរៀបចំ សម្រាប់សុំការអនុម័តពីក្រុមប្រឹក្សាភិបាល រាប់បញ្ចូលទាំង (ក្នុងចំណោមចំណុចផ្សេងៗទៀតជាច្រើន) ការត្រួតពិនិត្យឡើងវិញ និងការយល់ព្រមលើចំណុចដូចខាងក្រោម៖

- ផែនការយុទ្ធសាស្ត្រ/អាជីវកម្ម និងគម្រោងថវិកាប្រចាំឆ្នាំ។
- ការវិនិយោគថ្មីៗ ការផ្តាច់ខ្លួន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញក្រុមហ៊ុន ការរៀបចំរចនាសម្ព័ន្ធក្រុមហ៊ុនឡើងវិញ រាប់បញ្ចូលទាំងការបង្កើតក្រុមហ៊ុនបុត្រសម្ព័ន្ធ ការចូលហ៊ុន ឬសម្ព័ន្ធយុទ្ធសាស្ត្រ ទាំងនៅក្នុងស្រុក និងក្រៅស្រុក។
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងភាគលាភបណ្តោះអាសន្ន និងការផ្តល់យោបល់លើភាគលាភចុងក្រោយដែលត្រូវចែកជូនភាគហ៊ុនិក នៅមុនពេលផ្សព្វផ្សាយ និងប្រកាសផ្សាយជាសាធារណៈអំពី ការបែងចែកភាគលាភ។
- ការតែងតាំងអភិបាល និងប្រធាននាយកប្រតិបត្តិថ្មី និងការកំណត់ប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ផ្សេងៗរបស់ពួកគាត់។

ការទទួលខុសត្រូវរួមសំខាន់ៗរបស់ក្រុមប្រឹក្សាភិបាលមានដូចខាងក្រោម៖

- ផ្តល់នូវគោលដៅ និងគោលនយោបាយច្បាស់លាស់សម្រាប់ឲ្យមន្ត្រីប្រតិបត្តិជាន់ខ្ពស់អនុវត្ត។
- ធានាឲ្យមាននូវការត្រួតពិនិត្យគ្រប់គ្រាន់ព្រមទាំងមានប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រាន់ដើម្បីសម្រួលដល់ការអនុវត្តគោលនយោបាយរបស់ធនាគារផងដែរ។
- តាមដាននូវការជោគជ័យរបស់គណៈគ្រប់គ្រងក្នុងការអនុវត្តយុទ្ធសាស្ត្រ ផែនការ និងគម្រោងថវិកាដែលបានអនុម័តរួច។
- ស្វែងយល់ពីហានិភ័យចម្បងៗដែលទាក់ទងនឹងអាជីវកម្មរបស់ធនាគារ និងធានាថាមានប្រព័ន្ធបច្ចេកវិទ្យា ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងលើហានិភ័យប្រកបដោយប្រសិទ្ធភាព ក្នុងទស្សនវិស័យទទួលបានលទ្ធផល និងភាពជោគជ័យរយៈពេលវែងសម្រាប់ធនាគារ។
- តាមដានត្រួតពិនិត្យ និងសិក្សាវាយតម្លៃលើការអភិវឌ្ឍ ដែលអាចជះឥទ្ធិពល ដល់ផែនការយុទ្ធសាស្ត្រនានារបស់ធនាគារ។
- ពិនិត្យឡើងវិញលើភាពគ្រប់គ្រាន់ និងសុចរិតភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ និងប្រព័ន្ធព័ត៌មានគ្រប់គ្រង រាប់បញ្ចូលទាំងប្រព័ន្ធនៃការប្រតិបត្តិតាមវិធានច្បាប់ បទបញ្ជា សារាចរ និងគោលការណ៍ណែនាំនានាជាធរមាន។
- បញ្ជៀសវិវាទផលប្រយោជន៍ និងធានាការផ្សព្វផ្សាយព័ត៌មាន អំពីវិវាទផលប្រយោជន៍ដែលអាចកើតមាន។
- ប្រកាន់ខ្ជាប់ និងអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីធនាគារ ព្រមទាំងច្បាប់ វិធាន និងបទប្បញ្ញត្តិផ្សេងទៀតផងដែរ។

ក្រៅពីការទទួលខុសត្រូវសំខាន់ៗដែលបានរៀបរាប់ខាងលើ ក្រុមប្រឹក្សាភិបាលក៏ប្រគល់ការទទួលខុសត្រូវជាក់លាក់មួយចំនួនឲ្យគណៈកម្មាធិការនានាផងដែរ។ ក្នុងខណៈដែលគណៈកម្មាធិការទាំងនេះមានសិទ្ធិអំណាចពិភាក្សា និងសម្រេចលើបញ្ហាជាក់លាក់ណាមួយ គណៈកម្មាធិការនោះក៏ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល អំពីសេចក្តីសម្រេច និង/ឬអនុសាសន៍របស់ខ្លួន ហើយការទទួលខុសត្រូវចុងក្រោយ ចំពោះបញ្ហាទាំងអស់នោះនៅតែជារបស់ក្រុមប្រឹក្សាភិបាលទាំងមូល។

តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ គណៈកម្មាធិការនានាមានបង្ហាញនៅទំព័រ ៤០ ដល់ ៤៥។

ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល

ធនាគារអនុវត្តតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ ដែលជាគណៈកម្មាធិការមួយរបស់ ស៊ីអាយអិមប៊ី គ្រុប ហូលឌីង ប៊ើហាដ (CIMB Group Holdings Berhad)។ គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការនៃក្រុមហ៊ុនមេ ទទួលបន្ទុកកំណត់ និងបញ្ជូនបេក្ខភាពដែលសក្តិសមសម្រាប់តំណែងអភិបាលទៅក្រុមប្រឹក្សាភិបាល ដើម្បីសុំការអនុម័តយល់ព្រមលើការតែងតាំង មិនថាសម្រាប់បំពេញតំណែងដែលទំនេរ ឬបន្ថែមលើតំណែងដែលមានស្រាប់ ដើម្បីបំពេញតាមតម្រូវការប្រែប្រួលរបស់ធនាគារ។ មុនពេលផ្តល់អនុសាសន៍លើការតែងតាំងអភិបាលទៅ ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការរបស់ក្រុមហ៊ុនមេនឹងអនុវត្តការវាយតម្លៃហ្មត់ចត់ និងគ្រប់ជ្រុងជ្រោយលើបេក្ខភាពជាអភិបាល ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនានា ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ ធនាគារក៏ពិចារណាទៅលើប្រភេទអាជីវកម្មរបស់ធនាគារ និងផ្ទៃរផ្ទងជាមួយសមត្ថភាព និងការរួមចំណែក ដែលរំពឹងទុកពីបេក្ខភាព ដែលទទួលតំណែងនេះផងដែរ។

នីតិវិធីនៃការតែងតាំងត្រូវធ្វើឡើងស្របតាមប្រកាស និងគោលការណ៍ និងនីតិវិធីរបស់ក្រុមហ៊ុនមេ ស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របសម្រាប់បុគ្គលកាន់មុខងារ ដែលមានការទទួលខុសត្រូវសំខាន់របស់ក្រុមហ៊ុន (គោលការណ៍ស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប)។ គោលការណ៍នេះ ចែងនូវនីតិវិធីផ្លូវការមួយសម្រាប់ការតែងតាំងអភិបាល ប្រធានក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ។ បេក្ខភាពនីមួយៗ ត្រូវឆ្លងកាត់ការវាយតម្លៃដែលត្រឹមត្រូវ ហើយគណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការរបស់ក្រុមហ៊ុនមេត្រូវធ្វើការបញ្ជាក់ថា បេក្ខភាពនោះមានលក្ខខណ្ឌសក្តិសម និងត្រឹមត្រូវសម្រាប់មុខតំណែងដែលត្រូវតែងតាំង។

គោលការណ៍ស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប ក៏ចែងអំពីលក្ខណៈវិនិច្ឆ័យមួយចំនួនសម្រាប់ធ្វើការវាយតម្លៃពីភាពសក្តិសមរបស់បេក្ខភាពដែលត្រូវតែងតាំងដូចខាងក្រោម៖

i. សុចរិតភាព ភាពស្មោះត្រង់ និងកេរ្តិ៍ឈ្មោះបុគ្គល ដែលបេក្ខភាពម្នាក់ៗត្រូវមាន ដូចជាមានភាពស្មោះត្រង់ សុចរិតភាព ភាពឧស្សាហ៍ព្យាយាម គំនិតឯករាជ្យ និងមិនលម្អៀង។
ii. សមត្ថភាពដែលបេក្ខជនត្រូវមាន ដូចជាជំនាញ បទពិសោធន៍ការងារ សមត្ថភាព និងការប្តេជ្ញាចិត្ត ដែលចាំបាច់ ដើម្បីអនុវត្តតួនាទីរបស់ខ្លួន។
iii. សុចរិតភាពផ្នែកហិរញ្ញវត្ថុ ដែលបេក្ខជនត្រូវគ្រប់គ្រងឥណទាន ឬកិច្ចការហិរញ្ញវត្ថុរបស់ខ្លួនដោយប្រុងប្រយ័ត្នបំផុត។

នីតិវិធីសម្រាប់កំណត់អត្តសញ្ញាណ និងស្នើឈ្មោះបេក្ខជនដោយគណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការរបស់ក្រុមហ៊ុនមេ សម្រាប់ការតែងតាំងតំណែងនេះមាន ០៥ ដំណាក់កាល ដូចខាងក្រោម៖

ក្របខណ្ឌនៃការស្នើឈ្មោះបេក្ខជន

សំណើសុំតែងតាំងអភិបាលថ្មី គឺអាស្រ័យលើការពិនិត្យ និងអនុម័តយល់ព្រមជាមុនរបស់ធនាគារជាតិ នៃកម្ពុជា។

ការតែងតាំង និងការបោះឆ្នោតជ្រើសតាំងអភិបាលជាថ្មីម្តងទៀត

ជារៀងរាល់ឆ្នាំ នៅក្នុងមហាសន្និបាតប្រចាំឆ្នាំ ១/៣ នៃចំនួនសមាជិកក្រុមប្រឹក្សាភិបាលត្រូវបញ្ចប់តំណែងរបស់ខ្លួន ប៉ុន្តែពួកគាត់នៅតែមានសិទ្ធិអាចឈរឈ្មោះឲ្យគេបោះឆ្នោតសាជាថ្មីបាន នៅក្នុងមហាសន្និបាតប្រចាំឆ្នាំនោះ។ បន្ថែមពីលើនេះទៀត លក្ខន្តិកៈធនាគារត្រូវថា នៅក្នុងរយៈពេល ០៣ ឆ្នាំម្តង អភិបាលទាំងអស់ត្រូវបញ្ចប់ពីមុខតំណែងយ៉ាងហោចណាស់ឲ្យបានម្តង ប៉ុន្តែពួកគាត់នៅមានសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសរើសសាជាថ្មីបាននៅក្នុងមហាសន្និបាតប្រចាំឆ្នាំ។ គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការរបស់ក្រុមហ៊ុនមេ ត្រូវផ្តល់អនុសាសន៍លើសំណើសុំតែងតាំង និងបោះឆ្នោតជ្រើសរើសអភិបាលសាជាថ្មី ជូនក្រុមប្រឹក្សាភិបាល មុននឹងដាក់ជូនភាគទុនិកអនុម័ត នៅក្នុងមហាសន្និបាតប្រចាំឆ្នាំ។

កិច្ចប្រជុំ និងការផ្តល់ព័ត៌មានទៅក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រូវជួបប្រជុំជាប្រចាំ ដើម្បីពិភាក្សាលើយុទ្ធសាស្ត្រអាជីវកម្ម ប្រតិបត្តិការហិរញ្ញវត្ថុ បញ្ហាដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិ និងអភិបាលកិច្ច ក៏ដូចជារបាយការណ៍ស្តីពីបញ្ហាដែលគណៈកម្មាធិការនីមួយៗបានពិភាក្សាគ្នា។ ក្រុមប្រឹក្សាភិបាលជួបប្រជុំយ៉ាងហោចណាស់នៅរៀងរាល់ ០២ ខែម្តង ហើយក្នុងចំណោមរបៀបវារៈទាំងអស់ដែលដាក់ចូលក្នុងកិច្ចប្រជុំដើម្បីទទួលការពិភាក្សា ឬការអនុម័តពីក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាភិបាលពិនិត្យឡើងវិញ លើប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ ការគ្រប់គ្រងហានិភ័យ និងរបាយការណ៍ស្តីពីការអនុវត្តបទប្បញ្ញត្តិ និងធ្វើការអនុម័តលើលទ្ធផលប្រចាំត្រីមាសរបស់ធនាគារ។ ជារៀងរាល់ឆ្នាំ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវបានកំណត់កាលបរិច្ឆេទទុកមុនរួចជាស្រេច ដើម្បីអាចឲ្យអភិបាលទាំងអស់មានភាពងាយស្រួល ក្នុងការរៀបចំធ្វើកាលវិភាគប្រជុំផ្ទាល់ខ្លួនរបស់អភិបាល។ ឯកសារសម្រាប់កិច្ចប្រជុំដែលមានសំណើ និងរបាយការណ៍ផ្សេងៗទៀតត្រូវបានចែកជូនក្រុមប្រឹក្សាភិបាល ឲ្យបានមុនពេលដំណើរការកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដើម្បីអាចឲ្យអភិបាលទាំងអស់មានពេលវេលាគ្រប់គ្រាន់ ក្នុងការធ្វើការវាយតម្លៃលើសំណើទាំងនោះ ហើយប្រសិនបើចាំបាច់ ស្នើសុំព័ត៌មានបន្ថែម ដើម្បីជួយសម្រួលអភិបាល ក្នុងការបំពេញកាតព្វកិច្ចប្រកបដោយប្រសិទ្ធភាព។ នីតិវិធីនានាត្រូវបានបង្កើតឡើងទាក់ទងនឹងទម្រង់ ខ្លឹមសារ បទបង្ហាញ និងការចែកជូនឯកសារសម្រាប់កិច្ចប្រជុំ។ ឯកសារសម្រាប់កិច្ចប្រជុំបញ្ជាក់យ៉ាងច្បាស់អំពីប្រវត្តិ គោលបំណង បញ្ហាសំខាន់ៗ សនិទានភាព ផលប៉ះពាល់ និងព័ត៌មានផ្សេងៗទៀតដែលទាក់ទងនឹងសំណើនីមួយៗ ដើម្បីជួយឲ្យក្រុមប្រឹក្សាភិបាល អាចធ្វើសេចក្តីសម្រេចចិត្តបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព។

អភិបាលមានលទ្ធភាពទទួលបានគ្រប់ព័ត៌មានទាំងអស់របស់ធនាគារ។ តាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដែលធ្វើឡើងជារៀងទាត់ ក្រុមប្រឹក្សាភិបាលទទួលនូវព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពអំពីការអភិវឌ្ឍ និងប្រតិបត្តិការអាជីវកម្មរបស់ធនាគារ ក៏ដូចជាទទួលបានផងដែរនូវឯកសារមួយឈុត រាប់បញ្ចូលទាំងរបាយការណ៍ជារៀងទាត់ ស្តីពីការវិវឌ្ឍនៃអាជីវកម្ម និងឯកសារផ្សេងៗសម្រាប់ពិភាក្សាទាក់ទងនឹងបញ្ហាជាក់លាក់ណាមួយ។

អភិបាលក៏ត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល តាមរយៈប្រព័ន្ធទូរសព្ទផងដែរ។ រាល់ការពិភាក្សាដេញដោលនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល រាប់បញ្ចូលទាំងការខ្វែងគំនិតគ្នា ត្រូវបានកត់ត្រាទុកទាំងស្រុង សម្រាប់ធ្វើជាកំណត់ហេតុ នៃដំណើរការពិភាក្សារបស់អភិបាល។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវបានផ្ញើទៅគណៈគ្រប់គ្រង ក្នុងរយៈពេលមួយថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីកិច្ចប្រជុំត្រូវបានបញ្ចប់ ដើម្បីធានាថា សេចក្តីសម្រេច និងការណែនាំផ្សេងៗ ត្រូវបានអនុវត្តទាន់ពេលវេលា។ សេចក្តីព្រាងកំណត់ហេតុ ត្រូវបានបញ្ជូនទៅអភិបាលទាំងអស់ ដើម្បីធ្វើការពិនិត្យ និងផ្តល់អនុសាសន៍ មុនពេលដាក់បញ្ជូនកំណត់ហេតុចុងក្រោយ ទៅក្នុងរបៀបវារៈសម្រាប់អនុម័ត យល់ព្រម នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលបន្ទាប់។

នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អភិបាលប្រតិបត្តិត្រូវធ្វើការពន្យល់ឲ្យបានក្បោះក្បាយ អំពីបញ្ហាសំខាន់ៗ ទាក់ទងនឹងអាជីវកម្ម និងប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ។ ប្រធានគណៈកម្មាធិការសវនកម្មផ្តល់សេចក្តីសង្ខេបអំពីរបាយការណ៍សវនកម្ម ដែលបានពិភាក្សានៅកិច្ចប្រជុំគណៈកម្មាធិការសវនកម្មដើម្បីជាកំណត់ត្រាសម្រាប់ក្រុមប្រឹក្សាភិបាល ដែលរួមមានលទ្ធផលសវនកម្មសំខាន់ៗដែលធ្វើឡើងដោយសវនករផ្ទៃក្នុង ដើម្បីឲ្យក្រុមប្រឹក្សាភិបាលធ្វើការពិភាក្សា និងណែនាំ។ បន្ថែមពីលើនេះទៀត របាយការណ៍ពីនាយកនៃនាយកដ្ឋានប្រតិបត្តិតាម អំពីស្ថានភាពនៃការគោរពច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ និងនីតិវិធីផ្ទៃក្នុងដែលបានអនុម័តដោយធនាគារ ក៏ត្រូវបានរាយការណ៍ជូនក្រុមប្រឹក្សាភិបាលដើម្បីជ្រាបជាព័ត៌មានផងដែរ។ គណៈគ្រប់គ្រងក៏ត្រូវបានអញ្ជើញឲ្យធ្វើបទបង្ហាញអំពីសំណើ និងឆ្លើយតបសំណួរផ្សេងៗដែលក្រុមប្រឹក្សាភិបាលចោទសួរ តាមការចាំបាច់ផងដែរ។ គណៈគ្រប់គ្រងត្រូវចាត់វិធានការជាបន្ទាន់លើរាល់បញ្ហា ដែលលើកឡើងនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងត្រូវធ្វើបច្ចុប្បន្នភាពទៅក្រុមប្រឹក្សាភិបាលអំពីស្ថានភាពនៃបញ្ហាទាំងនោះ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកក្រោយ ឬ ប្រសិនបើយល់ថា បន្ទាន់ ត្រូវបញ្ជូនតាមការជូនដំណឹងជាលាយលក្ខណ៍អក្សរ។

អភិបាលណាម្នាក់ដែលមានជាប់ពាក់ព័ន្ធទទួលបានផលប្រយោជន៍ពីសំណើណាមួយ ឬប្រតិបត្តិការណាមួយ ត្រូវប្រកាសប្រាប់អំពីផលប្រយោជន៍ដែលពាក់ព័ន្ធនឹងខ្លួន ហើយត្រូវដកខ្លួនចេញពីការពិភាក្សា និងការបោះឆ្នោតគាំទ្រសំណើ ឬកិច្ចការដែលបានស្នើនោះ។ នីតិវិធីនេះត្រូវបានកត់ត្រាទុកទាំងស្រុង នៅក្នុងកំណត់ហេតុនៃដំណើរការកិច្ចប្រជុំ។

នៅដើមឆ្នាំហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលពិចារណាលើថវិកាប្រចាំឆ្នាំរបស់ធនាគារ ស្របជាមួយនឹងយុទ្ធសាស្ត្រ និងផែនការរបស់ធនាគារ ដែលបានបង្កើតឡើង នៅក្នុងកិច្ចប្រជុំពិភាក្សាថ្នាក់គ្រប់គ្រងប្រចាំឆ្នាំ។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលសរុបចំនួន ០៧ លើក ត្រូវបានរៀបចំឡើងនៅឆ្នាំ២០២០ ដោយមានវត្តមានរបស់អភិបាល ដូចមានរៀបរាប់ខាងក្រោម៖

	ចំនួនកិច្ចប្រជុំ	
អភិបាល	**បានចូលរួម**	**ចំនួនកិច្ចប្រជុំ**
Datuk Mohd Nasir Bin Ahmad ប្រធានក្រុមប្រឹក្សាភិបាល/អភិបាលឯករាជ្យមិនប្រតិបត្តិ	៧	៧
បណ្ឌិត ម៉ី កល្យាណ អភិបាលឯករាជ្យមិនប្រតិបត្តិ	៧	៧
Aisyah Lam Binti Adbullah អភិបាលឯករាជ្យមិនប្រតិបត្តិ	៧	៧
Omar Siddiq Bin Amin Noer Rashid អភិបាលមិនឯករាជ្យមិនប្រតិបត្តិ	៦	៧
Ahmad Shazli Bin Kamarulzaman អភិបាលមិនឯករាជ្យមិនប្រតិបត្តិ	៧	៧
ប៊ុន យ៉ីន អភិបាលមិនឯករាជ្យប្រតិបត្តិ និងជាប្រធាននាយកប្រតិបត្តិ	៧	៧

ការបណ្តុះបណ្តាល និងការអភិវឌ្ឍរបស់អភិបាល

កម្មវិធីបណ្តុះបណ្តាលអភិបាល គឺជាដំណើរការដ៏សំខាន់មួយក្នុងការតែងតាំងអភិបាលថ្មី ហើយក្រុមប្រឹក្សាភិបាលក៏ត្រូវយកចិត្តទុកដាក់លើតម្រូវការក្នុងការយល់ដឹងអំពីច្បាប់ និងបទប្បញ្ញត្តិថ្មីៗ បទដ្ឋានគណនេយ្យ ការប្រែប្រួលហានិភ័យអាជីវកម្ម និន្នាការទីផ្សារ និងការវិវឌ្ឍចុងក្រោយ បញ្ហាប្រឈមសំខាន់ៗនៅក្នុងទីផ្សារក្នុងស្រុក និងក្នុងតំបន់ និងក្នុងវិស័យធនាគារ។ ក្នុងគោលបំណងនេះ ក្រុមប្រឹក្សាភិបាលធ្វើការវាយតម្លៃលើតម្រូវការបណ្តុះបណ្តាល ដោយឈរលើមូលដ្ឋាន វាយតម្លៃតាមដំណាក់កាល ហើយកំណត់អំពីចំណុច ដែលអាចពង្រីកចំណេះដឹងរបស់អភិបាលអំពីបញ្ហា ដែលទាក់ទងនឹងធនាគារ។

វគ្គបណ្តុះបណ្តាល ដែលអភិបាលបានចូលរួម ដើម្បីអភិវឌ្ឍចំណេះដឹងថ្មីៗ៖

ប្រធានបទ	ប្រភេទវគ្គបណ្តុះបណ្តាល	ចំនួនម៉ោង/ថ្ងៃ	ចូលរួមដោយ
CIMB INSEAD Leadership Programme (CLP) Cohort 8	កិច្ចប្រជុំ (ជាសមាជិក)	៥ ម៉ោង	Datuk Mohd Nasir Bin Ahmad
PwC COVID-19 Webinar: Cyber and economic crime: Fraudsters and cyber criminals, too, can work from home	សិក្ខាសាលា (ជាអ្នកចូលរួម)	២ ម៉ោង	
FIDE FORUM Webinar «Outthink The Competition: Excelling in a Post Covid-19 World»	វេទិកា (ជាអ្នកចូលរួម)	២ ម៉ោង	
Webinar: A Conversation with Senator YB Tengku Datuk Seri Zafrul Tengku Abdul Aziz, Minister of Finance, Malaysia	កិច្ចពិភាក្សា (ជាអ្នកចូលរួម)	២ ម៉ោង	
ACCA-ICDM Inspiring Director Programme	កម្មវិធីសិក្សា (ជាវាគ្មិន)	២ ម៉ោង	
FIDE Forum: 4th Distinguished Board Leadership Series - Risk: A Fresh Look from the Board's Perspective	វេទិកា (ជាអ្នកចូលរួម)	២ ម៉ោង	
Invest Malaysia 2020: Powering Malaysia's Growth Engines	សន្និសីទ (ជាអ្នកចូលរួម)	៤ ម៉ោង	
Accountant General's Leadership Sharing Session	ផ្សេងៗ (ជាវាគ្មិន)	២ ម៉ោង	
CIMB: Risk Posture Workshop	សិក្ខាសាលា (ជាអ្នកចូលរួម)	២ ម៉ោង	
CIMB: The Cooler Earth Summit - Profit with a Purpose	សន្និសីទ (ជាអ្នកចូលរួម)	៣ ម៉ោង	
CIMB: The Cooler Earth Experiential Event, Taman Tugu Nature Education Walk	សន្និសីទ (ជាអ្នកចូលរួម)	២ ម៉ោង	
Sharing Session with Prokhas: Leading With Integrity	កិច្ចពិភាក្សា (ជាវាគ្មិន)	១ ម៉ោង	
AML Training for Directors	កម្មវិធីសិក្សា (ជាអ្នកចូលរួម)	៣ ម៉ោង	
The Cooler Earth Sustainability Summit: Advancing Customers and Society	សន្និសីទ (ជាវាគ្មិន)	២ ម៉ោង	
APEC CEO Dialogues 2020	សន្និសីទ (ជាអ្នកចូលរួម)	១,៥ ម៉ោង	
ICDM Members' Day: Bounce Back Together II: Reimagine and Rebuild	វេទិកា (ជាវាគ្មិន)	២ ម៉ោង	
Sustainability Training by UNEP FI & WWF	កម្មវិធីសិក្សា (ជាអ្នកចូលរួម)	៣ ម៉ោង	
CIMB: The Cooler Earth Summit - Profit with a Purpose	សន្និសីទ (ជាអ្នកចូលរួម)	៣ ម៉ោង	លោកស្រី Aisyah Lam Binti Abdullah
The Cooler Earth Sustainability Summit: Advancing Customers and Society	សន្និសីទ (ជាអ្នកចូលរួម)	២ ម៉ោង	
Sustainability Leadership Training 2020	កម្មវិធីសិក្សា	២,៥ ម៉ោង	លោក Omar SIddiq Amin Noer Rashid
Anti-Money Laundering / Counter Financing Terrorism	កម្មវិធីសិក្សាតាមប្រព័ន្ធអេឡិកត្រូនិក	៤ ម៉ោង	លោក Ahmad Shazli Bin Kamarulzaman
Business Continuity Management Awareness	កម្មវិធីសិក្សាតាមប្រព័ន្ធអេឡិកត្រូនិក	៤ ម៉ោង	
Data Protection	កម្មវិធីសិក្សាតាមប្រព័ន្ធអេឡិកត្រូនិក	៤ ម៉ោង	
Information Security Awareness	កម្មវិធីសិក្សាតាមប្រព័ន្ធអេឡិកត្រូនិក	៤ ម៉ោង	
BU: Make It Rain Webinar - Kopi with Zen	សិក្ខាសាលា	២,៥ ម៉ោង	
Future of Work Centre (FOWC) Town Hall	ផ្សេងៗ	១,៥ ម៉ោង	
Anti-Money Laundering / Counter Financing Terrorism	កម្មវិធីសិក្សាតាមប្រព័ន្ធអេឡិកត្រូនិក	៤ ម៉ោង	លោក ប៊ុន យ៉ីន

ក្នុងអំឡុងឆ្នាំដែលស្ថិតក្រោមការត្រួតពិនិត្យ ការធ្វើបច្ចុប្បន្នភាពជាទៀងទាត់លើការវិវឌ្ឍផ្នែកច្បាប់ ការផ្សព្វផ្សាយ ព័ត៌មាន និងបទដ្ឋានគណនេយ្យ អភិបាលកិច្ចក្រុមហ៊ុន និងការអនុវត្តល្អបំផុត ក៏ត្រូវបានផ្តល់ជូនសម្រាប់អភិបាលផងដែរ។

លេខាធិការក្រុមហ៊ុន

លេខាធិការក្រុមហ៊ុន បង្ហាញពីការគាំទ្រជាបន្តបន្ទាប់ក្នុងការផ្តល់យោបល់ និងជួយក្រុមប្រឹក្សាភិបាល លើបញ្ហាដែលទាក់ទងនឹងកិច្ចការរបស់ធនាគារ រាប់បញ្ចូលទាំងបញ្ហាដែលទាក់ទងនឹងការអនុវត្តស្របតាមបទប្បញ្ញត្តិរបស់ក្រុមហ៊ុន អភិបាលកិច្ចក្រុមហ៊ុន និងការអនុវត្តល្អបំផុត ប្រសិទ្ធភាពនៃសាលប្រជុំ និងកាតព្វកិច្ច និងការទទួលខុសត្រូវរបស់អភិបាល។ ក្នុងអំឡុងឆ្នាំដែលស្ថិតក្រោមការត្រួតពិនិត្យ ដំណើរការផ្សេងៗរបស់ក្រុមប្រឹក្សាភិបាលត្រូវបានពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ជាមួយនឹងទស្សនៈលើកកម្ពស់ដំណើរការនៃការធ្វើសេចក្តីសម្រេច និងប្រសិទ្ធភាពនៃមុខងារក្រុមប្រឹក្សាភិបាល។

លេខាធិការក្រុមហ៊ុនធានាថា កិច្ចប្រជុំក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងភាគទុនិកត្រូវបានរៀបចំឡើងស្របតាមវិធានច្បាប់ និងការអនុវត្តល្អបំផុតរបស់ធនាគារ ហើយធានាថាការកត់ត្រាដំណើរការកិច្ចប្រជុំក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងភាគទុនិក ត្រូវបានកត់ត្រាទុកទាំងស្រុង សម្រាប់ធ្វើជាកំណត់ហេតុ និងរក្សាទុកបានយ៉ាងល្អ។

លេខាធិការក្រុមហ៊ុន ក្រៅពីចូលរួមជួយការងារប្រធានក្រុមប្រឹក្សាភិបាល ក្នុងការរៀបចំរបៀបវារៈ និងរៀបចំដំណើរការកិច្ចប្រជុំក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងភាគទុនិក ក៏ត្រូវសម្របសម្រួលការទំនាក់ទំនង និងផ្សព្វផ្សាយសេចក្តីសម្រេចសំខាន់ៗ និងគោលការណ៍នានា រវាងក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនានា និងថ្នាក់គ្រប់គ្រងប្រតិបត្តិជាន់ខ្ពស់ផងដែរ។

អភិបាលទាំងអស់មានលទ្ធភាពពេញលេញក្នុងការស្នើយោបល់ពីលេខាធិការក្រុមហ៊ុន និងអាចស្វែងរកការពិគ្រោះយោបល់បែបវិជ្ជាជីវៈដោយឯករាជ្យពីប្រភពខាងក្រៅ ក្រោមបន្ទុកចំណាយរបស់ធនាគារ ដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ នីតិវិធីមួយត្រូវបានអនុម័តឡើង ដើម្បីជួយសម្រួលអភិបាលក្នុងការស្វែងរកការពិគ្រោះយោបល់បែបវិជ្ជាជីវៈដោយឯករាជ្យ។

គណៈកម្មាធិការនានា

ក្រុមប្រឹក្សាភិបាល ផ្ទេរការទទួលខុសត្រូវជាក់លាក់ដល់គណៈកម្មាធិការនានា ដែលរួមមានគណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការហានិភ័យ។ គណៈកម្មាធិការទាំងនេះធ្វើប្រតិបត្តិការតាមតួនាទី និងកាតព្វកិច្ច ដែលបានកំណត់យ៉ាងច្បាស់លាស់ ដូចមានចែងនៅក្នុងតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការនីមួយៗ ដែលបានអនុម័តយ៉ាងត្រឹមត្រូវ។

គណៈកម្មាធិការត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីកិច្ចពិភាក្សា សេចក្តីសម្រេច និងអនុសាសន៍របស់ខ្លួន។ ប្រធានគណៈកម្មាធិការសវនកម្ម និងប្រធានគណៈកម្មាធិការហានិភ័យ ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីបញ្ហាដែលបានលើកយកមកពិភាក្សា និងដោះស្រាយនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការរបស់ខ្លួន។ ក្រុមប្រឹក្សាភិបាលបានទទួលស្គាល់ថា ខណៈដែលគណៈកម្មាធិការទាំងនេះមានសិទ្ធិអំណាចធ្វើការពិភាក្សាលើបញ្ហានានា ដែលបានប្រគល់ជូនរាល់សេចក្តីសម្រេច និង/ឬអនុសាសន៍របស់គណៈកម្មាធិការទាំងនេះ ត្រូវបញ្ជូនទៅក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យ ហើយគណៈកម្មាធិការទាំងនេះ និងក្រុមប្រឹក្សាភិបាល ជារួមទទួលខុសត្រូវលើភាពជោគជ័យ អាជីវកម្ម យុទ្ធសាស្ត្រ ការគ្រប់គ្រងហានិភ័យ សកម្មភាពប្រតិបត្តិការអាជីវកម្ម និងប្រតិបត្តិការហិរញ្ញវត្ថុរបស់ធនាគារ។

ព័ត៌មានលម្អិតអំពីគណៈកម្មាធិការនានា មានបង្ហាញនៅក្នុងផ្នែកខាងក្រោមជាបន្តបន្ទាប់។

គណៈកម្មាធិការសវនកម្ម

សមាជិកគណៈកម្មាធិការសវនកម្មសុទ្ធតែជាអភិបាលឯករាជ្យមិនប្រតិបត្តិ ដែលមានចំណេះដឹង និងបទពិសោធន៍ ផ្នែកហិរញ្ញវត្ថុ។

ការទទួលខុសត្រូវចម្បងរបស់គណៈកម្មាធិការសវនកម្ម គឺធានាឲ្យមានការអនុវត្តអភិបាលកិច្ចរបស់ធនាគារបានល្អប្រសើរ ស្របពេលដែលធ្វើការពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ការផ្សព្វផ្សាយព័ត៌មាន ការគោរពបទប្បញ្ញត្តិច្បាប់ ការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងដំណើរការប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។ គណៈកម្មាធិការសវនកម្ម ជួបប្រជុំជាប្រចាំ ដើម្បីពិនិត្យលើលទ្ធផលការងារប្រចាំត្រីមាស របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ របាយការណ៍សវនកម្ម ដែលរាប់បញ្ចូលទាំងការអនុវត្ត ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ក៏ដូចជាប្រតិបត្តិការជាមួយភាគីសម្ព័ន្ធញាតិ។

គណៈកម្មាធិការសវនកម្មបានជួបប្រជុំចំនួន ០៧ ដង ក្នុងឆ្នាំ២០២០ ដែលមានវត្តមានសមាជិកចូលរួមដូចខាងក្រោម៖

	ចំនួនកិច្ចប្រជុំ	
សមាជិក	**បានចូលរួម**	**ចំនួនកិច្ចប្រជុំ**
បណ្ឌិត ម៉ី កល្យាណ ប្រធានគណៈកម្មាធិការសវនកម្ម/អភិបាលឯករាជ្យ មិនប្រតិបត្តិ	៧	៧
Datuk Mohd Nasir Bin Ahmad អភិបាលឯករាជ្យមិនប្រតិបត្តិ	៧	៧
លោកស្រី Aisyah Lam Binti Abdullah អភិបាលឯករាជ្យមិនប្រតិបត្តិ	៧	៧

តួនាទី និងកាតព្វកិច្ចរបស់គណៈកម្មាធិការសវនកម្មមានដូចខាងក្រោម៖

ចំណុចគន្លឹះនៃការទទួលខុសត្រូវ	**ការទទួលខុសត្រូវ**
ការត្រួតពិនិត្យផ្ទៃក្នុង/ការគ្រប់គ្រងហានិភ័យ/អភិបាលកិច្ច	ពិនិត្យឡើងវិញ លើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដំណើរការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចក្នុងសម្ព័ន្ធធនាគារ ស្របតាមលក្ខខណ្ឌតម្រូវនៅក្នុងប្រកាសស្តីពី អភិបាលកិច្ចនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។
សវនកម្មផ្ទៃក្នុង	ក. ធានាថា មុខងារសវនកម្មផ្ទៃក្នុងបានរៀបចំល្អប្រសើរ ដើម្បីធ្វើការត្រួតពិនិត្យ ឬអង្កេតក្នុងនាមគណៈកម្មាធិការសវនកម្ម ហើយមុខងារនេះត្រូវស្ថិតនៅក្រោមអំណាចនិងការគ្រប់គ្រងផ្ទាល់ពីគណៈកម្មាធិការសវនកម្ម។ ខ. ពិនិត្យ និងអនុម័តវិសាលភាពការងារសវនកម្មផ្ទៃក្នុង នីតិវិធី ចំនួនដងនៃការធ្វើសវនកម្មផ្ទៃក្នុង និងគម្រោងសវនកម្មប្រចាំឆ្នាំ។ គ. មើលការខុសត្រូវលើប្រសិទ្ធភាពនៃមុខងារសវនកម្មផ្ទៃក្នុង សមត្ថភាពបុគ្គលិក និងភាពគ្រប់គ្រាន់នៃធនធានរបស់សវនកម្មផ្ទៃក្នុង និងពិនិត្យមើលថាតើមុខងារនោះបានទទួលអំណាចចាំបាច់ ដើម្បីបំពេញការងារឬនៅ។ ឃ. ពិនិត្យរបាយការណ៍សំខាន់ៗ និងធានាថាគណៈគ្រប់គ្រងចាត់វិធានការណ៍កែតម្រូវទាន់ពេលវេលា ដើម្បីដោះស្រាយចំណុចខ្សោយក្នុងការគ្រប់គ្រង ការមិនបានអនុវត្តពេញលេញតាមគោលនយោបាយ ការតម្រូវរបស់ច្បាប់ និងបទប្បញ្ញត្តិនានា និងបញ្ហាផ្សេងទៀតដែលរកឃើញដោយសវនករផ្ទៃក្នុង ក៏ដូចជាផ្នែកដែលទទួលខុសត្រូវការគ្រប់គ្រងផ្ទៃក្នុងដទៃទៀត។ ង. កត់សម្គាល់ការមិនឯកភាពសំខាន់ៗរវាងនាយកសវនកម្មផ្ទៃក្នុង និងគណៈគ្រប់គ្រងដទៃទៀត មិនថាការមិនឯកភាពនោះត្រូវបានដោះស្រាយរួច ដើម្បីកំណត់ផលប៉ះពាល់ដែលការមិនឯកភាពទាំងនោះអាចមានចំពោះដំណើរការសវនកម្ម ឬលទ្ធផលសវនកម្មដែលលើកឡើងដោយសវនករ។ ច. ធានាការគោរពតាមច្បាប់ និងបទប្បញ្ញត្តិដែលអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងធានាថារបាយការណ៍របស់សវនករផ្ទៃក្នុងនឹងមិនតម្រូវឲ្យត្រួតពិនិត្យដោយគណៈគ្រប់គ្រងឡើយ។ ឆ. បង្កើតយន្តការដើម្បីវាយតម្លៃការបំពេញតួនាទី និងប្រសិទ្ធភាពរបស់មុខងារសវនកម្មផ្ទៃក្នុង។ ជ. វាយតម្លៃសកម្មភាពប្រតិបត្តិការ និងធ្វើសេចក្តីសម្រេចអំពីកញ្ចប់តម្លៃការរបស់នាយកសវនកម្មផ្ទៃក្នុង។ ឈ. អនុម័តលើការតែងតាំង ផ្លាស់ប្តូរ និងបណ្តេញចេញនាយកសវនកម្មផ្ទៃក្នុង ឬ បុគ្គលិកជាន់ខ្ពស់ដែលបំពេញមុខងារជាសវនករផ្ទៃក្នុង និងត្រូវទទួលការជូនដំណឹងអំពីការលាឈប់របស់បុគ្គលិកជាន់ខ្ពស់ជា សវនករផ្ទៃក្នុង ហើយត្រូវផ្តល់ឱកាសឲ្យសមាជិកដែល បានដាក់ពាក្យលាឈប់នោះបញ្ជាក់ប្រាប់ពីមូលហេតុនៃការលាឈប់។
សវនកម្មខាងក្រៅ	ក. ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលលើការតែងតាំង ឬការបញ្ឈប់សវនករខាងក្រៅ។ ខ. ពិភាក្សា និងពិនិត្យមើលឡើងវិញជាមួយសវនករខាងក្រៅមុននឹងចាប់ផ្តើមធ្វើសវនកម្មអំពីលក្ខណៈ និងទំហំការងារសវនកម្ម ហើយធានាលើការសម្របសម្រួលក្នុងករណីមាន ក្រុមហ៊ុនសវនកម្មច្រើនចូលរួម។ គ. វាយតម្លៃអំពីគោលដៅ ការបំពេញការងារ និង ឯកភាពរបស់សវនករខាងក្រៅ (ឧទាហរណ៍ ដោយការពិនិត្យ និងវាយតម្លៃពីទំនាក់ទំនងផ្សេងៗរវាងសវនករខាងក្រៅ និងធនាគារ)។

	យ. អនុម័តលើការផ្តល់សេវាដែលមិនទាក់ទងនឹងការងារសវនកម្មដែលផ្តល់ដោយសវនករខាងក្រៅ និងតាមដាន និងធ្វើការវាយតម្លៃថាតើសេវានោះអាចនឹងប៉ះពាល់ដល់ឯករាជ្យភាពរបស់ពួកគាត់ឬទេ។ ង. ធានាថា មានការពិនិត្យច្បាស់លាស់លើលក្ខខណ្ឌនៃការផ្តល់សេវាដែលមិនទាក់ទងនឹងការងារសវនកម្ម ដើម្បីចៀសវាងការប៉ះពាល់ដល់ការវិនិច្ឆ័យ ប្រកបដោយឯករាជ្យភាពរបស់សវនករខាងក្រៅ។ ច. ធានាថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ និងទាន់ពេលវេលា ដោយមានការត្រួតពិនិត្យឡើងវិញជាប្រចាំ លើភាពគ្រប់គ្រាន់នៃការធ្វើសំវិធានធនដែលចាំបាច់ និងចំពោះបំណុលអាក្រក់ និងសង្ស័យ។ ឆ. រក្សាការទំនាក់ទំនងស្មោះត្រង់ បើកចំហ ទាន់ពេលវេលា និងទៀងទាត់ ជាមួយសវនករខាងក្រៅ និងតម្រូវឲ្យសវនករខាងក្រៅរាយការណ៍មកកាន់គណៈកម្មាធិការសវនកម្មអំពីបញ្ហាសំខាន់ៗ (ដោយមិនមានវត្តមានរបស់គណៈគ្រប់គ្រង ប្រសិនបើចាំបាច់)។ ជ. ពិនិត្យឡើងវិញលើរបាយការណ៍គ្រប់គ្រងផ្ទៃក្នុងរបស់សវនករខាងក្រៅ និងធានាថាគណៈគ្រប់គ្រងចាត់វិធានការណ៍កែតម្រូវដើម្បីឆ្លើយតបទៅនឹងលទ្ធផលសវនកម្មខាងក្រៅ និងអនុសាសន៍ដែលលើកឡើងដោយសវនករខាងក្រៅ ទាន់ពេលវេលា។ ឈ. តាមដាន និងវាយតម្លៃប្រសិទ្ធភាពការងាររបស់សវនករខាងក្រៅ រួមទាំងជួបប្រជុំជាមួយសវនករខាងក្រៅយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ដោយមិនមានវត្តមានរបស់គណៈគ្រប់គ្រង ដើម្បីពិភាក្សាលើបញ្ហាគន្លឹះសំខាន់ៗ និងស្នើសុំយោបល់ពីសវនករខាងក្រៅវិញ។
លទ្ធផលសវនកម្ម ការត្រួតពិនិត្យផ្ទៃក្នុង និងបញ្ហានៃការប្រតិបត្តិតាមច្បាប់	ពិនិត្យឡើងវិញលើលទ្ធផលនៃការអង្កេតសំខាន់ៗ លទ្ធផលសវនកម្មជាប្រចាំ និងការត្រួតពិនិត្យផ្ទៃក្នុង និងការប្រតិបត្តិតាមច្បាប់ដែលរាយការណ៍ដោយសវនករផ្ទៃក្នុង សវនករខាងក្រៅ និងសវនករបស់និយ័តករ។
របាយការណ៍ហិរញ្ញវត្ថុ	ពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆ្នាំ មុនពេលទទួលការអនុម័តពីក្រុមប្រឹក្សាភិបាល ដោយផ្តោតសំខាន់លើ៖ • ការផ្លាស់ប្តូរណាមួយនៅក្នុងការអនុវត្ត និងគោលការណ៍គណនេយ្យ • បញ្ហាសំខាន់ៗដែលបានលើកឡើង រួមទាំងបញ្ហាទាក់ទងនឹងការរាយការណ៍ហិរញ្ញវត្ថុ ការវិនិច្ឆ័យសំខាន់ៗរបស់គណៈគ្រប់គ្រង ព្រឹត្តិការណ៍ឬប្រតិបត្តិការមិនប្រក្រតី និងសំខាន់ៗ និងរបៀបដែលបញ្ហាទាំងអស់ត្រូវបានបង្ហាញ • ការធ្វើសេចក្តីសន្និដ្ឋានពីបញ្ហាដែលកំពុងកើតឡើង និង • ការប្រតិបត្តិតាមស្តង់ដារគណនី និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ និងបទប្បញ្ញត្តិច្បាប់ដទៃផ្សេងទៀត
ប្រតិបត្តិការរបស់ភាគីសម្ព័ន្ធញាតិ	ពិនិត្យរាល់ប្រតិបត្តិការធ្វើឡើងជាមួយភាគីសម្ព័ន្ធញាតិ និងជូនដំណឹងដល់ក្រុមប្រឹក្សាភិបាលពីប្រតិបត្តិការទាំងនោះ។
ការពិនិត្យរបាយការណ៍ ពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ	ពិនិត្យភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់នៃសេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល នៅក្នុងរបាយការណ៍ក្រុមប្រឹក្សាភិបាល ការបង្ហាញពីអភិបាលកិច្ចធនាគារ របាយការណ៍ហិរញ្ញវត្ថុ និងសេចក្តីប្រកាសដំបូង ពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។
ការតាមដានការអនុវត្ត តាមគោលនយោបាយ ទំនាស់ផលប្រយោជន៍	តាមដានការអនុវត្តតាមគោលនយោបាយ ស្តីពីទំនាស់ផលប្រយោជន៍របស់ធនាគារ
ការពិនិត្យក្របខណ្ឌគ្រប់គ្រងផ្ទៃក្នុង	ពិនិត្យមតិយោបល់របស់ភាគីទីបី ចំពោះរចនាសម្ព័ន្ធ និងប្រសិទ្ធភាពនៃក្របខណ្ឌគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារ
ផ្សេងៗ	ក. ជូនដំណឹងដល់គណៈគ្រប់គ្រងជាន់ខ្ពស់ជាទៀងទាត់ អំពីបញ្ហាដែលប៉ះពាល់ដល់ធនាគារ។ ខ. កោះប្រជុំជាមួយសវនករផ្ទៃក្នុង សវនករខាងក្រៅ ឬទាំងពីរក្នុងពេលតែមួយ បើយល់ថា ចាំបាច់។ គ. ពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស និងប្រចាំឆ្នាំ សម្រាប់ដាក់បញ្ជូនទៅឲ្យក្រុមប្រឹក្សាភិបាលរបស់ធនាគារ និងធានានូវការបោះពុម្ពផ្សាយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំបានរហ័ស។

គណៈកម្មាធិការហានិភ័យ

ការទទួលខុសត្រូវចម្បងរបស់គណៈកម្មាធិការហានិភ័យ គឺត្រូវធានាថាមុខងារគ្រប់គ្រងហានិភ័យ ដែលត្រូវបានដាក់បញ្ចូលនៅក្នុងធនាគារ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ គណៈកម្មាធិការហានិភ័យត្រូវរាយការណ៍ទៅក្រុមប្រឹក្សាភិបាល នូវរាល់បញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យ នៅក្នុងធនាគារ។

គណៈកម្មាធិការហានិភ័យបានជួបប្រជុំចំនួន ១២ ដង ក្នុងឆ្នាំ២០២០ ដែលមានវត្តមានសមាជិកចូលរួមដូចខាងក្រោម៖

សមាជិក	ចំនួនកិច្ចប្រជុំ	
	បានចូលរួម	ចំនួនកិច្ចប្រជុំ
Aisyah Lam Binti Abdullah ប្រធានគណៈកម្មាធិការ/អភិបាលឯករាជ្យមិនប្រតិបត្តិ	១២	១២
ប៊ុន យ៉ីន ប្រធាននាយកប្រតិបត្តិ	១២	១២
គឿន រ៉ូឌ្ឍនា នាយកគ្រប់គ្រងហានិភ័យ	១១	១២
ហុង ជឿប នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម	១១	១២
ហេង ធីតា នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល	១២	១២
ហេង រ៉ៃត្រ នាយកបច្ចេកវិទ្យា និងប្រតិបត្តិការ	១១	១២
ហេង រ៉ុទ្ធី នាយកហិរញ្ញវត្ថុ	១០	១២
គី សាណា នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ	១១	១២

តួនាទី និងការកិច្ចរបស់គណៈកម្មាធិការហានិភ័យមានដូចខាងក្រោម៖

ចំណុចគន្លឹះនៃការទទួលខុសត្រូវ	ការទទួលខុសត្រូវ
ការគ្រប់គ្រងដើមទុន	• បែងចែកដើមទុនដែលមានហានិភ័យ (Capital-at-Risk) ទៅតាមប្រភេទជំនួញ និងហានិភ័យផ្សេងៗពីគ្នា ដើម្បីធានាថា ការបែងចែកហានិភ័យបានធ្វើគ្រប់គ្រាន់ អនុលោមតាមលក្ខខណ្ឌកំណត់ដោយបទប្បញ្ញត្តិច្បាប់ និងធានាថាធនាគារមានដើមទុនបម្រុងគ្រប់គ្រាន់ ដើម្បីប្រឈមមុខនឹងស្ថានភាពវិបត្តិផ្សេងៗ។ • បង្កើនតម្លៃភាគទុនិក តាមរយៈការវាយតម្លៃលើប្រាក់ចំណេញ និងហានិភ័យ (risk-return profiles) ពីដំណើរការប្រតិបត្តិការ ហើយធានាថាកម្រិតហានិភ័យ ដែលទទួលយកស្ថិតនៅក្នុងដែនកម្រិតដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារ។
គោលការណ៍គ្រប់គ្រងហានិភ័យ	• ពិនិត្យ និងជូនយោបល់ដល់ក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការអនុម័តលើគោលការណ៍ និងកម្រិតហានិភ័យដែលសមស្រប ដើម្បីរក្សាក្របខណ្ឌនៃការគ្រប់គ្រងហានិភ័យឲ្យស្របតាមផែនការអាជីវកម្មរបស់ធនាគារ ក្របខណ្ឌនៃ EWRM របស់ក្រុមហ៊ុនមេ និងស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលបានកំណត់។ • វាយតម្លៃ និងពិនិត្យលើសំណើសុំអនុម័តសម្រាប់ផលិតផលថ្មី ការវិនិយោគ អាជីវកម្ម យុទ្ធសាស្ត្រ និងផលិតផល ដែលត្រូវបានកែច្នៃ ដែលត្រូវអនុម័តជាគោលការណ៍ ឬផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលដើម្បីធ្វើការអនុម័ត។ • ពិនិត្យ និងអនុម័តលើសំណើកែប្រែតិវិធី និងដំណើរការប្រតិបត្តិការ។
ការប្រតិបត្តិតាម	• ជំរុញលើការគោរពតាមគោលការណ៍ និងកម្រិតហានិភ័យ។
ការកំណត់ និងវាស់វែងហានិភ័យ	• ដាក់ឲ្យប្រើប្រាស់នូវវិធីសាស្ត្រដ៏សមស្រប ដើម្បីកំណត់ និងវាស់វែងហានិភ័យគ្រប់ស្ថានភាព។ • បង្កើតយុទ្ធសាស្ត្រសម្រាប់វាយតម្លៃ ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យឲ្យស្ថិតក្នុងកម្រិតមួយដ៏សមស្រប។ • ពិភាក្សាសម្រេចលើវិធីសាស្ត្រ និងឧបករណ៍ សម្រាប់ធ្វើការវាស់វែងទៅលើបរិមាណហានិភ័យផ្សេងៗ ដើម្បីសុំការអនុម័តពីក្រុមប្រឹក្សាភិបាល។
ហានិភ័យបច្ចេកវិទ្យា	• ត្រួតពិនិត្យជាប្រចាំ លើបញ្ហាដែលទាក់ទងនឹងហានិភ័យបច្ចេកវិទ្យា ដែលរួមមានសុវត្ថិភាពបច្ចេកវិទ្យា និងហានិភ័យអ៊ីនធើណេត និងទម្រង់គ្រប់គ្រងហានិភ័យបច្ចេកវិទ្យា និងឧប្បត្តិហេតុធ្ងន់ធ្ងរ / ការមិនគោរពតាម ដើម្បីធានាថាបញ្ហាទាំងនេះត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាពនិងឆាប់រហ័ស។ • ត្រួតពិនិត្យលើហានិភ័យបច្ចេកវិទ្យាព័ត៌មានវិទ្យា រួមទាំងធ្វើការវាយតម្លៃហានិភ័យជាមុន លើសេវាកម្ម ធនាគារអេឡិកត្រូនិក ធ្វើការវាយតំលៃហានិភ័យ នៃការផ្តល់សេវាបច្ចេកវិទ្យាពីខាងក្រៅ ឬសេវាកម្មរបស់តតិយភាគី (Third Party)។ • ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍លើក្របខណ្ឌ / គោលនយោបាយដែលពាក់ព័ន្ធនឹងហានិភ័យបច្ចេកវិទ្យា ការកែប្រែសំខាន់ មុនពេលដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត។ • ត្រួតពិនិត្យឡើងវិញនូវក្របខណ្ឌគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា និងកម្រិតកំណត់ហានិភ័យបច្ចេកវិទ្យា ដែលណែនាំដោយធនាគារមេ ដើម្បីយកមកអនុវត្ត ឬក៏ធ្វើមូលដ្ឋានីយកម្មសម្រាប់អនុវត្តនៅក្នុងធនាគារ។ • ធានាឲ្យមានការត្រួតពិនិត្យឲ្យបានគ្រប់គ្រាន់ និងរឹងមាំ លើប្រព័ន្ធបច្ចេកវិទ្យា និងការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យា។
យុទ្ធសាស្ត្រប្រតិបត្តិតាម និងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម («AML / CFT»)	• ផ្តល់អនុសាសន៍សម្រាប់ការប្រតិបត្តិតាម និងយុទ្ធសាស្ត្រសម្រាប់ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់ធនាគារ • ជួយក្នុងការកំណត់គោលដៅសម្រាប់ការប្រតិបត្តិតាម និងគ្រប់គ្រងហានិភ័យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៅគ្រប់បណ្តាញអាជីវកម្ម។
ក្របខណ្ឌការប្រតិបត្តិតាម និងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម («AML / CFT»)	• ធ្វើការពិភាក្សាអំពីបញ្ហាការប្រតិបត្តិតាម និងបញ្ហាហានិភ័យ ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដើម្បីធានាថាបញ្ហាទាំងនេះត្រូវបានដោះស្រាយ ប្រកបដោយប្រសិទ្ធភាព និងឆាប់រហ័ស។ • ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ក្របខណ្ឌ / គោលនយោបាយ ការប្រតិបត្តិតាម និងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការកែសម្រួលសំខាន់ ចំពោះក្របខណ្ឌ / គោលនយោបាយហានិភ័យ ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។
ការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម	• ត្រួតពិនិត្យសមាសធាតុតារាងតុល្យការរបស់ធនាគារ រួមមានឥណទាន និងប្រាក់បញ្ញើ។ • ធានានូវការប្រកាន់ខ្ជាប់នូវទ្រឹស្តីសន្ទនិយម (holistic approach) ក្នុងការគ្រប់គ្រងតារាងតុល្យការរបស់ធនាគារ តាមរយៈការគ្រប់គ្រងហានិភ័យអត្រាការប្រាក់ ប្រកបដោយប្រសិទ្ធភាព ការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល ការគ្រប់គ្រងគម្លាតកម្រិតការប្រាក់ និងមូលធន។
ការថែរក្សាគុណភាពទ្រព្យសកម្ម	• ពិនិត្យថាផ្នែកអាជីវកម្ម និងគណៈកម្មាធិការឥណទាននានាបានកំណត់ច្បាស់លាស់ នូវដំណើរការត្រួតពិនិត្យគុណភាពទ្រព្យសកម្ម និងគណនីក្នុងការឃ្លាំមើល ដើម្បីកំណត់ បែងចែក រាយការណ៍ តាមដានឥណទានដែលមានបញ្ហា (ជាពិសេស គណនីមិនដំណើរការ) ស្របតាមគោលនយោបាយហានិភ័យឥណទាន/ និយ័តករ/ គោលនយោបាយ និងនីតិវិធីឥណទានផ្សេងៗដែលបានអនុម័ត/ស្តង់ដារគណនីផ្សេងៗ (ប្រសិនបើមាន)។ • ធានាថាធនាគាររក្សាបាននូវគុណភាពទ្រព្យសកម្ម តាមរយៈការពិនិត្យតាមដានយ៉ាងហ្មត់ចត់លើដំណើរការ និងការអនុម័ត លើឥណទានថ្មីៗ ព្រមទាំងការប្រមូលឥណទានដែលមិនដំណើរការ។ • សម្របសម្រួលនូវបញ្ហាដែលពាក់ព័ន្ធទៅនឹងការផ្ទេរគណនីរវាងផ្នែកអាជីវកម្ម និងក្រុមទារសំណង នៅពេលគណនីនោះបានក្លាយជាមិនដំណើរការ និងផ្ទុយមកវិញ។ • ត្រួតពិនិត្យឡើងវិញលើទ្រព្យសកម្មដំណើរការដែលរួមមាន៖ - គណនីឃ្លាំមើល យឺតយ៉ាវ ឬ មិនដំណើរការ - សំវិធានធននៃគណនី ដោយអាស្រ័យតាមប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា និងបទប្បញ្ញត្តិផ្សេងៗទៀត និង - បញ្ហាផ្សេងទៀតដែលពាក់ព័ន្ធនឹងគុណភាពទ្រព្យសកម្ម។ • ពិនិត្យឡើងវិញ និងពិភាក្សាលើផតហ្វូលីយ៉ូ និងរបាយការណ៍ឥណទានមិនដំណើរការ សម្រាប់ការកំណត់អត្តសញ្ញាណហានិភ័យ។
ការបន្តនិរន្តរភាពនៃអាជីវកម្ម	• ពិនិត្យឡើងវិញនូវផែនការបង្ការ (Contingency Plan) និងការគ្រប់គ្រងនិរន្តរភាពនៃអាជីវកម្ម (Business Continuity Management) សម្រាប់អនុវត្ត នៅពេលចាំបាច់ និងស្នើសុំការអនុម័តពីក្រុមប្រឹក្សាភិបាល ។
ការតែងតាំងសមាជិកគណៈកម្មាធិការ និងតែងតាំងអនុគណៈកម្មាធិការហានិភ័យ	• គណៈកម្មាធិការនេះអាចអនុម័តរាល់ការផ្លាស់ប្តូរសមាជិក នៅក្នុងមុខងារនៃសាជីវកម្ម (corporate function) ដដែល ដោយធ្វើការជូនដំណឹងទៅកាន់ក្រុមប្រឹក្សាភិបាល។ រីឯរាល់ការការផ្លាស់ប្តូរសមាជិក នៅក្រៅមុខងារនៃសាជីវកម្ម ឬ សំណើសុំកែប្រែលើលក្ខន្តិកៈ (Terms of Reference) ត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាលមុននឹងអនុវត្ត។ • ពិនិត្យឡើងវិញ និងអនុម័តលើលក្ខន្តិកៈ និងសមាសភាពនៃគណៈកម្មាធិការ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការហានិភ័យ រួមបញ្ចូលទាំងការតែងតាំង និងការដកចេញនូវសមាជិក និងអ្នកចូលរួមក្នុងគណៈកម្មាធិការទាំងនេះ ។

គណៈកម្មាធិការគ្រប់គ្រងនានា

គណៈកម្មាធិការគ្រប់គ្រងដូចមានរៀបរាប់ខាងក្រោម ត្រូវបានបង្កើតឡើងដើម្បីជួយការងាររបស់ប្រធាននាយកប្រតិបត្តិ និងគណៈគ្រប់គ្រង លើប្រតិបត្តិការអាជីវកម្មផ្សេងៗ និងជួយគាំទ្រដល់សកម្មភាពនានារបស់ធនាគារ៖

- គណៈកម្មាធិការគ្រប់គ្រង
- គណៈកម្មាធិការឥណទានកម្ពុជា
- គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម

គណៈកម្មាធិការគ្រប់គ្រង

គណៈកម្មាធិការគ្រប់គ្រងរាយការណ៍ជូនក្រុមប្រឹក្សាភិបាល នូវបញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ធនាគារ។

សមាជិក	
ប៊ុន យ៉ីន ប្រធាននាយកប្រតិបត្តិ	ប្រធាន
ហេង ធីតា នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល	សមាជិក
ហេង ឆូរ៉ង់ នាយករតនាភិបាល និង ទីផ្សារ	សមាជិក
ហុង ជៀប នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម	សមាជិក
គៀន វឌ្ឍនា នាយកគ្រប់គ្រងហានិភ័យ	សមាជិក
ហេង រ៉ុទ្ធី នាយកហិរញ្ញវត្ថុ	សមាជិក
អ៊ុំ ចិន្តាភក្តី នាយកធនធានសាជីវកម្ម	សមាជិក
ហេង វិបុត្រ នាយកបច្ចេកវិទ្យា និងប្រតិបត្តិការ	សមាជិក
គី សាណា នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ	សមាជិក
អ៊ីក ថានិន នាយកគ្រប់គ្រងផលិតផល	សមាជិក

កំណត់សម្គាល់៖

អ្នកចូលរួមអចិន្ត្រៃយ៍របស់គណៈកម្មាធិការ រួមមាននាយកសវនករផ្ទៃក្នុង និងនាយកប្រតិបត្តិតាម។

តួនាទី និងការកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងមានដូចខាងក្រោម៖

- ផ្តល់ប្រឹក្សាជូនប្រធាននាយកប្រតិបត្តិ។
- ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពប្រតិបត្តិការរបស់នាយកដ្ឋានអាជីវកម្មនីមួយៗ រួមមានតែមិនកំណត់ត្រឹមការត្រួតពិនិត្យលើមុខងារនៃគណៈកម្មាធិការនានា ឬក្រុមការងារ ដែលបានបង្កើតឡើងដោយគណៈកម្មាធិការគ្រប់គ្រង ដើម្បីអនុវត្តតួនាទីណាមួយ ប្រសិនបើចាំបាច់។
- ពិនិត្យរបាយការណ៍គ្រប់គ្រងហិរញ្ញវត្ថុ និងរបាយការណ៍គ្រប់គ្រងផ្សេងៗទៀតរបស់ធនាគារ។
- បង្កើតយុទ្ធសាស្ត្រ ផែនការអាជីវកម្ម និងផែនការថវិកាសម្រាប់ធនាគារ (រាប់បញ្ចូលទាំងចំណុចដែលទាក់ទងនឹងបច្ចេកវិទ្យាព័ត៌មាន)
- កំណត់ការងារដែលទាមទារឲ្យមានការសហការពីនាយកដ្ឋានច្រើន។
- ពិភាក្សាលើច្បាប់ និងបទប្បញ្ញត្តិសំខាន់ៗ។
- ការងារផ្សេងៗទៀត តាមការណែនាំរបស់ប្រធាននាយកប្រតិបត្តិ។
- ការងារផ្សេងៗទៀត តាមការណែនាំរបស់ក្រុមប្រឹក្សាភិបាល/ប្រធាននាយកប្រតិបត្តិរបស់ក្រុមហ៊ុនមេ។

គណៈកម្មាធិការឥណទានកម្ពុជា

គណៈកម្មាធិការឥណទានកម្ពុជា ធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងហានិភ័យ នូវរាល់បញ្ហាទាក់ទងនឹងការងារឥណទានរបស់ធនាគារ។

សមាជិក	
គៀន វឌ្ឍនា នាយកគ្រប់គ្រងហានិភ័យ	ប្រធាន
ប៊ុន យ៉ីន ប្រធាននាយកប្រតិបត្តិ	ប្រធានជំនួស
ហុង ជៀប នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម	សមាជិក
ហេង ធីតា[*១] នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល	សមាជិក
ចំណាន វនិតា នាយកគ្រប់គ្រងឥណទាន	សមាជិក
John Chuah Keat Kong[*២] ទីប្រឹក្សាឥណទានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម	សមាជិក
គី សាណា នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ	សមាជិក
ហុង ប៊ុនរ៉ៃត នាយកផ្នែកអាជីកម្ម នៃសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម	សមាជិក
Chong Kok Ping[*៣] នាយកគ្រប់គ្រងឥណទានថ្នាក់តំបន់	សមាជិក
Lim Gek Peng[*៤] ប្រធានគ្រប់គ្រងឥណទានពាណិជ្ជកម្ម និងគ្រឹះស្ថានហិរញ្ញវត្ថុ	សមាជិក
Michael Ng Mun Seng[*៣] នាយកវិភាគហានិភ័យឥណទានថ្នាក់តំបន់ស្តីទី	សមាជិក

កំណត់សម្គាល់៖

*[*១] សម្រាប់តែសេវាកម្មហិរញ្ញវត្ថុបុគ្គល*

*[*២] ជាសមាជិកដែលមានសំឡេងបោះឆ្នោតចាំបាច់ សម្រាប់សំណើឥណទាន ពីនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម ដែលស្ថិតនៅក្នុងកម្រិតកំណត់ឥណទានរបស់គណៈកម្មាធិការឥណទានកម្ពុជាតែប៉ុណ្ណោះ*

*[*៣] Chong Kok Ping ជាសមាជិកដែលមានសំឡេងបោះឆ្នោតចាំបាច់ សម្រាប់សំណើឥណទានពីនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម និងនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម ដែលសំណើឥណទាននោះហួសពីសិទ្ធិអំណាចសម្រេចរបស់គណៈកម្មាធិការឥណទានកម្ពុជា។ Michael Ng Mun Seng ឬ Leong Wai Chyi (សមាជិកជំនួស ក្នុងពេលអវត្តមានរបស់ Michael Ng Mun Seng) មកពីនាយកដ្ឋានយុទ្ធសាស្ត្រ និងវិភាគរបស់ក្រុមហ៊ុនមេ ជាសមាជិកដែលមានសំឡេងបោះឆ្នោត សម្រាប់សំណើឥណទានពីនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម នាយកដ្ឋានរតនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុធនាគារតែប៉ុណ្ណោះ*

*[*៤] ជាសមាជិកដែលមានសំឡេងបោះឆ្នោត សម្រាប់តែសំណើឥណទាន ពាក់ព័ន្ធនឹងគ្រឹះស្ថានហិរញ្ញវត្ថុតែប៉ុណ្ណោះ។*

តួនាទី និងការកិច្ចរបស់គណៈកម្មាធិការឥណទានមានដូចខាងក្រោម៖

- ត្រួតពិនិត្យឡើងវិញ និងអនុម័តលើឥណទានរបស់ធនាគារ ក្នុងកម្រិតកំណត់ឥណទាន ដែលក្រុមប្រឹក្សាភិបាលផ្តល់សិទ្ធិឲ្យ។
- ផ្តល់អនុសាសន៍ សម្រាប់ការសម្រេចរបស់ក្រុមប្រឹក្សាភិបាល លើរាល់សំណើឥណទានដែលហួសពីសិទ្ធិអំណាចសម្រេចរបស់គណៈកម្មាធិការឥណទានកម្ពុជា។
- ធានាថាសមតុល្យឥណទានទាំងមូលរបស់ធនាគារ ស្របតាមគោលការណ៍វំណនាំរបស់អាជ្ញាធរបញ្ញត្តិច្បាប់ និងស្របតាមគោលការណ៍ និងនីតិវិធីឥណទានដែលបានអនុម័ត។
- ត្រួតពិនិត្យឡើងវិញ និងអនុម័តលើហ្វាស៊ីលីធីរៀបចំឡើងវិញ និងវិធានការទារសំណង ដែលរួមមានការទូទាត់សងដោយសម្រុះសម្រួល និងឥណទានដែលត្រូវលុបចេញពីបញ្ជី ដែលនឹងត្រូវអនុវត្តស្របតាមលក្ខខណ្ឌពិន័យ។
- វាយតម្លៃសមតុល្យហានិភ័យ នៅពេលអនុម័តឥណទាន ដើម្បីធានាថាឥណទានដែលផ្តល់គឺស្ថិតនៅក្នុងហានិភ័យដែលអាចទទួលយកបានដោយធនាគារ។
- ត្រួតពិនិត្យឡើងវិញ និងវាយតម្លៃផលិតផលឥណទានផ្សេងៗរបស់ធនាគារ ដើម្បីធានាថាផលិតផលទាំងនោះត្រូវបាន អនុវត្តតាមបទដ្ឋាន និងគោលការណ៍ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល។
- ត្រួតពិនិត្យឡើងវិញ និងអនុម័តចំណាត់ថ្នាក់ឥណទានផ្ទៃក្នុងរបស់អ្នកខ្ចីម្នាក់ៗ តាមដែលអាចអនុវត្តបាន។
- ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍អំពីការកែប្រែ ឬវិសោធនកម្ម ក្នុងគោលការណ៍ឥណទាន និងគោលការណ៍ណែនាំ សម្រាប់ការអនុម័តរបស់គណៈកម្មាធិការនានាដែលពាក់ព័ន្ធ។
- អនុម័តការតែងតាំងដៃគូវិជ្ជាជីវៈ ដូចជាមេធាវី ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យ។
- បំពេញមុខងារដទៃទៀត តាមការណែនាំរបស់គណៈកម្មាធិការហានិភ័យ។

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម រាយការណ៍ទៅគណៈកម្មាធិការហានិភ័យ អំពីហានិភ័យសន្ធនីយភាព និងបញ្ហានានាដែលទាក់ទងនឹងទ្រព្យសកម្ម និងទ្រព្យអកម្មរបស់ធនាគារ។ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្មជួបប្រជុំចំនួន ១៤ ដង ក្នុងឆ្នាំ២០២០។

សមាជិក	
ប៊ុន យីន ប្រធាននាយកប្រតិបត្តិ	ប្រធាន
ហេង ធីតា នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល	សមាជិក
ហុង ជៀប នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម	សមាជិក
ហេង រ៉ុទ្ធី នាយកហិរញ្ញវត្ថុ	សមាជិក
ហេង តូរ៉ង់ នាយករតនាភិបាល និងទីផ្សារ	សមាជិក
គី សាណា នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ	សមាជិក
គឿន វឌ្ឍនា នាយកគ្រប់គ្រងហានិភ័យ	សមាជិក

តួនាទី និងការកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្មមានដូចខាងក្រោម៖

ត្រួតពិនិត្យតារាងតុល្យការ និងចំណូលការប្រាក់សុទ្ធ (NII)

- ត្រួតពិនិត្យឡើងវិញ និងវិភាគផែនការណ៍តារាងតុល្យការតាមផ្នែកអាជីវកម្ម ទ្រព្យសកម្ម និងទ្រព្យអកម្មចម្រុះ រូបិយប័ណ្ណ ភាពរឹកចម្រើន និងប្រាក់ចំណេញ។
- ត្រួតពិនិត្យឡើងវិញអំពីភាពខុសគ្នា រវាងតារាងតុល្យការជាក់ស្តែងធៀបនឹងផែនការ ដែលអាចប៉ះពាល់ទៅលើឥណទាន និងបញ្ញើ អនុបាតផ្សេងៗរបស់តារាងតុល្យការ ផែនការហិរញ្ញប្បទាន និងថាតើធនាគារនៅតែបន្តអនុវត្ត ក្នុងកម្រិតហានិភ័យដែលបានកំណត់ឬទេ។
- ត្រួតពិនិត្យឡើងវិញអំពីចំណូលការប្រាក់សុទ្ធ និងនិន្នាការ ដោយរួមបញ្ចូលការព្យាករណ៍ស្ថានភាព និងភាពខុសគ្នាពីផែនការចំណូលការប្រាក់សុទ្ធ និងធ្វើការលម្អិតអំពីសកម្មភាព ដែលបានតម្រូវឲ្យបានត្រឹមត្រូវ។
- ត្រួតពិនិត្យឡើងវិញអំពីផលប៉ះពាល់លើប្រាក់ចំណេញ ទាំងក្នុងករណីសេដ្ឋកិច្ចធម្មតា និងក្នុងករណីមានវិបត្តិសេដ្ឋកិច្ចផ្សេងៗ។
- ត្រួតពិនិត្យឡើងវិញ និងធានាថា ថ្លៃចំណាយលើហិរញ្ញប្បទាន ឬការកំណត់ថ្លៃផ្ទេរនៃហិរញ្ញប្បទាន (បើមាន) គឺត្រឹមត្រូវ និងធ្វើជាអាជ្ញាកណ្តាលរវាងផ្នែកអាជីវកម្មទាំងអស់ក្នុងការរៀបចំ និងការអនុវត្តការកំណត់ថ្លៃផ្ទេរនៃហិរញ្ញប្បទាន និងលើកកម្ពស់តម្លាភាពក្នុងធនាគារ។

ផែនការណ៍យុទ្ធសាស្ត្រនៃហិរញ្ញប្បទាន

- ត្រួតពិនិត្យឡើងវិញ អំពីផែនការណ៍យុទ្ធសាស្ត្រនៃហិរញ្ញប្បទាន ដែលត្រូវបានចាត់ទុកថាផែនការប្រតិបត្តិការនៃអាជីវកម្ម និងសិក្សាលទ្ធភាពដើម្បីធានាថា សកម្មភាពដែលតម្រូវដោយអ្នកគ្រប់គ្រងអាចអនុវត្តទៅបាន។
- ធានាថាសូចនាករក្រើនរំលឹកមុន ត្រូវបានធ្វើបច្ចុប្បន្នភាព និងសមស្រប យោងតាមទិន្នន័យដែលមានជាក់ស្តែង។

ការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម

- ត្រួតពិនិត្យលើក្របខណ្ឌគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម និងគោលការណ៍ (បើមាន) ដើម្បីធានាថាវាសមស្របតាមទំហំ និងភាពស្មុគស្មាញនៃប្រតិបត្តិការរបស់ធនាគារនាពេលបច្ចុប្បន្ន និងអនាគត។
- លើកកម្ពស់ភាពស្របគ្នារវាងគោលការណ៍ និងការអនុវត្តនៅក្នុងធនាគារ។
- ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍លើចំណាត់ការគ្រប់គ្រង (Management Action Triggers «MAT») ឬដែនកំណត់សម្រាប់ហានិភ័យសន្ធនីយភាព និងហានិភ័យអត្រាការប្រាក់នៅក្នុងបញ្ជីធនាគារ (IRRBB) ទៅគណៈកម្មាធិការហានិភ័យដើម្បីអនុម័ត។
- កំណត់ ពិនិត្យតាមដាន និងត្រួតពិនិត្យឡើងវិញលើយុទ្ធសាស្ត្រជម្លៀសរបស់ធនាគារ (បើមាន)។
- ត្រួតពិនិត្យឡើងវិញ និងធានាថាទម្រង់ហានិភ័យរបស់ធនាគារ គឺស្ថិតនៅក្រោមចំណាត់ការគ្រប់គ្រង (Management Action Triggers «MAT») ឬដែនកំណត់នៃហានិភ័យសន្ធនីយភាព និងហានិភ័យអត្រាការប្រាក់នៅក្នុងបញ្ជីធនាគារ (IRRBB) រួមទាំងលទ្ធផលពិសោធន៍ផ្ទៃក្នុងពេលមានវិបត្តិដោយរូបិយប័ណ្ណគោល។
- ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍គំរូប៉ារ៉ាម៉ែត្រហានិភ័យគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម និងលទ្ធផលនៃការបញ្ជាក់ជាគំរូ ទៅគណៈកម្មាធិការហានិភ័យដើម្បីអនុម័ត។
- កំណត់ និងត្រួតពិនិត្យឡើងវិញលើសន្ធនីយភាពរបស់ធនាគារ តម្រូវការហិរញ្ញប្បទាន និងការអនុវត្តសមស្របតាមតម្រូវការទាំងនេះ។

ការគ្រប់គ្រងហានិភ័យទីផ្សារ

- ត្រួតពិនិត្យវិធីសាស្ត្រវាស់វែងហានិភ័យទីផ្សាររបស់ធនាគារ ទាំងវិធីសាស្ត្រ និងប្រព័ន្ធផ្ទៃក្នុង និងបទប្បញ្ញត្តិណាដែលអនុវត្តបាន។
- ពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍លើលទ្ធផល ប៉ារ៉ាម៉ែត្រគំរូ ការធ្វៀងផ្ទាត់គំរូ សម្រាប់គណៈកម្មាធិការហានិភ័យកម្ពុជាអនុម័ត។
- ពិនិត្យឡើងវិញ និងអនុម័តការផ្លាស់ប្តូរបណ្តោះអាសន្ន តាមពេលវេលាកំណត់ ចំពោះកម្រិតហានិភ័យទីផ្សារ។

អំណាចនៃការអនុម័ត

- ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ក្របខណ្ឌគ្រប់គ្រងហានិភ័យទ្រព្យសកម្ម និងទ្រព្យអកម្ម និងគោលការណ៍ (បើមាន) ទៅគណៈកម្មាធិការហានិភ័យ ដើម្បីអនុម័ត។
- ត្រួតពិនិត្យឡើងវិញ និងអនុម័តលើវិធីសាស្ត្រ និងបទដ្ឋានគ្រប់គ្រងហានិភ័យទ្រព្យសកម្ម និងទ្រព្យអកម្ម (បើមាន) ដើម្បីគោរពតាមគោលការណ៍ដែលបានអនុម័ត។
- គាំទ្រគោលការណ៍ និងគោលនយោបាយហានិភ័យទីផ្សារ និងផ្តល់អនុសាសន៍ដល់គណៈកម្មាធិការហានិភ័យរបស់ធនាគារ ដើម្បីអនុម័ត។
- អនុម័តវិធីសាស្ត្រ និងបទដ្ឋានហានិភ័យទីផ្សារស្របតាមស្តង់ដារអនុម័ត និងគោលការណ៍អភិបាលកិច្ចហានិភ័យរបស់ធនាគារ។
- ត្រួតពិនិត្យឡើងវិញ និងអនុម័តលើវិធីសាស្ត្រ គោលការណ៍ ក្របខណ្ឌនៃថ្លៃចំណាយ លើហិរញ្ញប្បទាន ឬការកំណត់ថ្លៃផ្ទេរនៃហិរញ្ញប្បទាន។
- អនុម័តលើសំណើតម្លៃ ផ្អែកលើសិទ្ធិអំណាច ដែលបានផ្តល់ជូន។
- លើកឡើងទៅគណៈកម្មាធិការហានិភ័យរាល់ការបំពានចំណាត់ការគ្រប់គ្រង ឬដែនកំណត់ (ដែលមិនពាក់ព័ន្ធនឹងច្បាប់) ដែលមិនខុសឆ្ងាយពីដែនកំណត់ ដែលបានកំណត់ និងដើមទុន ឬសន្ទនីយភាព ឬកេរ្តិ៍ឈ្មោះធនាគារ។

គណនេយ្យភាព និងសវនកម្ម

ការធ្វើរបាយការណ៍ហិរញ្ញវត្ថុ

ដោយយោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ របាយការណ៍ហិរញ្ញវត្ថុ សម្រាប់ឆ្នាំហិរញ្ញវត្ថុនីមួយៗត្រូវរៀបចំឡើង។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (ហៅកាត់ថា «CIFRS») ហើយបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តម្រូវឲ្យក្រុមប្រឹក្សាភិបាល៖

i) ប្រើប្រាស់គោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន បន្ទាប់ពីនោះត្រូវអនុវត្តគោលការណ៍ទាំងនោះឲ្យបានស៊ីសង្វាក់គ្នា។
ii) អនុវត្តតាមការលាតត្រដាងព័ត៌មានរបស់ CIFRS ឬប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញឲ្យមានភាពត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវលាតត្រដាង ពន្យល់ និងកំណត់បរិមាណឲ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
iii) រក្សាទុកបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។
iv) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃអាជីវកម្ម លើកលែងតែមានករណីមិនសមរម្យក្នុងការសន្មតថា ធនាគារអាចនឹងបន្តប្រតិបត្តិការអាជីវកម្ម នៅពេលអនាគតដ៏ខ្លី និង
v) ត្រួតពិនិត្យ និងដឹកនាំធនាគារ ដោយចូលរួមលើរាល់ការសម្រេចចិត្តសំខាន់ៗទាំងអស់ ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការទាំងនេះត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលមានសេចក្តីពេញចិត្តនឹងការបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងការបង្ហាញនូវសមតុល្យភាព និងការវាយតម្លៃអំពីស្ថានភាពហិរញ្ញវត្ថុ និងការព្យាករ នាថ្ងៃអនាគត ប្រកបដោយភាពត្រឹមត្រូវ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដូចមានបង្ហាញនៅក្នុងរបាយការណ៍របស់អភិបាលនៅក្នុងទំព័រ ៨៦ ដល់ ៨៧ ស្តីពីរបាយការណ៍ហិរញ្ញវត្ថុនៃរបាយការណ៍ប្រចាំឆ្នាំនេះ។

គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្មជួយក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យដំណើរការ នៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ លទ្ធផលហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆមាសរបស់ធនាគារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវត្រួតពិនិត្យឡើងវិញ ដោយគណៈកម្មាធិការសវនកម្ម និងអនុម័តដោយក្រុមប្រឹក្សាភិបាល មុនពេលផ្តល់ជូនធនាគារជាតិ នៃកម្ពុជា។

ការត្រួតពិនិត្យផ្ទៃក្នុង

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវរួម លើការរក្សានូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ឲ្យមានភាពល្អប្រសើរ ដែលរួមមានដូចជា ការត្រួតពិនិត្យលើហិរញ្ញវត្ថុ ការធ្វើប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ការគោរពច្បាប់ និងបទប្បញ្ញត្តិនានា ក៏ដូចជាការគ្រប់គ្រងហានិភ័យ។ ទំហំ និងភាពស្មុគស្មាញនៃអាជីវកម្មរបស់ធនាគារទាមទារឲ្យមានជាចាំបាច់នូវការគ្រប់គ្រង និងការបែងចែកហានិភ័យត្រឹមត្រូវ។ លក្ខណៈនៃហានិភ័យទាំងនេះ មានន័យថា ព្រឹត្តិការណ៍ទាំងឡាយអាចនឹងកើតមានឡើង ហើយបណ្តាលឲ្យមានការខាតបង់ដោយមិនអាចដឹងមុន និងចៀសវាងបាន។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធត្រូវបានរៀបចំឡើង ដើម្បីផ្តល់នូវការធានាដ៏សមហេតុផលមួយ បើទោះបីជាវាមិនអាចធានាទាំងស្រុងចំពោះហានិភ័យដែលកើតចេញពីកំហុសធ្ងន់ធ្ងរ ការកេងបន្លំ ឬ ការខាតបង់ដែលកើតមានក្តី។

ក្រុមប្រឹក្សាភិបាលបានចាត់ទុកថា ក្របខណ្ឌ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធីត្រូវបានអនុវត្ត ដោយគណៈគ្រប់គ្រងរបស់ធនាគារក្នុងឆ្នាំហិរញ្ញវត្ថុ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ និងមានគ្រប់គ្រាន់ស្របតាមតម្រូវការរបស់ធនាគារ ក្នុងបរិយាកាសអាជីវកម្មនាពេលបច្ចុប្បន្ន។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានរៀបចំឡើងសម្រាប់ផ្តល់នូវការធានាដ៏សមស្របមួយ បើទោះបីជាវាមិនអាចធានាទាំងស្រុង ដើម្បីបង្កើតឲ្យបាននូវបទដ្ឋានជាក់លាក់មួយ សម្រាប់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងជួយធនាគារក្នុងការគ្រប់គ្រងហានិភ័យលើការបរាជ័យ ក្នុងការសម្រេចគោលដៅអាជីវកម្មក្តី ប៉ុន្តែវាប្រសើរជាងការលុបចោលនូវប្រព័ន្ធត្រួតពិនិត្យនេះដែរ។

សេចក្តីថ្លែងការណ៍អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលបង្ហាញពីស្ថានភាពត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារមានបង្ហាញនៅក្នុងទំព័រ ៤៩ ដល់ ៥១ នៃរបាយការណ៍ប្រចាំឆ្នាំនេះ។

សេចក្តីថ្លែងការណ៍ស្តីពីអភិបាលកិច្ចធនាគារ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១។

របាយការណ៍គណៈកម្មាធិការសវនកម្ម

សេចក្ដីសង្ខេប

គណៈកម្មាធិការសវនកម្មនៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ប្តេជ្ញាបំពេញតួនាទីរបស់ខ្លួនក្នុងការធានានូវការអនុវត្ត អភិបាលកិច្ចយ៉ាងល្អប្រសើរ ព្រមទាំងធានានូវការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។

១. សមាជិកចូលរួមកិច្ចប្រជុំ

ព័ត៌មានលម្អិតនៃសមាសភាពគណៈកម្មាធិការសវនកម្ម និងកិច្ចប្រជុំគណៈកម្មាធិការសវនកម្ម ដែលបានរៀបចំឡើងក្នុងឆ្នាំ ២០២០ មានរៀបរាប់ដូចខាងក្រោម៖

សមាជិក	មុខងារ	បានចូលរួម	ចំនួនកិច្ចប្រជុំ
បណ្ឌិត ម៉ី កល្យាណ	អភិបាលឯករាជ្យមិនប្រតិបត្តិ	៧	៧
Datuk Mohd Nasir Bin Ahmad	អភិបាលឯករាជ្យមិនប្រតិបត្តិ	៧	៧
Aisyah Lam Binti Abdullah	អភិបាលឯករាជ្យមិនប្រតិបត្តិ	៧	៧

ប្រធានគណៈកម្មាធិការសវនកម្ម ធ្វើសេចក្ដីរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីបញ្ហាទាំងឡាយណា ដែលត្រូវបានលើកឡើងក្នុងកិច្ចប្រជុំគណៈកម្មាធិការសវនកម្មរបស់ខ្លួន។

២. សមាសភាព

សមាភាពរបស់គណៈកម្មាធិការសវនកម្ម ត្រូវមានតែអភិបាលមិនប្រតិបត្តិប៉ុណ្ណោះ និងត្រូវមានអភិបាលយ៉ាងតិចបី (៣) រូប ដែលក្នុងចំណោមនោះ អភិបាលភាគច្រើនត្រូវជាអភិបាលឯករាជ្យ។ គណៈកម្មាធិការសវនកម្ម ដឹកនាំដោយអភិបាលឯករាជ្យចំនួនមួយ (១) រូប ដែលមានជំនាញផ្នែកច្បាប់ និងគណនេយ្យ និងមិនមែនជាប្រធានក្រុមប្រឹក្សាភិបាល។ នេះគឺដើម្បីជំរុញការពិភាក្សាបើកចំហ និងស្វាហាប់នូវរាល់បញ្ហាដែលលើកឡើងដោយគណៈកម្មាធិការសវនកម្ម។ គ្រប់សមាជិករបស់គណៈកម្មាធិការសវនកម្មទាំងអស់ត្រូវមានចំណេះដឹងទាក់ទងនឹងហិរញ្ញវត្ថុ ហើយជារួម គណៈកម្មាធិការត្រូវមានអភិបាលដែលមានជំនាញ ចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងទំនួលខុសត្រូវរបស់គណៈកម្មាធិការសវនកម្ម។

ក្រុមប្រឹក្សាភិបាលត្រូវអនុម័តដំណើរការមួយ សម្រាប់វាយតម្លៃប្រចាំឆ្នាំពីប្រសិទ្ធភាពរបស់គណៈកម្មាធិការសវនកម្ម ក៏ដូចជាការរួមចំណែករបស់សមាជិកម្នាក់ៗ ថាតើគណៈកម្មាធិការសវនកម្ម និងសមាជិកគណៈកម្មាធិការសវនកម្មបានបំពេញភារកិច្ច ស្របទៅតាមតួនាទី និងភារកិច្ច។

តំណែងទំនេរនៅក្នុងគណៈកម្មាធិការសវនកម្ម ត្រូវបំពេញក្នុងរយៈពេល បី (៣) ខែ។

៣. សិទ្ធិអំណាច

គណៈកម្មាធិការសវនកម្ម គឺជាគណៈកម្មាធិការមួយដែលទទួលបានការផ្ទេរសិទ្ធិពីក្រុមប្រឹក្សាភិបាល។ នៅក្នុងការអនុវត្តតួនាទីរបស់ខ្លួន គណៈកម្មាធិការសវនកម្មមានសិទ្ធិអំណាចពេញលេញក្នុងការធ្វើការស៊ើបអង្កេតលើបញ្ហានានា ដូចមានចែង នៅក្នុងតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម។ គណៈកម្មាធិការនេះ មានសិទ្ធិពេញលេញក្នុងការចូលរួម និងទាមទារឲ្យមានការសហការពីគណៈគ្រប់គ្រង ព្រមទាំងមានឆន្ទានុសិទ្ធិពេញលេញ ក្នុងការអញ្ជើញអភិបាល ឬមន្ត្រីប្រតិបត្តិណាម្នាក់ចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន។ គណៈកម្មាធិការសវនកម្មមានសិទ្ធិពេញលេញ និងគ្មានដែនកំណត់ ក្នុងការទទួលបាននូវព័ត៌មានផ្សេងៗ ព្រមទាំងការទទួលយកការប្រឹក្សាយោបល់ពីអ្នកជំនាញឯករាជ្យ ក្នុងករណីចាំបាច់ ដោយរាល់ចំណាយដែលពាក់ព័ន្ធទាំងអស់ជាបន្ទុករបស់ធនាគារ។ ធនាគារត្រូវផ្តល់ធនធានចាំបាច់នានាដល់គណៈកម្មាធិការសវនកម្ម ដើម្បីឲ្យគណៈកម្មាធិការសវនកម្មបំពេញការងាររបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព។

៤. តួនាទី និងការកិច្ចរបស់គណៈកម្មាធិការសវនកម្ម

តួនាទី និងកាតព្វកិច្ចរបស់គណៈកម្មាធិការសវនកម្មមានដូចខាងក្រោម៖

តួនាទី និងកាតព្វកិច្ចរបស់គណៈកម្មាធិការសវនកម្មមានដូចខាងក្រោម ៖	
ចំណុចគន្លឹះនៃការទទួលខុសត្រូវ	**ការទទួលខុសត្រូវ**
ការត្រួតពិនិត្យផ្ទៃក្នុង/ការគ្រប់គ្រងហានិភ័យ/អភិបាលកិច្ច	ពិនិត្យឡើងវិញលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដំណើរការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចក្នុងសម្ព័ន្ធធនាគារ ស្របតាមលក្ខខណ្ឌតម្រូវនៅក្នុងប្រកាស ស្តីពីអភិបាលកិច្ចនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។
សវនកម្មផ្ទៃក្នុង	ក. ធានាថា មុខងារសវនកម្មផ្ទៃក្នុងបានរៀបចំល្អប្រសើរ ដើម្បីធ្វើការត្រួតពិនិត្យ ឬអង្កេតក្នុងនាមគណៈកម្មាធិការសវនកម្ម ហើយមុខងារនេះត្រូវស្ថិតនៅក្រោមអំណាច និងការគ្រប់គ្រងផ្ទាល់ពីគណៈកម្មាធិការសវនកម្ម។ ខ. ពិនិត្យ និងអនុម័តវិសាលភាពការងារសវនកម្មផ្ទៃក្នុង នីតិវិធី ចំនួនដងនៃការធ្វើសវនកម្មផ្ទៃក្នុង និងគម្រោងសវនកម្មប្រចាំឆ្នាំ។ គ. មើលការខុសត្រូវលើប្រសិទ្ធភាពនៃមុខងារសវនកម្មផ្ទៃក្នុង សមត្ថភាពបុគ្គលិក និងភាពគ្រប់គ្រាន់នៃធនធានរបស់សវនកម្មផ្ទៃក្នុង និងពិនិត្យមើលថាតើមុខងារនោះបានទទួលអំណាចចាំបាច់ ដើម្បីបំពេញការងារឬនៅ។ ឃ. ពិនិត្យរបាយការណ៍សំខាន់ៗ និងធានាថាគណៈគ្រប់គ្រងចាត់វិធានការណ៍កែតម្រូវទាន់ពេលវេលា ដើម្បីដោះស្រាយចំណុចខ្សោយក្នុងការគ្រប់គ្រង ការមិនបានអនុវត្តពេញលេញតាមគោលនយោបាយ ការតម្រូវរបស់ច្បាប់ និងបទប្បញ្ញត្តិនានា និងបញ្ហាផ្សេងទៀតដែលរកឃើញដោយសវនករផ្ទៃក្នុង ក៏ដូចជាផ្នែកដែលទទួលខុសត្រូវការគ្រប់គ្រងផ្ទៃក្នុងដទៃទៀត។ ង. កត់សម្គាល់ការមិនឯកភាពសំខាន់ៗ រវាងនាយកសវនកម្មផ្ទៃក្នុង និងគណៈគ្រប់គ្រងដទៃទៀត មិនថាការមិនឯកភាពនោះត្រូវបានដោះស្រាយរួច ដើម្បីកំណត់ផលប៉ះពាល់ដែលការមិនឯកភាពទាំងនោះអាចមានចំពោះដំណើរការសវនកម្ម ឬលទ្ធផលសវនកម្មដែលលើកឡើងដោយសវនករ។ ច. ធានាការគោរពតាមច្បាប់ និងបទប្បញ្ញត្តិដែលអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងធានាថារបាយការណ៍របស់សវនករផ្ទៃក្នុងនឹងមិនតម្រូវឲ្យត្រួតពិនិត្យដោយគណៈគ្រប់គ្រងឡើយ។ ឆ. បង្កើតយន្តការដើម្បីវាយតម្លៃការបំពេញតួនាទី និងប្រសិទ្ធភាពរបស់មុខងារសវនកម្មផ្ទៃក្នុង។ ជ. វាយតម្លៃសកម្មភាពប្រតិបត្តិការ និងធ្វើសេចក្តីសម្រេចអំពីកញ្ចប់តម្លៃការរបស់នាយកសវនកម្មផ្ទៃក្នុង។ ឈ. អនុម័តលើការតែងតាំង ការផ្លាស់ប្តូរ និងការបណ្តេញចេញនាយកសវនកម្មផ្ទៃក្នុង ឬបុគ្គលិកជាន់ខ្ពស់ ដែលបំពេញមុខងារជាសវនករផ្ទៃក្នុង និងត្រូវទទួលការជូនដំណឹង អំពីការលាឈប់របស់បុគ្គលិកជាន់ខ្ពស់ជាសវនករផ្ទៃក្នុង ហើយត្រូវផ្តល់ឱកាសឲ្យសមាជិក ដែលបានដាក់ពាក្យលាឈប់នោះបញ្ជាក់ប្រាប់ពីមូលហេតុនៃការលាឈប់។
សវនកម្មខាងក្រៅ	ក. ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលលើការតែងតាំង ការបញ្ឈប់ និងកញ្ចប់តម្លៃការរបស់សវនករខាងក្រៅ។ ខ. ពិភាក្សា និងពិនិត្យមើលឡើងវិញជាមួយសវនករខាងក្រៅមុននឹងចាប់ផ្តើមធ្វើសវនកម្មអំពីលក្ខណៈ និងទំហំការងារសវនកម្ម ហើយធានាលើការសម្របសម្រួល ក្នុងករណីមានក្រុមហ៊ុនសវនកម្មច្រើនចូលរួម។ គ. វាយតម្លៃអំពីគោលដៅ ការបំពេញការងារ និងឯករាជ្យភាពរបស់សវនករខាងក្រៅ (ឧទាហរណ៍ ដោយការពិនិត្យ និងវាយតម្លៃពីទំនាក់ទំនងផ្សេងៗ រវាងសវនករខាងក្រៅ និងធនាគារ)។ ឃ. អនុម័តលើការផ្តល់សេវា ដែលមិនទាក់ទងនឹងការងារសវនកម្ម ដែលផ្តល់ដោយសវនករខាងក្រៅ និងតាមដាន និងធ្វើការវាយតម្លៃថាតើសេវានោះអាចនឹងប៉ះពាល់ដល់ឯករាជ្យភាពរបស់ពួកគាត់ឬទេ។ ង. ធានាថា មានការពិនិត្យច្បាស់លាស់ លើលក្ខខណ្ឌនៃការផ្តល់សេវាដែលមិនទាក់ទងនឹងការងារសវនកម្ម ដើម្បីចៀសវាងការប៉ះពាល់ដល់ការវិនិច្ឆ័យប្រកបដោយឯករាជ្យភាពរបស់សវនករខាងក្រៅ។ ច. ធានាថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ និងទាន់ពេលវេលា ដោយមានការត្រួតពិនិត្យឡើងវិញជាប្រចាំលើភាពគ្រប់គ្រាន់នៃការធ្វើសំវិធានធន ដែលចាំបាច់ និងចំពោះបំណុលអាក្រក់ និងសង្ស័យ។ ឆ. រក្សាការទំនាក់ទំនងស្មោះត្រង់ បើកចំហ ទាន់ពេលវេលា និងទៀងទាត់ ជាមួយសវនករខាងក្រៅ និងតម្រូវឲ្យសវនករខាងក្រៅរាយការណ៍មកកាន់គណៈកម្មាធិការសវនកម្ម អំពីបញ្ហាសំខាន់ៗ (ដោយមិនមានវត្តមានរបស់គណៈគ្រប់គ្រង ប្រសិនបើចាំបាច់)។ ជ. ពិនិត្យឡើងវិញលើរបាយការណ៍គ្រប់គ្រងផ្ទៃក្នុងរបស់សវនករខាងក្រៅ និងធានាថា គណៈគ្រប់គ្រងចាត់វិធានការណ៍កែតម្រូវ ដើម្បីឆ្លើយតបទៅនឹងលទ្ធផលសវនកម្មខាងក្រៅ និងអនុសាសន៍ដែលលើកឡើងដោយសវនករខាងក្រៅទាន់ពេលវេលា។ ឈ. តាមដាន និងវាយតម្លៃប្រសិទ្ធភាពការងាររបស់សវនករខាងក្រៅ រួមទាំងជួបប្រជុំជាមួយសវនករខាងក្រៅយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ដោយមិនមានវត្តមានរបស់គណៈគ្រប់គ្រង ដើម្បីពិភាក្សាលើបញ្ហាគន្លឹះសំខាន់ៗ និងស្នើសុំយោបល់ពីសវនករខាងក្រៅវិញ។
លទ្ធផលសវនកម្ម ការត្រួតពិនិត្យផ្ទៃក្នុង និងបញ្ហានៃការប្រតិបត្តិតាមច្បាប់	ពិនិត្យឡើងវិញលើលទ្ធផលនៃការអង្កេតសំខាន់ៗ លទ្ធផលសវនកម្មជាប្រចាំ និងការត្រួតពិនិត្យផ្ទៃក្នុង និងការប្រតិបត្តិតាមច្បាប់ដែលរាយការណ៍ដោយសវនករផ្ទៃក្នុង សវនករខាងក្រៅ និងសវនករបស់និយ័តករ។
របាយការណ៍ហិរញ្ញវត្ថុ	ពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស និងប្រចាំឆ្នាំ មុនពេលទទួលការអនុម័តពីក្រុមប្រឹក្សាភិបាល ដោយផ្តោតសំខាន់លើ៖ • ការផ្លាស់ប្តូរណាមួយនៅក្នុងការអនុវត្ត និងគោលការណ៍គណនេយ្យ • បញ្ហាសំខាន់ៗដែលបានលើកឡើង រួមទាំងបញ្ហាទាក់ទងនឹងការរាយការណ៍ហិរញ្ញវត្ថុ ការវិនិច្ឆ័យសំខាន់ៗរបស់គណៈគ្រប់គ្រង ព្រឹត្តិការណ៍ឬប្រតិបត្តិការមិនប្រក្រតី និងសំខាន់ៗ និងរបៀបដែលបញ្ហាទាំងអស់ត្រូវបានបង្ហាញ • ការធ្វើសេចក្តីសន្និដ្ឋានពីបញ្ហាដែលកំពុងកើតឡើង និង • ការប្រតិបត្តិតាមស្តង់ដារគណនី និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ និងបទប្បញ្ញត្តិច្បាប់ដទៃផ្សេងទៀត
ប្រតិបត្តិការរបស់ភាគីសម្ព័ន្ធញាតិ	ពិនិត្យរាល់ប្រតិបត្តិការធ្វើឡើងជាមួយភាគីសម្ព័ន្ធញាតិ និងជូនដំណឹងដល់ក្រុមប្រឹក្សាភិបាលពីប្រតិបត្តិការទាំងនោះ។
ការពិនិត្យរបាយការណ៍ពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ	ពិនិត្យភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់នៃសេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល នៅក្នុងរបាយការណ៍ក្រុមប្រឹក្សាភិបាល ការបង្ហាញពីអភិបាលកិច្ចធនាគាររបាយការណ៍ហិរញ្ញវត្ថុ និងសេចក្តីប្រកាសដំបូង ពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។
ការតាមដានការអនុវត្តតាមគោលនយោបាយទំនាស់ផលប្រយោជន៍	តាមដានការអនុវត្តតាមគោលនយោបាយ ស្តីពីទំនាស់ផលប្រយោជន៍របស់ធនាគារ
ការពិនិត្យក្របខណ្ឌគ្រប់គ្រងផ្ទៃក្នុង	ពិនិត្យមតិយោបល់របស់ភាគីទីបី ចំពោះរចនាសម្ព័ន្ធ និងប្រសិទ្ធភាពនៃក្របខណ្ឌគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារ
ផ្សេងៗទៀត	ក. ទាក់ទងជាមួយគណៈគ្រប់គ្រងជាន់ខ្ពស់ជាទៀងទាត់ ដើម្បីទទួលបានព័ត៌មានអំពីបញ្ហាដែលប៉ះពាល់ដល់ធនាគារ។ ខ. កោះប្រជុំជាមួយសវនករផ្ទៃក្នុង សវនករខាងក្រៅ ឬទាំងពីរក្នុងពេលតែមួយ បើយល់ថាចាំបាច់។ គ. ពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស និងប្រចាំឆ្នាំ សម្រាប់ដាក់បញ្ជូនទៅឲ្យក្រុមប្រឹក្សាភិបាលរបស់ធនាគារ និងធានានូវការបោះពុម្ពផ្សាយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំបានរហ័ស។

៥. សេចក្ដីសង្ខេបសកម្មភាពផ្សេងៗក្នុងឆ្នាំ ២០២០

៥.១.គណៈកម្មាធិការសវនកម្ម

ក. បានត្រួតពិនិត្យឡើងវិញ និងអនុម័តយល់ព្រមលើផែនការសវនកម្មប្រចាំឆ្នាំ វិសាលភាពការងារ និងតម្រូវការផ្នែកធនធានរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

ខ. បានត្រួតពិនិត្យវិធីសាស្ត្ររបស់សវនកម្មផ្ទៃក្នុង ក្នុងការវាយតម្លៃកម្រិតហានិភ័យក្នុងវិស័យផ្សេងៗ ដែលអាចធ្វើសវនកម្មបាន និងធានាថា មុខងារសវនកម្មផ្តោតសំខាន់ទៅលើវិស័យដែលមានកម្រិតហានិភ័យខ្ពស់។

គ. បានត្រួតពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យនានា ការធ្វើរបាយការណ៍ និងការគ្រប់គ្រងហានិភ័យ ដើម្បីធានាថា មានវិធីសាស្ត្រជាប្រព័ន្ធមួយក្នុងការកំណត់ វាយតម្លៃ និងកាត់បន្ថយហានិភ័យ លើវិស័យនានា។

ឃ. បានត្រួតពិនិត្យឡើងវិញនូវប្រសិទ្ធភាពនៃប្រតិបត្តិការ និងការប្រើប្រាស់ធនធានទាំងអស់នៅក្នុងធនាគារដោយសន្សំសំចៃ។

ង. បានត្រួតពិនិត្យឡើងវិញអំពីការតែងតាំងសវនករខាងក្រៅ ព្រមទាំងឯករាជ្យភាព និងប្រសិទ្ធភាពការងាររបស់ សវនករខាងក្រៅផងដែរ។

ច. បានត្រួតពិនិត្យឡើងវិញនូវផែនការសវនកម្មរបស់សវនករខាងក្រៅ វិសាលភាពការងារ និងលទ្ធផលនៃសវនកម្មប្រចាំឆ្នាំរបស់ធនាគារ។

ឆ. បានជួបជាមួយសវនករខាងក្រៅ នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២០ ដោយពុំមានវត្តមានរបស់គណៈគ្រប់គ្រង និងអភិបាលប្រតិបត្តិ ដើម្បីពិភាក្សាបញ្ហាពាក់ព័ន្ធនានា និងស្នើសុំយោបល់កែតម្រូវពីសវនករខាងក្រៅ។

ជ. បានត្រួតពិនិត្យឡើងវិញនូវបញ្ហាពាក់ព័ន្ធនឹងការត្រួតពិនិត្យផ្ទៃក្នុង ដែលរកឃើញដោយសវនករផ្ទៃក្នុង និងសវនករខាងក្រៅ ព្រមទាំងការឆ្លើយតបរបស់គណៈគ្រប់គ្រងចំពោះអនុសាសន៍របស់សវនករ និងការឯកភាពលើផែនការសកម្មភាពដែលត្រូវអនុវត្ត។

ឈ. បានត្រួតពិនិត្យឡើងវិញ នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសរបស់ធនាគារ។

ញ. បានត្រួតពិនិត្យឡើងវិញនូវប្រតិបត្តិការជាមួយភាគីសម្ព័ន្ធញាតិ និងភាពគ្រប់គ្រាន់នៃនីតិវិធីរបស់ធនាគារ ក្នុងការកំណត់ តាមដាន រាយការណ៍ និងត្រួតពិនិត្យឡើងវិញនូវប្រតិបត្តិការជាមួយភាគីសម្ព័ន្ធញាតិនោះ។

ដ. បានធានានូវការប្រតិបត្តិតាមវិធានច្បាប់ និងគោលការណ៍ផ្ទៃក្នុង ព្រមទាំងការវិវឌ្ឍនៃសកម្មភាពការងារនានា របស់គណៈគ្រប់គ្រងក្នុងការអនុវត្តតាមអនុសាសន៍របស់សវនកម្មផ្ទៃក្នុង និងសវនកម្មខាងក្រៅ។

៥.២. មុខងារសវនកម្មផ្ទៃក្នុង

ក. ការធ្វើសវនកម្មផ្ទៃក្នុង សម្រាប់ធនាគារ មានការជួយគាំទ្រពីនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រុមហ៊ុនមេ។

ខ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង អនុវត្តការងារប្រកបដោយឯករាជ្យភាព និងធានាលើភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលបានអនុវត្តដោយគណៈគ្រប់គ្រង។

គ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង ជួយគណៈកម្មាធិការសវនកម្ម និងគណៈគ្រប់គ្រងក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព ចំពោះការត្រួតពិនិត្យ លើប្រសិទ្ធភាពចំណាយ ការវាយតម្លៃលើការគ្រប់គ្រងហានិភ័យ និងការផ្តល់យោបល់លើវិធានការកាត់បន្ថយហានិភ័យ ដែលបានរកឃើញ និងធានានូវដំណើរការអភិបាលកិច្ចត្រឹមត្រូវ។

ឃ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង ផ្តល់របាយការណ៍ជាប្រចាំជូនដល់គណៈកម្មាធិការសវនកម្ម និងគណៈគ្រប់គ្រងដោយរាយការណ៍ អំពីលទ្ធផលនៃការធ្វើសវនកម្ម ដែលបញ្ជាក់អំពីប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងហានិភ័យសំខាន់ៗ។

ង. នាយកដ្ឋានសវនកម្មផ្ទៃក្នុង ធ្វើការស៊ើបអង្កេតលើសកម្មភាព ដែលសង្ស័យថាជាការកេងបន្លំ និងសកម្មភាពមិនប្រក្រតីផ្សេងទៀត។

៥.៣. របាយការណ៍សវនកម្មផ្ទៃក្នុង

ក. នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានបញ្ចប់ការធ្វើសវនកម្ម ក្នុងអំឡុងឆ្នាំចំនួន ១៧ លើក ដោយបានធ្វើសវនកម្មលើប្រតិបត្តិការសំខាន់ៗទាំងអស់។

ខ. រាល់បញ្ហាដែលនាយកដ្ឋានសវនកម្មផ្ទៃក្នុង រកឃើញត្រូវបានកត់ត្រាទុក និងតាមដានបន្តរហូតដល់បញ្ហាទាំងនោះត្រូវបានដោះស្រាយចប់ ហើយនឹងត្រូវរាយការណ៍រៀងរាល់ ០២ ខែម្តង ជូនគណៈកម្មាធិការសវនកម្ម ដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុង។

គ. ការវិវឌ្ឍនៃសកម្មភាពការងារ ក្នុងការអនុវត្តតាមអនុសាសន៍របស់នាយកដ្ឋានសវនកម្ម ក៏ត្រូវរាយការណ៍ជូនដល់គណៈកម្មាធិការសវនកម្មរៀងរាល់ ០២ ខែម្តងផងដែរ។

សេចក្តីថ្លែងការណ៍ ស្តីអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលផ្តល់សារៈសំខាន់ទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ និងប្តេជ្ញារក្សាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនោះឲ្យមានលក្ខណៈល្អប្រសើរ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបង្ហាញពីតម្រូវការចាំបាច់ចំពោះការប្រតិបត្តិការអាជីវកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល និងដំណើរការនៃការរៀបចំ និងត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ និងសមស្រប ព្រមទាំងការអនុវត្តស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមានផងដែរ។

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវជារួមលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ និងការគ្រប់គ្រងលើប្រព័ន្ធព័ត៌មានវិទ្យា។ ក្រុមប្រឹក្សាភិបាលក៏ទទួលស្គាល់ផងដែរថា ការត្រួតពិនិត្យឡើងវិញលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គឺជាដំណើរការរួមគ្នា និងត្រូវអនុវត្តជាបន្តបន្ទាប់នៅក្នុងធនាគារ ហើយវាត្រូវធ្វើការផ្លាស់ប្តូរ ស្របទៅនឹងបច្ចេកវិទ្យា បរិយាកាសអាជីវកម្ម និងបទប្បញ្ញត្តិច្បាប់ក្នុងន័យធ្វើឲ្យប្រសើរឡើងនូវដំណើរការនៃការកំណត់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវបានបង្កើតឡើងដើម្បីកំណត់ គ្រប់គ្រង និងត្រួតពិនិត្យហានិភ័យ រួមបញ្ចូលទាំងហានិភ័យប្រតិបត្តិការ ពោលគឺមិនមែនដើម្បីលុបបំបាត់ចោលនូវហានិភ័យ ដែលកើតចេញពីការបរាជ័យ ក្នុងការសម្រេចទិសដៅអាជីវកម្មនោះទេ។

ការគ្រប់គ្រងហានិភ័យ និងក្របខណ្ឌនៃការត្រួតពិនិត្យ

ធនាគារចាត់ទុកថាការគ្រប់គ្រងហានិភ័យ គឺជាធាតុមួយយ៉ាងសំខាន់នៃអាជីវកម្មរបស់ធនាគារ ហើយបញ្ចូលវប្បធម៌ហានិភ័យដ៏តឹងរឹងទៅក្នុងប្រតិបត្តិការ និងដំណើរការសម្រេចចិត្តរបស់ធនាគារ។ ជាមួយនឹងការយល់ដឹងអំពីអត្ថប្រយោជន៍នៃការគ្រប់គ្រងហានិភ័យសម្រាប់ធនាគារ ដើម្បីសម្រេចបាននូវការកើតចម្រើនប្រកបដោយនិរន្តរភាពបាន ក្រុមការងារគ្រប់គ្រងហានិភ័យចូលរួមតាំងពីដំណាក់កាលដំបូងនៃដំណើរការទទួលយកហានិភ័យ ដើម្បីផ្តល់នូវទស្សនៈឯករាជ្យ និងមតិយោបល់ រួមមានការវាយតម្លៃផលិតផលថ្មី ការកំណត់យុទ្ធសាស្ត្រ ការវាយតម្លៃឥណទាន ។ល។

ធនាគារ ដែលជាផ្នែកមួយនៃស៊ីអាយអិមបី គ្រុប (CIMB Group) បានបញ្ចូលនូវក្របខណ្ឌគ្រប់គ្រងហានិភ័យទូទៅមួយសម្រាប់សហគ្រាសទាំងមូល (EWRM) ដើម្បីគ្រប់គ្រងហានិភ័យ និងឱកាសរបស់ខ្លួន។ ក្របខណ្ឌគ្រប់គ្រងហានិភ័យទូទៅ សម្រាប់សហគ្រាសទាំងមូល ផ្តល់ជូនក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងរបស់ខ្លួននូវឧបករណ៍មួយ ដើម្បីធ្វើការប្រមើលមើលទុកជាមុន និងគ្រប់គ្រងលើហានិភ័យដែលមានស្រាប់ និងហានិភ័យដែលអាចនឹងកើតមានដោយធ្វើការពិចារណាទៅលើការកែប្រែនូវទម្រង់ហានិភ័យ ស្របតាមការផ្លាស់ប្តូរនៃយុទ្ធសាស្ត្រអាជីវកម្ម បញ្ញត្តិច្បាប់ និងសកម្មភាពការងារ។

សន្តិសុខព័ត៌មានវិទ្យា

សន្តិសុខព័ត៌មានវិទ្យា គឺតម្រូវឲ្យមានជាយុទ្ធសាស្ត្ររួមនៃការគ្រប់គ្រងទៅលើវិន័យរបស់អ្នកប្រើប្រាស់ដំណើរការប្រតិបត្តិ និងប្រព័ន្ធបច្ចេកវិទ្យា ក្នុងគោលបំណងដើម្បីពង្រឹងបន្ថែម លើកម្រិតការគ្រប់គ្រងសន្តិសុខព័ត៌មានវិទ្យា ធនាគារ ស៊ីអាយអិមបី ភីអិលស៊ី បានជ្រើសយកបច្ចេកវិទ្យា ដែលមានស្តង់ដារជាអន្តជាតិ ដំណើរការប្រតិបត្តិ និងបែបបទនៃការគ្រប់គ្រង អនុលោមទៅតាមធនាគារមេ។ អនុវត្តតាមផែនការសន្តិសុខព័ត៌មានវិទ្យា យុទ្ធសាស្ត្រនៃការចៃទ៉ា និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខព័ត៌មានវិទ្យា ប្រកបដោយប្រសិទ្ធភាព ទៅតាមក្រុមហ៊ុនមេដើម្បីគាំទ្រដំណើរអាជីវកម្មរបស់ធនាគារឲ្យមានសុវត្ថិភាពខ្ពស់។

ដើម្បីឲ្យស្របទៅតាមការរីកលូតលាស់នៃអាជីវកម្មធនាគារ និងការពង្រីកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ផែនការលើបច្ចេកវិទ្យារបស់យើងតែងតែត្រូវបានពិនិត្យឡើងវិញជារឿយៗ និងធ្វើការពង្រឹងបន្ថែម ដើម្បីឲ្យកាន់តែមានប្រសិទ្ធភាព ក្នុងការគ្រប់គ្រងហានិភ័យនៃការគំរាមកំហែងទាំងខាងក្នុង និងក្រៅ។ លើសពីនេះទៅទៀត ធនាគារ ស៊ីអាយអិមបី មានការពឹងផ្អែកទៅលើមជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខរបស់ក្រុមហ៊ុនមេ (Group's Security Operation Center) ដែលបង្កើតឡើងដើម្បីតាមដាន និងឆ្លើយតបទៅនឹងសកម្មភាពវាយប្រហារតាមប្រព័ន្ធអ៊ីនធើណេត (cyber-attack) ដែលអាចនឹងកើតឡើងដោយយថាហេតុ។

រីឯនៅកម្រិតសុវត្ថិភាពតាមបណ្តាញកុំព្យូទ័រវិញ ធនាគារ ស៊ីអាយអិមបី បានដំឡើងបន្ថែមនូវឧបករណ៍ការពារសុវត្ថិភាព (Firewall) និងការកំណត់លើការចូលប្រើប្រាស់ ដើម្បីគ្រប់គ្រងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ និងធនធានផ្សេងៗ ដែលមានក្នុងបណ្តាញទោះមើលឃើញ ឬមើលពុំឃើញក្តី ហើយអនុញ្ញាតទៅលើការដាក់កំហិតក្នុងការប្រើប្រាស់ និងការផ្តល់សិទ្ធនៅលើប្រព័ន្ធបណ្តាញកុំព្យូទ័រ។ លើសជាងនេះទៅទៀត ធនាគារក៏បានបំពាក់នូវប្រព័ន្ធការពារគ្រប់កុំព្យូទ័រទាំងអស់ដូចជា ការប្រឆាំងមេរោគ (Anti-Malware) ការបំលែងទិន្នន័យ (Encryption) ការទប់ស្កាត់នៃការបាត់បង់ទិន្នន័យ ការពារការជ្រៀតជ្រែក និងត្រោះរាល់ព័ត៌មាននៅលើគេហទំព័រ និងអ៊ីមែល ដែលអាចជួយកាត់បន្ថយហានិភ័យផ្ទៃកសន្តិសុខព័ត៌មានវិទ្យា នៅពេលទិន្នន័យត្រូវបានបញ្ជូនឆ្លងកាត់ប្រព័ន្ធបណ្តាញរបស់ធនាគារ។ និយមន័យមេរោគ និងការកំណត់ទៅលើកម្មវិធីបរិក្ខារខាងលើ តែងតែទទួលបានការធ្វើបច្ចុប្បន្នភាពឲ្យទាន់សភាពការណ៍ជានិច្ច ដើម្បីឲ្យពួកគេមានសមត្ថភាពការពារ ទប់ស្កាត់ និងកាត់បន្ថយនូវភាពងាយរងគ្រោះផ្សេងៗ។

ធនាគារក៏បានអនុវត្តកម្មវិធីលើកកម្ពស់សន្តិសុខព័ត៌មាន ដោយបានបណ្តុះបណ្តាលចំណេះដឹងទៅដល់បុគ្គលិកដែលជាមុខព្រួញ ដើម្បីបង្កើនការយល់ដឹងអំពីភាពជាងកជន ការលេចធ្លាយនៃព័ត៌មាន សុវត្ថិភាពព័ត៌មាន និងទំនួលខុសត្រូវលើផ្នែកសន្តិសុខព័ត៌មាន។ កម្មវិធីទាំងនេះមានដូចជា ការបណ្តុះបណ្តាលតាមប្រព័ន្ធសិក្សាអេឡិកត្រូនិកនឹងត្រូវប្រលងជារៀងរាល់ឆ្នាំ និងការចែកចាយជាព្រឹត្តិបត្រព័ត៌មានផ្សេងៗ។

ដំណើរការនៃការត្រួតពិនិត្យផ្ទៃក្នុងសំខាន់ៗ

ដំណើរការសំខាន់ៗដែលក្រុមប្រឹក្សាភិបាលបានបង្កើតឡើង ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់ និងសុចរិតភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង រួមបញ្ចូលទាំងការអនុវត្តតាមច្បាប់ បទប្បញ្ញត្តិ វិធាន សេចក្តីណែនាំ និងគោលការណ៍ណែនាំ ដែលមានជាធរមានមានដូចខាងក្រោម៖

គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្ម មានសមាជិកជាអភិបាលឯករាជ្យមិនប្រតិបត្តិ។ គណៈកម្មាធិការសវនកម្ម គឺជាគណៈកម្មាធិការមួយ ដែលទទួលបានការផ្ទេរសិទ្ធិអំណាចពីក្រុមប្រឹក្សាភិបាល ដើម្បីទទួលខុសត្រូវលើការត្រួតពិនិត្យការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ការផ្សព្វផ្សាយព័ត៌មាន ការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ការគ្រប់គ្រងហានិភ័យ ការអនុវត្តអភិបាលកិច្ច និងការតាមដានដំណើរការនៃការគ្រប់គ្រងលើការត្រួតពិនិត្យផ្ទៃក្នុងនៅក្នុងធនាគារ។ គណៈគ្រប់គ្រងជាន់ខ្ពស់ សវនករផ្ទៃក្នុង និងសវនករខាងក្រៅ ផ្តល់របាយការណ៍ជូនគណៈកម្មាធិការសវនកម្មអំពីប្រសិទ្ធភាព និងប្រសិទ្ធផលនៃការត្រួតពិនិត្យផ្ទៃក្នុង។

រាល់បញ្ហាសំខាន់ៗ និងគួរឲ្យកត់សម្គាល់ ដែលបានរកឃើញដោយសវនករផ្ទៃក្នុង សវនករខាងក្រៅ និងនិយ័តករត្រូវរាយការណ៍ទៅគណៈកម្មាធិការសវនកម្ម ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញ និងពិភាក្សា។ គណៈកម្មាធិការសវនកម្មត្រួតពិនិត្យឡើងវិញ និងធានាអំពីការអនុវត្តផែនការកាត់បន្ថយបញ្ហា ឬហានិភ័យរបស់គណៈគ្រប់គ្រង ដើម្បីការពារផលប្រយោជន៍របស់ធនាគារ និងរក្សាបានល្អនូវអភិបាលកិច្ចដ៏សមស្រប។ ការគ្រប់គ្រងផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ដែលត្រូវបានចាត់ថ្នាក់ថា មាន «ហានិភ័យលើសពីកម្រិតមធ្យម» ឬ «ហានិភ័យកម្រិតខ្ពស់» ដោយសវនករផ្ទៃក្នុងត្រូវទទួលការពិគ្រោះយោបល់ពីគណៈកម្មាធិការសវនកម្ម។

គណៈកម្មាធិការសវនកម្ម ក៏ធ្វើការត្រួតពិនិត្យឡើងវិញផងដែរនូវរាល់ប្រតិបត្តិការជាមួយភាគីសម្ព័ន្ធញាតិ ថ្លៃចំណាយលើសវនកម្ម និងថ្លៃចំណាយមិនពាក់ព័ន្ធនឹងកិច្ចការសវនកម្ម ដែលស្នើដោយសវនករខាងក្រៅរបស់ធនាគារ។

ការធ្វើបទបង្ហាញនានាអំពីផែនការអាជីវកម្ម ការវិវឌ្ឍថ្មីៗ ប្រតិបត្តិការនានា ហានិភ័យនៃអាជីវកម្ម និងការត្រួតពិនិត្យនានា ដើម្បីកាត់បន្ថយហានិភ័យត្រូវបានធ្វើឡើងដោយផ្នែកអាជីវកម្មពាក់ព័ន្ធ និងផ្នែកគាំទ្រអាជីវកម្ម ប្រសិនបើគណៈកម្មាធិការសវនកម្មគិតថាចាំបាច់។

សមាជិកគណៈកម្មាធិការសវនកម្ម ក៏ចូលរួមកិច្ចប្រជុំកំពូលរបស់គណៈគ្រប់គ្រងប្រចាំឆ្នាំរបស់ធនាគារ (Bank's Annual Management Summit) ផងដែរ ដែលនៅក្នុងកិច្ចប្រជុំនោះ ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មនីមួយៗធ្វើការ ត្រួតពិនិត្យឡើងវិញ នូវប្រតិបត្តិការនានារបស់ខ្លួនដែលបានធ្វើឡើងសម្រាប់ឆ្នាំនេះ ព្រមទាំងធ្វើការបង្ហាញអំពីយុទ្ធសាស្ត្រ និងផែនការនានា សម្រាប់ឆ្នាំបន្ទាប់ផងដែរ។

គណៈកម្មាធិការហានិភ័យ

គណៈកម្មាធិការហានិភ័យកំណត់អំពីកម្មវត្ថុនៃគោលការណ៍ហានិភ័យរបស់ធនាគារ និងបំពេញតួនាទី និងកាតព្វកិច្ចជំនួសឲ្យក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យលើការគ្រប់គ្រងហានិភ័យ។ ការទទួលខុសត្រូវចំពោះការត្រួតពិនិត្យលើការគ្រប់គ្រងហានិភ័យប្រចាំថ្ងៃ ត្រូវបានប្រគល់សិទ្ធិជូនទៅគណៈកម្មាធិការហានិភ័យ ដែលទទួលបន្ទុករាយការណ៍ដោយផ្ទាល់ទៅក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការហានិភ័យធ្វើការជួបប្រជុំជារៀងរាល់ខែ ឬតាមការចាំបាច់។

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម រាយការណ៍អំពីហានិភ័យសាច់ប្រាក់ងាយស្រួល និងបញ្ហាទាក់ទងនឹងទ្រព្យសកម្ម និងទ្រព្យអកម្មរបស់ធនាគារទៅគណៈកម្មាធិការហានិភ័យ។ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម ធ្វើការប្រជុំជារៀងរាល់ខែ ដោយមានតួនាទីចម្បងក្នុងការពិនិត្យតាមដាន និងដោយប្រើយុទ្ធសាស្ត្រគ្រប់គ្រង លើហានិភ័យហិរញ្ញវត្ថុនៃតារាងតុល្យការ។ គណៈកម្មាធិការនេះមានការទទួលខុសត្រូវជាក់លាក់ ចំពោះការគ្រប់គ្រងលើថ្លៃដើមឥណទាន ការរៀបចំអភិវឌ្ឍបន្ថែមលើការផ្តល់ប្រឹក្សាដែលសមស្រប ជូនគណៈកម្មាធិការហានិភ័យក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងហានិភ័យសាច់ប្រាក់ងាយស្រួល និងហានិភ័យអត្រាការប្រាក់ ការបែងចែកប្រភពហិរញ្ញប្បទាន និងការត្រួតពិនិត្យឡើងវិញ នូវសមាសភាពក្នុងតារាងតុល្យការពាក់ព័ន្ធនឹងឥណទាន និងប្រាក់បញ្ញើរបស់ធនាគារ។ ជារួមមកគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម ត្រួតពិនិត្យមើលការអនុវត្តនៃដំណើរការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព សម្រាប់គ្រប់គ្រងលើអត្រាការប្រាក់ សាច់ប្រាក់ងាយស្រួល និងហានិភ័យស្រដៀងគ្នាផ្សេងៗទៀត ដែលទាក់ទងនឹងតារាងតុល្យការរបស់ធនាគារ និងកម្រិតពាក់ព័ន្ធផ្សេងទៀត។

គណៈកម្មាធិការគ្រប់គ្រង

គណៈកម្មាធិការគ្រប់គ្រង គឺជាគណៈកម្មាធិការដែលបង្កើតឡើងដោយក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងបញ្ហាដែលកើតពីការធ្វើប្រតិបត្តិការប្រចាំថ្ងៃ។ កិច្ចប្រជុំគណៈកម្មាធិការនេះធ្វើឡើង រៀងរាល់មួយខែម្តង គឺនៅសប្តាហ៍ទី៣ នៃខែនីមួយៗ ឬតាមការចាំបាច់។ សមាសភាពរបស់គណៈកម្មាធិការគ្រប់គ្រងរួមមានសមាជិកមកពីនាយកដ្ឋាននានា រួមបញ្ចូលទាំងតំណាងមកពីនាយកដ្ឋានសវនករផ្ទៃក្នុងមួយរូប និងនាយកដ្ឋានប្រតិបត្តិតាមមួយរូប ដែលត្រូវបានអញ្ជើញចូលរួមប្រជុំជាអចិន្ត្រៃយ៍។

គោលការណ៍ និងនីតិវិធីផ្ទៃក្នុង

រាល់គោលការណ៍ និងនីតិវិធីផ្ទៃក្នុងរបស់ផ្នែកអាជីវកម្មទាំងអស់ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ គោលការណ៍ និងនីតិវិធីទាំងអស់នេះ ត្រូវបានប្រើប្រាស់ជាឧបករណ៍នាំផ្លូវមួយម្រាប់ការធ្វើប្រតិបត្តិការប្រចាំថ្ងៃ ដើម្បីធានាអំពីការប្រតិបត្តិតាមការត្រួតពិនិត្យផ្ទៃក្នុង និងបទប្បញ្ញត្តិច្បាប់ដែលមានជាធរមាន។ គោលការណ៍នេះរៀបចំឡើងក្នុងគោលបំណងធានាប្រសិទ្ធភាពនៃប្រតិបត្តិការឲ្យកាន់តែមានភាពប្រសើរឡើង ដោយធ្វើការពិចារណាផងដែរ ទៅលើបម្រែបម្រួលនៃវិស័យធនាគារ ដូចជាលក្ខខណ្ឌតម្រូវរបស់ច្បាប់ ហានិភ័យ និងវិធានការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីកាត់បន្ថយហានិភ័យ ព្រមទាំងផលិតផល និងសេវាកម្មថ្មីៗផងដែរ។

សវនកម្មផ្ទៃក្នុង

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ធ្វើការរាយការណ៍ដោយឯករាជ្យជូនគណៈកម្មាធិការសវនកម្ម ហើយនាយកដ្ឋានសវនកម្មផ្ទៃក្នុង មានឯករាជ្យភាពគ្រប់គ្រាន់ពីផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មផ្សេងទៀតលើគ្រប់សកម្មភាព និងប្រតិបត្តិការទាំងអស់។ ការទទួលខុសត្រូវចម្បងរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង គឺផ្តល់ការវាយតម្លៃឯករាជ្យលើភាពគ្រប់គ្រាន់ ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រងហានិភ័យ ដំណើរការគ្រប់គ្រង និងការត្រួតពិនិត្យ ដែលអនុវត្តដោយគណៈគ្រប់គ្រង។ ក្នុងការវាយតម្លៃទៅលើការត្រួតពិនិត្យផ្ទៃក្នុង នាយកដ្ឋានសវនកម្មផ្ទៃក្នុងអនុវត្តតាមសមាសភាគទាំងប្រាំ (៥) ដែលចែងនៅក្នុងក្របខណ្ឌរួមនៃការត្រួតពិនិត្យផ្ទៃក្នុង ដែលដាក់ចេញដោយគណៈកម្មាធិការ Committee of Sponsoring Organisations of the Treadway Commission (COSO) ដែលសមាសភាគទាំងនោះរួមមាន ស្ថានភាពនៃការត្រួតពិនិត្យ ការវាយតម្លៃហានិភ័យ សកម្មភាពត្រួតពិនិត្យ ការទំនាក់ទំនង និងព័ត៌មាន ហើយនឹងការពិនិត្យតាមដានសកម្មភាព។ COSO គឺជាអង្គភាពមួយដែលទទួលស្គាល់ជាអន្តរជាតិដែលផ្តល់សេចក្តីណែនាំ និងភាពជាអ្នកដឹកនាំផ្នែកទស្សនៈលើការត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យរបស់សហគ្រាស និងការទប់ស្កាត់ការកេងបន្លំ។

វិសាលភាពការងាររបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងគ្របដណ្តប់លើគ្រប់ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មទាំងអស់។ ការជ្រើសយកផ្នែកណាមួយមកធ្វើសវនកម្ម ត្រូវធ្វើឡើងដោយផ្អែកលើផែនការសវនកម្មប្រចាំឆ្នាំដែលត្រូវបានអនុម័តដោយគណៈកម្មាធិការសវនកម្ម។ ផែនការសវនកម្មប្រចាំឆ្នាំត្រូវបានបង្កើតឡើង ផ្អែកតាមការវាយតម្លៃកម្រិតហានិភ័យ គោលដៅ និងយុទ្ធសាស្ត្ររបស់ធនាគារ។ ផ្នែកទាំងឡាយណាដែលត្រូវបានវាយតម្លៃថាមានហានិភ័យកម្រិតខ្ពស់ គឺជាកម្មវត្ថុនៃការធ្វើសវនកម្មប្រចាំឆ្នាំ រីឯផ្នែកដែលទទួលការវាយតម្លៃថាមានហានិភ័យកម្រិតមធ្យម ឬទាប គឺជាកម្មវត្ថុនៃការធ្វើសវនកម្ម នៅវគ្គបន្តបន្ទាប់។ ក្រៅពីការវាយតម្លៃលើហានិភ័យ ផែនការសវនកម្មប្រចាំឆ្នាំបានដាក់បញ្ចូលផងដែរនូវនាយកដ្ឋាននានា ដែលត្រូវទទួលការធ្វើសវនកម្ម ដែលតម្រូវដោយបទប្បញ្ញត្តិច្បាប់ឬការកើតមាននូវការលួចបន្លំនាពេលថ្មីៗ ឬក៏ការទទួលការវាយតម្លៃថាមានហានិភ័យកម្រិតខ្ពស់កាលពីឆ្នាំចាស់ ឬចំណាត់ការថ្មីៗដាក់ចេញដោយនិយ័តករ ដោយផ្អែកតាមប្រតិបត្តិការទីផ្សារ ឬចំណាត់ការផ្សេងពីនេះ ព្រឹត្តិការណ៍ខាតបង់ទាំងឡាយណា ដែលត្រូវបានរាយការណ៍ ហើយដែលមានចំនួនទឹកប្រាក់រហូតដល់ ២៥.០០០ ដុល្លារអាមេរិក ឬលើសពីនេះ ឬការផ្លាស់ប្តូរសំខាន់ៗ ទៅលើប្រព័ន្ធកុំព្យូទ័រ ឬប្រតិបត្តិការ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងក៏ធ្វើការស៊ើបអង្កេតផងដែរ លើការសង្ស័យចំពោះការលួចបន្លំ ដែលប្រព្រឹត្តដោយបុគ្គលិក អតិថិជន និងតតិយជន ហើយផ្តល់អនុសាសន៍កែលម្អឲ្យកាន់តែប្រសើរឡើង ដើម្បីបង្ការកុំឲ្យបញ្ហាដដែលកើតមានឡើងសាជាថ្មីម្តងទៀត និងចាត់វិធានការចំពោះបុគ្គលពាក់ព័ន្ធ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានសិទ្ធិទទួលបានគ្រប់ព័ត៌មានទាំងអស់ ដែលចាំបាច់ដោយគ្មានការដាក់កំហិតក្នុងក្របខណ្ឌនៃការងាររបស់ខ្លួន។ វិសាលភាពការងាររបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងត្រូវបានបង្កើតឡើងដោយយោងតាមស្តង់ដារអន្តរជាតិនៃការប្រកបវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង របស់វិទ្យាស្ថានសវនករអន្តរជាតិ (IIA) និងគោលការណ៍វិណនាំផ្នែកបទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធ។

របាយការណ៍សវនកម្ម គឺជាលទ្ធផលចុងក្រោយនៃការងារសវនកម្ម ដែលបង្ហាញពីវិសាលភាពការងារសវនកម្ម ដែលបានបំពេញការវាយតម្លៃទូទៅនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ជាមួយនឹងព័ត៌មានលម្អិតនៃការរកឃើញដោយសវនកម្ម ការឆ្លើយតបពីគណៈគ្រប់គ្រង និងមតិយោបល់។ គណៈកម្មាធិការសវនកម្ម ធ្វើការត្រួតពិនិត្យឡើងវិញ និងវាយតម្លៃរាល់អញ្ញត្តិកម្ម ឬការមិនប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ដែលបានលើកឡើងដោយនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងតាមដានសកម្មភាពនានា ដើម្បីធានាថាគណៈគ្រប់គ្រងបានចាត់វិធានការកែតម្រូវសមស្រប និងជាបន្ទាន់។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដាក់ជូននូវរបាយការណ៍ទៅកាន់គណៈកម្មាធិការសវនកម្មរបស់ក្រុមហ៊ុនមេជារៀងរាល់មួយត្រីមាសម្តង។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងរៀបចំផែនការសវនកម្ម និងការចាត់ថ្នាក់សវនកម្ម ដោយអនុវត្តតាមវិធីសាស្ត្រដូចគ្នា ទៅនឹងវិធីសាស្ត្ររបស់សវនកម្មនៃក្រុមហ៊ុនមេ ដោយធ្វើការកែសម្រួល ប្រសិនបើចាំបាច់ ដើម្បីឲ្យសមស្របទៅនឹងបទប្បញ្ញត្តិ និងបរិយាកាសក្នុងស្រុក។

ក្របខណ្ឌនៃការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់

ក្រុមប្រឹក្សាភិបាលទទួលស្គាល់ថាមុខងារប្រតិបត្តិតាម គឺជាផ្នែកមួយសំខាន់ក្នុងការគ្រប់គ្រងរបស់ធនាគារ និងការត្រួតពិនិត្យផ្ទៃក្នុង ពីព្រោះវប្បធម៌នៃការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ដ៏រឹងមាំឆ្លុះបញ្ចាំងពីវប្បធម៌សាជីវកម្មដែលប្រកបដោយសុចរិតភាព និងក្រមសីលធម៌ខ្ពស់។

មុខងារការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់របស់ធនាគារ ត្រូវបានដឹកនាំដោយនាយកដ្ឋានប្រតិបត្តិតាម រួមជាមួយនឹងការប្រឹក្សាយោបល់ ក៏ដូចជាការណែនាំពីនាយកដ្ឋានច្បាប់ និងប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់របស់ក្រុមហ៊ុនមេ ដែលមានការិយាល័យនៅប្រទេសម៉ាឡេស៊ី។ មុខងារចម្បងរបស់នាយកដ្ឋានប្រតិបត្តិតាម គឺជួយសម្រួលផ្តល់ជំហ៊ីនាន តាមដាន អប់រំដល់ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ឲ្យអនុវត្តតាមច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍វិណនាំនានា។ ស្របតាមអភិបាលកិច្ចល្អ នាយកដ្ឋានប្រតិបត្តិតាមធ្វើការរាយការណ៍ទៅក្រុមប្រឹក្សាភិបាល ដោយឯករាជ្យ។

ធនាគារបានបង្កើតឲ្យមានក្របខណ្ឌនៃការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ ដែលតម្រូវឲ្យផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មទាំងអស់ត្រូវបង្កើតទម្រង់ត្រួតពិនិត្យការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ (Compliance Matrix) ដោយរួមបញ្ចូលនូវច្បាប់ បទប្បញ្ញត្តិ សេចក្តីណែនាំផ្សេងៗដែលពាក់ព័ន្ធនឹងការអនុវត្ត។ ទម្រង់ត្រួតពិនិត្យការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់តម្រូវឲ្យមានការធ្វើបច្ចុប្បន្នភាពចំពោះច្បាប់ បទប្បញ្ញត្តិ សេចក្តីណែនាំដែលត្រូវបានកែប្រែ ឬបង្កើតថ្មី ដើម្បីធានាលើការប្រតិបត្តិតាម។ ជាមួយគ្នានេះដែរ ផ្នែកអាជីវកម្ម ក៏ដូចជា ផ្នែកគាំទ្រអាជីវកម្ម បានអនុវត្តការវិភាគរាល់បទប្បញ្ញត្តិ គោលការណ៍វិណនាំដែលបានបង្កើតថ្មី ឬធ្វើវិសោធនកម្ម ដើម្បីធានាការប្រតិបត្តិតាមទៅលើច្បាប់ បទប្បញ្ញត្តិ គោលការណ៍វិណនាំទាំងនោះ។

បន្ថែមលើនោះទៀត ផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្មក៏ត្រូវធ្វើតេស្តដោយខ្លួនឯង (Self-Testing) តាមទម្រង់ត្រួតពិនិត្យការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ផងដែរ ហើយនាយកដ្ឋានប្រតិបត្តិតាមធ្វើការផ្ទៀងផ្ទាត់ លើលទ្ធផលនៃការធ្វើតេស្ត ដោយខ្លួនឯងនោះដោយឯករាជ្យ។ បន្ថែមពីនេះទៀត នាយកដ្ឋានប្រតិបត្តិតាមក៏បានអនុវត្តការត្រួតពិនិត្យឡើងវិញ (ដោយការចុះត្រួតពិនិត្យដល់ទីកន្លែង និងត្រួតពិនិត្យលើឯកសារផ្សេងៗ) ទៅលើផ្នែកអាជីវកម្ម និងផ្នែកគាំទ្រអាជីវកម្ម ផ្អែកតាមផែនការនៃការប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ (Compliance Work Plan) ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ លើសពីនេះទៅទៀត កម្មវិធីបណ្តុះបណ្តាលដែលបានកំណត់ទុក ត្រូវបានធ្វើឡើងយ៉ាងទៀងទាត់ ដើម្បីបង្កើតការយល់ដឹងអំពីក្របខណ្ឌនៃការប្រតិបត្តិតាម និងដើម្បីសម្រួលដល់ការអនុវត្ត សម្រាប់ធនាគារទាំងមូល។

ក្រុមប្រឹក្សាភិបាលក៏ត្រូវបានផ្តល់ជូននូវរបាយការណ៍ប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់ យ៉ាងទៀងទាត់ ដើម្បីឲ្យក្រុមប្រឹក្សាភិបាលយល់ច្បាស់ អំពីបញ្ហាប្រតិបត្តិតាមបទប្បញ្ញត្តិច្បាប់របស់ធនាគារ។

គោលការណ៍ និងនីតិវិធីនៃការអនុម័តលើផលិតផលថ្មី

គោលការណ៍ និងនីតិវិធីនៃការអនុម័ត លើផលិតផលថ្មី ត្រូវបានដាក់ឲ្យអនុវត្ត សម្រាប់គ្រប់ផលិតផល និងសេវាកម្មថ្មីៗទាំងអស់របស់ធនាគារ។ ផលិតផលថ្មី គឺសំដៅទៅលើផលិតផល និង/ឬសេវាកម្មទាំងឡាយណា ដែលផ្តល់ជូនដំបូងដោយធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី ឬជាការបញ្ចូល

ផលិតផលច្រើនជាផលិតផលតែមួយ ឬបម្រែបម្រួលទម្រង់របស់ ផលិតផលដែលមានស្រាប់ និង/ឬ សេវាកម្ម ដែលមានការប្រែប្រួលខ្លាំងនូវទម្រង់ហានិភ័យ ដូចដែលបានកំណត់ដោយនាយកដ្ឋានគ្រប់គ្រងហានិភ័យ។ គ្រប់សំណើសុំការអនុម័តលើផលិតផលថ្មី ត្រូវឆ្លងកាត់ដំណើរការនៃការត្រួតពិនិត្យហានិភ័យ ឲ្យបានស៊ីជម្រៅដោយអ្នកពាក់ព័ន្ធនានាទាំងនៅក្នុងធនាគារ និងនៅក្នុងក្រុមហ៊ុនមេ ដើម្បីធានាថាគ្រប់ផ្នែកសំខាន់ៗ និងផ្នែកដែលពាក់ព័ន្ធនឹងហានិភ័យ ត្រូវបានកំណត់ វាយតម្លៃ និងកាត់បន្ថយហានិភ័យ មុនពេលដំណើរការផលិតផល និង/ឬសេវាកម្មថ្មីៗនោះ។ បន្ទាប់មក សំណើសុំការអនុម័តលើផលិតផលថ្មីមួយរបស់ធនាគារ ត្រូវឆ្លងកាត់ការពិភាក្សាយ៉ាងហ្មត់ចត់ ដោយគណៈកម្មាធិការនានារបស់ធនាគារ និងក្រុមហ៊ុនមេ មុននឹងដាក់ជូនគណៈកម្មាធិការហានិភ័យ ដើម្បីធ្វើការអនុម័តចុងក្រោយ និងជូនដំណឹងអំពីការអនុម័តនេះទៅក្រុមប្រឹក្សាភិបាល។

ការគ្រប់គ្រងលើអញ្ញត្តិកម្ម និងការផ្សព្វផ្សាយ

ធនាគារបន្តសង្កត់ធ្ងន់លើសារៈសំខាន់នៃការប្រកាន់ខ្ជាប់នូវការគោរពតាមបទឃ្ស្ញាត្តិច្បាប់ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធីផ្សេងទៀតដើម្បីរក្សាកេរ្តិ៍ឈ្មោះរបស់ធនាគារ។ អញ្ញត្តិកម្ម ត្រូវបានលើកឡើង និងចាត់ចែងឲ្យបានទាន់ពេលវេលាប្រកបដោយតម្លាភាព។ ដើម្បីឈានទៅសម្រេចគោលដៅនេះ ធនាគារបានបង្កើតនូវនីតិវិធីគ្រប់គ្រងលើករណីអញ្ញត្តិកម្ម និងការផ្សព្វផ្សាយ ដើម្បីផ្សព្វផ្សាយករណីអញ្ញត្តិកម្មណាមួយកើតមានឡើង រួមមានការមិនប្រតិបត្តិតាមបទឃ្ស្ញាត្តិច្បាប់ ការមិនគោរពកាតព្វកិច្ច ការលួចបន្លំ និងការមិនគោរពតាមដំណើរការផ្ទៃក្នុង។ នីតិវិធីនេះជួយឲ្យមាននូវវិធានការកែលម្អទាន់ពេលវេលា និងពង្រឹងតម្លាភាព និងការត្រួតពិនិត្យរបស់គណៈគ្រប់គ្រង។

ស្ថិតក្រោមនីតិវិធីនៃការគ្រប់គ្រងលើអញ្ញត្តិកម្ម និងការផ្សព្វផ្សាយរបាយការណ៍ស្តីពីបញ្ហា ដែលកើតមានត្រូវផ្ញើជូន ក្នុងអំឡុងពេល ២៤ ម៉ោងនៃការរកឃើញ ឬនៃការជូនដំណឹងជំបូងបំផុត អំពីបញ្ហាដែលបានកើតឡើង។ ករណីអញ្ញត្តិកម្មទាំងនេះ នឹងត្រូវបានចាត់ចែងដោះស្រាយ ដោយផ្អែកលើភាពធ្ងន់ធ្ងរ និងផលប៉ះពាល់របស់វាទៅលើធុរកិច្ច ប្រតិបត្តិការ និងកេរ្តិ៍ឈ្មោះរបស់ធនាគារ។ ករណីអញ្ញត្តិកម្មនេះត្រូវសង្ខេប និងរាយការណ៍ទៅគណៈកម្មាធិការហានិភ័យប្រចាំខែ។

ក្រមសីលធម៌

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី មានស្តង់ដារក្រមសីលធម៌អប្បបរមាមួយសម្រាប់គ្រប់និយោជិតទាំងអស់របស់ខ្លួន អនុវត្តដែលរួមបញ្ចូលគ្រប់ទិដ្ឋភាពទាំងអស់នៃប្រតិបត្តិការធុរកិច្ចប្រចាំថ្ងៃ។ គោលការណ៍ណែនាំអំពីក្រមសីលធម៌ត្រូវបាន អនុម័តយកតាមក្រមសីលធម៌របស់ក្រុមហ៊ុនមេ និងបានដាក់បញ្ចូលនៅក្នុងនៃកិច្ចសន្យាការងារដែលយល់ព្រម និងចុះហត្ថលេខាដោយគ្រប់និយោជិតទាំងអស់។

គោលការណ៍ និងនីតិវិធីស្តីពីធនធានមនុស្ស

គោលការណ៍ និងនីតិវិធីស្តីពីធនធានមនុស្សត្រូវបានបង្កើតឡើង និងប្រើប្រាស់នៅក្នុងក្រុមហ៊ុនមេទាំងមូល ដោយមានវិសាលភាពលើគ្រប់ទិដ្ឋភាពទាំងអស់នៃការគ្រប់គ្រងធនធានមនុស្ស ក្នុងធនាគារ។ គោលការណ៍នេះបានកំណត់យ៉ាងច្បាស់លាស់ អំពីការជ្រើសរើសនិយោជិត ការដំឡើងឋានៈ ការផ្ទេរកន្លែងការងារ និងការបញ្ឈប់និយោជិតនៅក្នុងក្រុមហ៊ុនមេទាំងមូល។ គោលការណ៍ និងនីតិវិធីទាំងនេះត្រូវបានបង្កើតឡើងស្របតាមបទឃ្ស្ញាត្តិក្នុងស្រុកដែលពាក់ព័ន្ធ ដើម្បីធានាការប្រតិបត្តិតាមបទឃ្ស្ញាត្តិត្រូវបានអនុវត្ត។ និយោជិតទទួលការវាយតម្លៃការងាររបស់ខ្លួនជារៀងរាល់ឆ្នាំ ហើយតម្លៃការងារនេះធ្វើឡើង ដោយផ្អែកលើសូចនាករនៃការវាយតម្លៃលទ្ធផលការងារ (Key Performance Indicator) និងការវាស់វែងសមត្ថភាពគន្លឹះ។ កម្មវិធីសិក្សា និងអភិវឌ្ឍសមត្ថភាព ដែលរួមបញ្ចូលទាំងជំនាញ វគ្គបណ្តុះបណ្តាលបច្ចេកទេសត្រូវបានរៀបចំឡើង និងដាក់ឲ្យអនុវត្តក្នុងគោលដៅគាំទ្រ និងបង្កើនសមត្ថភាពនិយោជិត ដើម្បីធានាថានិយោជិតទាំងអស់អាចបំពេញភារកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព។ ធនាគារបានក្រើនរំលឹកដល់និយោជិតរបស់ខ្លួនជារឿយៗ អំពីគោលការណ៍ពាក់ព័ន្ធនានា តាមរយៈសារអេឡិកត្រូនិក ឬការជូនដំណឹងជាលាយលក្ខណ៍អក្សរ និងវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធនានា។ វគ្គបណ្តុះបណ្តាលមួយ ក្នុងចំណោមវគ្គបណ្តុះបណ្តាលផ្សេងទៀតស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មត្រូវបានធ្វើឡើងជារឿយៗ ដើម្បីការបញ្ជាក់ឲ្យឃើញអំពីទស្សនាទានរបស់ក្រុមហ៊ុនមេ ដែលមិនអធ្យាស្រ័យចំពោះអំពើកេងបន្លំ។ ចំណុចនេះក៏បានធ្វើការសង្កត់ធ្ងន់ដែរ នៅក្នុងកម្មវិធីបណ្តុះបណ្តាលតម្រង់ទិសរបស់ក្រុមហ៊ុន។

ការគ្រប់គ្រងនិរន្តរភាពនៃអាជីវកម្ម

ស៊ីអាយអិមប៊ី គ្រុប បានប្តេជ្ញាចិត្តក្នុងការការពារផលប្រយោជន៍របស់ម្ចាស់ភាគហ៊ុន កេរ្តិ៍ឈ្មោះរបស់ស្ថាប័ន និងការបង្កើតគុណតម្លៃ ដោយធានាឲ្យបាននូវនិរន្តរភាពអាជីវកម្ម និងមុខងារបម្រើការផ្សេងៗនៅក្នុងស៊ីអាយអិមប៊ី គ្រុប ទាំងមូល។ ទំនួលខុសត្រូវនៃការអនុវត្ត និងដាក់ឲ្យដំណើរការនូវគោលការណ៍គ្រប់គ្រងនិរន្តរភាពអាជីវកម្ម គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំ និងក្រុមប្រឹក្សាភិបាលរបស់ធនាគារ។

ក្របខណ្ឌនៃការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម (Business Continuity Management) ត្រូវបានជ្រើសយកពីក្រុមហ៊ុនមេ (ស៊ីអាយអិមប៊ី គ្រុប) មកអនុម័ត ដើម្បីកំណត់ឲ្យបានជាអប្បរមានូវកម្រិតនៃការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម ការបែងចែងនូវគោលការណ៍អនុវត្ត សម្រាប់គាំទ្រនាយកដ្ឋានផ្សេងៗ ហើយធ្វើឲ្យបាននូវនិរន្តរភាពអាជីវកម្ម និងសេវាកម្មសំខាន់ៗទាំងឡាយ នៅក្នុងពេលវេលាកំណត់ណាមួយ នៅពេលមានគ្រោះរំខានកើតឡើង។ ក្របខណ្ឌខាងលើមានចែងជាគោលដូចខាងក្រោម៖

(១) រក្សានូវគុណភាពសេវាកម្ម ដើម្បីបង្កើនទំនុកចិត្តដូចការរំពឹងទុករបស់អតិថិជន
(២) កាត់បន្ថយផលប៉ះពាល់ទៅលើអាជីវកម្ម នៅពេលមានគ្រោះរំខានកើតឡើង
(៣) មិនធ្វើឲ្យមានផលអវិជ្ជមានប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ធនាគារ
(៤) រក្សាឲ្យនូវការអនុលោមតាមច្បាប់ គោលការណ៍និរន្តរភាពអាជីវកម្ម និងបទឃ្ស្ញាត្តិផ្សេងៗ

ក្របខណ្ឌនៃការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម តែងតែមានការពិនិត្យឡើងវិញជានិច្ចកាល ដើម្បីធ្វើឲ្យស្របទៅតាមបទដ្ឋានរបស់ ក្រុមហ៊ុនមេ ស្របទៅតាមនីតិវិធីនៃការគ្រប់គ្រង និងការអនុវត្តនិរន្តរភាពអាជីវកម្ម រួមបញ្ចូលទាំងការវិភាគទៅលើមុខងារអាជីវកម្ម និងការបង្កើតនូវយុទ្ធសាស្ត្រនិរន្តរភាពអាជីវកម្ម ការឆ្លើយតបពេលមានគ្រោះរំខាន ការបង្កើតវប្បធម៌យល់ដឹងអំពីនិរន្តរភាពអាជីវកម្ម ការរៀបចំលំហាត់និរន្តរភាពអាជីវកម្ម និងការកែសម្រួលទៅលើផែនការនិរន្តរភាពអាជីវកម្មរបស់នាយកដ្ឋាននីមួយៗ។

ដោយអនុលោមតាមក្របខណ្ឌនៃការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម ផែនការនិរន្តរភាពអាជីវកម្ម ត្រូវបានធ្វើឡើងសម្រាប់មុខងារអាជីវកម្មសំខាន់ៗ ហើយផែនការនិរន្តរភាពពីគ្រោះមហន្តរាយ ត្រូវបានធ្វើឡើងសម្រាប់ប្រព័ន្ធកម្មវិធីផ្សេងៗ។ លំហាត់សាកល្បងលើផែនការទាំងពីរនេះតែងតែត្រូវបានធ្វើឡើងជាប្រចាំ។

លើសពីនេះទៀត ជារៀងរាល់ឆ្នាំធនាគាររៀបចំជាសិក្ខាសាលា អំពីការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម សម្រាប់នាយកដ្ឋានទាំងអស់ឲ្យបានចូលរួម ដើម្បីបង្កើនការយល់ដឹងបន្ថែមទៀត អំពីតួនាទី មុខងារ និងទំនួលខុសត្រូវរបស់ពួកគាត់។

ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

ធនាគារសង្កត់ធ្ងន់លើសារៈសំខាន់ ទៅលើការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងប្តេជ្ញាបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព លើការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT) ដោយការអនុលោមទៅតាមបទឃ្ស្ញាត្តិច្បាប់ គោលការណ៍ណែនាំ និងការអនុវត្តដែលល្អបំផុត សម្រាប់វិស័យធនាគារ។

ធនាគាររក្សាការអនុវត្តតាមគោលនយោបាយ និងនីតិវិធីស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារ និងជាបន្តបន្ទាប់ធ្វើបច្ចុប្បន្នកម្មជារៀងរាល់ពីរឆ្នាំម្តង ឬករណីមានការចាំបាច់ ដើម្បីឆ្លុះបញ្ចាំងពីនិន្នាការ និងយន្តការលើការលាងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

ប្រព័ន្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងប្រព័ន្ធគាំទ្រដទៃទៀតរបស់ធនាគារ បានសម្រួលដល់ការពិនិត្យហានិភ័យប្រឆាំងការសម្អាតប្រាក់ និងតាមដានលើប្រតិបត្តិការ អតិថិជន រួមទាំងសម្រួលដល់ការគ្រប់គ្រង Watchlist (Watchlist Management) ការយកចិត្តទុកដាក់ស្គាល់អតិថិជន (Customer Due Diligence / «Know Your Customer») និងការត្រួតពិនិត្យប្រតិបត្តិការអតិថិជន ដើម្បីការពារនិងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT Alert Monitoring)។ ធនាគារត្រូវធានានូវនីតិវិធី ធនធានមនុស្ស និងប្រព័ន្ធរបស់ធនាគារ មានលទ្ធភាពក្នុងការស្វែងរក និងកំណត់ហានិភ័យ ព្រមទាំងរាយការណ៍ប្រតិបត្តិការសង្ស័យទៅកាន់និយ័តករ។

កម្មវិធីបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងត្រូវបានធ្វើឡើងជាទៀតទាត់។ កម្មវិធីនេះត្រូវបានបំពេញបន្ថែមតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយ ករណីសិក្សាលើប្រតិបត្តិការជាក់ស្តែងអំពីហានិភ័យនៃការសម្អាតប្រាក់ និងការផ្តល់ហិរញ្ញប្បទានភេរវកម្ម ដោយធ្វើការសង្កត់ធ្ងន់លើតួនាទី និងការទទួលខុសត្រូវរបស់និយោជិតនីមួយៗ។ ធនាគារបាន និងបន្តចាត់វិធានការ ដើម្បីកាត់បន្ថយហានិភ័យដែលអាចកើតមាន ចំពោះធនាគារ ពាក់ព័ន្ធនឹងសកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងស្របពេលជាមួយគ្នានេះ ដើម្បីធានានូវការប្រតិបត្តិតាមបទឃ្ស្ញាត្តិច្បាប់ និងគោលការណ៍ណែនាំរបស់អាជ្ញាធរពាក់ព័ន្ធ។

សេចក្ដីសន្និដ្ឋាន

ក្រុមប្រឹក្សាភិបាលមានជំនឿថា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលកំពុងអនុវត្តមានលក្ខណៈគ្រប់គ្រាន់ក្នុងការការពារផលប្រយោជន៍របស់ភាគទុនិក និងទ្រព្យសកម្មរបស់ធនាគារ។ ក្រុមប្រឹក្សាភិបាលទទួលស្គាល់ថា ធនាគារមានដំណើរការប្រកបដោយប្រសិទ្ធភាពឥតឈប់ឈរចំពោះការកំណត់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យធំៗនៅក្នុងធនាគារ និងបានប្តេជ្ញាបន្តធ្វើការត្រួតពិនិត្យឡើងវិញ នូវប្រតិបត្តិការ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ រួមបញ្ចូលទាំងការត្រួតពិនិត្យផ្ទៃកហិរញ្ញវត្ថុ ប្រតិបត្តិការ និងការប្រតិបត្តិតាមបទឃ្ស្ញាត្តិច្បាប់ ព្រមទាំងការគ្រប់គ្រងហានិភ័យផងដែរ។

រចនាសម្ព័ន្ធគ្រប់គ្រងក្រុមហ៊ុនមេ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

ស៊ីអាយអិមប៊ី គ្រុប ហូលឌីង ប៊ើហាដ

១០០%

ស៊ីអាយអិមប៊ី គ្រុប អេសឌីអិន ប៊ើហាដ

៩៩,៩៩%

ធនាគារ ស៊ីអាយអិមប៊ី ប៊ើហាដ

១០០%

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី

រចនាសម្ព័ន្ធក្រុមហ៊ុន

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០)

របាយការណ៍ព័ត៌មានរបស់ធនាគារ

(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០)

ក្រុមប្រឹក្សាភិបាល

Datuk Mohd Nasir Bin Ahmad	ប្រធានក្រុមប្រឹក្សាភិបាល/ អភិបាលឯករាជ្យមិនប្រតិបត្តិ
បណ្ឌិត ម៉ី កល្យាណ	អភិបាលឯករាជ្យមិនប្រតិបត្តិ
Aisyah Lam Binti Abdullah	អភិបាលឯករាជ្យមិនប្រតិបត្តិ
Omar Siddiq Bin Amin Noer Rashid	អភិបាលមិនឯករាជ្យមិនប្រតិបត្តិ
Ahmad Shazli Bin Kamarulzaman	អភិបាលមិនឯករាជ្យមិនប្រតិបត្តិ
ប៊ុន យ៉ីន	អភិបាលមិនឯករាជ្យប្រតិបត្តិ

គណៈកម្មាធិការសវនកម្ម

បណ្ឌិត ម៉ី កល្យាណ	ប្រធាន/អភិបាលឯករាជ្យមិនប្រតិបត្តិ
Datuk Mohd Nasir Bin Ahmad	អភិបាលឯករាជ្យមិនប្រតិបត្តិ
Aisyah Lam Binti Abdullah	អភិបាលឯករាជ្យមិនប្រតិបត្តិ

គណៈកម្មាធិការហានិภัយ

Aisyah Lam Binti Abdullah	ប្រធាន/អភិបាលឯករាជ្យមិនប្រតិបត្តិ
ប៊ុន យ៉ីន	ប្រធាននាយកប្រតិបត្តិ / អភិបាលប្រតិបត្តិ
គឿន វឌ្ឍនា	នាយកគ្រប់គ្រងហានិภัយ
ហុង ជៀប	នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
ហេង ធីតា	នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល
ហេង វិបុត្រ	នាយកបច្ចេកវិទ្យា និងប្រតិបត្តិការ
ហេង រ៉ុន្ធី	នាយកហិរញ្ញវត្ថុ
គី សាណា	នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ

គណៈកម្មាធិការឥណទានកម្ពុជា

គឿន វឌ្ឍនា	ប្រធាន/នាយកគ្រប់គ្រងហានិภัយ
ប៊ុន យ៉ីន	ប្រធានជំនួស/ប្រធាននាយកប្រតិបត្តិ
ហុង ជៀប	នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
ហេង ធីតា	នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល
ចំណាន រ៉ានិតា	ប្រធានគ្រប់គ្រងឥណទាន
John Chuah Keat Kong	ទីប្រឹក្សាឥណទានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
គី សាណា	នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ
ហុង ប៊ុនរ៉ៃត	នាយកផ្នែកអាជីវកម្មនៃសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
Chong Kok Ping	នាយកគ្រប់គ្រងឥណទានថ្នាក់តំបន់
Lim Gek Peng	ប្រធានគ្រប់គ្រងឥណទានពាណិជ្ជកម្ម និងគ្រឹះស្ថានហិរញ្ញវត្ថុ
Michael Ng Mun Seng	នាយកវិភាគហានិภัយឥណទានស្តីទី

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និង ទ្រព្យអកម្ម

ប៊ុន យ៉ីន	ប្រធាន/ប្រធាននាយកប្រតិបត្តិ
ហេង ធីតា	នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល
ហុង ជៀប	នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
ហេង រ៉ុន្ធី	នាយកហិរញ្ញវត្ថុ
ហេង ឆូរ៉ង់	នាយករតនាភិបាល និងទីផ្សារ
គី សាណា	នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ
គឿន វឌ្ឍនា	នាយកគ្រប់គ្រងហានិภัយ

គណៈកម្មាធិការគ្រប់គ្រង

ប៊ុន យ៉ីន	ប្រធាននាយកប្រតិបត្តិ
ហេង ធីតា	នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល
ហេង ឆ្ងាំង	នាយករតនាភិបាល និងទីផ្សារ
ហុង ជៀប	នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម
គឿន វឌ្ឍនា	នាយកគ្រប់គ្រងហានិភ័យ
ហេង រ៉ុទ្ធី	នាយកហិរញ្ញវត្ថុ
អ៊ុំ ចិន្តាភក្តី	នាយកធនធានសាជីវកម្ម
ហេង វិបុត្រ	នាយកបច្ចេកវិទ្យា និងប្រតិបត្តិការ
គី សាណា	នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម សេវាប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុ
អ៊ុក ថានិន	នាយកគ្រប់គ្រងផលិតផល

(អ្នកចូលរួមអចិន្ត្រៃយ៍របស់គណៈកម្មាធិការ រួមមាន នាយកសវនកម្មផ្ទៃក្នុង និងនាយកប្រតិបត្តិតាម)

លេខាធិការក្រុមហ៊ុន៖

លី សោភា

Datin Rossaya Mohd Nashir

លេខចុះបញ្ជី៖

00010524

ការិយាល័យចុះបញ្ជី៖

២០អាបេ មហាវិថីព្រះនរោត្តម កែងផ្លូវ១១៨ សង្កាត់ផ្សារចាស់ រាជធានីភ្នំពេញ ១២២០៣ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ +៨៥៥ ២៣ ៩៨៨ ៣៨៨

ទូរសារ៖ +៨៥៥ ២៣ ៩៨៨ ០៩៩

គេហទំព័រ៖ www.cimbbank.com.kh

សវនករ៖

PricewaterhouseCoopers (Cambodia) Ltd.

៥៨C មហាវិថីព្រះសីហនុ ខណ្ឌចំការមន

រាជធានីភ្នំពេញ ១២២១០

ប្រអប់សំបុត្រ៖ ១១៤៧

ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៦០ ៦០៦

ទូរសារ៖ +៨៥៥ ២៣ ២១១ ៥៩៨

ព្រឹត្តិការណ៍សំខាន់ៗ និង ការចុះផ្សាយក្នុងសារព័ត៌មាន នៅឆ្នាំ២០២០

៥៨ ព្រឹត្តិការណ៍សំខាន់ៗ
៦៤ ការចុះផ្សាយក្នុងសារព័ត៌មាន

ឆ្នាំ

ខួប១០ឆ្នាំ នៃប្រតិបត្តិការ

នៅប្រទេសកម្ពុជា

ព្រឹត្តិការណ៍សំខាន់ៗ

ថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

កម្មវិធីដាំកូនឈើ និងបរិច្ចាគសម្ភារៈសិក្សា នៅវិទ្យាល័យកំពង់ថ្ម ខេត្តកំពង់ធំ

ជាផ្នែកមួយនៃសកម្មភាពទំនួលខុសត្រូវសង្គម ដើម្បីជួយត្រឡប់ទៅដល់សង្គមដែលយើងកំពុងប្រកបអាជីវកម្ម ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី បានចូលរួម ក្នុងសកម្មភាពសប្បុរសធម៌ ដែលបានរៀបចំដោយធនាគារជាតិ នៃកម្ពុជា នៅវិទ្យាល័យកំពង់ថ្ម ខេត្តកំពង់ធំ។ កម្មវិធីនេះមានការរៀបចំសកម្មភាពដាំកូនឈើ និងការបរិច្ចាគសម្ភារៈសិក្សា ទៅដល់វិទ្យាល័យ ដើម្បីលើកកម្ពស់វិស័យអប់រំ និងផ្សារភ្ជាប់សិស្សានុសិស្សទាំងអស់ ចូលរួមថែរក្សាដើមឈើ និងយល់ដឹងពីសារៈសំខាន់របស់ដើមឈើ ចំពោះផ្នែកបរិស្ថាន។

ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០

ពិធីប្រគល់អាហារូបករណ៍ របស់ធនាគារ ស៊ីអាយអ៊ីមប៊ី នៅការិយាល័យកណ្តាល អគារ Exchange Square រាជធានីភ្នំពេញ

ការអប់រំ គឺជាវិស័យស្នូលមួយ នៃកម្មវិធីទំនួលខុសត្រូវសង្គម ដែលធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី តែងតែឧបត្ថម្ភជារៀងរាល់ឆ្នាំ ដល់និស្សិតខ្វះខាត មកពីអង្គការដៃគូនានារបស់ធនាគារ ដើម្បីមានលទ្ធភាពបន្តការសិក្សាថ្នាក់បរិញ្ញាបត្ររបស់ពួកគេ នៅតាមសាកលវិទ្យាល័យក្នុងស្រុក ដែលពួកគេជ្រើសរើស។ ធនាគារបានផ្តល់អាហារូបករណ៍ពេញលេញ ទៅដល់និស្សិតចំនួន ៣រូប មកពីអង្គការមូលនិធិកុមារ (អង្គការ CCF) ដោយរ៉ាប់រងលើថ្លៃសិក្សា និងការចំណាយពាក់ព័ន្ធផ្សេងៗទៀត រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។

ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០

កម្មវិធីបរិច្ចាគឈាម របស់ធនាគារ ស៊ីអាយអ៊ីមប៊ី នៅការិយាល័យកណ្តាល អគារវ៉ីត្រាស់ រាជធានីភ្នំពេញ

ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី ដោយមានកិច្ចសហការពីមជ្ឈមណ្ឌលជាតិផ្តល់ឈាម បានរៀបចំកម្មវិធីបរិច្ចាគឈាម ដោយមានការចូលរួមពីគណៈគ្រប់គ្រង និងបុគ្គលិករបស់ធនាគារ ដែលបានស្ម័គ្រចិត្តបរិច្ចាគឈាម។ ព្រឹត្តិការណ៍នេះត្រូវបានបង្កើតឡើងមិនត្រឹមតែដើម្បីជួយសង្គ្រោះអាយុជីវិតជនរងគ្រោះប៉ុណ្ណោះទេ តែថែមទាំងលើកកម្ពស់ការយល់ដឹងរបស់បុគ្គលិក ពីបញ្ហាប្រឈម ដែលអ្នកជំងឺសង្គ្រោះបន្ទាន់កំពុងជួបប្រទះ។

កម្មវិធីទំនួលខុសត្រូវសង្គម

ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០

ពិធីប្រគល់អាហារូបករណ៍តំបន់អាស៊ាន របស់ធនាគារ ស៊ីអាយអិមប៊ី នៅការិយាល័យកណ្តាល អគារ Exchange Square រាជធានីភ្នំពេញ

និស្សិតឆ្នើមចំនួន ១៥រូប មកពីប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី សិង្ហបុរី ថៃ ហ្វីលីពីន វៀតណាម និងកម្ពុជា បានឈ្នះអាហារូបករណ៍តំបន់អាស៊ានរបស់ធនាគារ ស៊ីអាយអិមប៊ី ដើម្បីបន្តការសិក្សារបស់ខ្លួន នៅសាកលវិទ្យាល័យល្បីឈ្មោះនានា ក្នុងតំបន់អាស៊ាន និងជុំវិញពិភពលោក។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានរៀបចំពិធីប្រគល់អាហារូបករណ៍នេះ ដើម្បីអបអរសាទរ និងជូនពរ ដល់និស្សិតជ័យលាភីខ្មែរមួយរូប ដែលទទួលបានអាហារូបករណ៍ដ៏មានតម្លៃនេះ ក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យ ដែលខ្លួនពេញចិត្ត។

ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២០

កម្មវិធីដាំកូនឈើ និងពិធីអបអរខួបគម្រប់១០ឆ្នាំ របស់ធនាគារ ស៊ីអាយអិមប៊ី នៅប្រាសាទបន្ទាយក្តី ខេត្តសៀមរាប

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដោយមានកិច្ចសហការពីរដ្ឋបាលខេត្តសៀមរាប និងអាជ្ញាធរជាតិអប្សរា បានរៀបចំកម្មវិធីដាំកូនឈើ ក្នុងតំបន់រមណីយដ្ឋានប្រាសាទបន្ទាយក្តី ក្នុងខេត្តសៀមរាប។ ដោយមានការចូលរួមពីភ្ញៀវកិត្តិយសប្រមាណ ៥០០នាក់ កម្មវិធីនេះត្រូវបានចូលរួមជាអធិបតីភាព ពីអ្នកតំណាងអភិបាលខេត្តសៀមរាប និងអាជ្ញាធរជាតិអប្សារ ព្រមទាំងប្រធាននាយកប្រតិបត្តិរបស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។

ជាផ្នែកមួយ នៃសកម្មភាពទំនួលខុសត្រូវសង្គម ដើម្បីជួយត្រឡប់ ទៅដល់សង្គម ដែលយើងកំពុងប្រកបអាជីវកម្ម ធនាគារបានឧបត្ថម្ភ ក្នុងការរៀបចំកម្មវិធីនេះ ព្រមទាំងបានដាំកូនឈើជាង ១.៥០០ដើម ដើម្បីថែរក្សាបរិស្ថាន និងលើកកម្ពស់វិស័យទេសចរណ៍ និងបេតិកភណ្ឌជាតិ ក្នុងតំបន់រមណីយដ្ឋានអង្គរ ក៏ដូចជាអបអរសាទខួបគម្រប់១០ឆ្នាំ នៃដំណើរការអាជីវកម្មរបស់ធនាគារ ក្នុងប្រទេសកម្ពុជា។

ព្រឹត្តិការណ៍សំខាន់ៗ

ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០

កម្មវិធីបរិច្ចាគ ដល់ជនរងគ្រោះទឹកជំនន់ នៅរាជធានីភ្នំពេញ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានបរិច្ចាគប្រាក់ចំនួន ៤០លានរៀល ដល់ជនរងគ្រោះទឹកជំនន់ នៅតាមបណ្តាខេត្ត ដែលរងគ្រោះដោយគ្រោះមហន្តរាយទឹកជំនន់។ ជាផ្នែកមួយ នៃការរួមចំណែកជួយដល់រាជរដ្ឋាភិបាល ធនាគារជឿជាក់ថា ជំនួយសង្គ្រោះបន្ទាន់នេះនឹងជួយបំពេញតម្រូវការចាំបាច់ប្រចាំថ្ងៃ ក្នុងគ្រាអាសន្ន រួមមានម្ហូបអាហារ ថ្នាំ សង្ហរ និងសម្ភារៈប្រើប្រាស់ផ្សេងៗ ដល់ជនរងគ្រោះ ដែលត្រូវបានជាប់គាំង និងកាត់ផ្តាច់ ពីមធ្យោបាយធ្វើដំណើរ ខណៈដែលលំនៅស្ថានរបស់ពួកគេត្រូវបានខូចខាត ពីគ្រោះមហន្តរាយទឹកជំនន់។

ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២០

កម្មវិធីដាំកូនឈើ និងបរិច្ចាគសម្ភារៈសិក្សា របស់ធនាគារ ស៊ីអាយអិមប៊ី នៅវិទ្យាល័យ ព្រៃកដំបូក ខេត្តកំពង់ចាម

បរិស្ថាន និងការអប់រំ គឺវិស័យសួលសំខាន់ នៃកម្មវិធីទំនួលខុសត្រូវសង្គម ដែលធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី តែងតែយកចិត្តទុកដាក់ខ្ពស់។ ធនាគារបានរៀបចំកម្មវិធីសប្បុរសធម៌មួយ នៅវិទ្យាល័យ ព្រៃកដំបូក ក្នុងខេត្តកំពង់ចាម ដែលរួមមានការបរិច្ចាគថវិកាសាងសង់អគារសិក្សាមួយខ្នង ដើម្បីលើកកម្ពស់វិស័យអប់រំ និងការដាំកូនឈើ ដើម្បីផ្សារភ្ជាប់សិស្សានុសិស្សទាំងអស់ ចូលរួមចៃរក្សាដើមឈើ និងយល់ដឹងពីសារៈខាន់របស់ដើមឈើ ចំពោះផ្នែកបរិស្ថាន។

ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០

ទិវានារីអន្តរជាតិរបស់ធនាគារ ស៊ីអាយអិមប៊ី
នៅមជ្ឈមណ្ឌល Factory រាជធានីភ្នំពេញ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានប្រារព្ធទិវានារីអន្តរជាតិ ក្រោមអធិបតីភាពរបស់ប្រធាននាយកប្រតិបត្តិ និងគណៈគ្រប់គ្រងរបស់ធនាគារ រួមទាំងបុគ្គលិក និងភ្ញៀវកិត្តិយសប្រមាណ ១០០នាក់។ កម្មវិធីនេះត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់ការយល់ដឹង អំពីសារៈសំខាន់របស់ស្ត្រី ក្នុងការអភិវឌ្ឍសង្គម និងជាផ្នែកមួយ នៃការអបអរដល់ស្ត្រី ក្នុងប្រទេសកម្ពុជា និងជុំវិញពិភពលោក ហើយជាពិសេសសម្តែងសេចក្តីថ្លែងអំណរគុណ ដល់បុគ្គលិកស្ត្រីទាំងអស់របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ីផងដែរ។

ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ | ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០

កិច្ចប្រជុំបុគ្គលិករបស់ធនាគារ ស៊ីអាយអិមប៊ី ឆ្នាំ២០២០
នៅការិយាល័យកណ្តាល អគារ Exchange Square រាជធានីភ្នំពេញ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានរៀបចំកិច្ចប្រជុំបុគ្គលិកប្រចាំឆ្នាំ តាមរយៈប្រព័ន្ធអនឡាញ នៅទូទាំងធនាគារ ខណៈពេលកំពុងរាតត្បាតនៃជំងឺកូវីដ-១៩ ដើម្បីជូនដំណឹងដល់និយោជិតទាំងអស់ អំពីលទ្ធផល និងការវិវឌ្ឍអាជីវកម្ម ក៏ដូចជាពិភាក្សា អំពីយុទ្ធសាស្ត្ររបស់ធនាគារ សម្រាប់ឆ្នាំ២០២០ និងផែនការ សម្រាប់ឆ្នាំ២០២១។ កម្មវិធីនេះផ្តល់ឱកាសឲ្យនិយោជិតនូវក្របខណ្ឌជជែកដោយបើកចំហរ ជាមួយនឹងគណៈគ្រប់គ្រងរបស់ធនាគារ លើកឡើងពីការលំបាករបស់ពួកគេ និងផ្តល់ជាមតិយោបល់ ក្នុងន័យស្ថាបនាផងដែរ។

ព្រឹត្តិការណ៍សំខាន់ៗ

ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២០

ពិធីប្រគល់ពានរង្វាន់ CX STAR របស់ធនាគារ ស៊ីអាយអិមប៊ី នៅការិយាល័យកណ្តាល អគារ Exchange Square រាជធានីភ្នំពេញ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានរៀបចំពិធីប្រគល់ពានរង្វាន់ តាមរយៈប្រព័ន្ធអនឡាញ នៅទូទាំងធនាគារ ខណៈពេលកំពុងរាតត្បាតនៃជំងឺកូវីដ-១៩ ដើម្បីអបអរសាទរដល់ជ័យលាភី CX Star ដែលត្រូវបានទទួលស្គាល់ លើភាពលេចធ្លោនៃការបំពេញការងាររបស់ពួកគេ រួមមានការបំពេញចិត្តអតិថិជនលើសពីការរំពឹងទុក ប្រសិទ្ធផលការងារ និងការផ្តល់ភាពងាយស្រួល នៅកន្លែងការងារ។ កម្មវិធីនេះត្រូវបានបង្កើតឡើង ដើម្បីជាផ្នែកមួយ នៃការជំរុញទឹកចិត្ត ដល់ក្រុមការងារ TeamCIMB ឲ្យកាន់តែបំពេញការងារល្អប្រសើរ ទាំងនៅក្នុងធនាគារ និងការបម្រើសេវាកម្មអតិថិជន។

ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០

ពិធីអបអរខួបគម្រប់១០ឆ្នាំ របស់ធនាគារ ស៊ីអាយអិមប៊ី នៅការិយាល័យកណ្តាល អគារ Exchange Square រាជធានីភ្នំពេញ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ីបានប្រារព្ធពិធីអបអរខួបគម្រប់១០ឆ្នាំនៃការបើកដំណើរការធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា តាមរយៈប្រព័ន្ធអនឡាញ នៅទូទាំងធនាគារ ខណៈពេលកំពុងរាតត្បាតនៃជំងឺកូវីដ-១៩។ នៅក្នុងកម្មវិធីដ៏វិសេសវិសាលនេះ គណៈគ្រប់គ្រង និងបុគ្គលិករបស់ធនាគារ ស៊ីអាយអិមប៊ី ក្នុងប្រទេសកម្ពុជា ទទួលបានការជូនដំណឹងដោយផ្ទាល់ ពីលោកប្រធាននាយកប្រតិបត្តិ អំពីព័ត៌មានសំខាន់ៗ នៃលទ្ធផល និងសមិទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ក្នុងរយៈពេលកន្លងមកនេះ។ ជាការថ្លែងអំណរគុណដល់បុគ្គលិក សម្រាប់ការបន្តគាំទ្រ និងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ ធនាគារបានប្រគល់ពានរង្វាន់ ដល់បុគ្គលិក ដែលបានបម្រើការងាររយៈពេល១០ឆ្នាំ និង៥ឆ្នាំផងដែរ។

ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០

កម្មវិធីចាប់រង្វាន់ របស់ក្រុមហ៊ុន MAZDA
នៅមជ្ឈមណ្ឌល ដឹ ព្រេមៀ សែនសុខ រាជធានីភ្នំពេញ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចូលរួមក្នុងពិព័រណ៍នេះ ក្នុងនាមជាអ្នកឧបត្ថម្ភកម្មវិធីមួយ ដើម្បីពង្រឹងទំនាក់ទំនងអាជីវកម្ម ជាមួយនឹងក្រុមហ៊ុន HGB Group ដែលជាដៃគូធំមួយរបស់ធនាគារ សម្រាប់ផលិតផលឥណទានរថយន្ត។ ដោយមានអ្នកចូលរួមជាច្រើនរយនាក់ ដែលជាអតិថិជនរបស់ក្រុមហ៊ុន MAZDA ធនាគារបានរៀបចំស្តង់ពាណិជ្ជកម្ម ដើម្បីផ្សព្វផ្សាយស្លាកសញ្ញា និងផលិតផលធនាគារ ជាពិសេសឥណទានរថយន្ត និងសេវាកម្ម CIMB Preferred ក្នុងអំឡុងពេលព្រឹត្តិការណ៍នេះ។

ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០

កម្មវិធីទទួលស្វាគមន៍ការត្រឡប់មកវិញ
របស់និស្សិតអាហារូបករណ៍ CHEVENING
នៅគេហដ្ឋានរបស់ឯកអគ្គរាជទូតចក្រភពអង់គ្លេស រាជធានីភ្នំពេញ

កម្មវិធីទទួលស្វាគមន៍ការត្រឡប់មកវិញ របស់និស្សិតអាហារូបករណ៍ CHEVENING ត្រូវបានរៀបចំឡើង ដោយស្ថានទូតចក្រភពអង់គ្លេស ក្នុងប្រទេសកម្ពុជា ក្រោមអធិបតីភាពឯកអគ្គរាជទូតចក្រភពអង់គ្លេស និងអនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឬា។ ក្នុងនាមជាអ្នកឧបត្ថម្ភធំមួយ នៃកម្មវិធីអាហារូបករណ៍នេះជាច្រើនឆ្នាំកន្លងមក ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានចូលរួម ក្នុងព្រឹត្តិការណ៍នេះ ដើម្បីអបអរសាទរ និងស្វាគមន៍និស្សិតអាហារូបករណ៍ខ្មែរ ដែលបានបញ្ចប់ការសិក្សា ពីចក្រភពអង់គ្លេស ក្រោមកម្មវិធីអាហារូបករណ៍ CHEVENING។

ថ្ងៃទី១៤-១៦ ខែកុម្ភៈ ឆ្នាំ២០២០

ពិព័រណ៍អាពាហ៍ពិពាហ៍ លើកទី៥
នៅផ្សារទំនើប អូឡាំព្យា រាជធានីភ្នំពេញ

ពិព័រណ៍អាពាហ៍ពិពាហ៍ លើកទី៥ គឺជាពិព័រណ៍ធំបំផុតមួយ ប្រចាំឆ្នាំ២០២០ ក្នុងប្រទេសកម្ពុជា ហើយមានការគាំទ្រពីក្រសួងពាណិជ្ជកម្ម និងក្រសួងវប្បធម៌ និងវិចិត្រសិល្ប:។ ចំណុចចម្បងនៃពិព័រណ៍នេះ គឺជាការផ្សព្វផ្សាយកញ្ចប់ និងសេវាកម្មរៀបចំអាពាហ៍ពិពាហ៍ ដោយមានអ្នកចូលរួមទស្សនា ប្រមាណ ២០.០០០នាក់។ ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នេះ ធនាគារ ស៊ីអាយអិមប៊ី ក៏បានរួមចំណែកផ្សព្វផ្សាយ អំពីផលិតផល និងសេវាកម្ម សម្រាប់ដៃគូជិតរៀបការ និងគូស្រករថ្មីថ្មោងផងដែរ។

ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២០

ព្រឹត្តិការណ៍ជិះកង់ ឆ្នាំ២០២០
នៅប្រាសាទអង្គរវត្ត ខេត្តសៀមរាប

អ្នកជិះកង់ប្រមាណ ៤០០នាក់ បានចូលរួម ក្នុងព្រឹត្តិការណ៍ជិះកង់ នៅបរិវេនប្រាសាទអង្គរវត្ត ដែលត្រូវបានរៀបចំ ដោយសមាគមធនាគារ នៅកម្ពុជា ដោយមានការគាំទ្រ ពីគណៈកម្មាធិការជាតិអូឡាំពិក សហព័ន្ធកីឬាទោចក្រយានកម្ពុជា និងអាជ្ញាធរជាតិអប្សរា។ ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានរួមចំណែក ក្នុងព្រឹត្តិការណ៍ ដើម្បីលើកកម្ពស់ការយល់ដឹង ពីគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាព នៅកម្ពុជា និងពង្រឹងការភ្ជាប់ទំនាក់ទំនង ជាមួយនឹងស្ថាប័នពាក់ព័ន្ធនានា។ ក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នេះ ធនាគារបានរៀបចំស្តង់ពិព័រណ៍តូចមួយ ដើម្បីចែកជូនសាប៊ូអេកូ រហូតដល់អស់ពីស្តុកដល់អ្នកចូលរួម។

ការចុះផ្សាយក្នុងសារព័ត៌មាន

អាជ្ញាធរជាតិអប្សរា ស្វាគមន៍ត្រៀមស្ថាប៉ន១ដើម្បីចូលរួមដាំកូនឈើក្នុងអមណីយដ្ឋានអង្គរ

FRESH NEWS

FRESH NEWS

CIMB BANK
CIMB Bank PLC recognised as the "Cambodia's Best Company to Work for" by HR Asia
STAFF ANNUAL DINNER

THE WORLD NEWS
ធនាគារ CIMB ចូលរួមដាំ កូនឈើ ចំនួន ១៥០០ដើម ជាមួយអាជ្ញាធរជាតិ អប្សរាក្នុងអណីយដ្ឋានអង្គរ

Cambodia's best international bank 2019: CIMB
BEST BANK AWARDS 2019
View full 2019 rankings

ក្រុមប្រឹក្សាភិបាល

10TH
ANNIVERSARY
IN CAMBODIA

ក្រុមប្រឹក្សាភិបាល

DATUK MOHD NASIR BIN AHMAD

ប្រធានក្រុមប្រឹក្សាភិបាល / អភិបាលឯករាជ្យមិនប្រតិបត្តិ

សញ្ជាតិម៉ាឡេស៊ី

ត្រូវបានតែងតាំងជា អភិបាល នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩

ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ទាំង ០៧លើក ក្នុងឆ្នាំ២០២០

ជាសមាជិកគណៈកម្មាធិការសវនកម្ម

Datuk Mohd Nasir Ahmad ជាសមាជិក នៃសមាគមគណនេយ្យករ ជំនាញអន្តរជាតិ (Association of Chartered Certified Accountants (ACCA)) នៃចក្រភពអង់គ្លេស ព្រមទាំងជាគណនេយ្យករជំនាញមួយរូប នៃវិទ្យាស្ថានគណនេយ្យករម៉ាឡេស៊ី (Malaysian Institute of Accountants (MIA)) ហើយលោកបានទទួលសញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងពាណិជ្ជកម្ម (ឯកទេសហិរញ្ញវត្ថុ) ពីសាកលវិទ្យាល័យ កេបាងសាន ម៉ាឡេស៊ី (Universiti Kebangsaan Malaysia) ប្រទេសម៉ាឡេស៊ី។

លោកត្រូវបានតែងតាំងជា ប្រធានក្រុមប្រឹក្សាភិបាល/អភិបាលឯករាជ្យមិនប្រតិបត្តិ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩។

Datuk Mohd Nasir ត្រូវបានតែងតាំងជា អភិបាលឯករាជ្យ នៃស៊ីអាយអិមប៊ី គ្រុប ហូលឌីង ប៊ើហាដ (CIMB Group Holdings Berhad) ចាប់តាំងពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ និងត្រូវបានតែងតាំងជា ប្រធានក្រុមប្រឹក្សាភិបាល/អភិបាលឯករាជ្យ នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៨។ Datuk Mohd Nasir ក៏ធ្លាប់ធ្វើជា នាយកវិទ្យាស្ថានគណនេយ្យករម៉ាឡេស៊ី (MIA) ក្នុងអំឡុងពីខែសីហា ឆ្នាំ២០១១ រហូតដល់ខែកក្កដា ឆ្នាំ២០១៣។ នៅក្នុងខែកញ្ញា ឆ្នាំ២០១៣ លោកត្រូវបានជ្រើសតាំងធ្វើជា សមាជិកក្រុមប្រឹក្សា របស់ ACCA នៃចក្រភពអង់គ្លេស និងត្រូវបានជ្រើសតាំងម្តងទៀត នៅខែកញ្ញា ឆ្នាំ២០១៦ និង ខែវិច្ឆិកា ឆ្នាំ២០១៩។

លោកបាននាំយកនូវបទពិសោធន៍ដ៏ទូលំទូលាយ លើផ្នែកដឹកនាំ គ្រប់គ្រង ហិរញ្ញវត្ថុ និងគណនេយ្យ ដែលលោកមាន ក្នុងអំឡុងពេលជាង ៤០ឆ្នាំនេះ ដោយលោកបានចាប់ផ្តើមការងារដំបូងជាកម្មសិក្សាការីគណនេយ្យ ជាមួយក្រុមហ៊ុន តេណាហ្គា ណេសិនណល ប៊ើហាដ (Tenaga Nasional Berhad (TNB)) នៅក្នុងឆ្នាំ១៩៧៩ ហើយលោកបានផ្លាស់ប្តូរមុខតំណែងជាច្រើន នៅក្នុងនាយកដ្ឋានហិរញ្ញវត្ថុរបស់ក្រុមហ៊ុននេះ។

នៅក្នុងខែមករា ឆ្នាំ១៩៩៣ Datuk Mohd Nasir ត្រូវបានតែងតាំងជា អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ នៅក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ TNB គឺក្រុមហ៊ុន ម៉ាឡេស៊ី ត្រែនស្វ៊ីរមើរ មេនូហ្ស្ចរតឿរីង អេសឌីអិន ប៊ើហាដ (Malaysia Transformer Manufacturing Sdn Bhd) មុនពេលដែលលោកត្រូវបានតែងជា ប្រធាននាយកប្រតិបត្តិ ក្នុងខែមិថុនា ឆ្នាំ១៩៩៤។

នៅក្នុងខែមករា ឆ្នាំ២០០០ លោកបានចូលបម្រើការឲ្យក្រុមហ៊ុន ពីម៉ូដាឡាន កេបាងសាន ប៊ើហាដ (Sharikat Permodalan Kebangsaan Berhad) ក្នុងតំណែងជាប្រធាននាយកប្រតិបត្តិ។ នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ លោកត្រូវបានតែងតាំងជា ប្រធាននាយកប្រតិបត្តិ នៃក្រុមហ៊ុន ពឺបាដាណាន អ៊ុសាហាវ៉ាន ណេសិនណល ប៊ើហាដ (Perbadanan Usahawan Nasional Berhad) ហើយលោកបន្តកាន់តំណែងនេះ រហូតដល់ពេលលោកចូលនិវត្តន៍ នាថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១១។

Datuk Mohd Nasir ក៏មានតំណែងជាអភិបាល នៅក្នុងក្រុមហ៊ុនផ្សេងៗទៀត ដែលមានដូចជា ស៊ីរីម ប៊ើហាដ (SIRIM Berhad) ព្រូខាស អេសឌីអិន ប៊ើហាដ (Prokhas Sdn Bhd) និងស៊ីអាយអិមប៊ី អ៊ីអូភី មីនីជមិន អេសឌីអិន ប៊ើហាដ (CIMB EOP Management Sdn Bhd)។ លោកក៏ជាបរធនបាលមួយរូប នៃមូលនិធិ យ៉ាយ៉ាសាន់ ខ៉ែនសែឡ្ស យូនីតិន (Yayasan Canselor UNITEN) និងមូលនិធិ ពីដាណា លីដឺស្ហ៊ីប (Perdana Leadership Foundation) ផងដែរ។។

បណ្ឌិត ម៉ី កល្យាណ

អភិបាលឯករាជ្យមិនប្រតិបត្តិ

សញ្ជាតិខ្មែរ

ត្រូវបានតែងតាំងជា អភិបាល នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២

ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ទាំង ០៧លើក ក្នុងឆ្នាំ២០២០

ជាប្រធានគណៈកម្មាធិការសវនកម្ម

បណ្ឌិត ម៉ី កល្យាណ បានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ ពីសាកលវិទ្យាល័យ កូបេ (Kobe University) ប្រទេសជប៉ុន នៅឆ្នាំ១៩៨៤។ បន្ទាប់មក លោកបានទទួលការបណ្តុះបណ្តាល វគ្គជំនាញរយៈពេលខ្លី ស្តីពីការអភិវឌ្ឍពីទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិ ធនាគារពិភពលោក និងសាកលវិទ្យាល័យ ហាវើដ (Harvard University)។ លោកមានបទពិសោធន៍យ៉ាងទូលំទូលាយ លើផ្នែកអភិវឌ្ឍសេដ្ឋកិច្ច ក្នុងពិភពលោក។

បច្ចុប្បន្ន លោកមានតួនាទីផ្លូវការ ចំនួន០៣ នៅក្នុងក្របខណ្ឌរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជារួមមានដូចជា៖ (១) ទីប្រឹក្សាជាន់ខ្ពស់ (ឋានៈរដ្ឋមន្ត្រី) នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (Supreme National Economic Council) ដែលជាទីប្រឹក្សាសេដ្ឋកិច្ចរបស់នាយករដ្ឋមន្ត្រី (២) ប្រធានក្រុមប្រឹក្សាភិបាល នៃសាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ និង (៣) ប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា។ មុនពេលចូលបម្រើតួនាទីទាំងនោះ លោកធ្លាប់បានបំពេញការងារជាអ្នកសេដ្ឋកិច្ចជាន់ខ្ពស់ សម្រាប់កម្មវិធីសហប្រតិបត្តិការរបស់ UN/FAO-World Bank ប្រចាំនៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី អស់រយៈពេល ២០ឆ្នាំ។ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ លោកក៏ជាមន្ត្រីហិរញ្ញវត្ថុរបស់សាជីវកម្ម Kanematsu Gosho ដែលជាមជ្ឈមណ្ឌលពាណិជ្ជកម្ម នៅទីក្រុងអូសាកា និងទីក្រុងតូក្យូផងដែរ។ ក្រៅពីតួនាទីក្នុងក្របខណ្ឌរាជរដ្ឋាភិបាល លោកក៏ជាសមាជិកក្រុមប្រឹក្សាភិបាលមួយរូប នៃក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៌ អ៊ីសួរ៉ិនស៍ អ៊ីអិលស៊ី គិតចាប់តាំងពីខែធ្នូ ឆ្នាំ២០១៣មក។ ក្នុងអំឡុងពេល នៃវិជ្ជាជីវៈរបស់លោក លោកក៏បានធ្វើទស្សនកិច្ច និងបំពេញការងារ នៅតាមបណ្តាប្រទេស ប្រហែលជាង ១០០ប្រទេស។

ជាមួយនឹងបទពិសោធន៍ និងចំណេះដឹងដ៏ទូលំទូលាយ ដែលទទួលបានពីគ្រប់ទិសទី នៅជុំវិញពិភពលោក លោកមានក្តីសោមនស្ស ក្នុងការចូលរួមចំណែកអភិវឌ្ឍប្រទេសកម្ពុជា ទាំងក្នុងវិស័យឯកជន និងវិស័យសាធារណៈ។ លោកមានជំនឿថា ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ គឺជាគន្លឹះសំខាន់មួយ ដែលនាំប្រទេសកម្ពុជា ទៅរកការអភិវឌ្ឍ និងភាពជោគជ័យ។

ក្រុមប្រឹក្សាភិបាល

AISYAH LAM BINTI ABDULLAH

អភិបាលឯករាជ្យមិនប្រតិបត្តិ

- សញ្ជាតិម៉ាឡេស៊ី
- ត្រូវបានតែងតាំងជា អភិបាល នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨
- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ទាំង ០៧លើក ក្នុងឆ្នាំ ២០២០
- ជាប្រធានគណៈកម្មាធិការហានិភ័យ
- ជាសមាជិកគណៈកម្មាធិការសវនកម្ម

លោកស្រី Aisyah Lam ត្រូវបានតែងតាំងជា អភិបាលឯករាជ្យ និងជាប្រធាន នៃគណៈកម្មាធិការហានិភ័យរបស់ធនាគារ ចាប់តាំងពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨។ លោកស្រីក៏ជាអភិបាលឯករាជ្យ នៃធនាគារ ស៊ីអាយអ៊ីមប៊ី វៀតណាម និងជាប្រធាននាយកប្រតិបត្តិការ នៃក្រុមគ្លីនិកចាប់សសៃអាមេរិក (The American Chiropractic Clinic group) នៅប្រទេសវៀតណាមផងដែរ។

ចាប់ផ្តើមដំបូងនៃអាជីពការងារ ក្នុងវិស័យធនាគារ លោកស្រីបានធ្វើការ ឲ្យធនាគារ Standard Chartered Bank។ បន្ទាប់ពីនោះ លោកស្រីបានប្តូរទៅបម្រើការ នៅធនាគារ Deutsche (ប្រទេសម៉ាឡេស៊ី) ក្នុងឆ្នាំ១៩៩៤ ដោយនៅកន្លែងនោះ លោកស្រីបានកាន់តួនាទីជា ប្រធានគ្រប់គ្រងសាច់ប្រាក់សាជីវកម្ម ដោយបានបង្កើតពាណិជ្ជកម្មសាជីវកម្ម និងអាជីវកម្មប្រតិបត្តិការ តាមប្រព័ន្ធអ៊ីនធើណេតដំបូងគេ សម្រាប់ធនាគារ Deutsche នៅក្នុងប្រទេសម៉ាឡេស៊ី ហើយបន្ទាប់មកទៀត ចូលរួមក្នុងក្រុមផ្នែកលក់ថ្នាក់តំបន់ នៅប្រទេសសិង្ហបុរី។ ក្នុងឆ្នាំ២០០១ លោកស្រីបានផ្លាស់ប្តូរការងារ ទៅក្រុមហ៊ុន IslamicQ.com Asia (ទីក្រុងឌូបៃ) ដែលនៅទីនោះ លោកស្រីជាអ្នកគ្រប់គ្រងប្រចាំប្រទេស ដោយទទួលខុសត្រូវ លើការគ្រប់គ្រង អភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រអាជីវកម្ម នៅក្នុងតំបន់អាស៊ីនៃក្រុមហ៊ុននោះ។

ក្នុងឆ្នាំ២០០៣ លោកស្រី Aisyah បានវិលត្រឡប់មកប្រទេសម៉ាឡេស៊ី មកកាន់តួនាទីជា អគ្គនាយកគ្រប់គ្រងទ្រព្យសម្បត្តិ នៃធនាគារ Hong Leong Bank Berhad។ ជាមួយតំណែងនេះ លោកស្រីទទួលខុសត្រូវ លើការពង្រីកអាជីវកម្ម ការបង្កើនផតហ្វូលីយ៉ូ នៃទ្រព្យសកម្ម ក្រោមការគ្រប់គ្រង ការអភិវឌ្ឍ និងការគ្រប់គ្រង អាទិភាពរបស់ធនាគារ ក៏ដូចជាចាត់ចែងបណ្តាញផ្នែកលក់ នៃធនាគារជាន់ខ្ពស់ បន្ថែមទៅលើផ្នែកទំនាក់ទំនងសាខា។ លោកស្រី Aisyah ក៏បានផ្លាស់ទៅបម្រើការងារ នៅធនាគារ Citibank ក្នុងឆ្នាំ២០០៦ ដើម្បីគ្រប់គ្រង និងអភិវឌ្ឍផតហ្វូលីយ៉ូ របស់ផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ធនាគារនេះ ក្នុងប្រទេសម៉ាឡេស៊ី។

លោកស្រី Aisyah បានសម្រេចចិត្តចាកចេញពីទីក្រុងហាណូយ ប្រទេសវៀតណាម ក្នុងឆ្នាំ២០១០ ដើម្បីចាប់យកបទពិសោធន៍ថ្មី ក្នុងការបង្កើតផ្នែកអាជីវកម្មលក់រាយ ឲ្យធនាគារ Ngan Hang TMCP Bac A។ បេសកកម្មនាពេលនោះ គឺដើម្បីដាក់ចេញនូវហេដ្ឋារចនាសម្ព័ន្ធ ក្នុងធនាគារ ដើម្បីគាំទ្រដល់សេវាកម្ម និងផលិតផលអាជីវកម្មលក់រាយសំខាន់ៗ ស្របតាមគម្រោងយុទ្ធសាស្ត្រ ក្នុងការកសាង និងបណ្តុះផ្នែកនេះ ឲ្យក្លាយជាអាជីវកម្មចម្បងរបស់ធនាគារ។ បន្ទាប់ពីគម្រោងចប់សព្វគ្រប់អស់ លោកស្រីបានវិលត្រឡប់ទៅធនាគារ Hong Leong Bank Vietnam ដែលនៅទីនោះ ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៥ លោកស្រីបានអភិវឌ្ឍ និងកសាងអាជីវកម្មសេវាកម្មហិរញ្ញវត្ថុបុគ្គលសម្រាប់ធនាគារនេះ ក្នុងប្រទេសវៀតណាម។

ចាប់ផ្តើមពីការងារ ក្នុងវិស័យធនាគារ លោកស្រី Aisyah បានប្តូរការងារទៅវិស័យថែរក្សាសុខភាពវិញ ក្នុងឆ្នាំ២០១៦ ហើយបច្ចុប្បន្ននេះ លោកស្រីគ្រប់គ្រងក្រុមគ្លីនិកចាប់សសៃ ក្នុងប្រទេសវៀតណាម ទាំងលើគ្រប់ផ្នែកនៃប្រតិបត្តិការ ក៏ដូចជាការអភិវឌ្ឍអាជីវកម្ម។

លោកស្រី Aisyah Lam បានបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែក Chartered Marketing ពី Chartered Institute of Banking ចក្រភពអង់គ្លេស។

OMAR SIDDIQ BIN AMIN NOER RASHID

អភិបាលមិនឯករាជ្យមិនប្រតិបត្តិ

សញ្ជាតិម៉ាឡេស៊ី

ត្រូវបានតែងតាំងជា អភិបាល នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩
(លាលែងពីតំណែង នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១)

ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ចំនួន ០៦លើក
ក្នុងចំណោមកិច្ចប្រជុំ ទាំង ០៧ ក្នុងឆ្នាំ២០២០

លោក Omar Siddiq បានទទួលសញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ (កិត្តិយស) ជំនាញសេដ្ឋកិច្ច ពីសាលាសេដ្ឋកិច្ច និងវិទ្យាសាស្ត្រនយោបាយ ទីក្រុងឡុងដ៍ (London School of Economics and Political Science) ហើយលោកក៏ជាសមាជិកសមាគមន៍និស្សិត នៃវិទ្យាស្ថានគណនេយ្យករជំនាញ (Institute of Chartered Accountants) នៃប្រទេសអង់គ្លេស និងប្រទេសវ៉ែល (Wales) ផងដែរ។ លោកក៏ទទួលបានសញ្ញាបត្រឯកទេស ផ្នែកវិភាគហិរញ្ញវត្ថុ (Chartered Financial Analyst («CFA») Charter Holder) ដែលផ្តល់ដោយវិទ្យាស្ថាន CFA ផងដែរ។

ចាប់តាំងពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ លោក Omar ត្រូវបានតែងតាំងជា នាយកសេវាកម្មហិរញ្ញវត្ថុទ្រង់ទ្រាយធំ (Group Wholesale Banking) និងជាអនុប្រធាននាយកប្រតិបត្តិ របស់ស៊ីអាយអ៊ីមប៊ី គ្រុប នៅប្រទេសម៉ាឡេស៊ី។ មុនពេលចូលកាន់តំណែងទាំងនោះ លោកធ្លាប់ជាប្រធាននាយកប្រតិបត្តិការ របស់ស៊ីអាយអ៊ីមប៊ី គ្រុប។

មុនពេលដែលលោក Omar បានកាន់កាប់តំណែងខាងលើ លោកមានបទពិសោធន៍ផ្សេងៗទៀត រួមដូចខាងក្រោម៖

- នាយកសេវាកម្មហិរញ្ញវត្ថុទ្រង់ទ្រាយធំ និងអាជីវកម្មអន្តរជាតិ នៅធនាគារ អ អេច ប៊ី គ្រុប (RHB Banking Group)
- អភិបាលប្រតិបត្តិ និងប្រធាននាយកហិរញ្ញវត្ថុ (គ្រុប) នៃក្រុមហ៊ុនអាកាសចរណ៍ម៉ាឡេស៊ី
- អភិបាលប្រតិបត្តិ នៃនាយកដ្ឋានវិនិយោគ នៃក្រុមហ៊ុន ខាហ្សាណា ណាសិនណល ប៊ើហាដ (Khazanah Nasional Berhad) (ដែលជាក្រុមហ៊ុនវិនិយោគមូលនិធិទ្រព្យសម្បត្តិអធិបតេយ្យ របស់ប្រទេសម៉ាឡេស៊ី)
- នាយកគ្រប់គ្រង នៃនាយកដ្ឋានសេវកម្មធនាគារវិនិយោគ នៃធនាគារ វិនិយោគ ស៊ីអាយអ៊ីមប៊ី ប៊ើហាដ (CIMB Investment Bank Berhad)
- អភិបាលប្រតិបត្តិ នៃក្រុមប្រតិបត្តិការហិរញ្ញវត្ថុសាជីវកម្ម (Corporate Finance Practice) នៃក្រុមហ៊ុន ប្រាយ់ធ្លីតធ័រហាវ៉ូ(ភើស៍ (PricewaterhouseCoopers (PwC))។

លោក Omar ក៏ជាអភិបាលនៃធនាគារ ស៊ីអាយអ៊ីមប៊ី ថៃ (នៅប្រទេសថៃ) ផងដែរ។

ក្រុមប្រឹក្សាភិបាល

AHMAD SHAZLI BIN KAMARULZAMAN

អភិបាលមិនឯករាជ្យមិនប្រតិបត្តិ

សញ្ជាតិម៉ាឡេស៊ី

ត្រូវបានតែងតាំងជាអភិបាល នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩

ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលទាំង ០៧ លើក ក្នុងឆ្នាំ២០២០

លោក Ahmad Shazli Kamarulzaman (អាយុ ៤៩ ឆ្នាំ) បានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រ (កិត្តិយស) ជំនាញសេដ្ឋកិច្ច និងគណនេយ្យ ពីសាកលវិទ្យាល័យ ប្រ៊ីស្តុល (University of Bristol) នៃចក្រភពអង់គ្លេស។

លោកត្រូវបានតែងតាំងជាអភិបាលមិនឯករាជ្យមិនប្រតិបត្តិនាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩។

លោក Ahmad Shazli Kamarulzaman ជាអនុប្រធាននាយកប្រតិបត្តិ នៃនាយកដ្ឋានសេវាកម្ម ហិរញ្ញវត្ថុពាណិជ្ជកម្ម របស់ស៊ីអាយអិមប៊ី គ្រុប និងជា នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម នៃធនាគារ ស៊ីអាយអិមប៊ី នៅប្រទេសម៉ាឡេស៊ី។

ក្នុងនាមជាអនុប្រធាននាយកប្រតិបត្តិ នៃនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម របស់ស៊ីអាយអិមប៊ី គ្រុប លោក Ahmad Shazli ទទួលបន្ទុកគ្រប់គ្រង លើអាជីវកម្មរបស់ស៊ីអាយអិមប៊ី គ្រុប និងផ្នែកសហគ្រាសធុនតូច និងមធ្យម នៃធនាគារ ស៊ីអាយអិមប៊ី នៅប្រទេសម៉ាឡេស៊ី សិង្ហបុរី ឥណ្ឌូនេស៊ី ថៃ និងកម្ពុជា។

ក្នុងនាមជានាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម នៃធនាគារ ស៊ីអាយអិមប៊ី នៅប្រទេសម៉ាឡេស៊ី លោកមានទំនួលខុសត្រូវលើផ្នែកអាជីវកម្ម និងផ្នែកសហគ្រាសធុនតូច និងមធ្យម ក្នុងប្រទេសម៉ាឡេស៊ីទាំងមូល។ ការទទួលខុសត្រូវរបស់លោក រួមមានលើផ្នែកយុទ្ធសាស្ត្រ ឥណទាន ការគ្រប់គ្រងអតិថិជន ផលិតផល និងសេវាកម្ម ទាំងក្នុងផ្នែកសេវាកម្ម/អាជីវកម្មធនាគារទូទៅ (Conventional Banking) និងផ្នែកសេវាកម្ម/អាជីវកម្មធនាគារឥស្លាម (Islamic Banking)។ លោកក៏គ្រប់គ្រងលើប្រតិបត្តិការ ជើងសាជំនួញ និងជួលផងដែរ។

លោក Shazli បានដឹកនាំការផ្លាស់ប្តូរដ៏ជោគជ័យខ្លាំងមួយ លើនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុ ពាណិជ្ជកម្ម នៃធនាគារ ស៊ីអាយអិមប៊ី នៅប្រទេសម៉ាឡេស៊ី ហើយក្រោមការដឹកនាំរបស់លោក អាជីវកម្ម ហិរញ្ញវត្ថុពាណិជ្ជកម្ម បានបោះជំហានរីកចម្រើនគួរឲ្យកោតសរសើរ។ ចាប់តាំងពីចាប់ផ្តើមអាជីពការងារ ជាមួយស៊ីអាយអិមប៊ី នៅខែមករា ឆ្នាំ២០០៦ លោកជាបុគ្គលឆ្នើមម្នាក់នៅក្នុង ប្រតិបត្តិការស្តារ/ប្រមូលបំណុលរបស់ស៊ីអាយអិមប៊ី គ្រុប ដោយលោកបានបង្កើតផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិពិសេស ដើម្បីស្តារឡើងវិញ នូវឥណទានមិនដំណើរការ របស់នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុ សាជីវកម្ម នាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម/សហគ្រាសធុនតូច និងមធ្យម និងនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុបុគ្គល។ លោកជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនគ្រប់គ្រងទ្រព្យសម្បត្តិ សាថន (Sathorn Asset Management Co.) (ប្រទេសថៃ) និងក្រុមហ៊ុនគ្រប់គ្រងទ្រព្យសម្បត្តិពិសេសអាស៊ីអាគ្នេយ៍ ប៊ើហាដ (Southeast Asia Special Asset Management Berhad) ដែលជាក្រុមហ៊ុន Special Purpose Vehicle បង្កើតឡើងដើម្បីទិញទ្រព្យ/កម្ចី ដែលដាក់លក់ ដើម្បីជម្រះបំណុល (distressed loans/assets) ពីធនាគារ ស៊ីអាយអិមប៊ី នៅប្រទេសម៉ាឡេស៊ី។

លោក Ahmad Shazli បានចាប់ផ្តើមអាជីពការងាររបស់លោកនៅក្នុងធនាគារពាណិជ្ជ (merchant bank) នាំមុខគេមួយ មុនពេលលោកប្តូរទៅបម្រើការ នៅក្រុមហ៊ុនគ្រប់គ្រងទ្រព្យសម្បត្តិជាតិរបស់ម៉ាឡេស៊ី ឈ្មោះ ពេងហ្គូរសាន ដាណាហាតា ណាសិនណល ប៊ើហាដ (Pengurusan Danaharta Nasional Berhad (ហៅកាត់ថា ដាណាហាតា (Danaharta))។

បន្ថែមលើសពីនេះ លោក Shazli ក៏ជាស្ថាបនិកមួយរូប និងជារតនាគារិក នៃអង្គការ ក្រុមសកម្ម មាតាបិតាដើម្បីការអប់រំ (Parent Action Group for Education (ហៅកាត់ថា PAGE)) ដែលជាអង្គការមិនមែនរដ្ឋាភិបាលធ្វើកិច្ចការ ដើម្បីវិស័យអប់រំដំបូងគេបង្អស់របស់ប្រទេសម៉ាឡេស៊ី ដែលមានគោលបំណងផ្តល់ភាពឈានមុខគេលើប្រព័ន្ធអប់រំរបស់ប្រទេសម៉ាឡេស៊ី។

ប៊ុន យ៉ីន

ប្រធាននាយកប្រតិបត្តិ / អភិបាលមិនឯករាជ្យប្រតិបត្តិ

សញ្ជាតិខ្មែរ

ត្រូវបានតែងតាំងជា អភិបាល នាថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥

ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ទាំង ០៧លើក ក្នុងឆ្នាំ២០២០

ជាសមាជិកគណៈកម្មាធិការហានិភ័យ

លោក ប៊ុន យ៉ីន បានទទួលសញ្ញាបត្រឧត្តមសិក្សា ផ្នែកហិរញ្ញវត្ថុ គណនេយ្យ និងធនាគារ ពីក្រសួងហិរញ្ញវត្ថុ កម្ពុជា នៅឆ្នាំ១៩៨៧។

លោក ប៊ុន យ៉ីន ត្រូវបានតែងតាំងជា ប្រធាននាយកប្រតិបត្តិ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីការកាន់តំណែងជា អគ្គនាយករងរបស់ធនាគារ ចាប់តាំងពីពេលបង្កើតធនាគារដំបូង នៅក្នុងប្រទេសកម្ពុជា។ បន្ទាប់មក លោកត្រូវបានតែងតាំងជា អភិបាលប្រតិបត្តិ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥។ លោកក៏ជាសមាជិកនៃគណៈកម្មាធិការហានិភ័យរបស់ធនាគារផងដែរ។

ក្នុងតំណែងជា អភិបាលប្រតិបត្តិ/ប្រធាននាយកប្រតិបត្តិ លោក ប៊ុន យ៉ីន ទទួលខុសត្រូវរួមលើការអនុវត្តយុទ្ធសាស្ត្ររបស់ធនាគារ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល រៀបចំអាជីវកម្មរបស់ធនាគារ និងដឹកនាំប្រតិបត្តិការ ស្របតាមគោលដៅយុទ្ធសាស្ត្រ និងទិសដៅអាជីវកម្ម។ លោកធ្វើការដឹកនាំគណៈគ្រប់គ្រង ក្នុងការអនុវត្តយុទ្ធសាស្ត្រ និងទស្សនវិស័យរបស់ធនាគារ។ ក្នុងឋានៈជា អភិបាលប្រតិបត្តិ/ប្រធាននាយកប្រតិបត្តិ លោកទទួលខុសត្រូវ ចំពោះមុខក្រុមប្រឹក្សាភិបាល លើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ។

លោក ប៊ុន យ៉ីន បម្រើការនៅក្នុងវិស័យធនាគារ រយៈពេល ៤០ឆ្នាំមកហើយ។ ជាមួយបទពិសោធន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ ក្នុងវិស័យធនាគារ លោកយល់ច្បាស់ អំពីទីផ្សារក្នុងស្រុក ហើយលោកបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការដឹកនាំអាជីវកម្មរបស់ធនាគារ។ លោកក៏ត្រូវបានទទួលស្គាល់ថា ជាបុគ្គលដ៏សំខាន់មួយរូប នៅក្នុងឧស្សាហកម្មធនាគារទាំងមូលផងដែរ។

លេខាធិការក្រុមហ៊ុនរួម

DATIN ROSSAYA MOHD NASHIR

លេខាធិការក្រុមហ៊ុនរួម

សញ្ជាតិ ម៉ាឡេស៊ី

Datin Rossaya Mohd Nashir គឺជាលេខាធិការក្រុមហ៊ុន របស់ស៊ីអាយអិមប៊ី គ្រុប (CIMB Group)។ លោកស្រី បានចូលបម្រើការងារ ជាមួយធនាគារ ក្នុងការិយាល័យសេវាកម្មនីតិកម្មក្រុមហ៊ុន នៅក្នុងឆ្នាំ២០០២។ លោកស្រីគឺជាបុគ្គលមួយរូប ដែលជួយបង្កើតនាយកដ្ឋានលេខាធិការក្រុមហ៊ុនឡើង នៅក្នុងឆ្នាំ២០០៤ និងត្រូវបានតែងតាំងជាលេខាធិការក្រុមហ៊ុន របស់ស៊ីអាយអិមប៊ី គ្រុប នៅក្នុងឆ្នាំ២០០៦។

ជាមួយតួនាទីជាលេខាធិការក្រុមហ៊ុន លោកស្រីទទួលខុសត្រូវ ក្នុងការផ្តល់ការប្រឹក្សា និងដំបូន្មាន ពាក់ព័ន្ធនឹងតួនាទី និងកាតព្វកិច្ចផ្សេងៗ របស់ក្រុមប្រឹក្សាភិបាល ដើម្បីធានាថា ស៊ីអាយអិមប៊ី អនុវត្តអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។ លោកស្រីដើរតួនាទីជា អ្នកទំនាក់ទំនង រវាងក្រុមប្រឹក្សាភិបាល និងអ្នកពាក់ព័ន្ធសំខាន់ៗ ទាំងនៅក្នុងប្រទេសម៉ាឡេស៊ី និងនៅក្នុងប្រតិបត្តិការថ្នាក់តំបន់ របស់ស៊ីអាយអិមប៊ី គ្រុប ដើម្បីធានាថា ក្របខណ្ឌអភិបាលកិច្ចធនាគារ ត្រូវបានរៀបចំ ក្នុងលក្ខណៈមួយ ដែលគាំទ្រដល់ទស្សនវិស័យ របស់ស៊ីអាយអិមប៊ី គ្រុប។

លោកស្រីមានចំណេះដឹង ផ្នែកវិស័យធនាគារយ៉ាងទូលំទូលាយ ជាមួយបទពិសោធន៍ ក្នុងការងារលេខាធិការក្រុមហ៊ុនច្រើនជាង ២៥ឆ្នាំ។ មុនចូលបម្រើការងារ នៅក្នុងស៊ីអាយអិមប៊ី គ្រុប លោកស្រីបម្រើការងារឲ្យក្រុមហ៊ុន តើម៉ូដាឡាន ណេសិនណល ប៊ើហាដ (Permodalan National Berhad) ក្នុងតំណែងជាលេខាធិការក្រុមហ៊ុនរួម នៃក្រុមហ៊ុនបុត្រសម្ព័ន្ធមួយចំនួន នៃក្រុមហ៊ុននេះ។ លោកស្រីបានចាប់ផ្តើមអាជីពការងារដំបូង នៅក្រុមហ៊ុន ថាម អេនជីនេ៊រីង គ្រុប (Time Engineering Group)។

Datin Rossaya គឺជាសមាជិកមួយរូប នៃវេទិកាប្រឹក្សា អំពីនីតិវិធីក្រុមហ៊ុន (Corporate Practice Consulative Forum) របស់គណៈកម្មាការក្រុមហ៊ុន នៃម៉ាឡេស៊ី (Companies Commission of Malaysia) ហើយក៏ជាអភិបាលមួយរូប នៃក្រុមហ៊ុនបុត្រសម្ព័ន្ធមួយចំនួន នៅក្នុងស៊ីអាយអិមប៊ី គ្រុប។ លោកស្រីគឺជាជើងឯកនិរន្តភាពស៊ីអាយអិមប៊ី (CIMB Sustainability Champion)។ លោកស្រីបានផ្តួចផ្តើមគម្រោងមួយចំនួន ដើម្បីជំរុញនិរន្តរភាព នៅក្នុងកន្លែងធ្វើការ ឲ្យ #teamcimb។ លោកស្រីចូលរួមយ៉ាងសកម្ម ក្នុងការជំរុញការចូលរួមរបស់ស្ត្រី ក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយលោកស្រីបានចូលរួមសកម្មភាព ក្នុងកិច្ចផ្តួចផ្តើមតាមលក្ខណៈបណ្តាញផ្សេងៗ ដើម្បីលើកកម្ពស់បញ្ហានេះផងដែរ។

Datin Rossaya ទទួលបានសញ្ញាបត្រច្បាប់ ជំនាញច្បាប់ពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ ខូវិនទ្រី (Coventry University) ចក្រភពអង់គ្លេស។ លោកស្រី គឺជាលេខាធិការមួយរូប ដែលទទួលបានវិញ្ញាបនបត្រ ពីគណៈកម្មការក្រុមហ៊ុន នៃម៉ាឡេស៊ី (Companies Commission of Malaysia) ហើយលោកស្រីក៏ជាសមាជិក (affiliate) មួយរូប នៃវិទ្យាស្ថានរដ្ឋបាល និងលេខាធិការជំនាញ ម៉ាឡេស៊ីផងដែរ។

លី សោភា

លេខាធិការក្រុមហ៊ុនរួម

សញ្ជាតិខ្មែរ

លោកស្រី លី សោភា កាន់តួនាទីជាលេខាធិការក្រុមហ៊ុនរួម របស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី គិតចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១០មកម្ល៉ះ។ លោកស្រី គឺជាលេខាធិការក្រុមហ៊ុនរួមមួយរូប នៃក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការសវនកម្ម របស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី។ លោកស្រីក៏ជាលេខាធិការ នៃគណៈកម្មាធិការគ្រប់គ្រង និងជាអ្នកចូលរួមអចិន្ត្រៃយ៍ ក្នុងគណៈកម្មាធិការផ្សេងៗទៀត របស់ធនាគារ រួមមានដូចជា គណៈកម្មាធិការហានិភ័យ និងគណៈកម្មាធិការឥណទានកម្ពុជា។

មុនពេលចូលបម្រើការងារ ក្នុងធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី លោកស្រីធ្លាប់បម្រើការងារជាជំនួយការ នាយកប្រតិបត្តិជាន់ខ្ពស់នីតិកម្ម និងនាយកផ្នែកនីតិកម្ម និងកិច្ចការក្រុមហ៊ុន នៅក្នុងធនាគារធំមួយ ក្នុងប្រទេសកម្ពុជា។ ក្នុងពេលតែមួយ ក្រៅពីការបន្តការសិក្សា លោកស្រីបានបម្រើការងារ ផ្នែកនីតិកម្ម និងលេខាធិការក្រុមហ៊ុន អស់រយៈពេល ០៦ឆ្នាំ នៅនាយកដ្ឋាននីតិកម្ម និងកិច្ចការក្រុមហ៊ុន នៅកន្លែងដែលធ្លាប់បម្រើការងារពីមុន។

លោកស្រី លី សោភា បានទទួលសញ្ញាបត្របរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ពីសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០០៤ ហើយក្នុងឆ្នាំដដែលនេះ លោកស្រីក៏ទទួលបានសញ្ញាបត្របរិញ្ញាបត្រ ជំនាញគណនេយ្យ ពីមហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម នៃវិទ្យាស្ថានបច្ចេកវិទ្យា និងគ្រប់គ្រង (បច្ចុប្បន្នជា សាកលវិទ្យាល័យ ពុទ្ធិសាស្ត្រ) ផងដែរ។ ក្នុងឆ្នាំ២០០៧ លោកស្រីទទួលបានសញ្ញាបត្រថ្នាក់អនុបណ្ឌិត ជំនាញនីតិឯកជន ពីសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លោកស្រីទទួលបានវិញ្ញាបនបត្រ ផ្នែកការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT) ពី Asian Institute of Chartered Bankers នៅប្រទេសម៉ាឡេស៊ី ក្នុងឆ្នាំ២០១៧។

គណៈកម្មាធិការគ្រប់គ្រង

TH
ANNIVERSARY
IN CAMBODIA

គណៈកម្មាធិការគ្រប់គ្រង

ខ្មែរ

ហេង ធីតា

នាយកសេវាកម្មហិរញ្ញវត្ថុបុគ្គល

លោកស្រី ហេង ធីតា ទទួលបន្ទុកគ្រប់គ្រងទូទៅ និងសកម្មភាពហិរញ្ញវត្ថុ លើផ្នែកសេវាកម្មហិរញ្ញវត្ថុបុគ្គល របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ហើយភារកិច្ចរបស់លោកស្រី គឺរួមមានផ្នែកអភិវឌ្ឍន៍ផលិតផល ផ្នែកលក់ និងចែកចាយ និងផ្នែកគ្រប់គ្រងឥណទាន ទៅលើអតិថិជនបុគ្គល។ លោកស្រីជាអ្នកបង្កើតយុទ្ធសាស្ត្រអាជីវកម្ម និងទទួលខុសត្រូវ លើផ្នែកចែកចាយផលិតផលតាមសាខា សេវាកម្មហិរញ្ញវត្ថុជាន់ខ្ពស់ (Preferred Banking) ឥណទានគេហដ្ឋាន ឥណទានរថយន្ត និងសេវាកម្មប័ណ្ណឥណទាន (Credit Card)។

លោកស្រី ហេង ធីតា ចាប់ផ្តើមអាជីពការងារជា បុគ្គលិកផ្នែកលក់ នៅក្នុងក្រុមហ៊ុន នាំចេញ នាំចូល ហើយបន្ទាប់មកបានធ្វើការ នៅក្នុងក្រុមហ៊ុនផ្សាយពាណិជ្ជកម្មអន្តរជាតិមួយ អស់រយៈពេល ៤ ឆ្នាំ ផ្នែកទំនាក់ទំនងអតិថិជន មុននឹងលោកស្រីចេញទៅបន្តការសិក្សា នៅប្រទេសជប៉ុន។ ក្រោយពេលវិលមកប្រទេសកម្ពុជាវិញ លោកស្រីបានចូលបម្រើការងារ ជាអ្នកផ្តល់ប្រឹក្សា ដល់ធនាគារពិភពលោក ក្នុងកម្មវិធីមេគង្គអភិវឌ្ឍន៍ឯកជន (Mekong Private Development Facility)។

មុនពេលចូលបម្រើការងារ ក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រី ធីតា ធ្លាប់បំពេញការងារនៅធនាគារធំមួយក្នុងប្រទេសកម្ពុជាអស់រយៈពេល ៨ឆ្នាំដែលក្នុងអំឡុងពេលនោះ លោកស្រីកាន់តួនាទីគ្រប់គ្រងមួយចំនួន ដូចជានាយកផ្នែកទីផ្សារ នាយកផ្នែកគាំទ្រសេវាកម្មហិរញ្ញវត្ថុបុគ្គល ហើយបន្ទាប់មកជានាយកផ្នែកគ្រប់គ្រងបណ្តាញសាខា។

លោកស្រី ហេង ធីតា ទទួលបានបរិញ្ញាបត្រ ពីសាកលវិទ្យាល័យ ជាតិគ្រប់គ្រង (NUM) នៅរាជធានីភ្នំពេញ និងបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកទីផ្សារ និងអាជីវកម្ម នៅសាកលវិទ្យាល័យ អន្តរជាតិ នៃប្រទេសជប៉ុន។

ខ្មែរ

ហុង ជៀប

នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម

ជាមួយនឹងបទពិសោធន៍ការងារជាច្រើនឆ្នាំ នៅក្នុងវិស័យធនាគារពាណិជ្ជ លើផ្នែកបម្រើសេវាកម្មអតិថិជន ព្រមទាំងផ្នែកគ្រប់គ្រងហានិភ័យ លោក ហុង ជៀប មានចំណេះដឹងយ៉ាងស៊ីជម្រៅ លើវិស័យធនាគារ និងទំនាក់ទំនងអតិថិជន ក្នុងការផ្តល់នូវយោបល់ ដល់ផ្នែកដែលពាក់ព័ន្ធ ក្នុងដំណើរការអាជីវកម្មរបស់ធនាគារ ព្រមទាំងការគ្រប់គ្រងហានិភ័យ។ លោក ហុង ជៀប ក៏ធ្លាប់បានបម្រើការងារជានាយកគ្រប់គ្រងហានិភ័យ របស់ធនាគារបរទេសមួយ នៅក្នុងប្រទេសឡាវផងដែរ។

មុនពេលក្លាយជា នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ លោក ហុង ជៀប ធ្លាប់កាន់តំណែងជា នាយកគ្រប់គ្រងហានិភ័យ របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលលោកត្រូវទទួលបន្ទុក ផ្នែកគ្រប់គ្រងហានិភ័យទូទៅ និងជាប្រធានគណៈកម្មការឥណទាន នៅក្នុងធនាគារ ដោយធ្វើការយ៉ាងជិតស្និទ្ធ ជាមួយអង្គភាព ដែលពាក់ព័ន្ធ ដើម្បីធានាការអនុវត្តដ៏ខ្ជាប់ខ្ជួននូវវប្បធម៌គ្រប់គ្រងហានិភ័យ នៅក្នុងធនាគារទាំងមូល។

ក្នុងមុខតំណែងជា នាយកសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម លោក ហុង ជៀប ទទួលបន្ទុក ផ្នែកថែរក្សា និងបង្កើនគុណភាព ផ្នែកឥណទាន ប្រមូលប្រាក់បញ្ញើ ដើម្បីសម្រេចបានគោលដៅមូលធនរបស់ធនាគារ ពង្រីកប្រសិទ្ធភាពក្រុមការងារ និងពង្រឹងស្មារតីក្រុម រួមទាំងបង្កើនចំណូលមិនមែនការប្រាក់ របស់សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម។ ក្រៅពីនេះ លោក ហុង ជៀប បានពង្រឹងសហប្រតិបត្តិការ រវាងក្រុមការងារសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម និងក្រុមការងារដទៃទៀត នៅក្នុងធនាគារ ដើម្បីបង្កើនការលក់ តាមរយៈការណែនាំបន្ត និងការទាក់ទងអតិថិជន ឲ្យប្រើផលិតផល និងសេវាកម្មផ្សេងៗទៀត ក្នុងគោលបំណងផ្តល់នូវបទពិសោធន៍បម្រើសេវាកម្មអតិថិជន ឲ្យកាន់តែល្អប្រសើរ។

លោក ហុង ជៀប ទទួលបានសញ្ញាបត្របរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអាជីវកម្ម ហើយបានបញ្ចប់ការសិក្សា លើកម្មវិធីភាពជាអ្នកដឹកនាំ CIMB-INSEAD ផងដែរ។

ខ្ញុំស្រឡាញ់

ហេង តូរ៉ង់

នាយករតនាភិបាល និងទីផ្សារ

លោក ហេង តូរ៉ង់ គឺជាបុគ្គលមួយរូប ក្នុងគណៈកម្មាធិការគ្រប់គ្រង របស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី ដែលបានចូលរួមដំបូង នៅពេលធនាគារត្រូវបានបង្កើត ក្នុងឆ្នាំ២០១០។ លោកបានចាប់ផ្តើមការងារ ក្នុងតួនាទីជាអ្នកបង្កើត និងដឹកនាំនាយកដ្ឋានគ្រប់គ្រងហានិភ័យ និងកិច្ចការលេខាធិការ របស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ។ នៅពាក់កណ្តាលឆ្នាំ២០១៣ លោកត្រូវបានប្រគល់ កាតព្វកិច្ចឲ្យដឹកនាំនាយកដ្ឋានរតនាភិបាល និងទីផ្សារ ដែលរួមមានការគ្រប់គ្រងតារាងតុល្យការ របស់ធនាគារ និងការលក់ផលិតផល ផ្នែករតនាភិបាល ដូចជាប្រតិបត្តិការទិញលក់មូលនិធិ នៅក្នុងទីផ្សារ ប្តូរដុំ និងទីផ្សារអន្តរធនាគារ ប្រតិបត្តិការទិញលក់រូបិយវត្ថុ-រូបិយប័ណ្ណ និងការណែនាំអំពីផលិតផល វិនិយោគក្រៅស្រុកផ្សេងៗ ជូនអតិថិជន រួមទាំងការក្សារនូវទំនាក់ទំនងដ៏រឹងមាំ ជាមួយធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុដែគូនានា។ ក្រៅពីមុខតំណែងជាសមាជិកម្នាក់ របស់គណៈកម្មាធិការគ្រប់គ្រង លោកតូរ៉ង់ ក៏មានវត្តមាន និងតួនាទី នៅក្នុងគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម ហើយនិងគណៈកម្មាធិការគ្រប់គ្រងហានិភ័យផងដែរ។

មុនពេលចូលបម្រើការងារ នៅធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី លោក តូរ៉ង់ ធ្លាប់ជាប្រធានផ្នែក គ្រប់គ្រងហានិភ័យសាច់ប្រាក់ និងទីផ្សារ រួមទាំងមានបទពិសោធន៍អនុវត្តផ្ទាល់ ក្នុងការគ្រប់គ្រង សាច់ប្រាក់ និងរតនាភិបាល នៃធនាគារធំមួយ នៅក្នុងប្រទេសកម្ពុជា អស់រយៈពេល ៦ឆ្នាំ។

លោក តូរ៉ង់ បានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រ ផ្នែកគណនេយ្យ ពីសាកលវិទ្យាល័យគ្រប់គ្រង ក្នុងឆ្នាំ២០០៣ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រ នៃកម្ពុជា ក្នុងឆ្នាំ២០១១ និងវគ្គសិក្សាជាន់ខ្ពស់ Accelerated Universal Bankers Programme ពីសាកល វិទ្យាល័យ បច្ចេកវិទ្យា ណានយ៉ាង (Nanyang Technological University) ក្នុងប្រទេសសិង្ហបុរី នៅឆ្នាំ២០១៤។

ខ្ញុំស្រឡាញ់

គី សាណា

នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម ប្រតិបត្តិការធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ

លោកស្រី គី សាណា បានបម្រើការងារ ក្នុងវិស័យធនាគារ ជាង ១៨ឆ្នាំ។ លោកស្រីបានចាប់ផ្តើម អាជីព ជាមួយនឹងធនាគារអន្តរជាតិជាច្រើន និងកាន់មុខតំណែងផ្សេងៗគ្នា គិតចាប់ពីផ្នែកបម្រើសេវាកម្ម អតិថិជន ដល់ផ្នែកគាំទ្រប្រតិបត្តិការធនាគារ រួមមានផ្នែកឥណទាន និងហិរញ្ញប្បទានពាណិជ្ជកម្ម ដល់គណៈគ្រប់គ្រងជាន់ខ្ពស់។ លោកស្រីបានចូលបម្រើការងារ នៅធនាគារ ស៊ីអាយអ៊ីមប៊ី ភីអិលស៊ី ក្នុងឆ្នាំ២០១០ ជាប្រធានសាខា ដែលជាសាខាដំបូងគេបង្អស់របស់ធនាគារ។ លោកស្រីទទួលបន្ទុក លើសេវាកម្មធនាគារជាន់ខ្ពស់ (Preferred Banking) និងសេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម មុនពេល ត្រូវបានតែងតែជា នាយកសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម ប្រតិបត្តិការធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។

នៅក្នុងមុខតំណែងនេះ លោកស្រី សាណា ទទួលខុសត្រូវ លើការគ្រប់គ្រងទំនាក់ទំនងសេវាកម្ម ធនាគារ ជាមួយអតិថិជនក្រុមហ៊ុនធំៗ និងដំណើរការរបស់សេវាកម្មហិរញ្ញវត្ថុសាជីវកម្មទាំងមូល ក្នុង ធនាគារ នៅប្រទេសកម្ពុជា។ លើសពីសេវាកម្មផ្តល់ឥណទានសាជីវកម្ម បែបប្រពៃណី លោកស្រីមាន តួនាទី ក្នុងការផ្តល់ដំណោះស្រាយ និងគុណតម្លៃបន្ថែម ស្របនឹងតម្រូវការសេវាកម្មប្រតិបត្តិការធនាគារ រួមមានការគ្រប់គ្រងសាច់ប្រាក់ ហិរញ្ញប្បទានពាណិជ្ជកម្ម និងសេវាធនាគារ តាមប្រព័ន្ធអ៊ីនធើណេត។

ក្នុងអំឡុងពេល នៃការបំពេញការងាររបស់ខ្លួន លោកស្រី សាណា ទទួលបានពានរង្វាន់មួយ ចំនួន រួមមាន៖

១. ពានរង្វាន់សាខាឆ្នើមប្រចាំឆ្នាំ ២០១១ ពីធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា
២. ពានរង្វាន់បុគ្គលិគ្គឆ្នើមប្រចាំឆ្នាំ ២០១១ ពីធនាគារ ស៊ីអាយអ៊ីមប៊ី ក្នុងប្រទេសកម្ពុជា
៣. ពានរង្វាន់អ៊ីមមើ៉ូល ឆ្នាំ ២០១៣ (Emerald Award 2013) សម្រាប់អ្នកគ្រប់គ្រងថ្នាក់ កណ្តាល ពីស៊ីអាយអ៊ីមប៊ី គ្រុប

លោកស្រី សាណា បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញបត្រ ផ្នែកគណនេយ្យ ពីវិទ្យាស្ថាន ជាតិគ្រប់គ្រង និងបញ្ចប់វគ្គសិក្សា Accelerated Universal Bankers Programme នៅសាកលវិទ្យាល័យ បច្ចេកវិទ្យាណានយ៉ាង (Nayang Technological University) ក្នុងប្រទេសសិង្ហបុរី។

គណៈកម្មាធិការគ្រប់គ្រង

ខ្មែរ

អ៊ុំ ចិន្ទាភក្តី

នាយកធនធានសាជីវកម្ម

ក្នុងនាមជាគណៈគ្រប់គ្រងមួយរូប ដែលបានចូលរួមជំបូងគេ នៅពេលធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ត្រូវបានបង្កើតឡើង លោកស្រី អ៊ុំ ចិន្ទាភក្តី គឺជាបុគ្គលសំខាន់ ដែលបានជំរុញឲ្យមានភាពជោគជ័យ ក្នុងការគ្រប់គ្រងដឹកនាំ លើយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្ស ដែលរួមមានការជ្រើសរើសបុគ្គលិកសក្តានុពល / ការគ្រប់គ្រងអនុវត្តន៍ការងារ និងប្រាក់រង្វាន់លើកទឹកចិត្ត / ការចូលរួមសកម្មភាពសង្គមនានា ក្នុងន័យផ្សារភ្ជាប់ការប្រាស្រ័យទាក់ទង រវាងនិយោជិត និងនិយោជក / វប្បធម៌នៃការកសាង និងការបណ្តុះបណ្តាល និងគ្រប់គ្រងធនធានមនុស្ស។ លោកស្រីធានាថា ធនាគារ ស៊ីអាយអិមប៊ី គឺជាស្ថាប័នការងារឈានមុខគេមួយ នៅលើទីផ្សារ។ ក្នុងឆ្នាំ២០២០ លោកស្រីជួយជ្រោមជ្រែង ដល់ធនាគារ ដើម្បីឈ្នះពានរង្វាន់ «ទីកន្លែងការងារល្អបំផុត ក្នុងប្រទេសកម្ពុជា» ដែលជាសមិទ្ធផលគួរជាទីមោទនរបស់ស្ថាប័នទាំងមូល។

រហូតមកដល់បច្ចុប្បន្ន លោកស្រី ភក្តី រួមចំណែក ក្នុងការសម្រេចបានសមិទ្ធផលរបស់ធនាគារ តាមរយៈការកសាង ពង្រឹង និងបង្កើនសមត្ថភាពនិយោជិត ប្រកបដោយភាពប្រកួតប្រជែង និងជំរុញដល់ធនធានមនុស្ស ឲ្យអស់ពីលទ្ធភាពរបស់ពួកគេ។ ចំណុចផ្តោតចម្បងរបស់លោកស្រី គឺរួមមានការទាក់ទាញ និងការរក្សាទុក នូវនិយោជិតសក្តានុពល ដែលជួយពន្លឿនភាពរីកចម្រើន និងនិរន្តភាពរបស់អាជីវកម្ម សម្រាប់រយៈពេលខ្លី មធ្យម និងរយៈពេលវែងរបស់ធនាគារ។ យុទ្ធសាស្ត្រ និងគំនិតគន្លឹះរបស់លោកស្រី សម្រាប់ទិសដៅអនាគតជំរុញការធ្វើបច្ចុប្បន្នភាពរបស់ធនាគារ ដើម្បីតាមទាន់ការអភិវឌ្ឍ នៅក្នុងសម័យឌីជីថល និងបច្ចេកវិទ្យា។ លោកស្រីអភិវឌ្ឍនិយោជិត ជាមួយនឹងជំនាញ ចំណេះដឹង និងសមត្ថភាពការងារថ្មីៗ ដែលជាតម្រូវការ រួមមានផ្នែកឌីជីថល ទិន្នន័យ និងរចនា តាមរយៈកម្មវិធីបណ្តុះបណ្តាល និងការសិក្សារៀនសូត្រចម្រុះបែប ទាំងនៅក្នុងប្រទេស និងថ្នាក់តំបន់ ស្របតាមបទពិសោធន៍ការងារជាក់ស្តែង។

លោកស្រី ភក្តី មានជំនាញទំនាក់ទំនងយ៉ាងល្អ ដែលអាចធ្វើការយ៉ាងជិតស្និទ្ធ បានដោយរលូន ជាមួយថ្នាក់ដឹកនាំ ក្នុងការបង្កើត និងអនុវត្តផែនការ នៃការសម្រេចជោគជ័យ ក្រោមការជួយគាំទ្រ យ៉ាងពេញទំហឹង ពីកម្មវិធីបណ្តុះបណ្តាល និងកម្មវិធីអភិវឌ្ឍន៍ នៅក្នុងប្រទេស និងថ្នាក់តំបន់។

ក្រៅពីជំនាញ ផ្នែកគ្រប់គ្រងធនធានមនុស្ស លោកស្រីទទួលបន្ទុក លើការដឹកនាំចាត់ចែង ផ្នែករដ្ឋបាល ការគ្រប់គ្រងគម្រោងបង្កើត និងពង្រីកសាខា និងការិយាល័យការងារ ក៏ដូចជាលទ្ធកម្មជាយុទ្ធសាស្ត្រ។ លោកស្រីពិនិត្យមើលគម្រោងសំខាន់ៗ ដែលធានានូវប្រសិទ្ធភាព និងប្រសិទ្ធផល នៃការគ្រប់គ្រងចំណាយ។

មុនពេលចាប់ផ្តើមចូលបម្រើការងារ ក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រី អ៊ុំ ចិន្ទាភក្តី មានបទពិសោធន៍១៥ឆ្នាំ ក្នុងតំណែងជាអ្នកគ្រប់គ្រង ផ្នែកធនធានមនុស្ស ជាមួយបណ្តាស្ថាប័នជាច្រើនរួចមកហើយ។ លោកស្រីបានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលពាណិជ្ជកម្ម ពីវិទ្យាស្ថាន ជាតិគ្រប់គ្រង ក្នុងប្រទេសកម្ពុជា។

ខ្មែរ

ហេង រ៉ុទ្ធី

នាយកហិរញ្ញវត្ថុ

លោក ហេង រ៉ុទ្ធី គឺជាបុគ្គលមួយរូប ក្នុងគណៈកម្មាធិការគ្រប់គ្រង របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលបានចូលរួមជំបូង នៅពេលធនាគារត្រូវបានបង្កើត ក្នុងឆ្នាំ២០១០។ ភារកិច្ចចម្បងរបស់លោក គឺរួមមានការគ្រប់គ្រងមុខងារហិរញ្ញវត្ថុ រៀបចំផែនការ ដឹកនាំ និងគ្រប់គ្រងបុគ្គលិក ក្នុងការអភិវឌ្ឍ អនុវត្ត និងរៀបចំគោលការណ៍ និងនីតិវិធី សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ថវិកា គណនេយ្យ ពន្ធដារ និងរបាយការណ៍បទប្បញ្ញត្តិ ព្រមទាំងយុទ្ធសាស្ត្រអាជីវកម្មរបស់ធនាគារទាំងមូល។

លោក រ៉ុទ្ធី ត្រួតពិនិត្យផងដែរ លើប្រព័ន្ធ និងរបាយការណ៍គណនេយ្យ ការគ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំផែនការអាជីវកម្ម និងដើរតួនាទីជា អ្នកសម្របសម្រួល ជាមួយក្រុមហ៊ុនមេ នៅប្រទេសម៉ាឡេស៊ី។ មុនពេលចូលបម្រើការងារ នៅធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកមានបទពិសោធន៍ ៨ឆ្នាំ ក្នុងការងារគ្រប់គ្រងហិរញ្ញវត្ថុ និងកាន់តួនាទីជា នាយករងហិរញ្ញវត្ថុ នៅធនាគារធំមួយ ក្នុងប្រទេសកម្ពុជា។

លោក រ៉ុទ្ធី ទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ជំនាញហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ បញ្ញាសាស្ត្រកម្ពុជា ហើយបានបញ្ចប់ការសិក្សា ថ្នាក់គណនេយ្យករជាន់ខ្ពស់ (ACCA: Association of Chartered Certified Accountants) ពីសាលាពាណិជ្ជកម្ម CamEd ដែលជាស្ថាប័នទទួលបានសិទ្ធិជាផ្លូវការ ពីចក្រភពអង់គ្លេស ក្នុងការបណ្តុះបណ្តាល ACCA នៅប្រទេសកម្ពុជា។

ខ្ញុំស្រឡាញ់

អ៊ុក ថានិន

នាយកគ្រប់គ្រងផលិតផល

លោក អ៊ុក ថានិន បានចូលបម្រើការងារ នៅក្នុងធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី ក្នុងឆ្នាំ២០១៧ ដែលមានតួនាទីត្រួតពិនិត្យ លើនាយកដ្ឋានគ្រប់គ្រងផលិតផល។ ទំនួលខុសត្រូវការងាររបស់លោក គឺរួមមានការគ្រប់គ្រង ការសម្របសម្រួល និងការអនុវត្តគម្រោង បទប្បញ្ញត្តិ និងសេចក្តីណែនាំ ដែលពាក់ព័ន្ធនឹងផលិតផលថ្មីៗ និងមានស្រាប់ ដើម្បីស្របតាមតម្រូវការទីផ្សារ។ ក្នុងឆ្នាំកន្លងមកនេះ លោកបានចាត់ចែងនាយកដ្ឋានគ្រប់គ្រងផលិតផល និងបាននាំយកផលិតផលថ្មីៗ ដោយជោគជ័យ ដែលនាំឲ្យធនាគារ ស៊ីអាយអ៊ីមប៊ី កាន់តែមានភាពប្រកួតប្រជែងមួយកម្រិតទៀត នៅលើទីផ្សារ។ មិនតែប៉ុណ្ណោះ លោកបានដឹកនាំសម្របសម្រួល លើគម្រោងទូទាំងធនាគារជាច្រើន ដែលភាគច្រើន គឺទាក់ទងនឹងកម្មវិធីនិរន្តរភាព និងកម្មវិធីសេវាធនាគារ តាមទូរសព្ទចល័ត។

មុនពេលចូលបម្រើការងារ ក្នុងធនាគារ ស៊ីអាយអ៊ីមប៊ី លោកមានបទពិសោធន៍ ៩ឆ្នាំ នៅក្នុងវិស័យឧស្សាហកម្មហិរញ្ញវត្ថុ ក្នុងផ្នែកផ្សេងៗគ្នា ដូចជាសេវាកម្មធនាគារ ជាប់រងទូទៅ ការគ្រប់គ្រងឥណទាន និងសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម។

លោក ថានិន ធ្លាប់ទទួលអាហារូបករណ៍ ពីរដ្ឋាភិបាលសិង្គបុរី និងអាហារូបករណ៍ Fulbright។ លោកបានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រ ពីសាកលវិទ្យាល័យជាតិ សិង្គបុរី ក្នុងឆ្នាំ២០០៦ ហើយលោកក៏ទទួលបានអាហារូបករណ៍ Fulbright ផងដែរ ដោយបានបញ្ចប់ការសិក្សា ថ្នាក់អនុបណ្ឌិត ពីសាកលវិទ្យាល័យ Vanderbilt នៅសហរដ្ឋអាមេរិក ក្នុងឆ្នាំ២០១២។ លោកបានក្លាយជាសមាជិក Beta Gamma Sigma ដែលជាស្ថាប័នអន្តរជាតិ សម្រាប់ថ្នាក់ឧត្តមសិក្សា ផ្នែកអាជីវកម្ម។

ខ្ញុំស្រឡាញ់

ហេង វិបុត្រ

នាយកបច្ចេកវិទ្យា និងប្រតិបត្តិការ

លោក ហេង វិបុត្រ បានចូលបម្រើការងារ នៅក្នុងធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី ក្នុងនាមជានាយកបច្ចេកវិទ្យា និងប្រតិបត្តិការ នៅខែសីហា ឆ្នាំ២០១៨។ លោកទទួលបន្ទុកមើលការខុសត្រូវទៅលើផ្នែកព័ត៌មានវិទ្យា សន្តិសុខព័ត៌មានវិទ្យា ការគ្រប់គ្រងគម្រោងព័ត៌មានវិទ្យា អភិបាលកិច្ចទិន្នន័យ ព្រមទាំងមុខងារការធានា លើការអនុលោមតាមបច្ចេកវិទ្យាព័ត៌មាន។

ក្រៅពីការគ្រប់គ្រង លើបច្ចេកវិទ្យាព័ត៌មាន លោក វិបុត្រ ក៏ទទួលខុសត្រូវ លើផ្នែកប្រតិបត្តិការរបស់ធនាគារទាំងមូលផងដែរ និងធានាថា រាល់ប្រតិបត្តិការប្រចាំថ្ងៃ ត្រូវប្រព្រឹត្តទៅដោយរលូន ផ្អែកលើគោលការណ៍ នីតិវិធី បទប្បញ្ញត្តិ និងការអនុលោមតាមច្បាប់។ មិនតែប៉ុណ្ណោះ លោកត្រូវដឹកនាំ និងអនុវត្តយុទ្ធសាស្ត្រ សម្រាប់ផ្នែកបច្ចេកវិទ្យា និងប្រតិបត្តិការ ដើម្បីស្របតាមកំណើនអាជីវកម្ម និងផែនការយុទ្ធសាស្ត្ររបស់ក្រុមហ៊ុនមេ។

លោក វិបុត្រ មានបទពិសោធន៍ការងារជាង ១៨ឆ្នាំ ក្នុងវិស័យធនាគារ ហើយលោកបានចាប់ផ្តើមអាជីពការងារជា វិស្វករសរសេរកម្មវិធីកុំព្យូទ័រ ក្នុងឆ្នាំ២០០៣។ មុនពេលចូលបម្រើការ នៅធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី លោកធ្លាប់បំពេញការងារជា នាយកសេវាកម្មបច្ចេកវិទ្យាព័ត៌មាន ជាមួយនឹងធនាគារក្នុងស្រុកដ៏ធំមួយ ក្នុងប្រទេសកម្ពុជា។

លោក ហេង វិបុត្រ ទទួលបានសញ្ញាបត្របរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

គណៈកម្មាធិការគ្រប់គ្រង

ខ្មែរ

លី សោភា

នាយកនីតិកម្ម និងលេខាធិការក្រុមហ៊ុន

លោកស្រី លី សោភា មានតួនាទីជានាយកនីតិកម្ម និងលេខាធិការក្រុមហ៊ុន នៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ចាប់តាំងពីថ្ងៃចាប់ផ្តើមប្រតិបត្តិការដំបូងរបស់ធនាគារ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១០។ លោកស្រី ទទួលបន្ទុកចាត់ចែងតួនាទីនីតិកម្ម និងលេខាធិការក្រុមហ៊ុន។ លោកស្រី គឺជាលេខាធិការក្រុមហ៊ុនមួយរូប នៃក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការសវនកម្ម របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី។ លោកស្រីក៏ជាលេខាធិការនៃគណៈកម្មាធិការគ្រប់គ្រង និងជាអ្នកចូលរួមអចិន្ត្រៃយ៍ ក្នុងគណៈកម្មាធិការផ្សេងៗទៀតរបស់ធនាគារ រួមមានដូចជា គណៈកម្មាធិការហានិភ័យ និងគណៈកម្មាធិការឥណទានកម្ពុជា។

មុនពេលចូលបម្រើការងារ ក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី លោកស្រីធ្លាប់បម្រើការងារជាជំនួយការ នាយកប្រតិបត្តិជាន់ខ្ពស់នីតិកម្ម និងនាយកផ្នែកនីតិកម្ម និងកិច្ចការក្រុមហ៊ុន នៅក្នុងធនាគារធំមួយ ក្នុងប្រទេសកម្ពុជា។ ក្នុងពេលតែមួយ ក្រៅពីការបន្តការសិក្សា លោកស្រីបានបម្រើការងារ ផ្នែកនីតិកម្ម និងលេខាធិការក្រុមហ៊ុន អស់រយៈពេល ០៦ឆ្នាំ នៅនាយកដ្ឋាននីតិកម្ម និងកិច្ចការក្រុមហ៊ុន នៅកន្លែងដែលធ្លាប់បម្រើការងារពីមុន។

លោកស្រី លី សោភា បានទទួលសញ្ញាបត្របរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ពីសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០០៤ ហើយក្នុងឆ្នាំដដែលនេះ លោកស្រីក៏ទទួលបានសញ្ញាបត្របរិញ្ញាបត្រ ជំនាញគណនេយ្យ ពីមហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម នៃវិទ្យាស្ថានបច្ចេកវិទ្យា និងគ្រប់គ្រង (បច្ចុប្បន្នជា សាកលវិទ្យាល័យពុទ្ធិសាស្ត្រ) ផងដែរ។ ក្នុងឆ្នាំ២០០៧ លោកស្រីទទួលបានសញ្ញាបត្រថ្នាក់អនុបណ្ឌិត ជំនាញនីតិឯកជន ពីសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លោកស្រីទទួលបានវិញ្ញាបនបត្រ ផ្នែកការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT) ពី Asian Institute of Chartered Bankers នៅប្រទេសម៉ាឡេស៊ី ក្នុងឆ្នាំ២០១៧។

ខ្មែរ

គឿន វឌ្ឍនា

នាយកគ្រប់គ្រងហានិភ័យ

លោក គឿន វឌ្ឍនា គឺជានាយកគ្រប់គ្រងហានិភ័យ របស់ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលមានតួនាទីត្រួតពិនិត្យ លើការគ្រប់គ្រងហានិភ័យ និងធ្វើការយ៉ាងជិតស្និទ្ធ ជាមួយនឹងផ្នែកអាជីវកម្ម ផ្សេងទៀត ព្រមទាំងក្រុមការងារហានិភ័យ របស់ស៊ីអាយអិមប៊ី គ្រុប ដើម្បីបញ្ចូល និងបញ្ជ្រាបវប្បធម៌គ្រប់គ្រងហានិភ័យ នៅក្នុងធនាគារ។

លោក វឌ្ឍនា គឺជាអ្នកចូលរួមដំបូងមួយរូប ក្នុងការបង្កើតក្រុមការងារគ្រប់គ្រងឥណទាន នៅក្នុងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ក្នុងឆ្នាំ២០១០ ដែលត្រួតពិនិត្យមើលឥណទាន លើគ្រប់ផ្នែកអាជីវកម្ម (សេវាកម្មហិរញ្ញវត្ថុបុគ្គល សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្ម និងសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម)។ លោកមានចំណេះដឹង និងបទពិសោធន៍ដ៏ទំលូទំលាយ លើផ្នែកគ្រប់គ្រងឥណទាន។ លោកបានពង្រឹងជំនាញរបស់ខ្លួនបន្ថែម ជាមួយនឹងការយល់ដឹង អំពីអតិថិជន និងវិស័យធនាគារ តាមរយៈការធ្វើការជាមួយក្រុមការងារគ្រប់គ្រងឥណទាន ក្នុងប្រទេសម៉ាឡេស៊ី និងសិង្គបុរី ដែលទទួលបន្ទុកត្រួតពិនិត្យសំណើសុំឥណទានទាំងអស់ ពីប្រទេសកម្ពុជា ថៃ និងម៉ាឡេស៊ី។

លោក គឿន វឌ្ឍនា ត្រូវបានតែងតាំងជា ប្រធានគណៈកម្មការឥណទាន ដោយផ្អែកលើបទពិសោធន៍ដ៏ក្រាស់ក្រែល ផ្នែកគ្រប់គ្រងឥណទាន រយៈពេលជាង ១៥ឆ្នាំ ក្នុងវិស័យធនាគារ។ លោកផ្តល់នូវទិសដៅ និងការណែនាំ ដើម្បីរក្សា និងទាក់ទាញអតិថិជនល្អ។ ព្រមទាំងធានាឲ្យបាននូវគុណភាពឥណទាន ដែលធនាគារមាន។ ក្រៅពីនេះ លោកពិនិត្យមើលការគ្រប់គ្រងហានិភ័យប្រភេទផ្សេងទៀត ដែលរួមមានហានិភ័យប្រតិបត្តិការ ហានិភ័យទីផ្សារ និងហានិភ័យសន្ធនីយភាពជាដើម។

លោក វឌ្ឍនា ទទួលបានសញ្ញាបត្របរិញ្ញាបត្រ ផ្នែកធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រគណិតវិទ្យា។ ជាមួយគ្នានេះ លោកបានបញ្ចប់ការសិក្សាកម្មវិធីបណ្តុះបណ្តាល លើជំនាញវាយតម្លៃឥណទាន របស់ CIMB-Omega និង Accelerated Universal Bankers Programme ពីសាកលវិទ្យាល័យ បច្ចេកវិទ្យាណានយ៉ាង (Nanyang Technological University) ក្នុងប្រទេសសិង្គបុរី។

ខ្ញុំស្រឡាញ់

ឈុន ពុទ្ធកុម្ភៈវត្តី

នាយកប្រតិបត្តិតាម

លោកស្រី ឈុន ពុទ្ធកុម្ភៈវត្តី បានចូលបម្រើការងារ នៅធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី ក្នុងមុខតំណែងជា នាយកប្រតិបត្តិតាម នៅខែសីហា ឆ្នាំ២០១៧។ លោកស្រីទទួលបន្ទុក លើការងារគ្រប់គ្រងរួម លើមុខងារប្រតិបត្តិតាម និងរាយការណ៍ ទៅកាន់ក្រុមប្រឹក្សាភិបាល នៃធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី។ ក្នុងមុខតំណែងជានាយកប្រតិបត្តិតាម លោកស្រីវត្តី ត្រួតពិនិត្យ និងណែនាំការងារទាំងឡាយ ដែលទាក់ទងនឹងផ្នែកប្រតិបត្តិតាម នៅក្នុងធនាគារ និងជាអ្នកទំនាក់ទំនងចម្បង ជាមួយនឹងធនាគារជាតិ នៃកម្ពុជា និងអាជ្ញាធរដទៃទៀត។

លោកស្រី ឈុន ពុទ្ធកុម្ភៈវត្តី បានចាប់ផ្តើមអាជីពការងារជា សវនករ ក្នុងក្រុមហ៊ុនសវនកម្ម អន្តរជាតិមួយ ហើយបន្ទាប់មក លោកស្រីបានចាប់យកតួនាទីការងារ ផ្នែកប្រតិបត្តិតាម ក្នុងវិស័យហិរញ្ញវត្ថុ។ លោកស្រីវត្តី មានបទពិសោធន៍ការងារ១០ឆ្នាំ ក្នុងវិស័យធនាគារ ជាមួយនឹងជំនាញផ្នែកប្រតិបត្តិតាម និងគ្រប់គ្រងហានិភ័យប្រតិបត្តិការ។ មុនពេលចូលបម្រើការងារ ក្នុងធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី លោកស្រីវត្តី ធ្លាប់បម្រើការងារជា នាយកគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងគ្រប់គ្រងផ្ទៃក្នុង នៅធនាគារធំមួយក្នុងប្រទេសកម្ពុជា។

លោកស្រីវត្តី បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យ បញ្ញាសាស្ត្រ កម្ពុជា និងបញ្ចប់ការសិក្សា ផ្នែកប្រតិបត្តិតាម ពីវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ។ ក្នុងឆ្នាំ២០២០ លោកស្រីទទួលបានវិញ្ញាបនបត្រ កម្រិតអន្តរជាតិ ផ្នែកប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ពីសមាគមអន្តរជាតិ ផ្នែកប្រតិបត្តិតាម ។

ខ្ញុំស្រឡាញ់

លោក ខៀវ ឡានីន

នាយកសវនកម្មផ្ទៃក្នុង

ក្នុងនាមជាអ្នកចូលរួមចំណែកមួយរូប ក្នុងគណៈកម្មាធិការគ្រប់គ្រង របស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី នៅពេលបើកដំណើរការដំបូង ក្នុងឆ្នាំ២០១០ លោក ខៀវ ឡានីន ទទួលខុសត្រូវ លើការអភិវឌ្ឍ ពិនិត្យមើលផែនការសវនកម្ម យុទ្ធសាស្ត្រ ស្តង់ដារ និងគោលការណ៍ ព្រមទាំងការគ្រប់គ្រងទូទៅ ក្នុងនាយកដ្ឋានសវនកម្មផ្ទៃក្នុង របស់ធនាគារ។

លោក ឡានីន បានចូលបម្រើការងារ ក្នុងវិស័យធនាគារ ជាពិសេសមុខងារ សវនកម្មផ្ទៃក្នុង ជាមួយនឹងបទពិសោធន៍ជាង ១៨ឆ្នាំមកហើយ ដែលលោកមានសមត្ថភាព ក្នុងការបំពេញតួនាទីយ៉ាងមានប្រសិទ្ធភាព និងជាជំនួយ ទៅដល់គណៈកម្មាធិការសវនកម្ម និងគណៈគ្រប់គ្រង ក្នុងការបង្កើតការគ្រប់គ្រងចំណាយ ប្រកបដោយប្រសិទ្ធភាព ការវាយតម្លៃហានិភ័យ ការផ្តល់អនុសាសន៍ លើវិធានការកាត់បន្ថយហានិភ័យ និងការធានាដំណើរការអភិបាលកិច្ច ឲ្យបានល្អប្រសើរ។

លោក ឡានីន ទទួលបានសញ្ញាបត្របរិញ្ញាបត្រ ផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង និងបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ ពីសាកលវិទ្យាល័យ ហ្ស៊ីលប្រាយ។ បច្ចុប្បន្ន លោកកំពុងសិក្សាថ្នាក់សវនករផ្ទៃក្នុង ពីវិទ្យាស្ថាន សវនករផ្ទៃក្នុង។

របាយការណ៍ ហិរញ្ញវត្ថុ

៨៦ របាយការណ៍ក្រុមប្រឹក្សាភិបាល
៨៨ របាយការណ៍សវនករឯករាជ្យ
៩០ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
៩១ របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ
៩២ របាយការណ៍បម្រែបម្រួលមូលធន
៩៣ របាយការណ៍លំហូរសាច់ប្រាក់
៩៤ កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
១៤០ ព័ត៌មានហិរញ្ញវត្ថុបន្ថែម ទៅតាមតម្រូវការរបស់ធនាគារជាតិ នៃកម្ពុជា

ឆ្នាំ

ខួប១០ឆ្នាំ នៃប្រតិបត្តិការ

នៅប្រទេសកម្ពុជា

របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី (ហៅកាត់ថា «ធនាគារ») សូមដាក់ជូនរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលបានធ្វើសវនកម្មរួចហើយ សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

អំពីធនាគារ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី បានបង្កើតឡើងនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ហើយធនាគារនេះគឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលកាន់កាប់ទាំងស្រុងដោយ CIMB Bank Berhad ដែលជាធនាគារមានអាជ្ញាប័ណ្ណចុះបញ្ជីអាជីវកម្ម នៅប្រទេសម៉ាឡេស៊ី។ ក្រុមហ៊ុន CIMB Group Holdings Berhad ដែលបានចុះបញ្ជីជាក្រុមហ៊ុនសាជីវកម្មសាធារណៈ នៅប្រទេសម៉ាឡេស៊ី គឺជាក្រុមហ៊ុនមេធំបង្អស់។

សកម្មភាពអាជីវកម្មចម្បងៗ

សកម្មភាពអាជីវកម្មចម្បងៗរបស់ធនាគារ គឺការផ្តល់សេវាផ្នែកធនាគារជាច្រើនប្រភេទ និងសេវាដែលពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

លទ្ធផលប្រតិបត្តិការ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារសម្រាប់ឆ្នាំ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ នៅលើទំព័រទី៩១។

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ មិនមានការប្រកាស ឬការបង់ភាគលាភទេ។

ដើមទុន

ក្នុងអំឡុងឆ្នាំ មិនមានការផ្លាស់ប្តូរភាគទុនិករបស់ធនាគារទេ ។

ក្នុងអំឡុងឆ្នាំ ធនាគារបានផ្ទេរប្រាក់ចំណេញរក្សាទុករបស់ខ្លួនចំនួន ១៧.៥០០.០០០ ដុល្លារអាមេរិក ដើម្បីរក្សាទុកជាដើមទុនបម្រុង។

ហ្វាស៊ីលីធីហិរញ្ញវត្ថុអាក្រក់ និងសង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋាន សមរម្យ ពាក់ព័ន្ធទៅនឹងការជម្រះបុរេប្រទាន និងឥណទានអាក្រក់ចេញពីបញ្ជី ឬការធ្វើសំវិធានធនការខាតបង់ដែល បណ្តាលមកពីការថយចុះតម្លៃ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា រាល់បុរេប្រទាន និងឥណទានអាក្រក់ទាំងអស់ដែលបានដឹង ត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រាសំវិធានធនបាត់បង់គ្រប់គ្រាន់ សម្រាប់បុរេប្រទាន និងឥណទានអាក្រក់ និងសង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមកម្រិតនៃការយល់ដឹង ក្រុមប្រឹក្សាភិបាលពុំបានដឹងពី កាលៈទេសៈណាមួយ ដែលនាំឲ្យចំនួនបុរេប្រទាន និងឥណទានអាក្រក់ ដែលបានជម្រះចេញពីបញ្ជី ឬចំនួនសំវិធានធន បុរេប្រទាន និងឥណទានអាក្រក់ និងសង្ស័យ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានតម្លៃមិនគ្រប់គ្រាន់ ជាសារវន្តនោះទេ។

ទ្រព្យសកម្ម

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្ម ដែលទំនងជាមិនអាចទទួលបានមកវិញនៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ទៅតាមតម្លៃនៅក្នុងបញ្ជីរបស់ធនាគារ ត្រូវបានកាត់បន្ថយឲ្យស្មើនឹងតម្លៃដែលរំពឹងថានឹងអាចលក់បាន នៅលើទីផ្សារជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមកម្រិតនៃការយល់ដឹង ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលបណ្តាលឲ្យតម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានតម្លៃមិនត្រឹមត្រូវជាសារវន្តនោះទេ។

បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

ក. មិនមានបន្ទុកណាមួយ លើទ្រព្យសកម្មរបស់ធនាគារ ដែលបានកើតឡើង ដោយសារការដាក់បញ្ចាំ ដើម្បីការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក និង

ខ. មិនមានបំណុលយថាភាពណាមួយរបស់ធនាគារ ដែលបានកើតឡើង ចាប់តាំងពីដំណាច់ឆ្នាំមក ក្រៅពីបំណុលផ្សេងៗ នៅក្នុងដំណើរការអាជីវកម្មធនាគារធម្មតានោះទេ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗរបស់ធនាគារ ដែលត្រូវបានទាមទារឲ្យសង ឬអាចនឹងត្រូវទាមទារឲ្យសង ក្នុងរយៈពេល១២ខែ បន្ទាប់ពីដំណាច់ឆ្នាំ ដែលនឹង ឬអាចនឹងមានផល ប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន នៅថ្ងៃផុតកំណត់សងនោះទេ។

ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចបណ្តាលឲ្យចំនួនទឹកប្រាក់ ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានកំហុសឆ្គងជាសារវន្តនោះឡើយ។

ប្រតិបត្តិការដែលមានលក្ខណៈមិនធម្មតា

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ សម្រាប់ឆ្នាំហិរញ្ញវត្ថុនេះ ពុំមានរងនូវផលប៉ះពាល់ជាសារវន្តពីគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងខុសពីធម្មតានោះទេ។ តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ក្នុងចន្លោះពេល រវាងដំណាច់ឆ្នាំហិរញ្ញវត្ថុ មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងខុសប្រក្រតី ដែលទំនងជាមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ក្នុងឆ្នាំដែលរបាយការណ៍នេះត្រូវបានធ្វើឡើងនោះទេ។

ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលនៅបម្រើការក្នុងអំឡុងឆ្នាំ និងរហូតមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម ៖

Datuk Mohd Nasir Bin Ahmad	ប្រធានក្រុមប្រឹក្សាភិបាល/ អភិបាលឯករាជ និងមិនប្រតិបត្តិ
បណ្ឌិត ម៉ី កល្យាណ	អភិបាលឯករាជ និងមិនប្រតិបត្តិ
លោកស្រី Aisyah Lam Binti Abdullah	អភិបាលឯករាជ និងមិនប្រតិបត្តិ
លោក Omar Siddiq Bin Amin Noer Rashid	អភិបាលមិនឯករាជ និងមិនប្រតិបត្តិ
លោក Ahmad Shazli Kamarulzaman	អភិបាលមិនឯករាជ និងមិនប្រតិបត្តិ
លោក ប៊ុន យ៉ីន	អភិបាលប្រតិបត្តិ/ប្រធាននាយកប្រតិបត្តិ

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល ចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវ ក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់ សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (ហៅកាត់ថា «CIFRS»)។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ តម្រូវឲ្យក្រុមប្រឹក្សាភិបាល៖

១. ប្រើប្រាស់គោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន បន្ទាប់ពីនោះត្រូវអនុវត្តគោលការណ៍ទាំងនោះឲ្យបានស៊ីសង្វាក់គ្នា។
២. អនុវត្តតាមការលាតត្រដាងព័ត៌មានរបស់ CIFRS ឬប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញឲ្យមានភាពត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវលាតត្រដាង ពន្យល់ និងកំណត់បរិមាណឲ្យបានត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
៣. រក្សាទុកបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ប្រកបដោយប្រសិទ្ធភាព។
៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃអាជីវកម្ម លើកលែងតែមានករណីមិនសមរម្យក្នុងការសន្មតថា ធនាគារអាចនឹងបន្តប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង
៥. ត្រួតពិនិត្យ និងដឹកនាំធនាគារ ដោយចូលរួមលើរាល់ការសម្រេចចិត្តសំខាន់ៗទាំងអស់ ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការទាំងនេះត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ធនាគារបានអនុវត្តតាមតម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ ព្រមទាំងកំណត់សម្គាល់ទាំងឡាយបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០២០ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ត្រូវបានអនុម័ត ដោយក្រុមប្រឹក្សាភិបាល។

ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

ធនាគារ ស៊ីអាយអ៊ីប៊ី អ៊ីន្ធឺណេស៊ី CIMB BANK PLC

លោក ប៊ុន យ៉ីន
អភិបាលប្រតិបត្តិ/ប្រធាននាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១

របាយការណ៍សវនករឯករាជ្យ

ជូនភាគទុនិកធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី

មតិយោបល់របស់យើងខ្ញុំ

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញត្រឹមត្រូវ នូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ ស៊ីអាយអ៊ីមប៊ី ភីអ៊ីលស៊ី (ហៅកាត់ថា «ធនាគារ») គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់ សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (ហៅកាត់ថា «CIFRS»)។

របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ រួមមាន៖

- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០
- របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ សម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធន សម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ និងព័ត៌មានពន្យល់ផ្សេងៗទៀត។

មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាម ស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា (ហៅកាត់ថា «ស្តង់ដារ សវនកម្ម»)។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ដែលអនុលោមទៅតាមស្តង់ដារទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌ *ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* នៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថាភ័ស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជាមូលដ្ឋាន សម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

ឯករាជ្យ

យើងខ្ញុំមានឯករាជ្យពីក្រុមហ៊ុន ដែលអនុលោមទៅតាមក្រមសីលធម៌អន្តរជាតិ សម្រាប់គណនេយ្យករវិជ្ជាជីវៈ (រួមទាំងស្តង់ដារឯករាជ្យអន្តរជាតិ) ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារក្រមសីលធម៌អន្តរជាតិ សម្រាប់គណនេយ្យករ (ហៅកាត់ថា «ក្រមសីលធម៌អន្តរជាតិ») និងអនុលោមទៅតាមក្រមសីលធម៌របស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (ហៅកាត់ថា «ក្រមសីលធម៌ វគសក») ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ចំពោះរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា។ យើងខ្ញុំបានបំពេញកាតព្វកិច្ច ក្នុងការទទួលខុសត្រូវផ្នែកក្រមសីលធម៌ផ្សេងៗទៀតដែលកំណត់ដោយក្រមសីលធម៌អន្តរជាតិ និងក្រមសីលធម៌ វគសក។

ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងទទួលខុសត្រូវ ចំពោះព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលយើងខ្ញុំបានទទួលនាកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ រួមមានរបាយការណ៍ក្រុមប្រឹក្សាភិបាល និងព័ត៌មានហិរញ្ញវត្ថុបន្ថែមទៅតាមតម្រូវការរបស់ធនាគារជាតិ នៃកម្ពុជា ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំទេ។

មតិយោបល់របស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានានិងអះអាង ចំពោះព័ត៌មានទាំងនោះទេ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ដែលបានរៀបរាប់ខាងលើ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះ មានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពីកំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ។

ផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញ ទៅលើព័ត៌មានផ្សេងៗដែលយើងខ្ញុំទទួលបាន មុនកាលបរិច្ឆេទនៃ របាយការណ៍សវនករនេះ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្ត ដែលកើតចេញពីព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងទាំងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ។

ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងបង្ហាញរបាយការណ៍ទាំងនោះឲ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាម CIFRS និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុងដែលគណៈគ្រប់គ្រងកំណត់ថាមាន ភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃ អំពីលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មាន ដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗ ដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យ សម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងមានគម្រោងបិទអាជីវកម្មរបស់ក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬដោយមិនមានជម្រើសណាផ្សេង ប្រកបដោយភាពប្រាកដប្រជាណាមួយ។

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្ម លើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺស្វែងរកអំណះអំណាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនករ ដែលមានមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថាសវនកម្មដែលបានធ្វើឡើងដោយអនុលោមទៅតាមស្តង់ដារសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្ត ដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយវាត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថាវាជះឥទ្ធិពល លើមូលដ្ឋាននៃការសម្រេចចិត្ត ផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដារសវនកម្ម តម្រូវឲ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យប្រកបដោយ វិជ្ជាជីវៈ និងរក្សាការសង្ស័យស្របតាមវិជ្ជាជីវៈ ក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងស្វែងរកភ័ស្តុតាងសវនកម្មគ្រប់គ្រាន់ និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសឆ្គងជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងអចេតនា ដោយសារការក្លែងបន្លំរួមមាន ការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុស ឬការរំលងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្រប ទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំ ទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។
- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យ ដែលបានប្រើប្រាស់ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធ ដែលគណៈគ្រប់គ្រងបានធ្វើឡើង។
- សន្និដ្ឋានលើភាពសមស្រប នៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្មរបស់គណៈគ្រប់គ្រងអាស្រ័យទៅលើភ័ស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើងកម្រិតណា ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា ដែលអាចបណ្តាលឲ្យមានការសង្ស័យជាដុំកំភួន ទៅលើលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា វាមានភាពមិនច្បាស់លាស់ជាសារវន្ត បានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនករ ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ចំពោះការលាតត្រដាងព័ត៌មាន នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនោះ នៅមិនទាន់គ្រប់គ្រាន់ទៀត យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានសរុបរបស់យើងខ្ញុំ អាស្រ័យទៅលើភ័ស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន រហូតដល់ថ្ងៃចុះហត្ថលេខា លើរបាយការណ៍សវនកមរនេះ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានាក្នុងពេលអនាគត អាចបណ្តាលឲ្យក្រុមហ៊ុនឈប់បន្តនិរន្តរភាពអាជីវកម្ម។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការលាតត្រដាងព័ត៌មានផ្សេងៗ និងកំណត់ថារបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែង ដែលអាចធ្វើឲ្យមានការបង្ហាញត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នក ដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗ ដូចជាទំហំការងារ តាមផែនការ និងពេលវេលាសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្ត ក្នុងការគ្រប់គ្រងផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ។

ជ. ក្រុមហ៊ុន ប្រាយវ៉ែតធ័រហាវ៉ូសកើស៍ (ខេមបូឌា)

ឡាង ហ៊ី
Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

	កំណត់សម្គាល់	២០២០		២០១៩	
		ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្ម					
សាច់ប្រាក់ក្នុងដៃ	៤	៨៩.៤៥១.៥៣០	៣៦១.៨៣១.៤៣៩	៥៩.៩០៥.៣១៣	២៤៤.១១៤.១៥០
ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល	៥	២១១.៩៩៥.៦៩៩	៨៥៧.៥២២.៦០២	១៩៩.៦៥៦.០៥០	៨១៣.៥៩៨.៤០៤
ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ	៦	៦៦.០១៤.៨៦៩	២៦៧.០៣០.១៤៥	១៤.៣៨៩.៤៩៧	៥៨.៦៣៧.២០០
ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដកវិលស់	៧	៨៤៧.០៤០.២០៦	៣.៤២៦.២៧៧.៦៣៣	៦៩៣.៧៦៣.៩០៦	២.៨២៧.០៨៧.៩១៧
ប្រាក់តម្កល់តាមច្បាប់នៅធនាគារកណ្តាល	៨	៧៧.២៣២.៦៦៧	៣១២.៤០៦.១៣៨	១១៤.៥២៦.១៨៤	៤៦៦.៦៩៤.២០០
ទ្រព្យសម្បត្តិ និងបរិក្ខារ	៩	៤.៩៦០.៣៥៧	២០.០៦៤.៦៤៤	៥.២៩៤.៦០៩	២១.៥៧៥.៥៣២
ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់	១០	៤.៦៥៧.១១០	១៨.៨៣៨.០១០	២.៩៤៧.២៨៤	១២.០១០.១៨២
ទ្រព្យសកម្មអរូបី	១១	១.៩០៤.៤៦៩	៧.៧០៣.៥៧៧	១.៣៧៦.២២៧	៥.៦០៨.១២៥
ពន្ធពន្យាទ្រព្យសកម្ម	១២	២.១០៩.១៥៨	៨.៥៣១.៥៤៤	១.៩២៥.១០០	៧.៨៤៤.៧៨២
ទ្រព្យសកម្មផ្សេងៗ	១៣	៤.២០០.១១២	៦.៩៨៩.៤៥៣	៤.៨៧៣.២៤០	១៩.៨៥៨.៤៥៣
ទ្រព្យសកម្មសរុប		១.៣០៩.៥៦៦.១៧៧	៥.២៩៧.១៩៥.១៨៥	១.០៩៨.៦៥៧.៤១០	៤.៤៧៧.០២៨.៩៤៥
បំណុល និងមូលធន					
បំណុល					
ប្រាក់បញ្ញើរបស់ធនាគារ	១៤	១៣៥.៥០១.១៨២	៥៤៨.១០២.២៨១	៤១.៩៧៨.៩៤៦	១៧១.០៦៤.២០៥
ប្រាក់បញ្ញើរបស់អតិថិជន	១៥	៨៩៥.៨៩៨.៨៥៨	៣.៦២៣.៩១០.៨៨១	៧៩០.៧៨៣.២១៤	៣.២២២.៤១.៥៩៧
ប្រាក់កម្ចី	១៦	៦៤.២៥៣.៣២៨	២៥៩.៩០៤.៧១២	៧៤.៤៧៧.៤៦០	៣០៣.៤៩៥.៦៥០
អនុបំណុល	១៧	៤៧.៤១១.០០០	១៩១.៧៧៧.៤៩៥	៣៧.៣១៦.៤៧៩	១៥២.០៦៤.៦៥២
បំណុលភតិសន្យា	៩	៥.៣៨១.៥៩៨	២១.៧៦៨.៥៦៤	៥.៦៣៦.០១២	២២.៩៦៦.៧៤៩
បំណុលពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ	២៩	៥.១២២.៣៧៥	២០.៧២០.០០៧	៤.៥៤៤.៥៤៨	១៨.៥១៩.០៣៣
អត្ថប្រយោជន៍បុគ្គលិក	១៨	២.៥៧៦.៧៨៧	១០.៤២៣.១០៣	២.០៧៥.៣៧៩	៨.៤៥៧.១៦៩
បំណុលផ្សេងៗ	១៩	១៦.១១៧.៨១៩	៦៥.១៩៦.៥៧៨	២៥.៦៤៣.០៧៣	១០៤.៤៩៥.៥២១
បំណុលសរុប		១.១៧២.២៦២.៩៤៧	៤.៧៤១.៨០៣.៦២១	៩៨២.៤៥៥.១១១	៤.០០៣.៥០៤.៥៧៦
មូលធន					
ដើមទុន	២០	៧៥.០០០.០០០	៣០៣.៣៧៥.០០០	៧៥.០០០.០០០	៣០៥.៦២៥.០០០
ប្រាក់ចំណេញរក្សាទុក		៣៧.២៩៣.៩២៧	១៥០.៩៧៦.០៣០	៣៣.៩៥៧.៣៧៥	១៣៧.៣៧២.៩០៦
ដើមទុនបម្រុង	២១	១៧.៥០០.០០០	៧០.៧៨៧.៥០០	-	-
ទុនបម្រុងតាមច្បាប់	២២	៧.៥០៩.៣០៣	៣០.៣៦៥.៨៥០	៧.២៨៤.៩២៤	២៩.២៨៧.៩៧៧
ទុនបម្រុងផ្សេងៗ		-	(១១២.៨១៦)	-	១.២៣៨.៤៨៦
មូលធនសរុប		១៣៧.៣០៣.២៣០	៥៥៥.៣៩១.៥៦៤	១១៦.២០២.២៩៩	៤៧៣.៥២៤.៣៦៩
បំណុល និងមូលធនសរុប		១.៣០៩.៥៦៦.១៧៧	៥.២៩៧.១៩៥.១៨៥	១.០៩៨.៦៥៧.៤១០	៤.៤៧៧.០២៨.៩៤៥

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី៩៤ ដល់ទំព័រទី១៣៩ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

	កំណត់សម្គាល់	២០២០		២០១៩	
		ដុល្លារអាមេរិក	៣ន់រៀល	ដុល្លារអាមេរិក	៣ន់រៀល
ចំណូលការប្រាក់	២៣	៥៨.៣៥៩.២៨៩	២៣៧.៩៣០.៨២១	៤៨.៩០៣.៤៨៦	១៩៨.១៥៦.៩២៥
ចំណាយការប្រាក់	២៣	(២១.៣៥៨.៩២១)	(៨៧.០៨០.៣២១)	(១៦.៤៩៥.២៣៦)	(៦៦.៨៣៨.៦៩៦)
ចំណូលការប្រាក់សុទ្ធ	២៣	៣៧.០០០.៣៦៨	១៥០.៨៥០.៥០០	៣២.៤០៨.២៥០	១៣១.៣១៨.២២៩
ចំណូលកម្រៃជើងសា	២៤	៧.១២១.៦៨៩	២៩.០៣៥.១២៦	៦.៨៩៦.១៨១	២៧.៩៤៣.៣២៥
ចំណាយកម្រៃជើងសា	២៤	(១.០៨៤.០០០)	(៤.២៥៦.៣៨៨)	(១.៣៨៧.៥៩៥)	(៥.៦២២.៥៣៥)
ចំណូលកម្រៃជើងសាសុទ្ធ	២៤	៦.០៧៧.៦៨៩	២៤.៧៧៨.៧៣៨	៥.៥០៨.៥៨៦	២២.៣២០.៧៩០
ខាតពីការថយចុះតម្លៃឥណទាន	២៥	(១.៥៩៩.៣០៥)	(៦.៥២០.៣៦៦)	(៦៥៥.២៤៣)	(២.៦៥៥.០៤៥)
ចំណូលប្រតិបត្តិការផ្សេងៗ		១.៣៤៦.៨០៥	៥.៤៩០.៩២៤	១.១៣៧.៧៤៣	៤.៦១០.១៣៥
ចំណេញផ្សេងៗ - សុទ្ធ		៥០.៦៦៩	២០៦.៥៧៨	២០.៤០៤	៨២.៦៧៧
ចំណូលប្រតិបត្តិការផ្សេងៗសុទ្ធ		(២០១.៨៣១)	(៨២២.៨៦៤)	៥០២.៩០៤	២.០៣៧.៧៦៧
ចំណាយ					
ចំណាយបុគ្គលិក	២៦	(៩.៩៧០.០៧៩)	(៤០.៦៤៨.០១២)	(៩.៤០១.៩៦២)	(៣៨.០៩៦.៧៥០)
រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី	២៧	(២.៤៣០.៩០០)	(៩.៩១០.៧៧៩)	(២.១៥៧.៧៩០)	(៨.៧៤៣.៣៦៥)
ចំណាយប្រតិបត្តិការផ្សេងៗ	២៨	(៣.៧១៧.៧៨១)	(១៥.១៥៧.៣៩៣)	(៣.៩៩៧.៨៤១)	(១៦.១៩៩.២៥២)
		(១៦.១១៨.៧៦០)	(៦៥.៧១៦.១៨៤)	(១៥.៥៥៧.៥៩៣)	(៦៣.០៣៩.៣៦៧)
ចំណេញមុនពន្ធលើប្រាក់ចំណូល		២៦.៧៥៧.៤៦៦	១០៩.០៩០.១៩០	២២.៨៦២.១៤៧	៩២.៦៣៧.៤១៩
ចំណាយពន្ធលើប្រាក់ចំណូល	២៩	(៥.៦៥៦.៥៣៥)	(២៣.០៦១.៦៩៣)	(៤.៦៤៩.៧២១)	(១៨.៨៤០.៦៦៩)
ចំណេញក្នុងឆ្នាំ		២១.១០០.៩៣១	៨៦.០២៨.៤៩៧	១៨.២១២.៤២៦	៧៣.៧៩៦.៧៥០
លទ្ធផលលម្អិតផ្សេងៗ៖					
ខ្នង់ដែលមិនត្រូវបានចាត់ថ្នាក់ក្នុងចំណេញ-ខាត					
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(១.៣៥១.៣០២)	-	១.៧២៩.៣០៨
លទ្ធផលលម្អិតផ្សេងៗក្នុងឆ្នាំ កាត់កងជាមួយពន្ធ		-	(១.៣៥១.៣០២)	-	១.៧២៩.៣០៨
លទ្ធផលលម្អិតផ្សេងៗសរុបក្នុងឆ្នាំ		២១.១០០.៩៣១	៨៤.៦៧៧.១៩៥	១៨.២១២.៤២៦	៧៥.៥២៦.០៥៨
ចំណេញរបស់៖					
ម្ចាស់ធនាគារ		២១.១០០.៩៣១	៨៦.០២៨.៤៩៧	១៨.២១២.៤២៦	៧៣.៧៩៦.៧៥០
លទ្ធផលលម្អិតសរុបរបស់៖					
ម្ចាស់ធនាគារ		២១.១០០.៩៣១	៨៤.៦៧៧.១៩៥	១៨.២១២.៤២៦	៧៥.៥២៦.០៥៨

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី៩៤ ដល់ទំព័រទី១៣៩ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

	ដើមទុន		ប្រាក់ចំណេញរក្សាទុក		ដើមទុនបម្រុង		ទុនបម្រុងតាមច្បាប់		ទុនបម្រុងផ្សេងៗ		សរុប	
	ជុំលានអាមេរិក	ពាន់រៀល	ជុំលានអាមេរិក	ពាន់រៀល	ជុំលានអាមេរិក	ពាន់រៀល	ជុំលានអាមេរិក	ពាន់រៀល	ជុំលានអាមេរិក	ពាន់រៀល	ជុំលានអាមេរិក	ពាន់រៀល
សមតុល្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩	៧៥.000.000	៣០១.៣៥0.000	១៧.0៩៨.១៥៧	៦៩.0៥៩.៣៥៥	-	-	៥.៨៩១.៧១6	២៣.៨0៤.៧៧៨	-	(៤៩0.៨២២)	៩៧.៩៨៩.៨៧៣	៣៩៣.៧២៣.៣១១
ចំណេញក្នុងឆ្នាំ	-	-	១៨.២១២.៨២6	៧៣.៧៩6.៧៥0	-	-	-	-	-	-	១៨.២១២.៨២6	៧៣.៧៩6.៧៥0
លទ្ធផលលម្អិតផ្សេងៗ	-	-	-	-	-	-	-	-	-	១.៧២៩.៣0៨	-	១.៧២៩.៣0៨
លទ្ធផលលម្អិតសរុបក្នុងឆ្នាំ	-	-	១៨.២១២.៨២6	៧៣.៧៩6.៧៥0	-	-	-	-	-	១.៧២៩.៣0៨	១៨.២១២.៨២6	៧៥.៥២6.0៥៨
ប្រតិបត្តិការជាមួយភាគទុនិកក្នុងនាមជាភាគទុនិក												
ការផ្ទេរទៅទុនបម្រុងតាមច្បាប់ (កំណត់សម្គាល់ ២២)	-	-	(១.៣៥៣.២0៨)	(៥.៨៨៣.១៩៩)	-	-	១.៣៥៣.២0៨	៥.៨៨៣.១៩៩	-	-	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	៨.២៧៥.000	-	-	-	-	-	-	-	-	-	៨.២៧៥.000
ប្រតិបត្តិការសរុបជាមួយភាគទុនិក	-	៨.២៧៥.000	(១.៣៥៣.២0៨)	(៥.៨៨៣.១៩៩)	-	-	១.៣៥៣.២0៨	៥.៨៨៣.១៩៩	-	-	-	៨.២៧៥.000
សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	៧៥.000.000	៣0៥.៦២៥.000	៣៣.៩៥៧.៣៧៥	១៣៧.៣៧២.៩0៦	-	-	៧.២៨៨.៩២៨	២៩.២៨៧.៩៧៧	-	១.២៣៨.៨៨6	១១6.២0២.២៩៩	៨៧៣.៥២៨.៣6៩
សមតុល្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២0	៧៥.000.000	៣0៥.៦២៥.000	៣៣.៩៥៧.៣៧៥	១៣៧.៣៧២.៩0៦	-	-	៧.២៨៨.៩២៨	២៩.២៨៧.៩៧៧	-	១.២៣៨.៨៨6	១១6.២0២.២៩៩	៨៧៣.៥២៨.៣6៩
ចំណេញក្នុងឆ្នាំ	-	-	២១.១00.៩៣១	៨6.0២៨.៨៩៧	-	-	-	-	-	-	២១.១00.៩៣១	៨6.0២៨.៨៩៧
លទ្ធផលលម្អិតផ្សេងៗ	-	-	-	-	-	-	-	-	-	(១.៣៥១.៣0២)	-	(១.៣៥១.៣0២)
លទ្ធផលលម្អិតសរុបក្នុងឆ្នាំ	-	-	២១.១00.៩៣១	៨6.0២៨.៨៩៧	-	-	-	-	-	(១.៣៥១.៣0២)	២១.១00.៩៣១	៨៤.6៧៧.១៩៥
ប្រតិបត្តិការជាមួយភាគទុននិកក្នុងនាមជាជាភាគទុនិក៖												
ការផ្ទេរទៅដើមបម្រុង (កំណត់សម្គាល់ ២១)	-	-	(១៧.៥00.000)	(៧១.៣៨៧.៥00)	១៧.៥00.000	៧១.៣៨៧.៥00	-	-	-		-	-
ការផ្ទេរទៅទុនបម្រុងតាមច្បាប់ (កំណត់សម្គាល់ ២២)	-	-	(២6៤.៣៧៩)	(១.0៧៧.៨៧៣)	-	-	២6៤.៣៧៩	១.0៧៧.៨៧៣	-	-	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(២.២៥0.000)	-	-	-	(៥60.000)	-	-	-	-	-	(២.៨១0.000)
ប្រតិបត្តិការសរុបជាមួយភាគទុនិក	-	(២.២៥0.000)	(១៧.៧6៤.៣៧៩)	(៧២.៤២៥.៣៧៣)	១៧.៥00.000	៧0.៧៨៧.៥00	២6៤.៣៧៩	១.0៧៧.៨៧៣	-	-	-	(២.៨១0.000)
សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២0	៧៥.000.000	៣0៣.៣៧៥.000	៣៧.២៩៣.៩២៧	១៥0.៩៧6.0៣0	១៧.៥00.000	៧0.៧៨៧.៥00	៧.៥0៩.៣0៣	៣0.៣6៥.៨៥0	-	(១១២.៨១6)	១៣៧.៣0៣.២៣0	៥៥៥.៣៩១.៥6

- |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី៩៤ ដល់ទំព័រទី១៣៩ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

	កំណត់សម្គាល់	២០២០		២០១៩	
		ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ					
សាច់ប្រាក់ចេញពី/(បានប្រើក្នុង)ប្រតិបត្តិការ	៣១	៦៥.៦៥៥.៤៧៥	២៦៧.៦៧៧.៣៧៣	(៦១.២២១.៣០៩)	(២៤៧.៨៩៥.១៧២)
ការប្រាក់បានទទួល		៥៧.៦៦០.៨៥២	២៣៥.០៨៣.២៩៤	៤៧.៦២៩.២៥២	១៩២.៩៩៣.៧២៩
ការប្រាក់បានបង់		(១៩.០៣៤.៥៥៤)	(៧៧.៦០៣.៨៧៧)	(១៤.៤៧១.៤៥០)	(៥៨.៦៣៨.៣១៥)
ពន្ធលើប្រាក់ចំណូលបានបង់	២៩	(៥.២៦២.៧៦៦)	(២១.៤៥៦.២៩៧)	(៣.៧៧១.៣៦៦)	(១៥.២៨១.៥៧៥)
មូលនិធិសោធននិវត្តន៍បុគ្គលិកបានបង់	១៨	(២០៣.៩៧៣)	(៨៣១.៥៩៨)	(១៥៣.៧៤៩)	(៦២២.៩៩១)
សាច់ប្រាក់សុទ្ធចេញពី/(បានប្រើក្នុង) សកម្មភាពប្រតិបត្តិការ		៩៨.៨១៥.០៣៨	៤០២.៨៦៨.៨៩៥	(៣១.៩៨៨.៦២២)	(១២៩.៤៤៤.៣២៤)
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ					
មូលបត្រអាចជួញដូរបាន		១៥.១៧៩.០០០	៦១.៨៨៤.៧៨៣	(៧៤.៤៧៦.០០០)	(៣០១.៧៧៦.៧៥២)
ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ		(២.៦៤៧.៦៩៧)	(១០.៧៩៤.៦៦១)	(១.០២៤.៥៥៦)	(៤.១៥១.៥០១)
ការទិញទ្រព្យសកម្មអរូបី		(៥៧៣.២០៨)	(២.៣៣៦.៩៦៩)	(៦៧៤.៦៩៧)	(២.៧៣៣.៨៧២)
សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ		៣៣.៦៦៤	១៣៧.២៤៨	១១.៤៥៣	៤៦.៤០៨
សាច់ប្រាក់សុទ្ធចេញពី/(បានប្រើក្នុង) សកម្មភាពវិនិយោគ		១១.៩៩១.៧៥៩	៤៨.៨៩០.៤០១	(៧៦.១៦៣.៨០០)	(៣០៨.៦១៥.៧១៧)
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន					
សាច់ប្រាក់បានពីប្រាក់កម្ចី	១៦	១៧០.៣៥១.៨១១	៦៩៤.៥២៤.៣៣៣	១២៨.០៥៣.៩៨៨	៥១៨.៨៧៤.៧៥៩
ការទូទាត់សងប្រាក់កម្ចី	១៦	(១៨១.០៣៤.៣៤៩)	(៧៣៨.០៧៧.០៤១)	(៦៤.៣៤៨.២៤០)	(២៦០.៧៣៩.០៦៨)
សាច់ប្រាក់បានពីអនុបំណុល	១៧	១០.០០០.០០០	៤០.៧៧០.០០០	៣០.០០០.០០០	១២១.៥៦០.០០០
ប្រាក់ដើមនៃការទូទាត់ភតិសន្យា		(១.២៦៦.៦៨៨)	(៥.១៦៤.២៨៧)	(១.១១៦.៦៩៣)	(៤.៥២៤.៨៤០)
សាច់ប្រាក់សុទ្ធ(បានប្រើក្នុង)/ចេញពី សកម្មភាពហិរញ្ញប្បទាន		(១.៩៤៩.២២៦)	(៧.៩៤៦.៩៩៥)	៩២.៥៨៩.០៥៥	៣៧៥.១៧០.៨៥១
កំណើន/(តំហយ)សាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ		១០៨.៨៥៧.៥៦៧	៤៤៣.៨១២.៣០១	(១៥.៥៦៣.៣៦៧)	(៦២.៨៨៩.១៩០)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ		១៨៣.២៧១.៥៣៥	៧៤៦.៨៣១.៥០៦	១៩៨.៨៣៤.៩០២	៧៩៨.៩១៨.៦៣៦
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(៨.៩៨១.៥៨៩)	-	១០.៨០២.០៦០
សាច់ប្រាក់ និងសាច់ប្រាក់សមមូលដំណាច់ឆ្នាំ	៣០	២៩២.១២៩.១០២	១.១៨១.៦៦២.២១៨	១៨៣.២៧១.៥៣៥	៧៤៦.៨៣១.៥០៦

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី៩៤ ដល់ទំព័រទី១៣៩ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

១. ព័ត៌មានទូទៅ

ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ត្រូវបានបង្កើតឡើងនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ដោយវិញ្ញាបនបត្រចុះបញ្ជីលេខ ០០០១០៥២៤ ចេញដោយក្រសួងពាណិជ្ជកម្ម និងបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០។ ធនាគារគឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលកាន់កាប់ទាំងស្រុងដោយ CIMB Bank Berhad ដែលជាធនាគារមានអាជ្ញាប័ណ្ណចុះបញ្ជីអាជីវកម្ម នៅប្រទេសម៉ាឡេស៊ី។ ក្រុមហ៊ុន CIMB Group Holdings Berhad ដែលបានចុះបញ្ជីជាក្រុមហ៊ុនសាជីវកម្មសាធារណៈ នៅប្រទេសម៉ាឡេស៊ី គឺជាក្រុមហ៊ុនមេធំបង្អស់។

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺពាក់ព័ន្ធនឹងអាជីវកម្មធនាគារគ្រប់ទិដ្ឋភាពទាំងអស់ និងផ្តល់សេវាផ្សេងៗ ដែលពាក់ព័ន្ធនឹងផ្នែកហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា។ ធនាគារបានទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មធនាគារ ដែលចេញដោយធនាគារជាតិ នៃកម្ពុជា (ហៅកាត់ថា «ធនាគារកណ្តាល») នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅផ្ទះលេខ២០AB មហាវិថីព្រះនរោត្តម កែងផ្លូវលេខ១១៨ សង្កាត់ផ្សារចាស់ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមប្រឹក្សាភិបាលបានអនុម័តឲ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១។

២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញខាងក្រោម។ គោលការណ៍ទាំងនេះ ត្រូវបានអនុវត្តយ៉ាងមានសង្គតិភាពគ្រប់ឆ្នាំ ដែលបានដាក់បង្ហាញទាំងអស់ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយអនុលោមទៅតាម ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (CIFRS) ដែលផ្នែកទាំងស្រុង ទៅតាមស្តង់ដារទាំងអស់ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សា ស្តង់ដារគណនេយ្យអន្តរជាតិ រួមទាំងបំណកស្រាយ និងវិសោធនកម្មផ្សេងៗ ដែលអាចកើតមានក្នុងកាលៈទេសៈណាមួយ ចំពោះស្តង់ដារនីមួយៗ។

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំតាមវិធីសាស្ត្រថ្លៃដើម។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលស្របទៅតាម CIFRS តម្រូវឲ្យប្រើប្រាស់ការប៉ាន់ស្មានគណនេយ្យជាក់លាក់សំខាន់ៗ។ ហើយវាក៏តម្រូវឲ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ នៅក្នុងដំណើរការនៃការអនុវត្តគោលការណ៍គណនេយ្យនេះផងដែរ។ ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្ត ចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៣ ។

របាយការណ៍ហិរញ្ញវត្ថុជាភាសាអង់គ្លេស ត្រូវបានរៀបចំឡើងចេញពី របាយការណ៍ហិរញ្ញវត្ថុជាភាសាខ្មែរ។ ក្នុងករណីមិនមានសង្គតិភាព ឬមានភាពខុសគ្នាក្នុងការបកស្រាយ រវាងភាសាទាំងពីរនោះត្រូវយករបាយការណ៍ហិរញ្ញវត្ថុ ជាភាសាខ្មែរជាគោល។

២.២ ស្តង់ដារគណនេយ្យថ្មី និងបំណកស្រាយ

i) ស្តង់ដារគណនេយ្យថ្មី និងវិសោធនកម្ម ដែលធនាគារបានអនុវត្ត

ធនាគារបានអនុវត្តស្តង់ដារគណនេយ្យថ្មី និងវិសោធនកម្មដូចខាងក្រោមលើកដំបូង ចំពោះរបាយការណ៍ប្រចាំ ឆ្នាំរបស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលចាប់ផ្តើម នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០៖

- និយមន័យនៃ Material - វិសោធនកម្ម CIAS 1 និង CIAS 8
- កែសម្រួលនិយមន័យពាក្យរបស់គណនេយ្យសម្រាប់របាយការណ៍ហិរញ្ញវត្ថុ

វិសោធនកម្មដែលបានចុះបញ្ជីខាងលើ មិនធ្វើឲ្យមានផលប៉ះពាល់ណាមួយទៅលើចំនួន ដែលបានទទួលស្គាល់ក្នុងការិយបរិច្ឆេទមុន និងមិនរំពឹងថាមានផលប៉ះពាល់ជាសារវន្តសម្រាប់ការិយបរិច្ឆេទនេះ និងការិយបរិច្ឆេទនាពេលអនាគត។

ii) ស្តង់ដារគណនេយ្យថ្មី និងបំណកស្រាយ ដែលធនាគារមិនទាន់បានអនុវត្ត

ធនាគារមិនបានអនុវត្តមុនកាលកំណត់នូវស្តង់ដារគណនេយ្យថ្មី និងបំណកស្រាយដែលត្រូវបានចេញផ្សាយរួច ប៉ុន្តែមិនទាន់ចាំបាច់ត្រូវអនុវត្ត សម្រាប់ការិយបរិច្ឆេទរាយការណ៍ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ទេ។ ធនាគារមិនរំពឹងថាស្តង់ដារទាំងនេះមានផលប៉ះពាល់ជាសារវន្ត លើមូលធនរបស់ធនាគារ សម្រាប់ការិយបរិច្ឆេទរាយការណ៍នេះ និងការិយបរិច្ឆេទរាយការណ៍ នាពេលអនាគត និងចំពោះប្រតិបត្តិការ នាពេលអនាគតខាងមុខនេះទេ។

២.៣ការប្តូររូបិយប័ណ្ណ

i) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានវាស់វែងដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បង ដែលធនាគារធ្វើប្រតិបត្តិការ (ហៅកាត់ថា «រូបិយប័ណ្ណគោល»)។ ការកំណត់យកប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណគោល ដោយសារប្រាក់ដុល្លារអាមេរិកមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការរបស់ធនាគារ។ របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណ សម្រាប់បង្ហាញរបស់ធនាគារ។

ii) ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗ ត្រូវបានកត់ត្រាប្តូរទៅជារូបិយប័ណ្ណគោល ដោយប្រើអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណ ដែលបណ្តាលមកពីការទូទាត់តាមប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណផ្សេងៗ ក្រៅពីប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់នាដំណាច់ឆ្នាំ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ-ខាត។

iii) ការបង្ហាញជាប្រាក់រៀល

អនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម របាយការណ៍ហិរញ្ញវត្ថុត្រូវបង្ហាញជាប្រាក់រៀល។ របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរសាច់ប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើអត្រាប្តូរប្រាក់ជាមធ្យមក្នុងឆ្នាំ។ ទ្រព្យសកម្ម និងបំណុល ដែលបានបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ និងមូលធនភាគទុនិក ត្រូវបានប្តូរតាមអត្រាប្តូរប្រាក់ថ្ងៃបិទបញ្ជី នាកាលបរិច្ឆេទរាយការណ៍។ លម្អៀងពីការប្តូររូបិយប័ណ្ណទាំងអស់ ដែលកើតមកពីការប្តូរមូលធនភាគទុនិក ត្រូវបានទទួលស្គាល់ផ្ទាល់ក្នុងមូលធន ហើយរាល់លម្អៀងពីការប្តូររូបិយប័ណ្ណទាំងអស់ផ្សេងៗទៀត ត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗ។

ធនាគារបានប្រើអត្រាប្តូរប្រាក់ផ្លូវការ ដែលផ្សព្វផ្សាយដោយធនាគារជាតិ នៃកម្ពុជា។ គិតត្រឹមកាលបរិច្ឆេទរាយការណ៍ អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំគឺ ១ ដុល្លារអាមេរិក ស្មើនឹង ៤.០៧៧ រៀល (២០១៩ ៖ ១ ដុល្លារអាមេរិក ស្មើនឹង ៤.០៥២ រៀល) ហើយអត្រាប្តូរប្រាក់ចិទបញ្ជីគឺ ១ ដុល្លារអាមេរិក ស្មើនឹង ៤.០៤៥ រៀល (២០១៩ ៖ ១ ដុល្លារអាមេរិក ស្មើនឹង ៤.០៧៥ រៀល)។

២.៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

ក្នុងការដាក់បង្ហាញរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមាន សាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើ និងការដាក់ប្រាក់មិនជាប់កម្រិត នៅធនាគារកណ្តាល និងធនាគារផ្សេងៗ និងការវិនិយោគសាច់ប្រាក់ងាយស្រួលរយៈពេលខ្លី ដែលមានរយៈពេលកំណត់បីខែ ឬតិចជាងបីខែ ដែលធនាគារអាចមានលទ្ធភាពពេញលេញក្នុងការដកសាច់ប្រាក់ ក្នុងគោលបំណងនៅពេលចាំបាច់ និងមានហានិភ័យបម្រែបម្រួលតម្លៃតិចតួច។

ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល និងធនាគារផ្សេងៗ ត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ឥណទានវិចារូបន៍ ត្រូវបានដាក់បង្ហាញជាបំណុលនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

២.៥ ទ្រព្យសកម្មហិរញ្ញវត្ថុ

(ក) ចំណាត់ថ្នាក់

ធនាគារបែងចែកទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួន ជាទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែង តាមថ្លៃដើមដករំលស់ ដែលក្នុងនោះ រួមមាន សាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល និងធនាគារផ្សេងៗ ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់ និងទ្រព្យសកម្មផ្សេងៗ។

ការធ្វើចំណាត់ថ្នាក់នេះ គឺអាស្រ័យទៅតាមគំរូអាជីវកម្មរបស់ធនាគារ ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលក្ខខណ្ឌក្នុងកិច្ចសន្យានៃលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

ធនាគារបានធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួន តាមថ្លៃដើមដករំលស់តែក្នុងករណីដែលស្របតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោមប៉ុណ្ណោះ៖

- ទ្រព្យសកម្មដែលត្រូវបានកាន់កាប់ក្នុងគំរូអាជីវកម្ម ដែលមានគោលបំណងដើម្បីប្រមូលលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យា និង
- លក្ខខណ្ឌក្នុងកិច្ចសន្យាដែលនាំឲ្យមានកាលបរិច្ឆេទជាក់លាក់នានា ចំពោះលំហូរសាច់ប្រាក់ ដែលជាការទូទាត់ប្រាក់ដើម និងការប្រាក់ទាំងស្រុង ទៅលើចំនួនប្រាក់ដើមដែលនៅមិនទាន់ទូទាត់។

(ខ) ការទទួលស្គាល់ និងការឈប់ទទួលស្គាល់

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ នៅពេលដែលធនាគារក្លាយជាភាគីមួយ ក្នុងកិច្ចសន្យានៃឧបករណ៍ណាមួយ។ ការទិញ និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុតាមមធ្យោបាយធម្មតា ត្រូវបានទទួលស្គាល់នាកាលបរិច្ឆេទជួញដូរ ជាកាលបរិច្ឆេទដែលធនាគារធ្វើការទិញ ឬលក់ទ្រព្យសកម្ម។

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានឈប់ទទួលស្គាល់ នៅពេលដែលសិទ្ធិក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្មនោះបានហួសកាលកំណត់ ឬត្រូវបានផ្ទេរ ហើយធនាគារបានផ្ទេរនូវរាល់ហានិភ័យជាសារវន្ត និងផលកម្មសិទ្ធិទាំងអស់។ ចំណេញ ឬខាតពីការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ត្រូវបានទទួលស្គាល់ នៅក្នុងចំណេញ-ខាត នៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគេឈប់ទទួលស្គាល់។

(គ) ការវាស់វែង

នាពេលទទួលស្គាល់លើកដំបូង ធនាគារវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្រប បូកបន្ថែមជាមួយនឹងចំណាយប្រតិបត្តិការផ្សេងៗ ដែលបានចំណាយផ្ទាល់ ក្នុងការទិញទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងករណីដែលទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានវាស់វែងតាមតម្លៃសមស្រប ក្នុងចំណេញ-ខាត («FVPL»)។ ចំណាយប្រតិបត្តិការនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានកត់ត្រាតាម FVPL ត្រូវបានកត់ត្រាជាចំណាយក្នុងចំណេញ-ខាត។ បន្ទាប់ពីការទទួលស្គាល់លើកដំបូងភ្លាម សំវិធានធនសម្រាប់ការថយចុះតម្លៃឥណទានរំពឹងទុក («ECL») ត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្ម ដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដែលធ្វើឲ្យមានការខាតតាមគណនេយ្យមួយ ដែលត្រូវបានទទួលស្គាល់ក្នុងចំណេញ-ខាត នៅពេលទ្រព្យសកម្មមួយត្រូវបានបង្កើតឡើងថ្មី។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានដេរីវេទីវ ត្រូវបានគេគិតទៅលើចំនួនរបស់វាទាំងស្រុង នៅពេលធ្វើការកំណត់លំហូរសាច់ប្រាក់របស់វាសម្រាប់ការទូទាត់ប្រាក់ដើម និងការប្រាក់ទាំងស្រុង។

ឧបករណ៍បំណុល

ការវាស់វែងឧបករណ៍បំណុល គឺអាស្រ័យទៅលើគំរូអាជីវកម្មរបស់ធនាគារ ក្នុងការគ្រប់គ្រងទ្រព្យសកម្ម និងលក្ខណៈនៃលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មនោះ។ ធនាគារធ្វើចំណាត់ថ្នាក់ឧបករណ៍បំណុលរបស់ខ្លួនជាទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានវាស់វែងតាមថ្លៃដើមដករំលស់។

ថ្លៃដើមដករំលស់៖ ទ្រព្យសកម្មដែលត្រូវបានកាន់កាប់ សម្រាប់ការប្រមូលលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យា ដែលលំហូរសាច់ប្រាក់នោះគឺជាការទូទាត់ប្រាក់ដើម និងការប្រាក់ទាំងស្រុង (SPPI) ត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។ តម្លៃយោងនៃទ្រព្យសកម្មទាំងនេះ ត្រូវបានកែតម្រូវទៅតាមសំវិធានធនការខាតបង់ឥណទានរំពឹងទុក ដែលបានទទួលស្គាល់។ ចំណូលការប្រាក់ ដែលបានពីទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះ ត្រូវបានដាក់បញ្ចូលនៅក្នុងចំណូលការប្រាក់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព។

ចំពោះឥណទានផ្តល់ឲ្យបុគ្គលិកសម្រាប់ទិញផ្ទះ ដែលមានអត្រាការប្រាក់ទាបជាងអត្រាទីផ្សារ ត្រូវបានទទួលស្គាល់លើកដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់សាច់ប្រាក់នាពេលអនាគត និងធ្វើអប្បហារ តាមអត្រាការប្រាក់លើទីផ្សារនៃឥណទានប្រហាក់ប្រហែលគ្នា។ ចំនួនលម្អៀងរវាងសាច់ប្រាក់បានបង់ និងតម្លៃបច្ចុប្បន្ននៃសាច់ប្រាក់ត្រូវទទួលក្នុងពេលអនាគត ត្រូវបានទទួលស្គាល់ជាបុរេប្រទានអត្ថប្រយោជន៍បុគ្គលិក ក្នុងខ្នង់ទ្រព្យសកម្មផ្សេងៗ។

(ឃ) ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ

ធនាគារធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ នៅពេលដែលគំរូអាជីវកម្ម សម្រាប់ការគ្រប់គ្រងទ្រព្យសកម្មរបស់ខ្លួនមានការប្រែប្រួល។

(ង) ការថយចុះតម្លៃ

ធនាគារវាយតម្លៃការខាតឥណទានរំពឹងទុក («ECL») តាមមូលដ្ឋានរំពឹងមើលទៅថ្ងៃអនាគត ដែលទាក់ទងជាមួយនឹងឧបករណ៍បំណុលរបស់ខ្លួន ដែលវាស់វែងតាមថ្លៃដើមដករំលស់ ព្រមទាំងហានិភ័យដែលកើតពីកិច្ចសន្យាផ្តល់ឥណទាន (រួមទាំង ឥណទានវិចារូបន៍ និងហ្វាស៊ីលីធី ដែលអាចប្រើប្រាស់ឡើងវិញ) និងកិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ។ ធនាគារទទួលស្គាល់សំវិធានធន សម្រាប់ការខាតបង់ចំពោះការខាតប្រភេទនេះ នាកាលបរិច្ឆេទរាយការណ៍។ ការវាស់វែង ECL ឆ្លុះបញ្ចាំងពី៖

- ចំនួនលម្អៀង និងចំនួនដែលបានថ្លឹងប្រូបាប ដែលត្រូវបានកំណត់ដោយធ្វើការវាយតម្លៃ លើលទ្ធភាពដែលអាចកើតឡើងមួយចំនួន
- ពេលវេលានៃតម្លៃទឹកប្រាក់ និង
- ព័ត៌មានដែលមានភាពសមហេតុផល និងមានការគាំទ្រ ដែលអាចរកបានដោយពុំចាំបាច់មានការចំណាយ និងការខំប្រឹងប្រែងលើសលប់ នាកាលបរិច្ឆេទរាយការណ៍ អំពីព្រឹត្តិការណ៍នាពេលអតីតកាល ពេលបច្ចុប្បន្ន និងការព្យាករអំពីលក្ខខណ្ឌ នាពេលអនាគត

ធនាគារបានអនុវត្តវិធីសាស្ត្របីដំណាក់កាល ចំពោះការវាស់វែងការខាតឥណទានរំពឹងទុក សម្រាប់ប្រភេទដូចខាងក្រោម៖

- ឧបករណ៍បំណុលដែលវាស់វែងតាមថ្លៃដើមដករំលស់ និង
- កិច្ចសន្យាផ្តល់ឥណទាន (រួមទាំងឥណទានវិចារូបន៍ ដែលមិនទាន់បានដកប្រាក់ និងហ្វាស៊ីលធី អាចប្រើប្រាស់ឡើងវិញ) និងកិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ

អនុវត្តវិធីសាស្ត្របីដំណាក់កាល ផ្អែកទៅលើបម្រែបម្រួលហានិភ័យឥណទាន ចាប់តាំងពីការទទួលស្គាល់លើកដំបូង៖

(i) ដំណាក់កាលទី ១ ៖ ECL ១២ខែ

ដំណាក់កាលទី១ រួមបញ្ចូលនូវទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមានកំណើនហានិភ័យឥណទានគួរឲ្យកត់សម្គាល់ ចាប់តាំងពីការកត់ត្រាលើកដំបូង ឬមានហានិភ័យឥណទានកម្រិតទាបនាកាលបរិច្ឆេទរាយការណ៍។ ECL១២ខែ ត្រូវបានកត់ត្រា ហើយចំណូលការប្រាក់ត្រូវបានគណនា តាមចំនួនតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

(ii) ដំណាក់កាលទី ២ ៖ ECL ពេញមួយអាយុកាល – មិនមានការថយចុះតម្លៃឥណទាន

ដំណាក់កាលទី ២ រួមមានទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានកំណើនហានិភ័យឥណទានជាសារវន្ត ចាប់តាំងពីការកត់ត្រាលើកដំបូង (លើកលែងតែវាមានហានិភ័យឥណទានទាប នាកាលបរិច្ឆេទរាយការណ៍) ប៉ុន្តែមិនមានភ័ស្តុតាងជាក់ស្តែងបង្ហាញពីការថយចុះតម្លៃ។ ECL ពេញមួយអាយុកាលត្រូវបានកត់ត្រា ហើយចំណូលការប្រាក់ត្រូវបានគណនាតាមចំនួនតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

(iii) ដំណាក់កាលទី ៣ ៖ ECL ពេញមួយអាយុកាល – មានការថយចុះតម្លៃឥណទាន

ដំណាក់កាលទី ៣ រួមមានទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានភ័ស្តុតាងជាក់ស្តែងបង្ហាញពីការថយចុះតម្លៃ នាកាលបរិច្ឆេទរាយការណ៍។ ECL ពេញមួយអាយុកាលត្រូវបានកត់ត្រា ហើយចំណូលការប្រាក់ត្រូវបានគណនាតាមចំនួនតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

២.៦ បំណុលហិរញ្ញវត្ថុ

បំណុលហិរញ្ញវត្ថុត្រូវបានកត់ត្រា នៅពេលដែលធនាគារក្លាយជាភាគីមួយ នៅក្នុងកិច្ចសន្យានៃឧបករណ៍ណាមួយ។ បំណុលហិរញ្ញវត្ថុរបស់ធនាគារមួយមាន ប្រាក់បញ្ញើរបស់ធនាគារ ប្រាក់បញ្ញើរបស់អតិថិជន ប្រាក់កម្ចី អនុបំណុលនិងបំណុលហិរញ្ញវត្ថុផ្សេងៗ។

បំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់លើកដំបូង តាមតម្លៃសមស្របដកចំណាយប្រតិបត្តិការចំពោះបំណុលប្រតិបត្តិការទាំងអស់ ដែលមិនវាស់វែងតាមតម្លៃសមស្រប ក្នុងចំណេញ-ខាត។

បំណុលហិរញ្ញវត្ថុដែលមិនត្រូវបានចាត់ថ្នាក់ តាមតម្លៃសមស្រប ក្នុងចំណេញ-ខាត ត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។ បំណុលហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ មានដូចជា ប្រាក់បញ្ញើរបស់ធនាគារ ប្រាក់បញ្ញើរបស់អតិថិជន ប្រាក់កម្ចី អនុបំណុល និងបំណុលផ្សេងៗ។

បំណុលហិរញ្ញវត្ថុត្រូវបានគេឈប់ទទួលស្គាល់ នៅពេលដែលវាត្រូវបានបង្វិលអស់ ឬបើមិនដូច្នោះទេ វាត្រូវបានព្រមព្រៀងឲ្យបញ្ឈប់ការសងប្រាក់តទៅទៀត។

២.៧ កិច្ចសន្យាផ្តល់ឥណទាន និងកិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ

កិច្ចសន្យាផ្តល់ឥណទាន (រួមមានឥណទានវិបារូបន៍ ដែលមិនទាន់បានដកប្រាក់ និងហ្វាស៊ីលីធី អាចប្រើប្រាស់ឡើងវិញ) ដែលធនាគារបានផ្តល់ ត្រូវបានវាស់វែងតាមចំនួនសំវិធានធនបាត់បង់។ ធនាគារមិនបានផ្តល់កិច្ចសន្យាផ្តល់ឥណទានណាមួយ ដែលមានអត្រាការប្រាក់ទាបជាងអត្រាទីផ្សារទេ ឬកិច្ចសន្យាដែលអាចត្រូវបានទូទាត់ជាសាច់ប្រាក់សុទ្ធ ឬតាមរយៈការផ្តល់ ឬការចេញឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតទេ។

ចំពោះកិច្ចសន្យាផ្តល់ឥណទាន (រួមមានឥណទានវិបារូបន៍ ដែលមិនទាន់បានដកប្រាក់ និងហ្វាស៊ីលីធី ដែលអាចប្រើប្រាស់ឡើងវិញ) ការខាតឥណទានរំពឹងទុកត្រូវបានទទួលស្គាល់ជាសំវិធានធន (ដែលត្រូវបានដាក់បង្ហាញក្នុងបំណុលផ្សេងៗ)។ ទោះជាយ៉ាងណាក៏ដោយ ចំពោះកិច្ចសន្យាដែលរួមបញ្ចូលទាំងឥណទាន និងកិច្ចសន្យាដែលមិនទាន់ដកប្រាក់ ហើយដែលធនាគារមិនអាចកំណត់ការខាតឥណទានរំពឹងទុកដាច់ដោយឡែក ចំពោះកិច្ចសន្យាឥណទានដែលមិនទាន់ដកប្រាក់ ត្រូវបានទទួលស្គាល់រួមគ្នា ក្នុងសំវិធានធនឥណទានបាត់បង់។ ក្នុងករណីដែលការខាតឥណទានរំពឹងទុករួមបញ្ចូលគ្នា លើសពីចំនួនតម្លៃយោងដុលរបស់ឥណទាន នោះការខាតឥណទានរំពឹងទុកត្រូវបានទទួលស្គាល់ជាសំវិធានធន។

កិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ គឺជាកិច្ចសន្យាទាំងឡាយណា ដែលតម្រូវឲ្យអ្នកចេញផ្សាយការធានា ធ្វើការទូទាត់ជាក់លាក់មួយ ដើម្បីផ្តល់សំណងទៅអ្នកកាន់កាប់ ចំពោះការខាតបង់ដែលកើតមានឡើង ដោយសារកូនបំណុល ណាមួយមិនបានសងបំណុលនៅពេលដល់ថ្ងៃកំណត់ ដោយអនុលោមទៅតាមលក្ខខណ្ឌនៃឧបករណ៍បំណុលនោះ។ ការធានាផ្នែកហិរញ្ញវត្ថុប្រភេទនេះ គឺត្រូវបានផ្តល់ឲ្យធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ និងអង្គភាពផ្សេងៗ ជំនួសគ្រឹះស្ថានទាំងនេះ ដើម្បីធានាលើឥណទាន ឥណទានវិបារូបន៍ និងហ្វាស៊ីលីធីធនាគារផ្សេងៗ។

ការធានាផ្នែកហិរញ្ញវត្ថុត្រូវបានទទួលស្គាល់លើកដំបូង ក្នុងរបាយការណ៍ហិរញ្ញវត្ថុ តាមតម្លៃសមស្រប នាកាលបរិច្ឆេទផ្តល់ការធានានោះ។ ការធានាត្រូវបានព្រមព្រៀងតាមលក្ខខណ្ឌស្មុគ្រគ្រិតស្មើភាពគ្នា ហើយតម្លៃបុព្វលាភដែលបានព្រមព្រៀង មានចំនួនប្រហាក់ប្រហែលនឹងតម្លៃនៃកាតព្វកិច្ចក្នុងការធានា។ បុព្វលាភដែលត្រូវទទួលនាពេលអនាគតមិនត្រូវបានទទួលស្គាល់ទេ។ បន្ទាប់មកកិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុត្រូវបានវាស់វែងតាមចំនួនណាមួយ ដែលខ្ពស់ជាងគេ រវាងចំនួនដែលត្រូវបានកំណត់ដោយផ្អែកទៅតាមគំរូការខាតឥណទានរំពឹងទុក ក្រោម CIFRS 9 ស្តីពី «ឧបករណ៍ហិរញ្ញវត្ថុ» និងចំនួន ដែលត្រូវបានទទួលស្គាល់លើកដំបូងដកនឹងចំនួនប្រាក់ចំណូលបង្គរ ដែលត្រូវបានទទួលស្គាល់ដោយផ្អែកទៅតាមគោលការណ៍របស់ CIFRS 15 ស្តីពី «ប្រាក់ចំណូលពីកិច្ចសន្យាជាមួយអតិថិជន» ទៅតាមការសមស្រប។

ការប៉ាន់ស្មានត្រូវបានកំណត់ដោយផ្អែកទៅតាមបទពិសោធន៍ នៃប្រតិបត្តិការប្រហាក់ប្រហែលគ្នា និងប្រវត្តិនៃការខាតបង់ក្នុងគ្រាកន្លងមក និងបូកបន្ថែមជាមួយនឹងការវិនិច្ឆ័យរបស់គណៈគ្រប់គ្រង។ ចំណូលកម្រៃសោយហ៊ុយដែលរកបាន ត្រូវបានទទួលស្គាល់តាមមូលដ្ឋានថេរ អាស្រ័យទៅតាមអាយុកាលនៃការធានានោះ។

កំណើនបំណុលដែលពាក់ព័ន្ធនឹងការធានា ត្រូវបានរាយការណ៍នៅក្នុងចំណេញ-ខាត ក្នុងខ្នង់ចំណាយប្រតិបត្តិការ។

២.៨ ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួនទឹកប្រាក់សុទ្ធបន្ទាប់ពីកាត់កងត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលធនាគារមានសិទ្ធិតាមផ្លូវច្បាប់ក្នុងការកាត់កងចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ ហើយធនាគារមានបំណងនឹងទូទាត់តាមមូលដ្ឋានចំនួនទឹកប្រាក់សុទ្ធ ឬមានបំណងកត់ត្រាទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

២.៩ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗ ដែលបានចំណាយក្នុងការទិញទ្រព្យនោះ។

ចំណាយបន្តបន្ទាប់ផ្សេងៗ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យនោះ ឬត្រូវបានទទួលស្គាល់ជាទ្រព្យដាច់ដោយឡែកតាមការសមស្រប តែនៅពេលដែលមានភាពប្រាកដថាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះនឹងហូរចូលមកក្នុងធនាគារ ហើយថ្លៃដើមនៃទ្រព្យនោះអាចត្រូវបានវាស់វែងគួរឲ្យជឿជាក់បានតែប៉ុណ្ណោះ។ រាល់ចំណាយលើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងចំណេញ-ខាត ក្នុងឆ្នាំហិរញ្ញវត្ថុដែលប្រតិបត្តិការនោះកើតឡើង។

ការងារកំពុងដំណើរការមិនត្រូវបានដករំលស់ទេ។ ការដករំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាជាបន្ទុក ក្នុងចំណេញ-ខាត តាមមូលដ្ឋានថេរ អាស្រ័យទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសកម្មនីមួយៗ និងទៅតាមអត្រាប្រចាំឆ្នាំ ដូចខាងក្រោម៖

	អត្រារំលស់
ការកែលម្អលើទ្រព្យជួល	២០% ឬ ចិរវេលានៃកិច្ចសន្យាជួល ប្រសិនបើវាខ្លីជាង
បរិក្ខារការិយាល័យ	១០% ទៅ ២០%
បរិក្ខារកុំព្យូទ័រ	២០% ទៅ ៣៣%
យានយន្ត	២០%

ការដកតម្លៃ លើការងារកំពុងដំណើរការ ចាប់ផ្តើមឡើងនៅពេលដែលទ្រព្យសកម្មមានភាពរួចរាល់សម្រាប់ការប្រើប្រាស់។ អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មត្រូវបានត្រួតពិនិត្យ និងកែតម្រូវតាមការសមស្របនា ដំណាច់កាលបរិច្ឆេទរាយការណ៍។

ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មណាមួយ លើសពីតម្លៃដែលអាចស្រង់មកវិញបាន វាត្រូវបានកត់ត្រាបន្ថយឲ្យនៅត្រឹមតម្លៃប៉ាន់ស្មាន ដែលអាចស្រង់មកវិញបាន។

ចំណេញ និងខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសាច់ប្រាក់បានពីការលក់ និងតម្លៃយោង ហើយត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត។

២.១០ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីដែលរួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ និងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានរាយការណ៍តាមថ្លៃដើមដកតម្លៃសរុប និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើងក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់។ ថ្លៃដើមត្រូវបានដកតម្លៃសរុបក្នុងរយៈពេលបីឆ្នាំ តាមវិធីសាស្ត្រតម្លៃសរុបថេរ លើកលែងតែអាជ្ញាប័ណ្ណសម្រាប់កម្មវិធីធនាគារ ដែលមានអាយុកាលប្រើប្រាស់ដប់ឆ្នាំ។

ការងារកំពុងដំណើរការមិនត្រូវបានដកតម្លៃសរុបទេ។ ចំណាយនានាពាក់ព័ន្ធនឹងការថែរក្សាទ្រព្យសកម្មអរូបី ត្រូវបានទទួលស្គាល់ជាចំណាយ នៅពេលដែលប្រតិបត្តិការនោះបានកើតឡើង។

២.១១ ការថយចុះតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មទាំងឡាយណា ដែលមានអាយុកាលប្រើប្រាស់មិនកំណត់ មិនត្រូវបានដកតម្លៃសរុបទេ និងត្រូវបានត្រួតពិនិត្យប្រចាំឆ្នាំរកការថយចុះតម្លៃរបស់វា នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយចង្អុលបង្ហាញថាតម្លៃយោងរបស់វា នឹងមិនអាចស្រង់មកវិញបាន។ ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានទទួលស្គាល់តាមចំនួនលម្អៀងរវាងតម្លៃយោងនៃទ្រព្យនោះធៀបជាមួយតម្លៃដែលអាចស្រង់មកវិញបាន។ តម្លៃដែលអាចស្រង់មកវិញបាន គឺជាតម្លៃមួយណាដែលខ្ពស់ជាងគេ រវាងតម្លៃសមស្របនៃទ្រព្យនោះ ដកចំណាយក្នុងការលក់ចេញ និងតម្លៃនៅប្រើប្រាស់។ ក្នុងការប៉ាន់ស្មានរកការថយចុះតម្លៃ ទ្រព្យសកម្មត្រូវបានដាក់ជាក្រុមតូចៗបំផុត ដែលគេអាចកំណត់លំហូរសាច់ប្រាក់របស់វាដាច់ដោយឡែកពីគ្នា ដែលវាមានឯករាជ្យទាំងស្រុងពីលំហូរសាច់ប្រាក់ចូលរបស់ទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មដទៃ (ក្រុមបង្កើតសាច់ប្រាក់)។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលមានការថយចុះតម្លៃ ត្រូវបានត្រួតពិនិត្យរកមើលលទ្ធភាព ក្នុងការកត់ត្រាការថយចុះតម្លៃត្រឡប់ទៅវិញ នៅរៀងរាល់ដំណាច់ការិយបរិច្ឆេទរាយការណ៍នីមួយៗ។

ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាជាបន្ទុកក្នុងចំណេញ-ខាតក្នុងការិយបរិច្ឆេទដែលប្រតិបត្តិការនោះបានកើតឡើង។ ការកត់ត្រាត្រលប់មកវិញនៃការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាក្នុងចំណេញ-ខាតទៅតាមចំនួនតម្លៃយោងនៃទ្រព្យសកម្មនោះ ដែលមិនលើសតម្លៃយោងដែលបានកំណត់ កាត់កងជាមួយនឹងរំលស់ ប្រសិនបើមិនបានទទួលស្គាល់ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។

២.១២ ភតិសន្យា

ធនាគារជាភាគីអ្នកជួល

នៅពេលចាប់ផ្តើមកិច្ចសន្យា ធនាគារវាយតម្លៃថាតើកិច្ចសន្យានោះ ឬខ្លឹមសាររបស់វាជាភតិសន្យាដែរឬទេ។ កិច្ចសន្យាមួយ ឬ ខ្លឹមសារនៃកិច្ចសន្យាមួយត្រូវបានចាត់ទុកថាជាភតិសន្យា ប្រសិនបើកិច្ចសន្យានោះផ្តល់សិទ្ធិ ក្នុងការគ្រប់គ្រងការប្រើប្រាស់ទ្រព្យសកម្ម ដែលត្រូវបានកំណត់មួយ ក្នុងរយៈពេលណាមួយ ជាថ្នូរនឹងការបង់ប្រាក់។

កិច្ចសន្យាអាចមានទាំងធាតុភតិសន្យា និងធាតុមិនមែនភតិសន្យា។ ធនាគារបានបែងចែកសាច់ប្រាក់ក្នុង កិច្ចសន្យាជាធាតុភតិសន្យា និងធាតុមិនមែនភតិសន្យា អាស្រ័យលើថ្លៃឈ្នួលដែលពាក់ព័ន្ធរបស់វា។

លក្ខខណ្ឌក្នុងភតិសន្យាត្រូវបានចរចាឡើងវិញ តាមមូលដ្ឋានដាច់ដោយឡែក និងមានលក្ខខណ្ឌខុសៗពីគ្នា។ កិច្ចព្រមព្រៀងភតិសន្យាមិនបានបណ្តាលឲ្យមានកិច្ចសន្យាណាមួយ ក្រៅពីអត្ថប្រយោជន៍ដែលបានធានា នៅក្នុងទ្រព្យសកម្មភតិសន្យា ដែលត្រូវបានកាន់កាប់ដោយភាគីម្ចាស់ជួលនោះទេ។ ទ្រព្យសកម្មដែលត្រូវបានជួល អាចនឹងមិនត្រូវបានប្រើប្រាស់ជាទ្រព្យធានាក្នុងការខ្ចីប្រាក់ទេ។

ភតិសន្យាត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ដែលមានសិទ្ធិប្រើប្រាស់ និងជាបំណុលពាក់ព័ន្ធនាកាលបរិច្ឆេទ ដែលទ្រព្យសកម្មដែលបានជួល មានភាពរួចរាល់សម្រាប់ប្រើប្រាស់។

ទ្រព្យសកម្ម និងបំណុល ដែលកើតពីភតិសន្យា ត្រូវបានវាស់វែងជាដំបូងតាមមូលដ្ឋានតម្លៃបច្ចុប្បន្ន។

(i) បំណុលភតិសន្យា

បំណុលភតិសន្យារួមបញ្ចូលនូវតម្លៃបច្ចុប្បន្នសុទ្ធនៃការទូទាត់ភតិសន្យាថេរ (រួមទាំងការបង់ប្រាក់ថេរផ្សេងៗ) ដកនឹងការលើកទឹកចិត្តផ្សេងៗ សម្រាប់ការជួលដែលត្រូវទទួលបាន។

ការទូទាត់ភតិសន្យាដែលត្រូវធ្វើឡើងក្រោមជម្រើសដែលអាចពន្យារយៈពេលបាន ប្រកបដោយភាពសមហេតុផល ត្រូវបានរួមបញ្ចូលនៅក្នុងការវាស់វែងបំណុល។

ការទូទាត់ភតិសន្យាត្រូវបានធ្វើអប្បហារ ដោយប្រើអត្រាជាក់ស្តែងក្នុងភតិសន្យា។ ប្រសិនបើអត្រាការប្រាក់មិនអាចកំណត់បានដោយភាពងាយស្រួលនោះ ដែលជាទូទៅចំពោះករណីភតិសន្យានៅក្នុងធនាគារ អត្រាកំណើន ប្រាក់កម្ចីរបស់ភាគីអ្នកជួលត្រូវបានប្រើប្រាស់ ហើយវាគឺជាអត្រាដែលភាគីអ្នកជួលនីមួយៗត្រូវចំណាយ ដើម្បីទទួលបានប្រាក់កម្ចី ដែលមានភាពចាំបាច់ ដើម្បីទទួលបានទ្រព្យសកម្មដែលមានតម្លៃប្រហាក់ប្រហែលនឹងទ្រព្យសកម្ម ដែលមានសិទ្ធិប្រើប្រាស់ នៅក្នុងបរិយាកាសសេដ្ឋកិច្ចស្រដៀងគ្នា ជាមួយនឹងលក្ខខណ្ឌ និងការធានាប្រហាក់ប្រហែលគ្នា។

ដើម្បីកំណត់អត្រាកំណើនប្រាក់កម្ចី ធនាគារអាចធ្វើទៅបានដោយប្រើហិរញ្ញប្បទានភាគីទីបីដែលទទួលបានពីភាគីអ្នកជួលនីមួយៗ គឺជាចំណុចចាប់ផ្តើម ហើយកែតម្រូវលើការផ្លាស់ប្តូរលក្ខខណ្ឌហិរញ្ញប្បទាន ចាប់តាំងពីហិរញ្ញប្បទានភាគីទីបីទទួលបាន។

ការទូទាត់ភតិសន្យាត្រូវបានបែងចែករវាងប្រាក់ដើម និងចំណាយការប្រាក់។ ចំណាយការប្រាក់ត្រូវបានកត់ត្រាជាបន្ទុកក្នុងចំណេញ-ខាត ក្នុងរយៈពេលនៃភតិសន្យានោះ ដើម្បីបង្កើតអត្រាការប្រាក់ថេរតាមកាលកំណត់មួយ លើចំនួនសមតុល្យបំណុលដែលនៅសល់ក្នុងការិយបរិច្ឆេទនីមួយៗ។

(ii) ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់

ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ត្រូវបានវាស់វែងជាដំបូងតាមថ្លៃដើម ដែលរួមមាន៖

- ចំនួនទឹកប្រាក់នៃបំណុលភតិសន្យា ដែលបានវាស់វែងលើកដំបូង
- ការទូទាត់ភតិសន្យាណាមួយ ដែលបានធ្វើឡើងនៅកាលបរិច្ឆេទចាប់ផ្តើម ឬមុនកាលបរិច្ឆេទចាប់ផ្តើមដកការលើកទឹកចិត្តផ្សេងៗ ដែលទទួលបានពីការជួល
- ចំណាយផ្ទាល់លើកដំបូង និង
- ចំណាយសម្រាប់ការជួសជុសឡើងវិញ ប្រសិនបើមាន

ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ ជាទូទៅត្រូវបានដកតម្លៃសរុប តាមមូលដ្ឋានរំលស់ថេរ លើរយៈពេលណាមួយដែលខ្លីជាងគេ រវាងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម និងរយៈពេលជួល។ ប្រសិនបើធនាគារមានបំណងជាក់លាក់ដ៏សមហេតុផលក្នុងការទិញ នោះទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់នោះត្រូវបានដកតម្លៃសរុប លើអាយុកាលប្រើប្រាស់មូលដ្ឋានរបស់ទ្រព្យសកម្មនោះ។

បន្ទាប់មកទៀត ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ ត្រូវបានវាស់វែងតាមថ្លៃដើមដកតម្លៃសរុប និងការខាត ដែលបណ្តាលមកពីការថយចុះតម្លៃបង្គរ ប្រសិនបើមាន។

(iii) ការទូទាត់ភតិសន្យាក្រោមការលើកលែងផ្សេងៗ

ការទូទាត់នានាដែលពាក់ព័ន្ធនឹងភតិសន្យា ដែលមានរយៈពេលខ្លី ត្រូវបានកត់ត្រាក្នុងចំណេញ-ខាតតាមមូលដ្ឋានថេរលើរយៈពេលនៃភតិសន្យា។ ភតិសន្យាដែលមានរយៈពេលខ្លី រួមមានការជួលទីតាំងសម្រាប់ទូ ATM។

២.១៣ ពន្ធលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូល គឺជាចំនួនប្រាក់ពន្ធដែលត្រូវបង់ លើប្រាក់ចំណូលជាប់ពន្ធ ក្នុងការិយបរិច្ឆេទបច្ចុប្បន្ន ដោយផ្អែកទៅតាមអត្រាពន្ធលើប្រាក់ចំណូលដែលចូលជាធរមាន និងធ្វើនិយ័តកម្ម ទៅតាមបម្រែបម្រួលពន្ធពន្យាទ្រព្យសកម្ម និងបំណុលពន្ធពន្យា ដែលបណ្តាលឲ្យមានលម្អៀងបណ្តោះអាសន្ន និងការខាតពន្ធដែលមិនបានប្រើប្រាស់។

ចំណាយពន្ធលើប្រាក់ចំណូលក្នុងគ្រា ត្រូវបានគណនាតាមមូលដ្ឋានច្បាប់ពន្ធ ដែលបានអនុម័ត រួចជាស្ថាពរ ឬត្រូវបានអនុម័តរួចមួយផ្នែកធំនាកាលបរិច្ឆេទវាយការណ៍ នៅក្នុងប្រទេសដែលធនាគារធ្វើប្រតិបត្តិការអាជីវកម្ម និងបង្កើតប្រាក់ចំណេញជាប់ពន្ធ។

ពន្ធពន្យាត្រូវបានកត់ត្រាសំវិធានធនពេញលេញ ដោយប្រើវិធីសាស្ត្របំណុល លើចំនួនលម្អៀងបណ្តោះអាសន្នរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល និងតម្លៃយោងរបស់វានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ពន្ធពន្យាត្រូវបានកំណត់ដោយប្រើអត្រាពន្ធតាមច្បាប់ពន្ធ ដែលត្រូវបានអនុម័តរួចជាស្ថាពរ ឬត្រូវបានអនុម័តរួចមួយផ្នែកធំ នាកាលបរិច្ឆេទវាយការណ៍។

ពន្ធពន្យាទ្រព្យសកម្មត្រូវបានទទួលស្គាល់ លុះត្រាតែមានភាពប្រាកដថានឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត សម្រាប់យកលម្អៀងបណ្តោះអាសន្នមកប្រើប្រាស់។ ពន្ធពន្យាទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទវាយការណ៍នីមួយៗ ហើយត្រូវបានកាត់បន្ថយទៅតាមចំនួន ដែលទំនងជាមិនមានប្រាក់ចំណេញជាប់ពន្ធត្រូវបានកត់ត្រា។

ពន្ធពន្យាទ្រព្យសកម្មត្រូវបានកាត់កងជាមួយនឹងបំណុលពន្ធពន្យា ប្រសិនបើមានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីកាត់កងបំណុលពន្ធក្នុងឆ្នាំជាមួយនឹងពន្ធទ្រព្យសកម្មក្នុងឆ្នាំ ហើយប្រសិនបើវាទាក់ទងនឹងពន្ធលើប្រាក់ចំណូល ដែលកំណត់ដោយអាជ្ញាធរពន្ធដារតែមួយ ទៅលើអង្គភាពជាប់ពន្ធតែមួយ។

ពន្ធក្នុងឆ្នាំនិងពន្ធពន្យាត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត លើកលែងតែវាពាក់ព័ន្ធជាមួយនឹងខ្ទង់ផ្សេងៗ ដែលបានទទួលស្គាល់ផ្ទាល់ ក្នុងលទ្ធផលលម្អិតផ្សេងៗ ឬក្នុងមូលធន។ ក្នុងករណីនេះ ពន្ធត្រូវបានទទួលស្គាល់ក្នុងលទ្ធផលលម្អិតផ្សេងៗ ឬត្រូវបានទទួលស្គាល់ផ្ទាល់ ក្នុងមូលធនដែរ។

២.១៤ សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់ នៅពេលដែលមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាអាចតម្រូវឲ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់ត្រូវបានប៉ាន់ស្មានគួរឲ្យជឿជាក់បាន។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន កម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចទាំងមូល។ សំវិធានធនត្រូវបានទទួលស្គាល់ ទោះបីជាកម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះមានចំនួនតូចក៏ដោយ។

សំវិធានធនត្រូវបានគណនាតាមតម្លៃបច្ចុប្បន្ននៃចំណាយដែលត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃសាច់ប្រាក់គិតតាមពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធនដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានទទួលស្គាល់ជាចំណាយការប្រាក់។

២.១៥ ទុនបម្រុងតាមច្បាប់

ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុត្រូវបានតម្រូវឲ្យគណនាសំវិធានធនតាមច្បាប់ អនុលោមទៅតាមប្រកាសលេខធ៧-០១៧-៣៤៤ប្រ.ក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី «ចំណាត់ថ្នាក់ហានិភ័យតំណាទាន និងសំវិធានធនលើអ៊ីមហ្គេរមិន»។ ប្រសិនបើសំវិធានធនតាមច្បាប់បង្គរ មានចំនួនខ្ពស់ជាងការថយចុះតម្លៃបង្គរ ផ្អែកតាម CIFRS 9 នោះ «ការបំពេញបន្ថែម - topping up» នឹងត្រូវបានកត់ត្រាជាទុនបម្រុងតាមច្បាប់ និងត្រូវបានដាក់បង្ហាញនៅក្នុងមូលធន។ បន្ទាប់មក ទុនបម្រុងត្រូវបានកត់ត្រាត្រឡប់ទៅវិញ (រហូតដល់សូន្យ) ប្រសិនបើសំវិធានធនតាមច្បាប់បង្គរមានចំនួនស្មើគ្នា ឬទាបជាងការថយចុះតម្លៃបង្គរ ដែលផ្អែកតាម CIFRS 9 ។ ទុនបម្រុងតាមច្បាប់ត្រូវបានតម្កល់ទុកមួយឡែក ជាទ្រនាប់ទុន ហើយមិនអាចបែងចែកបាន និងមិនត្រូវបានអនុញ្ញាតឲ្យរួមបញ្ចូលនៅក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធទេ។

២.១៦ អត្ថប្រយោជន៍បុគ្គលិក

i) អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី

អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី ត្រូវបានកត់ត្រាបង្គរក្នុងឆ្នាំ ដែលបុគ្គលិកបានបម្រើការងារឲ្យធនាគារ។

ii) អត្ថប្រយោជន៍បុគ្គលិករយៈពេលវែងផ្សេងៗ - ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

នៅខែមិថុនា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើវិសោធនកម្មលើច្បាប់ស្តីពីការងារ ដែលណែនាំពីគម្រោង ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។ បន្ទាប់មក នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ប្រកាសលេខ ៤៤៣ K.B/Br.K.Kh.L ត្រូវបានចេញផ្សាយ ដោយបានផ្តល់នូវគោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់នេះ។ អនុលោមទៅតាមច្បាប់/ប្រកាសនេះ អង្គភាពនីមួយៗតម្រូវឲ្យទូទាត់ប្រាក់បំណាច់អតីតភាពការងារឲ្យនិយោជិត ដែលមានកិច្ចសន្យាការងារមិនមានរយៈពេលកំណត់ដូចខាងក្រោម៖

- ប្រាក់បំណាច់ការងារប្រចាំឆ្នាំ - ចូលជាធរមានក្នុងខែមករា ឆ្នាំ២០១៩ - ស្មើនឹង ១៥ ថ្ងៃ នៃប្រាក់បៀវត្សរ៍ប្រចាំខែរបស់បុគ្គលិក និងអត្ថប្រយោជន៍ក្នុងឆ្នាំនីមួយៗគិតជាមធ្យម ដែលត្រូវទូទាត់រៀងរាល់ ៦ ខែម្តង នៅថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី៣១ ខែធ្នូ (៧.៥ ថ្ងៃ ក្នុងការទូទាត់ម្តងៗ)។
- ការបើករំឭកប្រាក់បំណាច់អតីតភាពការងារ - និយោជិតមានសិទ្ធិទទួលបានការបើករំឭកប្រាក់បំណាច់អតីតភាពការងារ ស្មើនឹង ១៥ ថ្ងៃនៃប្រាក់បៀវត្សរ៍របស់ពួកគេក្នុងមួយឆ្នាំ គិតចាប់តាំងពីថ្ងៃចូលបម្រើការងាររហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ហើយនៅតែបន្តការងារជាមួយធនាគារ។ ការបើករំឭកប្រាក់បំណាច់អតីតភាពការងារ អាស្រ័យទៅតាមចំនួនឆ្នាំអតីតភាពការងាររបស់បុគ្គលិកម្នាក់ៗ ហើយមិនត្រូវលើសពី៦ខែនៃប្រាក់ បៀវត្សរ៍ដុលជាមធ្យមទេ។ នៅថ្ងៃទី២២ ខែមីនាឆ្នាំ២០១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីណែនាំលេខ ០៤២/១ K.B/S.N.N.Kh.L ដើម្បីពន្យាពេលការបើករំឭកប្រាក់បំណាច់អតីតភាពការងារ ដែលនឹងត្រូវទូទាត់ឲ្យចំនួនបីថ្ងៃ ក្នុងខែមិថុនា និងខែធ្នូ ចាប់ផ្តើមនៅខែធ្នូ ឆ្នាំ២០២១។

ការទូទាត់ប្រាក់បំណាច់ការងារប្រចាំឆ្នាំ ត្រូវបានចាត់ទុកថាជាអត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី ហើយវាត្រូវបានកត់ត្រាបង្គរ ក្នុងឆ្នាំដែលបុគ្គលិកបានបម្រើការងារឲ្យធនាគារ។

ការបើករំឭកប្រាក់បំណាច់អតីតភាពការងារ ត្រូវបានចាត់ថ្នាក់ជាអត្ថប្រយោជន៍បុគ្គលិករយៈពេលវែង។ បំណុលប្រាក់រំឭកអតីតភាពការងារ ត្រូវបានកត់ត្រាតាមតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ច ដែលបានកំណត់នាការិយបរិច្ឆេទវាយការណ៍ ដោយប្រើវិធីសាស្ត្រ projected unit credit ដើម្បីធ្វើការប៉ាន់ស្មានឲ្យបានកាន់តែល្អនូវតម្លៃចុងក្រោយ ដែលធនាគារត្រូវបង់ឲ្យបុគ្គលិក ជាផ្ទួនៗនឹងការបម្រើការងារឲ្យធនាគារក្នុងពេលបច្ចុប្បន្ន និងក្នុងឆ្នាំកន្លងមក។ តម្លៃបច្ចុប្បន្ននៃការបើករំឭកប្រាក់បំណាច់អតីតភាពការងារ ត្រូវបានកំណត់ដោយធ្វើអប្បហារលើចំនួនទឹកប្រាក់ប៉ាន់ស្មាន ដែលត្រូវទូទាត់នាពេលអនាគត ដោយយោងទៅតាមសញ្ញាប័ណ្ណសាជីវកម្ម ដែលមានគុណភាពខ្ពស់នៃរូបិយប័ណ្ណរបស់បំណុលនោះ។

iii) **អត្ថប្រយោជន៍បុគ្គលិកផ្សេងៗ - មូលនិធិសោធននិវត្តន៍បុគ្គលិក**

ធនាគារបានកត់ត្រាមូលនិធិសោធននិវត្តន៍បុគ្គលិក សម្រាប់ជាអត្ថប្រយោជន៍ដល់បុគ្គលិកពេញសិទ្ធិទាំងអស់។ ទាំងនិយោជិត និងនិយោជក បង់វិភាគទាន ៥% នៃប្រាក់ឈៀវត្សរ៍ប្រចាំខែរបស់បុគ្គលិកម្នាក់ៗ។ បុគ្គលិកដែលបានបម្រើការងាររយៈពេលបីឆ្នាំ ឬតិចជាងនេះ នៅពេលលាឈប់ពីការងារ ឬចូលនិវត្ត នឹងទទួលបានត្រឹមតែវិភាគទានបង្ករបស់ខ្លួនតែប៉ុណ្ណោះ។ បន្ទាប់ពីបីឆ្នាំ បុគ្គលិកម្នាក់ៗនឹងទទួលបានទាំងវិភាគទានរបស់ពួកគេ និងវិភាគទានរបស់ធនាគារ។

មូលនិធិនេះ ត្រូវបានរក្សាទុកក្នុងគណនីធនាគារដោយឡែក សម្រាប់បុគ្គលិកម្នាក់ៗ ប៉ុន្តែស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារ។ ធនាគារផ្តល់ការប្រាក់ ទាំងចំពោះវិភាគទានរបស់ធនាគារ និងវិភាគទានរបស់បុគ្គលិក តាមអត្រាការប្រាក់របស់ប្រាក់បញ្ញើមានកាលកំណត់១២ខែ។ ចំណាយវិភាគទាន (៥% ពីធនាគារ) ត្រូវបានកត់ត្រាក្នុងចំណេញ-ខាត តាមមូលដ្ឋានប្រចាំខែ។

២.១៧ ចំណូល និងចំណាយការប្រាក់

ចំណូល និងចំណាយការប្រាក់ពីឧបករណ៍ហិរញ្ញវត្ថុ ដែលវាស់វែងតាមថ្លៃដើមដករំលស់ ត្រូវបានទទួលស្គាល់ក្នុង «ចំណូលការប្រាក់» និង «ចំណាយការប្រាក់» ក្នុងចំណេញ-ខាត ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។

វិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព គឺជាវិធីសាស្ត្រ ក្នុងការគណនាថ្លៃដើមដករំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុមួយឬបំណុលហិរញ្ញវត្ថុមួយ និងជាវិធីសាស្ត្រក្នុងការបែងចែកចំណូលការប្រាក់ ឬចំណាយការប្រាក់ លើរយៈពេលដែលពាក់ព័ន្ធ។ អត្រាការប្រាក់មានប្រសិទ្ធភាព គឺជាអត្រាដែលធ្វើអប្បហារជាក់ស្តែងចំពោះការទូទាត់សាច់ប្រាក់ ឬបង្កាន់ដៃទទួលប្រាក់ប៉ាន់ស្មាននាពេលអនាគត ក្នុងរយៈពេលនៃអាយុកាលប៉ាន់ស្មានរបស់ឧបករណ៍ហិរញ្ញវត្ថុ ឬក្នុងរយៈពេលណាមួយដែលខ្លីជាង ទៅតាមការសមស្រប ចំពោះតម្លៃយោងសុទ្ធរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ នៅពេលគណនាអត្រាការប្រាក់មានប្រសិទ្ធភាព ធនាគារបានកត់ត្រារាល់លក្ខខណ្ឌក្នុងកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ និងបានរួមបញ្ចូលនូវកម្រៃ ឬកំណើនចំណាយនានា ដែលបានចំណាយដោយផ្ទាល់ទៅលើឧបករណ៍នោះ នឹងវាជាផ្នែកមួយនៃអត្រាការប្រាក់មានប្រសិទ្ធភាព ប៉ុន្តែមិនមែនជាការខាតឥណទាននាពេលអនាគតទេ។

ចំណូលការប្រាក់ត្រូវបានគណនាដោយអនុវត្តនូវអត្រាការប្រាក់មានប្រសិទ្ធភាព ចំពោះតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ លើកលែងតែចំពោះ៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការថយចុះតម្លៃដែលបានទិញ ឬបានបង្កើតឡើង (Purchased or originated credit-impaired financial assets - POCI) ដែលអត្រាការប្រាក់មានប្រសិទ្ធភាពសម្រាប់កែតម្រូវឥណទានលើកដំបូង ត្រូវបានអនុវត្តចំពោះថ្លៃដើមដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមែនជា POCI ប៉ុន្តែបានក្លាយជាឥណទានដែលមានការថយចុះតម្លៃមួយផ្នែកធំ (ឬ «ដំណាក់កាលទី ៣») ដែលចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់មានប្រសិទ្ធភាព ចំពោះថ្លៃដើមដករំលស់របស់វា (ឧ. កាត់កងជាមួយនឹងសំវិធានធនការខាតឥណទានរំពឹងទុក)។

២.១៨ ចំណូលកម្រៃជើងសា

ចំណូលកម្រៃជើងសាត្រូវបានទទួលស្គាល់ជាចំណូល នៅពេលដែលវាបានបំពេញតាមគំរូលក្ខខណ្ឌទាំងអស់ (កាតព្វកិច្ចនៃដំណើរការត្រូវបានទទួលយក ហើយការគ្រប់គ្រងត្រូវបានផ្ទេរក្នុងពេលវេលាណាមួយ ឬ ចំណុចនៃពេលវេលាណាមួយ)។

កម្រៃក្នុងដំណើរការផ្តល់ឥណទាន បុរេប្រទាន និងហិរញ្ញប្បទាន ដែលទំនងជាអាចត្រូវបានផ្តល់ឲ្យ ត្រូវបានពន្យា (ជាមួយនឹងចំណាយផ្ទាល់ពាក់ព័ន្ធ) ហើយចំណូលដែលជាផ្នែកនៃអត្រាការប្រាក់មានប្រសិទ្ធភាពរបស់ឧបករណ៍ហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ដោយធ្វើនិយ័តកម្ម ទៅលើអត្រាការប្រាក់មានប្រសិទ្ធភាពរបស់ឧបករណ៍ហិរញ្ញវត្ថុនោះ។

៣. ការប៉ាន់ស្មានគណនេយ្យសំខាន់ៗ និងការវិនិច្ឆ័យ

ធនាគារធ្វើការប៉ាន់ស្មាន និងការសន្មតដោយគិតទៅលើអនាគតកាល។ តាមនិយមន័យ លទ្ធផលនៃការប៉ាន់ស្មានគណនេយ្យ កម្រស្មើគ្នាជាមួយនឹងលទ្ធផលជាក់ស្តែងណាស់។ ដើម្បីធ្វើឲ្យមាតិកាព័ត៌មាននៃការប៉ាន់ស្មានកាន់តែមានភាពល្អប្រសើរឡើង ធាតុអថេរជាក់លាក់សំខាន់ៗដែលជាធាតុធ្វើឲ្យមានការប៉ះពាល់ជាសារវន្តចំពោះលទ្ធផល និងស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានធ្វើតេស្តរកភាពងាយប្រែប្រួលរបស់វាចំពោះបម្រែបម្រួលប៉ារ៉ាម៉ែត្រមូលដ្ឋាន។ ការប៉ាន់ស្មាន និងការសន្មតចំពោះតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល ក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់ ត្រូវបានកត់សម្គាល់ដូចខាងក្រោម៖

i) **សំវិធានធនការខាតឥណទានរំពឹងទុក ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើមដករំលស់**

សំវិធានធនការខាតឥណទានរំពឹងទុក ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើមដករំលស់ តម្រូវឲ្យប្រើប្រាស់គំរូស្មុគស្មាញ និងការសន្មតជាក់លាក់ ចំពោះលក្ខខណ្ឌសេដ្ឋកិច្ចនាពេលអនាគត និងលក្ខណៈរបស់ឥណទាន (ឧ. លទ្ធភាពដែលអតិថិជនអាចមិនសងប្រាក់ និងបណ្តាលឲ្យមានការខាតបង់)។

ការវិនិច្ឆ័យជាក់លាក់មួយចំនួន ក៏ត្រូវបានតម្រូវនៅក្នុងការអនុវត្តតម្រូវការគណនេយ្យ សម្រាប់ការវាស់វែង ECL ផងដែរ ដូចជា៖

- ការបង្កើតក្រុមទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានលក្ខណៈស្រដៀងគ្នា ក្នុងគោលបំណងដើម្បីវាស់វែង ECL
- ជ្រើសរើសគំរូ និងការសន្មតសមស្រប សម្រាប់ការវាស់វែង ECL
- ការកំណត់លក្ខណៈវិនិច្ឆ័យ ចំពោះកំណើនហានិភ័យឥណទានអតិថិជន ដែលមានកំណើនហានិភ័យជាសារវន្ត («SICR»)
- អនុវត្តការសន្មត និងការវិភាគ លើលំហូរសាច់ប្រាក់នាពេលអនាគតរំពឹងទុក និងព័ត៌មានដែលព្យាករអំពីអនាគត
- អនុវត្តវិធីសាស្ត្រមិនមែនបច្ចេកទេសចំពោះ ECL ដោយពិចារណាបន្ថែមលក្ខណៈវិនិច្ឆ័យផ្នែកគុណភាពបន្ថែម សម្រាប់ SICR ចំពោះឥណទានដែលត្រូវបានរៀបចំឡើងវិញ ដោយសារផលប៉ះពាល់នៃ COVID-19 និងការកំណត់សេណារីយ៉ូដែលថ្លឹងប្រូបាប ដែលឆ្លុះបញ្ចាំងអំពីលក្ខខណ្ឌសេដ្ឋកិច្ចចុងក្រោយបំផុត ដែលរងផលប៉ះពាល់ដោយសារ COVID-19 ដែលមិនត្រូវបានរួមបញ្ចូលនៅក្នុងគំរូ ECL ដែលមានស្រាប់។

ii) **អត្ថប្រយោជន៍បុគ្គលិករយៈពេលវែងផ្សេងៗ - ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ**

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ អាស្រ័យទៅលើកត្តាមួយចំនួនដែលត្រូវបានកំណត់ដោយមូលដ្ឋានមួយ ដែលប្រើប្រាស់ការសន្មតមួយចំនួន។ ការសន្មតដែលត្រូវបានប្រើប្រាស់ក្នុងការកំណត់ចំណាយចុងក្រោយ សម្រាប់ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ រួមមានអត្រាបម្រែបម្រួលបុគ្គលិក និងអត្រាអប្បហារ។ បម្រែបម្រួលណាមួយ ក្នុងការសន្មតទាំងនេះ នឹងធ្វើឲ្យមានផលប៉ះពាល់ លើតម្លៃយោងរបស់កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។

iii) **លក្ខខណ្ឌភតិសន្យា**

ក្នុងការកំណត់លក្ខខណ្ឌភតិសន្យា គណៈគ្រប់គ្រងពិចារណាទៅលើភាពជាក់ស្តែង និងលក្ខខណ្ឌទាំងអស់ ដែលបង្កើតឲ្យមានការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច ដើម្បីអនុវត្តជម្រើស ក្នុងការបន្តការជួល ឬជម្រើសមិនបន្តការជួល។ ជម្រើសក្នុងការបន្តការជួល (ឬរយៈពេលបន្ទាប់ពីជម្រើសបញ្ឈប់ការជួល) ត្រូវបានរួមបញ្ចូលនៅក្នុងលក្ខខណ្ឌភតិសន្យា ប្រសិនបើភតិសន្យានោះមានភាពជាក់លាក់សមហេតុផល សម្រាប់ការបន្តការជួល (ឬមិនបញ្ឈប់តែប៉ុណ្ណោះ)។

៤. សាច់ប្រាក់ក្នុងដៃ

	២០២០		២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
រយៈពេលខ្លី				
ប្រាក់ដុល្លារអាមេរិក	៨៦.០៧៩.០៨២	៣៨៨.១៨៩.៨៨៧	៥៧.៣៨៨.៨៧០	២៣៣.៨៥៩.៦៤៥
ប្រាក់រៀល	៣.៣៧២.៤៤៨	១៣.៦៨១.៥៥២	២.៥១៦.៤៤៣	១០.២៥៤.៥០៥
	៨៩.៤៥១.៥៣០	៣៦១.៨៣១.៤៣៩	៥៩.៩០៥.៣១៣	២៤៤.១១៤.១៥០

៥. ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល

	២០២០		២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
រយៈពេលខ្លី				
គណនីចរន្ត	១៣៦.២០១.១២៦	៥៥០.៩៣៣.៥៥៥	១០៧.៥៦៩.០២៩	៤៣៨.៣៤៣.៧៩៣
គណនីទូទាត់	៤៤៨.១៤៣	១.៨១២.៧៣៨	១.៨៦០.២៩៦	៥.៩៥០.៧០៧
មូលបត្រអាចជួញដូរបាន (i)	៧៥.៣៨៦.៤៣០	៣០៤.៧៧៦.៣០៩	៩០.៦២៦.៧២៥	៣៦៩.៣០៣.៩០៤
សរុបរយៈពេលខ្លី	២១១.៩៩៥.៦៩៩	៨៥៧.៥២២.៦០២	១៩៩.៦៥៦.០៥០	៨១៣.៥៩៨.៤០៤
	២១១.៩៩៥.៦៩៩	៨៥៧.៥២២.៦០២	១៩៩.៦៥៦.០៥០	៨១៣.៥៩៨.៤០៤

(i) ធនាគារបានតម្កល់មូលបត្រអាចជួញដូរបាន (NCDs) ដែលមានទឹកប្រាក់ចំនួន ៩.៧៥២.៣២៤ ដុល្លារអាមេរិក (៣១ ធ្នូ ២០១៩ ៖ ១១.៧៣០.០០០ ដុល្លារអាមេរិក) ជាមួយធនាគារកណ្តាល ជាទ្រព្យបញ្ចាំលើហ្វាស៊ីលីធី សម្រាប់ទូទាត់។ NCDs ផ្សេងទៀត ដែលមានទឹកប្រាក់ចំនួន ៦៥.៥៩៤.១០៦ ដុល្លារអាមេរិក (៣១ ធ្នូ ២០១៩ ៖ ៧៨.៧០០.០០០ ដុល្លារអាមេរិក) នៅធនាគារកណ្តាល ត្រូវបានដាក់ជាទ្រព្យបញ្ចាំ ចំពោះប្រាក់កម្ចីលើប្រតិបត្តិការផ្តល់ សន្ធនីយភាពដោយមានការធានា (LPCO) (កំណត់សម្គាល់ ១៦)។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារមិនទាន់បានប្រើឥណទានវិចារូបន៍ ចំពោះហ្វាស៊ីលីធីសម្រាប់ការទូទាត់នេះនៅឡើយទេ។

អត្រាការប្រាក់ប្រចាំឆ្នាំនៃប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល មានដូចខាងក្រោម៖

	២០២០	២០២១
គណនីចរន្ត	0%	0%
គណនីទូទាត់	0%	0%
មូលបត្រអាចជួញដូរបាន	0,០៧% ទៅ ១,០៩%	0,២៨% ទៅ ១,០៩%

៦. ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ

(ក) វិភាគតាមស្ថានភាពនិវាសនដ្ឋាន

	២០២០		២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារក្នុងប្រទេស	៣៥.២១០.៣៥៣	១៤២.៤២៥.៨៧៨	១.៨១០.៣១៨	៧.៣៧៧.០៤៦
ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារក្រៅប្រទេស	៣០.៨១៧.៩៥០	១២៤.៦៥៨.៦០៨	១២.៥៨២.៩៣៦	៥១.២៧៥.៤៦៤
	៦៦.០២៨.៣០៣	២៦៧.០៨៤.៤៨៦	១៤.៣៩៣.២៥៤	៥៨.៦៥២.៥១០
ដក៖ សំវិធានធនការខាតឥណទានរំពឹងទុក	(១៣.៤៣៤)	(៥៤.៣៤១)	(៣.៧៥៧)	(១៥.៣១០)
	៦៦.០១៤.៨៦៩	២៦៧.០៣០.១៤៥	១៤.៣៨៩.៤៩៧	៥៨.៦៣៧.២០០

(ខ) វិភាគតាមប្រភេទគណនី

	២០២០		២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារក្នុងប្រទេស៖				
ប្រាក់បញ្ញើមានកាលកំណត់	៣២.៦២៧.៣១៧	១៣១.៩៧៧.៤៩៧	-	-
គណនីសន្សំ	២.០១២.៣២៤	៨.១៣៩.៨៥១	១.០០៣.៤៦១	៤.០៨៩.១០៤
គណនីចរន្ត	៥៧០.៧១២	២.៣០៨.៥៣០	៨០៦.៨៥៧	៣.២៨៧.៩៤២
ដក៖ សំវិធានធនការខាតឥណទានរំពឹងទុក	(៧.១២១)	(២៨.៨០៥)	(៤៧៣)	(១.៩២៧)
សមតុល្យនៅធនាគារក្នុងប្រទេសសរុប	៣៥.២០៣.២៣២	១៤២.៣៩៧.០៧៣	១.៨០៩.៨៤៥	៧.៣៧៥.១១៩
ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារក្រៅប្រទេស៖				
ប្រាក់បញ្ញើមានកាលកំណត់	២៤.០២៤.៥៣៧	៩៧.១៧៩.២៥២	៦.២២០.៣៥២	២៥.៣៤៧.៩៣៤
គណនីចរន្ត	៦.៧៩៣.៤១៣	២៧.៤៧៩.៣៥៦	៦.៣៦២.៥៨៤	២៥.៩២៧.៥៣០
ដក៖ សំវិធានធនការខាតឥណទានរំពឹងទុក	(៦.៣១៣)	(២៥.៥៣៦)	(៣.២៨៤)	(១៣.៣៨៣)
សមតុល្យនៅធនាគារក្រៅប្រទេសសរុប	៣០.៨១១.៦៣៧	១២៤.៦៣៣.០៧២	១២.៥៧៩.៦៥២	៥១.២៦២.០៨១
	៦៦.០១៤.៨៦៩	២៦៧.០៣០.១៤៥	១៤.៣៨៩.៤៩៧	៥៨.៦៣៧.២០០

(គ) វិភាគតាមកាលកំណត់ឥណទាន

	២០២០		២០១៩	
	ជុំល្ហារអាមេរិក	ពាន់រៀល	ជុំល្ហារអាមេរិក	ពាន់រៀល
រយៈពេលខ្លី	៦៦.០១៤.៨៦៩	២៦៧.០៣០.១៤៥	១៤.៣៨៩.៤៩៧	៥៨.៦៣៧.២០០
	៦៦.០១៤.៨៦៩	២៦៧.០៣០.១៤៥	១៤.៣៨៩.៤៩៧	៥៨.៦៣៧.២០០

អត្រាការប្រាក់ប្រចាំឆ្នាំនៃប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ មានដូចខាងក្រោម៖

	២០២០	២០១៩
គណនីចរន្ត	0,00% - 0,៣៥%	0,00% - 0,៨0%
គណនីសន្សំ	១,២៥% - ២,២៥%	១,២៥%
ប្រាក់បញ្ញើមានកាលកំណត់	0,0៥% - ២,00%	១,២0% - ២,៤៥%

៧. ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់

	២០២០		២០១៩	
	ជុំល្ហារអាមេរិក	ពាន់រៀល	ជុំល្ហារអាមេរិក	ពាន់រៀល
ឥណទានរយៈពេលវែង	៤៨៤.៦៧៨.៦៨៦	១.៧៩៨.៧២៥.២៨៥	៣៨២.៥៣២.៣៥៨	១.៣៩៥.៨១៩.៣៨៣
ឥណទានទិញគេហដ្ឋាន	២៣៣.៦១0.៥៦៣	៩៨៤.៩៥៤.៧២៧	២១៧.៦១៩.៥១១	៨៨៦.៧៩៩.៥0៧
ឥណទានវិចារូបន៍	៨៣.២៦១.១៧២	៣៣៦.៧៩១.៤៤១	៦៤.២៨0.៩២១	២៦១.៩៤៤.៧៥៣
សក្ខីបត្រឥណទាន ជំនឿទុកចិត្ត	៧៦.២៣៦.៧៧៤	៣0៨.៣៧៧.៧៥១	៥៨.៧១៥.៦២0	២៣៩.២៦៦.១៥២
ឥណទានដែលអាចប្រើឡើងវិញបាន	៤.២៨៤.១៩៨	១៧.៣២៩.៥៨១	៤.៦៨៣.៣៣៤	១៩.0៨៤.៥៨៦
ឥណទានបុគ្គល	២.៩៩៨.0៩២	១២.១២៧.២៨២	៣.៣0៣.៩0៥	១៣.៤៦៣.៤១៣
ឥណទានយានយន្ត	៣.៥៩២.២៤២	១៤.៥៣0.៦១៩	២.១៥៧.៣៩៨	៨.៧៩១.៣៩៧
ប័ណ្ណឥណទាន	៩0៥.៩៥៤	៣.៦៦៤.៥៨៤	១.៦៩៨.៦0៥	៦.៩២១.៨១៥
ឥណទានរយៈពេលខ្លី	១.0៧៩.៣៧៦	៤.៣៦៦.0៧៥	៦៩១.២៩៦	២.៨១៧.0៣១
ឥណទានដុលសរុប	៨៥0.៦៤៧.0៥៧	៣.៤៤0.៨0៧.៣៤៥	៦៩៥.៦៨២.៩៤៤	២.៨៣៤.៩0៧.៩៩៧
ដក៖ សំវិធានធនការខាតឥណទានរំពឹងទុក (កំណត់សម្គាល់ ៣៤.១ (ច)(i))	(៣.៦0៦.៨៥១)	(១៤.៥៨៩.៧១២)	(១.៩១៩.0៣៨)	(៧.៨២0.0៨0)
ឥណទានសុទ្ធសរុប	៨៨៧.0៨0.២0៦	៣.៤២៦.២៧៧.៦៣៣	៦៩៣.៧៦៣.៩0៦	២.៨២៧.0៨៧.៩១៧

(ក) សំវិធានធនការខាតឥណទានរំពឹងទុក

បម្រែបម្រួលសំវិធានធនសម្រាប់ការខាតបង់ឥណទាន មានដូចខាងក្រោម៖

	២០២០		២០១៩	
	ជុំល្ហារអាមេរិក	ពាន់រៀល	ជុំល្ហារអាមេរិក	ពាន់រៀល
ECL ១២ខែ (ជំណាក់កាលទី ១)	២.៦៥៨.១២៨	១0.៧៥២.១១២	១.៦៨0.៥២១	៦.៨៨៨.១២៣
ECLពេញមួយអាយុកាល-មិនថយចុះតម្លៃឥណទាន (ជំណាក់កាលទី ២)	២១.៨៥៣	៨៨.៣៩៥	២៦.២៣៧	១0៦.៩១៦
ECLពេញមួយអាយុកាល-ថយចុះតម្លៃឥណទាន (ជំណាក់កាលទី ៣)	៩២៦.៨៧៨	៣.៧៨៩.២0៥	២១២.២៨0	៨៦៥.0៨១
	៣.៦0៦.៨៥១	១៤.៥៨៩.៧១២	១.៩១៩.0៣៨	៧.៨២0.0៨0

(ខ) វិភាគតាមប្រភេទអាជីវកម្ម

	២០២០		២០១៩	
	ជុំល្ហារអាមេរិក	ពាន់រៀល	ជុំល្ហារអាមេរិក	ពាន់រៀល
ឥណទានទិញគេហដ្ឋាន	២៣៤.៣៨៨.0៦២	៩៤៨.0៩៩.៧១១	២១៩.0៥៧.៧៥៤	៨៩២.៦៦0.៣៤៨
លក់ដុំ និងលក់រាយ	១៥៣.៦៤២.៨៨៥	៦២១.៤៨៥.៤៧0	១១៤.១៨0.២៩៣	៤៦៥.២៨៤.៦៩៤
នាំចូល និងនាំចេញ	១៤៣.៩៨0.៧៣៥	៥៨២.៤0២.0៧៣	១0៥.៤៩៩.១៥៤	៤២៩.៩0៩.0៥៣
ត្រឹះស្ថានហិរញ្ញវត្ថុ	៦៤.៩៥៥.៦៤២	២៦២.៧៤៥.៥៧២	៣៥.២២៣.៣៧៧	១៤៣.៥៣៥.២៦១
ផលិតកម្ម	៥៤.៦៨១.៧៦៣	២២១.១៨៧.៧៣១	៥១.២៥0.១១៧	២0៨.៨៤៤.២២៧
សំណង់	៥៤.៥៧៣.១៤៨	២២0.៧៤៨.៣៨៤	៣២.៤៨៤.៧0១	១៣២.៣៧៥.១៥៧
សេវាមិនមែនហិរញ្ញវត្ថុផ្សេងៗ	៤៥.៦៣៣.៦0៦	១៨៤.៥៨៧.៩៣៦	៣៧.៤៥២.៩0៨	១៥២.៦២0.៦00
ហិរញ្ញវត្ថុ ធានារ៉ាប់រង អចលនទ្រព្យ និងសេវាអាជីវកម្ម	៤១.៨១៦.៤៣៥	១៦៩.១៨៧.៤៨0	៣៩.៣១៩.៤៦២	១៦0.២២៦.៨0៨
ការដឹកជញ្ជូន ឃ្លាំងទំនិញ និងទំនាក់ទំនង	២២.៦៣៣.៣៥៦	៩១.៥៥១.៩២៥	២២.៨៧៦.៧៣២	៩៣.២២២.៦៨៣
អគ្គិសនី ហ្គាស និងទឹកស្អាត	៦.៩៨២.១៣0	២៨.២៤២.៧១៦	៧.៨១១.៩៧៧	៣១.៨៣៣.៨0៦
ផ្សេងៗ	២៧.៣៥៩.២៩៥	១១0.៦៦៨.៣៨៧	៣0.៥២៦.៤៦៩	១២៤.៣៩៥.៣៦0
ឥណទានដុលសរុប	៨៥0.៦៤៧.0៥៧	៣.៤៤0.៨0៧.៣៤៥	៦៩៥.៦៨២.៩៤៤	២.៨៣៤.៩0៧.៩៩៧

(គ) វិភាគតាមចំណាត់ថ្នាក់តណទាន

	២០២០		២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
តណទានដំណើរការ				
ចំនួនដុល	៨៤៤.៨៤៦.៣០៩	៣.៤១៧.៤០៣.៣១៩	៦៩២.៩០២.១៤៤	២.៨២៣.៥៧៦.២៣៧
ចំនួនដែលមាន ហានិភ័យមិនសង	៨៩៨.៩៤០.៩៦៧	៣.៦៣៦.២១៦.២១២	៧៣៩.៨៥២.៦០៣	៣.០១៤.៨៩៩.៣៥៧
សវិធានធនការខាត តណទានរំពឹងទុក	២.៦៥៨.១២៤	១០.៧៥២.១១២	១.៦៨០.៥២១	៦.៨៤៨.១២៣
តណទានក្រោមដំណើរការ				
ចំនួនដុល	១.៣៦៤.៣៣៥	៥.៥១៨.៧៣៥	១.៦១៤.៩១៥	៦.៥៨០.៧៧៩
ចំនួនដែលមាន ហានិភ័យមិនសង	២.៥៥៨.៨៥០	១០.៣៨៨.៩៣០	២.០១៦.២០៧	៨.២១៦.០៤៤
សវិធានធនការខាត តណទានរំពឹងទុក	២១.៨៥៣	៨៨.៣៩៥	២៦.២៣៧	១០៦.៩១៦
តណទានមិនដំណើរការ				
ចំនួនដុល	៤.៤៣៦.៤១៣	១៧.៩៤៥.២៩១	១.១៦៥.៨៨៥	៤.៧៥០.៩៨១
ចំនួនដែលមាន ហានិភ័យមិនសង	៧.៦២០.៩០៣	៣០.៨២៦.៥៥៣	១.៦៨១.៦៥៩	៦.៨៥២.៧៦០
សវិធានធនការខាត តណទានរំពឹងទុក	៩២៦.៨៧៤	៣.៧៤៩.២០៥	២១២.២៨០	៨៦៥.០៤១
សរុប				
ចំនួនដុល	៨៥០.៦៤៧.០៥៧	៣.៤៤០.៨៦៧.៣៤៥	៦៩៥.៦៨២.៩៤៤	២.៨៣៤.៩០៧.៩៩៧
ចំនួនដែលមាន ហានិភ័យមិនសង	៩០៩.១២០.៣២០	៣.៦៧៧.៣៩១.៦៩៥	៧៤៣.៥៥០.៨៦៩	៣.០២៩.៩៦៨.១៦១
សវិធានធនការខាត តណទានរំពឹងទុក	៣.៦០៦.៨៥១	១៤.៥៨៩.៧១២	១.៩១៩.០៣៨	៧.៨២០.០៨០

(ឃ) វិភាគតាមកាលកំណត់តណទាន

	២០២០		២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
មិនលើស១ឆ្នាំ	១៧៣.៧៧២.៣៦០	៧០២.៩០៩.១៩៦	១៤៣.៣៩៤.២៣០	៥៨៤.៣៣១.៤៨៧
លើស១ឆ្នាំ និងមិន លើស៣ឆ្នាំ	៧៥.១៥៥.០១៣	៣០៤.០០២.០២៨	៦៨.៩១៨.៩០៣	២៨០.៨៤៤.៥៣០
លើស៣ឆ្នាំ និងមិន លើស៥ឆ្នាំ	១៧៥.១២៧.០៤១	៧០៨.៣៨៨.៨៨១	១៤៨.៤១២.៦០២	៦០៤.៧៨១.៣៥៣
លើស៥ឆ្នាំ	៤២៦.៥៩២.៦៤៣	១.៧២៥.៥៦៧.២៤០	៣៣៤.៩៥៧.២០៩	១.៣៦៤.៩៥០.៦២៧
តណទានដុលសរុប	៨៥០.៦៤៧.០៥៧	៣.៤៤០.៨៦៧.៣៤៥	៦៩៥.៦៨២.៩៤៤	២.៨៣៤.៩០៧.៩៩៧

(ង) វិភាគតាមហានិភ័យតណទាន

	២០២០		២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ហានិភ័យធម្មតា	៧៩០.៤៨៥.៧៥៨	៣.១៩៧.៥១៤.៨៩១	៥៩២.៤០១.៤៤៦	២.៤១៤.០៣៥.៨៩៣
ហានិភ័យធំ	៦០.១៦១.២៩៩	២៤៣.៣៥២.៤៥៤	១០៣.២៨១.៤៩៨	៤២០.៨៧២.១០៤
តណទានដុលសរុប	៨៥០.៦៤៧.០៥៧	៣.៤៤០.៨៦៧.៣៤៥	៦៩៥.៦៨២.៩៤៤	២.៨៣៤.៩០៧.៩៩៧

ហានិភ័យធំត្រូវបានកំណត់និយមន័យ ដោយធនាគារកណ្តាលថា ជាហានិភ័យតណទានទូទៅ ចំពោះអ្នកទទួលជាឯកត្តជនណាមួយ ដែលលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

(ច) វិភាគតាមទំនាក់ទំនង

	២០២០		២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ភាគីពាក់ព័ន្ធ	១.៧៧៨.៤៦៨	៧.១៩៣.៩០៣	៨៧៤.៧០៩	៣.៥៦៤.៤៣៩
ភាគីមិនពាក់ព័ន្ធ	៨៤៨.៨៦៨.៥៨៩	៣.៤៣៣.៦៧៣.៤៤២	៦៩៤.៨០៨.២៣៥	២.៨៣១.៣៤៣.៥៥៨
តណទានដុលសរុប	៨៥០.៦៤៧.០៥៧	៣.៤៤០.៨៦៧.៣៤៥	៦៩៥.៦៨២.៩៤៤	២.៨៣៤.៩០៧.៩៩៧

(ឆ) វិភាគតាមនិវាសនដ្ឋាន

	២០២០		២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
និវាសដ្ឋាន	៨៥០.៦៤១.៩១៥	៣.៤៤០.៨៤៦.៥៤៦	៦៩៥.៥៦០.៥១៧	២.៨៣៤.៤០៩.១០៧
អនិវាសដ្ឋាន	៥.១៤២	២០.៧៩៩	១២២.៤២៧	៤៩៨.៨៩០
តណទានដុលសរុប	៨៥០.៦៤៧.០៥៧	៣.៤៤០.៨៦៧.៣៤៥	៦៩៥.៦៨២.៩៤៤	២.៨៣៤.៩០៧.៩៩៧

(ជ) អត្រាការប្រាក់

	២០២០	២០១៩
តណទានរយៈពេលវែង	២,០០% - ១៨,០០%	៦,៣០% - ១៨,០០%
តណទានទិញគេហដ្ឋាន	៣,៥០% - ១១,០០%	៣,៥០% - ១១,០០%
តណទានវិចារូបន៍	៦,០០% - ១១,០០%	៥,០០% - ១០,០០%
សក្តីបត្រតណទានជំនឿទុកចិត្ត	៦,០០% - ៨,០០%	៦,០០% - ៨,៧៥%
តណទានដែលអាចប្រើឡើងវិញបាន	៦,៥០% - ៨,០០%	៧,០០% - ៧,២០%
តណទានបុគ្គល	៨,០០% - ២៤,០០%	៨,០០% - ២៤,០០%
តណទានយានយន្ត	៦,៥០% - ១៨,០០%	៦,៥០% - ១៨,០០%
ប័ណ្ណតណទាន	១៨,០០%	១៨,០០%

៨. ប្រាក់តម្កល់តាមច្បាប់នៅធនាគារកណ្តាល

	២០២០		២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
រយៈពេលខ្លី				
ទុនបម្រុងកាតព្វកិច្ច (i)	៦៩.៧៣២.៦៦៧	២៨២.០៦៨.៦៣៨	១០៧.០២៦.១៨៨	៤៣៦.១៣១.៧០០
រយៈពេលវែង				
ប្រាក់តម្កល់ធានា លើដើមទុន (ii)	៧.៥០០.០០០	៣០.៣៣៧.៥០០	៧.៥០០.០០០	៣០.៥៦២.៥០០
	៧៧.២៣២.៦៦៧	៣១២.៤០៦.១៣៨	១១៤.៥២៦.១៨៨	៤៦៦.៦៩៤.២០០

(i) ទុនបម្រុងកាតព្វកិច្ច

យោងតាមប្រកាសលេខ ធ៧-០២០-២៣០ ប្រ.ក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ទុនបម្រុងកាតព្វកិច្ចអប្បបរមា ត្រូវបានផ្លាស់ប្តូរមក ៧% សម្រាប់គ្រប់រូបិយប័ណ្ណ និងមានប្រសិទ្ធិភាព ចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ដែលអត្រាមុនការផ្លាស់ប្តូរគឺ ៨% សម្រាប់ប្រាក់រៀល និង១២,៥% សម្រាប់រូបិយប័ណ្ណផ្សេងៗ។ ទុនបម្រុងកាតព្វកិច្ច ពុំមានការប្រាក់ទេ។

(ii) ប្រាក់តម្កល់ធានាលើដើមទុន

យោងតាមប្រកាសលេខ ធ៧-០១-១៣៦ប្រ.ក. ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ចេញដោយធនាគារកណ្តាល ស្តីពី «ប្រាក់តម្កល់ធានាលើដើមទុន» តម្រូវឲ្យធនាគារតម្កល់ប្រាក់ចំនួន ១០% នៃដើមទុនចុះបញ្ជីរបស់ធនាគារ ជាប្រាក់តម្កល់ធានាលើដើមទុននៅធនាគារកណ្តាល។ ប្រាក់តម្កល់នេះមិនសម្រាប់ប្រើប្រាស់ ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារទេ ហើយនឹងត្រូវបង្វិលជូនធនាគារវិញ នៅពេលដែលធនាគារស្ម័គ្រចិត្តបញ្ចប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួន នៅក្នុងប្រទេសកម្ពុជា។

អត្រាការប្រាក់ប្រចាំឆ្នាំ

	២០២០	២០១៩
ប្រាក់តម្កល់ធានាលើដើមទុន	០,០៩% ទៅ ០,៤៨%	០,៤៨% ទៅ ៣,០០%
ទុនបម្រុងកាតព្វកិច្ច	0%	0%

៩. ភតិសន្យា

កំណត់សម្គាល់នេះផ្តល់នូវព័ត៌មានអំពីភតិសន្យា ដែលធនាគារជាភាគីអ្នកជួល។

ធនាគារជួលអគារមួយចំនួន សម្រាប់ធ្វើប្រតិបត្តិការជាការិយាល័យកណ្តាល និងការិយាល័យសាខា។ ជាទូទៅ កិច្ចសន្យាជួលត្រូវបានធ្វើឡើង សម្រាប់រយៈពេលកំណត់ចាប់ពី ២ឆ្នាំ រហូតដល់ ១០ឆ្នាំ។ ភតិសន្យាទាំងនេះ មានរយៈពេលជួលដែលបញ្ជាក់ពីការឡើងថ្លៃ និងសិទ្ធិបន្តកិច្ចសន្យាខុសៗគ្នា។ ចំពោះការបន្តកិច្ចសន្យាជាថ្មី លក្ខខណ្ឌនៃភតិសន្យា ទាំងនេះត្រូវបានចរចាឡើងវិញ។

(ក) ចំនួនទឹកប្រាក់ដែលបានកត់ត្រា នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

	២០២០		២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
ទ្រព្យសកម្មដែលមាន សិទ្ធិប្រើប្រាស់ (រយៈពេលវែង)				
អគារ	៤.៩៦០.៣៥៧	២០.០៦៤.៦៤៤	៥.២៩៤.៦០៩	២១.៥៧៥.៥៣២
	៤.៩៦០.៣៥៧	២០.០៦៤.៦៤៤	៥.២៩៤.៦០៩	២១.៥៧៥.៥៣២
បំណុលភតិសន្យា				
រយៈពេលខ្លី	១.២៤៧.៣១៦	៥.០៤៥.៣៩៣	១.១៨៧.១៩៥	៤.៨៣៧.៨២០
រយៈពេលវែង	៤.១៣៤.២៨២	១៦.៧២៣.១៧១	៤.៤៤៨.៨១៧	១៨.១២៨.៩២៩
	៥.៣៨១.៥៩៨	២១.៧៦៨.៥៦៤	៥.៦៣៦.០១២	២២.៩៦៦.៧៤៩

មិនមានការបន្ថែមទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ក្នុងអំឡុងឆ្នាំទេ (២០១៩ ៖ សូន្យ)

(ខ) ចំនួនទឹកប្រាក់ដែលបានកត់ត្រា នៅក្នុងរបាយការណ៍ចំណេញ-ខាត

	២០២០		២០១៩	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
រំលស់ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់				
អគារ	១.៣២២.៦១៣	៥.៣៩២.២៩៣	១.១៧៩.៧៧៩	៤.៧៨០.៤៦៥
ចំណាយរំលស់ (កំណត់សម្គាល់ ២៧)	១.៣២២.៦១៣	៥.៣៩២.២៩៣	១.១៧៩.៧៧៩	៤.៧៨០.៤៦៥
ចំណាយការប្រាក់លើបំណុលភតិសន្យា				
អគារ	២៣៦.៧៨៨	៩៦៥.៣៨៥	២២៨.៣២៧	៩២៥.១៨១
ចំណាយការប្រាក់ (កំណត់សម្គាល់ ២៣)	២៣៦.៧៨៨	៩៦៥.៣៨៥	២២៨.៣២៧	៩២៥.១៨១
ចំណាយពាក់ព័ន្ធនឹងភតិសន្យារយៈពេលខ្លី (រួមបញ្ចូលក្នុងចំណាយប្រតិបត្តិការផ្សេងៗ) (កំណត់សម្គាល់ ២៨)	២១២.៨៧៤	៨៦៧.៨៨៧	២៤៧.៤៥៧	១.០០២.៦៩៦
ចំណាយពាក់ព័ន្ធនឹងភតិសន្យាសរុប	១.៧៧២.២៧៥	៧.២២៥.៥៦៥	១.៦៥៥.៥៦៣	៦.៧០៨.៣៤២

លំហូរសាច់ប្រាក់ចេញសរុប សម្រាប់ភតិសន្យាឆ្នាំ២០២០ មានចំនួន ១.៤៧៩.៥៦២ ដុល្លារអាមេរិក (២០១៩៖ ១.៣៤៥.០២០ ដុល្លារអាមេរិក)។

១០. ទ្រព្យសម្បត្តិ និងបរិក្ខារ

រយៈពេលវែង	ការកែលម្អ ទ្រព្យជួល ដុល្លារអាមេរិក	បរិក្ខារ ការិយាល័យ ដុល្លារអាមេរិក	បរិក្ខារកុំព្យូទ័រ ដុល្លារអាមេរិក	យានយន្ត ដុល្លារអាមេរិក	ការងារកំពុងដំណើរការ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩						
ថ្លៃដើម	៥.៧២៣.៩៤៩	១.៣០៣.៤៤២	២.៨៦០.៥២៥	១.០៩៦.៥២០	៤៨៩.៩១១	១១.៤៧៤.៣៤៧
រំលស់បង្គរ	(៤.៥០០.៤៧៩)	(១.០០៦.១៩៩)	(២.៥៦៨.១០៦)	(៦១៦.៦០៦)	-	(៨.៦៩១.៣៩០)
តម្លៃចុះបញ្ជីសុទ្ធ	១.២២៣.៤៧០	២៩៧.២៤៣	២៩២.៤១៩	៤៧៩.៩១៤	៤៨៩.៩១១	២.៧៨២.៩៥៧
គិតជាពាន់រៀល	៤.៩១៥.៩០២	១.១៩៤.៣២២	១.១៧៤.៩៤០	១.៩២៨.២៩៤	១.៩៦៨.៤៦៣	១១.១៨១.៩២១
សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩						
តម្លៃចុះបញ្ជីសុទ្ធដើមគ្រា	១.២២៣.៤៧០	២៩៧.២៤៣	២៩២.៤១៩	៤៧៩.៩១៤	៤៨៩.៩១១	២.៧៨២.៩៥៧
បន្ថែម	-	១១៤.០៥៤	៨០.៣៩៨	១៤៣.៨៨៤	៦៩៩.០៤៦	១.០៣៧.៣៨២
ផ្ទេរ	១១៨.៨៨៥	៧.១៦៧	៣២.៩២៣	-	(១៥៨.៩៧៥)	-
រំលស់	(៤៣៤.៦៥៤)	(១០៥.៨៣២)	(១៧៥.៣៧០)	(១៥៧.១៩៩)	-	(៨៧៣.០៥៥)
តម្លៃចុះបញ្ជីសុទ្ធចុងគ្រា	៩០៧.៧០១	៣១២.៦៣២	២៣០.៣៧០	៤៦៦.៥៩៩	១.០២៩.៩៨២	២.៩៤៧.២៨៤
នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩						
ថ្លៃដើម	៥.៨៤២.៨៣៤	១.៤២៤.៦៦៣	២.៩៧៣.៨៤៦	១.១៩៣.០៦៤	១.០២៩.៩៨២	១២.៤៦៤.៣៨៩
រំលស់បង្គរ	(៤.៩៣៥.១៣៣)	(១.១១២.០៣១)	(២.៧៤៣.៤៧៦)	(៧២៦.៤៦៥)	-	(៩.៥១៧.១០៥)
តម្លៃចុះបញ្ជីសុទ្ធ	៩០៧.៧០១	៣១២.៦៣២	២៣០.៣៧០	៤៦៦.៥៩៩	១.០២៩.៩៨២	២.៩៤៧.២៨៤
គិតជាពាន់រៀល	៣.៦៩៨.៨៨២	១.២៧៣.៩៧៥	៩៣៨.៧៥៨	១.៩០១.៣៩១	៤.១៩៧.១៧៦	១២.០១០.១៨២
ថ្ងៃទី០១ ខែមករា ឆ្នាំ២០២០						
ថ្លៃដើម	៥.៨៤២.៨៣៤	១.៤២៤.៦៦៣	២.៩៧៣.៨៤៦	១.១៩៣.០៦៤	១.០២៩.៩៨២	១២.៤៦៤.៣៨៩
រំលស់បង្គរ	(៤.៩៣៥.១៣៣)	(១.១១២.០៣១)	(២.៧៤៣.៤៧៦)	(៧២៦.៤៦៥)	-	(៩.៥១៧.១០៥)
តម្លៃចុះបញ្ជីសុទ្ធ	៩០៧.៧០១	៣១២.៦៣២	២៣០.៣៧០	៤៦៦.៥៩៩	១.០២៩.៩៨២	២.៩៤៧.២៨៤
គិតជាពាន់រៀល	៣.៦៩៨.៨៨២	១.២៧៣.៩៧៥	៩៣៨.៧៥៨	១.៩០១.៣៩១	៤.១៩៧.១៧៦	១២.០១០.១៨២
សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០						
តម្លៃចុះបញ្ជីសុទ្ធដើមគ្រា	៩០៧.៧០១	៣១២.៦៣២	២៣០.៣៧០	៤៦៦.៥៩៩	១.០២៩.៩៨២	២.៩៤៧.២៨៤
បន្ថែម	៤៦៦.៤៨១	១៩២.៨៩៩	៤៧៣.៦១៦	៩៦.៣០០	១.៤២២.២១៣	២.៦៥១.៥០៩
ផ្ទេរ	១.៣០៣.០៣០	-	-	-	(១.៣០៣.០៣០)	-
រំលស់	(៤៧៦.៥១៦)	(១០៨.០៤០)	(១៧៨.២៩៦)	(១៧៨.៨៣១)	-	(៩៤១.៦៨៣)
តម្លៃចុះបញ្ជីសុទ្ធចុងគ្រា	២.២០០.៦៩៦	៣៩៧.៤៩១	៥២៥.៦៩០	៣៨៤.០៦៨	១.១៤៩.១៦៥	៤.៦៥៧.១១០
នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០						
ថ្លៃដើម	៧.៦១២.៣៤៥	១.៦១៧.៥៦២	៣.៤៤៧.៤៦២	១.១៧២.៦២៩	១.១៤៩.១៦៥	១៤.៩៩៩.១៦៣
រំលស់បង្គរ	(៥.៤១១.៦៤៩)	(១.២២០.០៧១)	(២.៩២១.៧៧២)	(៧៨៨.៥៦១)	-	(១០.៣៤២.០៥៣)
តម្លៃចុះបញ្ជីសុទ្ធ	២.២០០.៦៩៦	៣៩៧.៤៩១	៥២៥.៦៩០	៣៨៤.០៦៨	១.១៤៩.១៦៥	៤.៦៥៧.១១០
គិតជាពាន់រៀល	៨.៩០១.៨១៥	១.៦០៧.៨៥១	២.១២៦.៤១៦	១.៥៥៣.៥៥៥	៤.៦៤៨.៣៧៣	១៨.៨៣៨.០១០

១១. ទ្រព្យសកម្មអរូបី

រយៈពេលវែង	កម្មវិធីកុំព្យូទ័រ ជុំលាវអាមេរិក	ការងារកំពុងដំណើរការ ជុំលាវអាមេរិក	សរុប ជុំលាវអាមេរិក
ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩			
ថ្លៃដើម	៣.៦២២.៧៧៩	២២៧.៨៦៩	៣.៨៥០.៦៤៨
រំលស់បង្គរ	(៣.២៣៣.៦៧២)	-	(៣.២៣៣.៦៧២)
តម្លៃចុះបញ្ជីសុទ្ធ	៣៨៩.១០៧	២២៧.៨៦៩	៦១៦.៩៧៦
គិតជាពាន់រៀល	១.៥៦៣.៤៣២	៩១៥.៥៧៨	២.៤៧៩.០១០
សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩			
តម្លៃចុះបញ្ជីសុទ្ធដើមគ្រា	៣៨៩.១០៧	២២៧.៨៦៩	៦១៦.៩៧៦
បន្ថែម	-	៨៦៤.២០៧	៨៦៤.២០៧
ផ្ទេរ	១៣.៩៦៥	(១៣.៩៦៥)	-
រំលស់	(១០៤.៩៥៦)	-	(១០៤.៩៥៦)
តម្លៃចុះបញ្ជីសុទ្ធចុងគ្រា	២៩៨.១១៦	១.០៧៨.១១១	១.៣៧៦.២២៧
នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩			
ថ្លៃដើម	៣.៦៣៦.៧៤៤	១.០៧៨.១១១	៤.៧១៤.៨៥៥
រំលស់បង្គរ	(៣.៣៣៨.៦២៨)	-	(៣.៣៣៨.៦២៨)
តម្លៃចុះបញ្ជីសុទ្ធ	២៩៨.១១៦	១.០៧៨.១១១	១.៣៧៦.២២៧
គិតជាពាន់រៀល	១.២១៤.៨២៣	៤.៣៩៣.៣០២	៥.៦០៨.១២៥
ថ្ងៃទី០១ ខែមករា ឆ្នាំ២០២០			
ថ្លៃដើម	៣.៦៣៦.៧៤៤	១.០៧៨.១១១	៤.៧១៤.៨៥៥
រំលស់បង្គរ	(៣.៣៣៨.៦២៨)	-	(៣.៣៣៨.៦២៨)
តម្លៃចុះបញ្ជីសុទ្ធ	២៩៨.១១៦	១.០៧៨.១១១	១.៣៧៦.២២៧
គិតជាពាន់រ៉ៀល	១.២១៤.៨២៣	៤.៣៩៣.៣០២	៥.៦០៨.១២៥
សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០			
តម្លៃចុះបញ្ជីសុទ្ធដើមគ្រា	២៩៨.១១៦	១.០៧៨.១១១	១.៣៧៦.២២៧
បន្ថែម	១២៧.២៨៩	៥៦៧.៥៥៧	៦៩៤.៨៤៦
ផ្ទេរ	៣១៨.០២២	(៣១៨.០២២)	-
រំលស់	(១៦៦.៦០៤)	-	(១៦៦.៦០៤)
តម្លៃចុះបញ្ជីសុទ្ធចុងគ្រា	៥៧៦.៨២៣	១.៣២៧.៦៤៦	១.៩០៤.៤៦៩
នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០			
ថ្លៃដើម	៤.០៨២.០៥៥	១.៣២៧.៦៤៦	៥.៤០៩.៧០១
រំលស់បង្គរ	(៣.៥០៥.២៣២)	-	(៣.៥០៥.២៣២)
តម្លៃចុះបញ្ជីសុទ្ធ	៥៧៦.៨២៣	១.៣២៧.៦៤៦	១.៩០៤.៤៦៩
គិតជាពាន់រ៉ៀល	២.៣៣៣.២៤៩	៥.៣៧០.៣២៨	៧.៧០៣.៥៧៧

១២. ពន្ធពន្យាទ្រព្យសកម្ម

	២០២០		២០១៩	
	ជុំលាវអាមេរិក	ពាន់រ៉ៀល	ជុំលាវអាមេរិក	ពាន់រ៉ៀល
ពន្ធពន្យាទ្រព្យសកម្ម	៣.១៨៦.៥៩៧	១២.៨៨៩.៧៨៥	៣.០៦៥.៩៨៨	១២.៤៩៣.៩០១
បំណុលពន្ធពន្យា	(១.០៧៧.៤៣៩)	(៤.៣៥៨.២៤១)	(១.១៤០.៨៨៨)	(៤.៦៤៩.១១៩)
ពន្ធពន្យាទ្រព្យសកម្មសុទ្ធ – រយៈពេលវែង	២.១០៩.១៥៨	៨.៥៣១.៥៤៤	១.៩២៥.១០០	៧.៨៤៤.៧៨២

បម្រែបម្រួលពន្ធពន្យាទ្រព្យសកម្មសុទ្ធ ក្នុងអំឡុងឆ្នាំ មានដូចខាងក្រោម៖

	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
នៅថ្ងៃទី០១ ខែមករា	១.៩២៥.១០០	៧.៨៤៤.៧៨២	១.៤៥១.៦៦៨	៥.៨៣២.៨០២
កត់ត្រាខាងខ្នង់ឥណទានក្នុងចំណេញ-ខាត (កំណត់សម្គាល់ ២៩ (ខ))	១៨៤.០៥៨	៧៥០.៤០៤	៤៧៣.៤៣២	១.៩១៨.៣៤៦
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(៦៣.៦៤២)	-	៩៣.៦៣៤
នៅថ្ងៃទី៣១ ខែធ្នូ	២.១០៩.១៥៨	៨.៥៣១.៥៤៤	១.៩២៥.១០០	៧.៨៤៤.៧៨២

(i) បម្រែបម្រួលពន្ធពន្យាទ្រព្យសកម្ម

	ខាតពីការថយចុះតម្លៃ ដុល្លារអាមេរិក	កម្រៃឥណទានមិនទាន់រំលស់ ដុល្លារអាមេរិក	បំណុលកតិសន្យា ដុល្លារអាមេរិក	ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ដុល្លារអាមេរិក	មូលនិធិសោធននិវត្តន៍ ដុល្លារអាមេរិក	រំលស់ពន្ធើន ដុល្លារអាមេរិក	បង្គរផ្សេងៗ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
២០១៩								
នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩	៩៦.៣១៧	៣៤៥.៣៧៩	១.១៤៣.២៤៣	២៧.៩៦៨	២៩៧.៥០២	៦៣៥.៤២៣	៧៣.៥៩២	២.៦១៩.៤២៤
កត់ត្រាខាងខ្នង់ឥណទាន/(បន្ទុក) ក្នុងចំណេញ-ខាត	១៣៥.៤៨៤	២០៩.០០១	(១៦.០៤១)	-	៨៩.៦០៦	៣២.៥៩៣	(៤.០៧៩)	៤៤៦.៥៦៤
នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	២៣១.៨០១	៥៥៤.៣៨០	១.១២៧.២០២	២៧.៩៦៨	៣៨៧.១០៨	៦៦៨.០១៦	៦៩.៥១៣	៣.០៦៥.៩៨៨
គិតជាពាន់រៀល	៩៤៤.៥៨៩	២.២៥៩.០៩៩	៤.៥៩៣.៣៤៨	១១៣.៩៧០	១.៥៧៧.៤៦៥	២.៧២២.១៦៥	២៨៣.២៦៥	១២.៤៩៣.៩០១
២០២០								
នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២០	២៣១.៨០១	៥៥៤.៣៨០	១.១២៧.២០២	២៧.៩៦៨	៣៨៧.១០៨	៦៦៨.០១៦	៦៩.៥១៣	៣.០៦៥.៩៨៨
កត់ត្រាខាងខ្នង់ឥណទាន/(បន្ទុក) ក្នុងចំណេញ-ខាត	៣០៥.៥៦១	៣៤.៧១៨	(៥០.៨៨២)	-	(១៨៣.៤១៣)	(២៨.៣៧៥)	៣.០០០	១២០.៦០៩
នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០	៥៣៧.៣៦២	៥៨៩.០៩៨	១.០៧៦.៣២០	២៧.៩៦៨	២៨៣.៦៩៥	៦៣៩.៦៤១	៧២.៥១៣	៣.១៨៦.៥៩៧
គិតជាពាន់រៀល	២.១៧៣.៦២៩	២.៣៨២.៩០១	៤.៣៥៣.៧១៥	១១៣.១៣១	៩៨៥.៧៤៦	២.៥៨៧.៣៤៨	២៩៣.៣១៥	១២.៨៨៩.៧៨៥

(ii) បម្រែបម្រួលបំណុលពន្ធពន្យា

	ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស ដុល្លារអាមេរិក	ចំណេញពីការប្តូររូបិយប័ណ្ណមិនទានកត់ត្រា-សុទ្ធ ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
២០១៩			
នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩	(១.០៨៧.៥៨០)	(៨០.១៧៦)	(១.១៦៧.៧៥៦)
កត់ត្រាខាងខ្នង់ឥណទាន/(បន្ទុក) ក្នុងចំណេញ-ខាត	២៨.៦៥៨	(១.៧៩០)	២៦.៨៦៨
នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩	(១.០៥៨.៩២២)	(៨១.៩៦៦)	(១.១៤០.៨៨៨)
